

# អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច ក្នុងរបបខ្មែរក្រហម

**Rochelle Braaf**

**2014**

# អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច ក្នុងរបបខ្មែរក្រហម

@ March 2014
Rochelle Braaf
Cambodian Defenders Project
Gender-Based Violence Program
1LEo, Street 450, Sangkat Tuol Tompong II
Khan Chamkarmorn, Phnom Penh, Cambodia
http://gbvkr.org/

# មាតិកា




អក្សរកាត់ ... iv
ការឧទ្ទិស និងសេចក្តីថ្លែងអំណរគុណ ... v
សេចក្តីសង្ខេប ... vii
១. សេចក្តីផ្តើម ... ១
១.១ អំពើហិង្សាផ្លូវភេទក្នុងប្រទេសកម្ពុជា ... ១
១.២ រចនាសម្ព័ន្ធរបាយការណ៍ ... ៤
២. សាវតា ... ៦
២.១ អំពើហិង្សាផ្លូវភេទក្នុង និងក្រោយពេលសង្គ្រាម ... ៦
២.២ ខ្មែរក្រហម និងកម្ពុជាប្រជាធិបតេយ្យ ... ៧
២.៣ អំពើហិង្សាក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ... ១១
២.៤ ខ្មែរក្រហម និងជនជាតិភាគតិច ... ១៤
៣. ការរៀបចំការសិក្សាស្រាវជ្រាវ ... ២៤
៣.១ ទំហំ និងគោលបំណងនៃការសិក្សាស្រាវជ្រាវ ... ២៤
៣.២ វិធីសាស្ត្រ ... ២៥
៣.៣ ការកម្រិត ... ៣០
៤. លទ្ធផលរកឃើញ ... ៣២
៤.១ ប្រជាសាស្ត្រ ... ៣២
៤.២ ការរៀបការដោយបង្ខំ ... ៣៧
៤.៣ ការរំលោភសេពសន្ថវៈ ... ៤៧
៤.៤ ការរួមភេទដើម្បីរស់រានមានជីវិត ... ៥១
៤.៥ ទាសករផ្លូវភេទ ... ៥៤
៤.៦ អំពើហិង្សាផ្លូវភេទដទៃទៀត ... ៥៨
៤.៧ ផលប៉ះពាល់នៃអំពើហិង្សាផ្លូវភេទលើជនរងគ្រោះ និងការឆ្លើយតប ... ៦២
៤.៨ ការឆ្លើយតបនឹងសំណួរនៃការសិក្សាស្រាវជ្រាវ ... ៦៩
៥. សេចក្តីសន្និដ្ឋាន ... ៨០
សទ្ទានុក្រម ... ៨៤

# ពាក្យកាត់



| | |
|---|---|
| CDP | ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| CEDAW | អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ |
| CPK | បក្សកុម្មុយនីស្តកម្ពុជា |
| ECCC | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| ICC | តុលាការឧក្រិដ្ឋកម្មអន្តរជាតិ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| TPO | អង្គការចិត្តសង្គមអន្តរវប្បធម៌ |
| VSS | ផ្នែកគាំពារជនរងគ្រោះ |

# ការឧទ្ទិស និង សេចក្តីថ្លែងអំណរគុណ



ការស៊ើបអង្កេតលើអំពើហិង្សាផ្លូវភេទ ដែលបានកើតឡើងស្ទើរតែជាងសែសិបឆ្នាំកន្លងមក ហើយ គឺជាបញ្ហាដ៏លំបាកបំផុតក្នុងប្រទេសមួយដែលនៅតែបន្តដោះស្រាយអំពើប្រល័យពូជសាសន៍ ប្រព្រឹត្តដោយពួកខ្មែរក្រហម ហើយនៅក្នុងនោះអំពើហិង្សាផ្លូវភេទនៅតែបន្តជារឿងអាថ៌កំបាំង និង ជាភាពអាម៉ាស់មិនទាន់ត្រូវបានដោះស្រាយនៅឡើយ។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ ដែលផ្តោតលើបញ្ហាកើតមានចំពោះជនជាតិភាគតិចក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហម កាន់តែមានភាពស្មុគស្មាញ ដោយសារសហគមន៍ជនជាតិភាគតិចទាំងនេះតែងតែត្រូវបានរើសអើង និងរស់នៅឯកោ។ ការណែនាំ និងការគាំទ្ររបស់បុគ្គល និងអង្គការខាងក្រោមមានសារៈប្រយោជន៍ ក្នុងការជួយឱ្យការសិក្សាស្រាវជ្រាវនេះដំណើរការទៅបាន។

ជាបឋម ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងសម្រាប់បុរសស្ត្រីចំនួន១០៥នាក់ ដែល ស្វាគមន៍ផ្តល់បទសម្ភាសជាមួយក្រុមការងារស្រាវជ្រាវយើងនៅផ្ទះរបស់ពួកគាត់។ ពួកគាត់បើកចំហ ក្នុងការចែករំលែកបញ្ហាដែលពួកគាត់បានជួបប្រទះ ដូចជា អំពើហិង្សាផ្លូវភេទ ការប៉ះទង្គិចផ្លូវចិត្ត និង ការបាត់បង់។ ភាពរឹងមាំ និងការជាសះស្បើយឡើងវិញរបស់ពួកគាត់ពីភាពឈឺចាប់ដ៏ខ្លោចផ្សានៅ មិនទាន់មានភាពប្រសើរនៅឡើយ។ ពួកគាត់កំពុងទទួលបានការលើកទឹកចិត្តឱ្យមានភាពក្លាហាន ក្នុងការលាតត្រដាងបញ្ហាក្នុងចិត្ត និង ក្តីប្រាថ្នារបស់ខ្លួនក្នុងការរស់នៅប្រកបដោយសេចក្តីសុខក្នុង ពេលអនាគត។

បុគ្គលិកនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បាននឹងកំពុងបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការ រៀបចំឯកសារទាក់ទងនឹងបទឧក្រិដ្ឋអំពើហិង្សាផ្លូវភេទ និងគាំទ្រអ្នកនៅរស់រានមានជីវិតក្នុងការ ស្វែងរកយុត្តិធម៌អន្តរកាល។ ការសិក្សាស្រាវជ្រាវនេះត្រូវបានជំរុញ និងរៀបចំឡើងដោយក្រុមការងារ គម្រោងអំពើហិង្សាយេនឌ័រ ដែលដឹកនាំដោយ ដួង សាវ៉ន និង មិត្តរួមការងារ អេង ណារី ហង្ស ចរិយា ហុង ណៃស៊ីម ស្រ៊ា រដ្ឋា និង បេនី យី ដែលបានជួយរៀបចំគម្រោងសិក្សាស្រាវជ្រាវ ធ្វើសេចក្តីព្រាង កម្រងសំណួរសម្រាប់បទសម្ភាស បណ្តុះបណ្តាលអ្នកសម្ភាស ចុះបំពេញការងារតាមមូលដ្ឋាន វាយតម្លៃ និងកែសម្រួលរបាយការណ៍។

ការងារកន្លងមករបស់អ្នកស្រាវជ្រាវអំពីសិទ្ធិស្ត្រីក្នុងប្រទេសកម្ពុជា ពិតជាមានសារៈប្រយោជន៍ ក្រៃលែងដល់ការរៀបចំការសិក្សាស្រាវជ្រាវនេះ។ ការរៀបចំការសិក្សាស្រាវជ្រាវនេះទទួលបានការ ណែនាំដ៏មានតម្លៃពី Kasumi Nakagawa, katrina Natale និង Theresa de Langis។

# ការឧទ្ទិស និង សេចក្តីថ្លែងអំណរគុណ

គម្រោងសិក្សាស្រាវជ្រាវនេះ ដឹកនាំដោយអ្នកនាង Rochelle Braaf ដែលបានចូលរួមជាមួយក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាក្នុងខែមិថុនា ឆ្នាំ២០១៣ ក្នុងនាមជាអ្នកស្ម័គ្រចិត្តជនជាតិអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ។ អ្នកនាងទទួលបានសញ្ញាបត្របណ្ឌិតផ្នែកភូមិសាស្ត្រមនុស្ស (Human Geography) ពីសាកលវិទ្យាល័យ Macquarie និងបានចូលរួមជាមួយក្រុមការងារដោយមានបទពិសោធន៍ទាក់ទងនឹងអំពើហិង្សាយេនឌ័ររយៈពេលដប់បីឆ្នាំមកហើយ។

ការសិក្សាស្រាវជ្រាវនេះ ទទួលបានជំនួយដ៏ធំធេងពីអង្គការ និងអន្តរការីជាច្រើន ដែលជួយដល់ក្រុមការងារសិក្សាស្រាវជ្រាវក្នុងការទាក់ទងអ្នកផ្តល់បទសម្ភាសគោលដៅ។ យើងក៏សូមថ្លែងអំណរគុណចំពោះ អង់ ចាន់រិទ្ធ នៅអង្គការទទួលបានយុត្តិធម៌ (Access to Justice) សម្រាប់គម្រោងជនរងគ្រោះជនជាតិភាគតិចក្នុងរបបខ្មែរក្រហម ទឹម មីនា និង Sonja Meyer នៅអង្គការក្តីករុណា កុក ថាយ Fatily Sa នៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងថ្នាក់ដឹកនាំមូលដ្ឋានដែលនៅតាមសហគមន៍នានា បានជួយសម្របសម្រួលក្នុងការទាក់ទងជាមួយអ្នកផ្តល់បទសម្ភាស។យើងខ្ញុំក៏សូមថ្លែងអំណរ-គុណចំពោះ ជូរ នី យូស ផល ណូស មុត អ៊ូ មឿត ម៉ា ដុល តត គីមស្រួយ មាស ចាន់ថន វ៉ាន់ សុងមាស មឿង ឡាស ម៉ាត់ សីលេស ការីន និងសិត ម៉ាលី សម្រាប់ការចូលរួមចំណែកក្នុងការសិក្សាស្រាវជ្រាវនេះ។

ទិន្នន័យត្រូវបានប្រមូលដោយកម្មសិក្សាការីនៃការសិក្សាស្រាវជ្រាវនេះ ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការបំពេញការងារ និងកត់ត្រាទិន្នន័យទទួលបានពីបទសម្ភាស។ យើងខ្ញុំសូមអរគុណចំពោះ ឆេង ច័ន្ទនីតា ឈឹង រចនា ជួប សារឿម កែវ បុប្ផាឧសភា នូ វុទ្ធី នុច ស្រីនាងផៃ វ៉ាឌី ផង់ ច័ន្ទនូ និង ស ឈីវហ៊្គិច ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងការប្តេជ្ញាចិត្តចំពោះបញ្ហានេះ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះមជ្ឈមណ្ឌលសិក្សាតាមបច្ចេកវិទ្យាទំនើប (Centre for Advanced Studies) និងសេវាបកប្រែ Intracare សម្រាប់ការបកប្រែប្រតិចារិក និង SEDECA សម្រាប់ការវិភាគទិន្នន័យ។

ជាចុងក្រោយ គម្រោងសិក្សាស្រាវជ្រាវនេះអាចដំណើរការទៅបានដោយមានការផ្តល់មូល-និធិពីអង្គការសេវាសន្តិភាពស៊ីវិល (the Civil Peace Service) នៃ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH ។ យើងខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការចំពោះ GIZ ដែលបានជួយរៀបចំការស៊ើបអង្កេតសំខាន់ៗលើអំពើហិង្សាផ្លូវភេទក្នុងអំឡុងពេលសង្គ្រាម និងឯកសារស្តីពីរឿងរ៉ាវរបស់ជនជាតិភាគតិច។

# សេចក្តីសង្ខេប



## សាវតា គោលបំណង និងវិធីសាស្ត្រ

នាថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ពួកខ្មែរក្រហមបានគ្រប់គ្រងប្រទេសកម្ពុជា ដោយផ្លាស់ប្តូររបបគ្រប់គ្រងទៅជាកម្ពុជាប្រជាធិបតេយ្យ បន្ទាប់មករបបដ៏ឃោរឃៅបំផុតដែលមានការកាប់សម្លាប់ក៏បានចាប់ផ្តើមឡើងក្នុងប្រវត្តិសាស្ត្រសម័យទំនើប។ ស្ថិតក្នុងរបបនេះរយៈពេលបីឆ្នាំប្រាំបីខែ ប្រជាជនកម្ពុជាត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅ និងជម្លៀសចេញពីកន្លែងខ្លួនរស់នៅ បង្ខំឱ្យធ្វើពលកម្ម ទទួលរងទណ្ឌកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំង។ តាមការប៉ាន់ស្មាន ប្រជាជនចំនួន ១,៥ លាននាក់ បានបាត់បង់ជីវិតដោយសារការសម្លាប់ ភាពអត់ឃ្លាន ការអស់កម្លាំង និងជំងឺ។ ទោះបីជាមានការស៊ើបអង្កេតជាច្រើនលើអំពើសាហាវយង់ឃ្នងដែលបានកើតឡើងក្នុងអំឡុងរបបនេះក៏ដោយ ក៏មានការសិក្សាស្រាវជ្រាវ និងការអត្ថាធិប្បាយតិចតួចប៉ុណ្ណោះដែលបានផ្តោតលើអំពើហិង្សាផ្លូវភេទកើតមានក្នុងរបបនេះ។

ដូចគ្នានឹងស្ថានភាពសង្គ្រាមដទៃទៀតដែរ ភស្តុតាងបានបង្ហាញថា មនុស្សជាច្រើនបានទទួលរងអំពើហិង្សាផ្លូវភេទដ៏ធ្ងន់ធ្ងរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការសិក្សាស្រាវជ្រាវដំបូងមួយចំនួនដែលពិនិត្យមើលលើបញ្ហានេះបានលើកឡើងថា ជនជាតិភាគតិចមួយចំនួនអាចត្រូវបានគេកំណត់ជាគោលដៅជាក់លាក់សម្រាប់អំពើហិង្សាបែបនេះ។ ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់ភស្តុតាងជាមូលដ្ឋានអំពីបទឧក្រិដ្ឋទាំងនេះដែលប្រព្រឹត្តលើជនជាតិភាគតិច។

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំឡើង ដើម្បីចងក្រងទិន្នន័យអំពីទំហំ និង លក្ខណៈនៃអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ផលវិបាកនៃបទឧក្រិដ្ឋនេះ ដើម្បីយល់ដឹងឱ្យបានកាន់តែប្រសើរអំពីតម្រូវការរបស់អ្នកនៅរស់រានមានជីវិតសម្រាប់ជួយគាំទ្រពួកគេឱ្យមានភាពប្រសើរឡើងវិញ។ តាមការរំពឹងទុក រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតអាចបង្ហាញឱ្យឃើញថា ពួកគេត្រូវប្រឹងប្រែងធ្វើការតស៊ូមតិ ដើម្បីទទួលបានយន្តការផ្តល់យុត្តិធម៌អន្តរកាល និងការគាំទ្រ។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងឆ្លើយតបនឹងសំណួរសិក្សាស្រាវជ្រាវ ដូចជា (១) តើជនជាតិភាគតិចទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមដែរឬទេ? (២) តើនរណាជាជន




*បន្ទប់ឃុំឃាំងគុកទួលស្លែង*

រងគ្រោះ និងនរណាជាជនល្មើស? (៣) តើព័ត៌មានលម្អិត និងលក្ខណៈនៃអំពើហិង្សានេះយ៉ាងដូចម្ដេចដែរ? (៤) តើជនជាតិភាគតិចឆ្លងកាត់រឿងរ៉ាវខុសគ្នាពីប្រជាជនកម្ពុជាដទៃទៀតដែរឬទេ?

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានអនុវត្តក្នុងខេត្តចំនួនប្រាំមួយដោយផ្ដោតលើរឿងរ៉ាវដែលជនជាតិភាគតិចវៀតណាម ខ្មែរក្រោម ខ្មែរឥស្លាម និងជនជាតិចាមបានឆ្លងកាត់។ ជនជាតិភាគតិចវៀតណាមរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើទុក្ខបុកម្នេញ ដោយសារគេចាត់ទុកថាជា "សត្រូវនៃបដិវត្តន៍" និងជាការគំរាមកំហែងដល់រដ្ឋ។ ខ្មែរក្រោម ដែលមានដើមកំណើត និងវប្បធម៌ជាជនជាតិខ្មែរ ប៉ុន្តែបច្ចុប្បន្នភាគច្រើនរស់នៅក្នុងភាគខាងត្បូងប្រទេសវៀតណាម ក៏ត្រូវបានធ្វើទុក្ខបុកម្នេញពីរបបនេះដែរ ដោយសារគេយល់ឃើញថា ក្រុមនេះមានសម្ពន្ធភាពជាមួយជនជាតិវៀត-ណាម។ មូស្លីម ជាទូទៅសំដៅលើខ្មែរឥស្លាម ឬ ពេលខ្លះ សំដៅលើក្រុមជនជាតិចាមជាក់លាក់ បានរស់នៅក្នុងប្រទេសកម្ពុជាជាច្រើន សតវត្សរ៍មកហើយ។ ពួកខ្មែរក្រហមស្អប់គ្រប់សាសនា ហើយដើម្បីរំលាយក្រុមខ្មែរឥស្លាមនេះចោលនៅក្នុងប្រជាជនកម្ពុជា ពួកខ្មែរក្រហមបានព្យាយាមបំបែកក្រុមគ្រួសារ និងសហគមន៍ជនជាតិនេះ ដោយការផ្សារភ្ជាប់ពួកមូស្លីមជាមួយប្រជាជនខ្មែរតាមរយៈការរៀបការជាមួយគ្នា និងហាមឃាត់ពួកមូស្លីមមិនឱ្យប្រតិបត្តិតាមសាសនា និងវប្បធម៌របស់ខ្លួនឡើយ។

ការប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងតាមរយៈបទសម្ភាសផ្ទាល់ជាមួយអ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យទាំងបុរស និងស្ត្រីចំនួន១០៥នាក់ ដែលបច្ចុប្បន្ន ពួកគាត់មានអាយុលើសពីសែសិបឆ្នាំហើយ។ ក្នុងបទសម្ភាស ពួកគាត់ត្រូវបានសម្ភាសតាមរយៈកម្រងសំណួរបើកបិទ ដោយរក្សាការសម្ងាត់អំពីអ្វីដែលពួកគាត់បានដឹងអំពីអំពើហិង្សាផ្លូវភេទ ផលប៉ះពាល់នៃអំពើហិង្សាដែលបន្តកើតមានលើអ្នកនៅរស់រានមានជីវិត ការស្វែងរកជំនួយខ្លួនឯង កត្តាប្រឈម និងតម្រូវការ។

## សេចក្ដីសង្ខេបអំពីលទ្ធផលរកឃើញ

ស្ទើរតែពីរភាគបីនៃអ្នកផ្ដល់បទសម្ភាសទាំង១០៥នាក់ ធ្លាប់ទទួលរងដោយផ្ទាល់នូវអំពើហិង្សាផ្លូវភេទក្នុងរបបនេះ (ភាគច្រើនពួកគេត្រូវបានបង្ខំឱ្យរៀបការជាមួយគ្នា) ហើយច្រើនជាងពាក់កណ្ដាលបានឃើញ និងដឹងឮអំពីអំពើហិង្សាផ្លូវភេទក្នុងទម្រង់មួយចំនួនប្រព្រឹត្តលើអ្នកដទៃដែលជាទូទៅ គឺការចាប់រំលោភសេពសន្ថវៈ។ លទ្ធផលរកឃើញសំខាន់ៗនៃអំពើហិង្សាផ្លូវភេទទាំងនេះ ត្រូវបានលើកឡើងមកពិភាក្សាដូចខាងក្រោម។

**ការរៀបការដោយបង្ខំ៖** ឯកសារនៅកន្លែងផ្សេងទៀតបង្ហាញថា ពួកខ្មែរក្រហមបានបង្ខំប្រជាជនរាប់រយពាន់អ្នកឱ្យរៀបការ ជាញឹកញាប់ រៀបការជាមួយអ្នកដែលមិនធ្លាប់ស្គាល់គ្នា ដើម្បី

គ្រប់គ្រង និងចាប់បង្ខំគ្រួសារទាំងនេះឱ្យបង្កើតកូនសម្រាប់របបខ្លួន។[1]

អ្នកផ្ដល់បទសម្ភាសជនជាតិភាគតិចភាគច្រើន (៦៧%) ក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យរៀបការ។ ជនរងគ្រោះចំនួនបីភាគយល់ព្រមរៀបការតាមការចាប់បង្ខំនេះ ដោយសារតែភាពភ័យខ្លាចត្រូវគេសម្លាប់ ឬ ការដាក់ទណ្ឌកម្មផ្សេងៗ ហើយជនរងគ្រោះភាគច្រើនបដិសេធមិនរៀបការតែពេលដំបូងប៉ុណ្ណោះ។ ក្នុងចំណោមអ្នកផ្ដល់បទសម្ភាសចំនួន៤២នាក់ ដែលបដិសេធមិនរៀបការក្នុងពេលដំបូង មាន៣៥នាក់ត្រូវបានគំរាមកំហែង ឬ ដាក់ទណ្ឌកម្មតាមរូបភាពមួយចំនួន។ ក្នុងចំណោមអ្នកដែលបដិសេធមិនរៀបការក្នុងពេលដំបូង មានពីរនាក់ក្នុងចំណោមអ្នកទាំងនោះ នៅទីបំផុត ពួកខ្មែរក្រហមបង្ខំឱ្យរៀបការជាប្ដីប្រពន្ធ ឬ ជ្រើសរើសដៃគូឱ្យធ្វើជាប្ដីប្រពន្ធជាបន្តបន្ទាប់។ ពិធីរៀបការមានលក្ខណៈដូចគ្នា ដែលមានការចូលរួមពីប្ដីប្រពន្ធជាច្រើនរយគូក្នុងពេលតែមួយ។ នៅពេលដែលភ្នាក់ងារខ្មែរក្រហមចូលរួមក្នុងពិធីរៀបការ មិនសូវមានវត្តមានសមាជិកគ្រួសារឡើយ។ មនុស្សមួយចំនួនមិនដឹងខ្លួនថា ពួកគេត្រូវរៀបការឡើយ រហូតទាល់តែពិធីរៀបការបានរៀបចំឡើង។ អ្នកផ្ដល់បទសម្ភាសមួយចំនួនបានប្រាប់ថា ពួកគេរៀបការដោយការភ្ជង់នឹងកាំភ្លើង។

អ្នកដែលរៀបការដោយបង្ខំ ក៏ត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យរួមដំណេកជាមួយគ្នាផងដែរ។ អ្នកផ្ដល់បទសម្ភាសជនជាតិភាគតិចស្ទើរតែទាំងអស់ដែលត្រូវបានបង្ខំឱ្យរៀបការបានរៀបរាប់ថា ពួកខ្មែរក្រហមតាមដានពួកគេនៅពេលយប់ ដើម្បីធានាថាពួកខ្លួនរួមដំណេកជាមួយគ្នា។ បុរសជាប្ដីមួយចំនួនបានបង្ខំប្រពន្ធថ្មីរបស់ខ្លួនរួមដំណេក។ ការបង្ខំរួមភេទក្នុងការរៀបការដោយបង្ខំបានធ្វើឱ្យបុរស និងស្ត្រីទទួលរងនូវការឈឺចាប់ដូចគ្នា។ ក្នុងចំណោមអ្នកផ្ដល់បទសម្ភាសចំនួន៤០នាក់ ដែលបានរៀបការដោយបង្ខំលើកដំបូង មានចំនួន២៩គូរស់នៅមានកូនជាមួយគ្នា ហើយមាន២៦គូបន្តរស់នៅជាមួយគ្នាក្រោយពីការដួលរលំនៃរបបខ្មែរក្រហម និងក្នុងចំណោមអ្នកទាំង២៦គូនោះ មាន២៣គូមានកូនជាមួយគ្នា។ ក្នុងចំណោមផលវិបាកនៃការរៀបការដោយបង្ខំ បុរស និងស្ត្រីមួយចំនួនបន្តរស់នៅទាំងមិនសប្បាយចិត្ត។ ស្ត្រីម្នាក់បាននិយាយថា ខ្លួនរស់នៅក្នុងទំនាក់ទំនងហិង្សា។ ជនរងគ្រោះជាច្រើនបានបង្ហាញពីទុក្ខសោកដ៏ធំធេងរបស់ខ្លួន ដែលមិនអាចមានសិទ្ធិជ្រើសរើសដៃគូពេញចិត្តរបស់ខ្លួន និងមិនអាចរៀបការតាមប្រពៃណីរបស់ខ្លួន។

---

1 ភស្តុតាង រួមមាន អំណះអំណាងរបស់អ្នកនៅរស់រានមានជីវិត ដែលប្រមូលបានពីបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សូមមើល Nakagawa, K, *អំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម។ រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)* (ភ្នំពេញ ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០០៨) Natale, K, *ខ្ញុំមានអារម្មណ៍ថា ព្រលឹងរបស់ខ្ញុំហោះហើរចេញពីរាងកាយខ្ញុំ។ ការសិក្សាស្រាវជ្រាវអំពី អំពើហិង្សាផ្លូវភេទក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងខេត្តបាត់ដំបង និងខេត្តស្វាយរៀង* (ភ្នំពេញ ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០១១) Yim, S, *អតីតភាព និងបច្ចុប្បន្នភាពរបស់អ្នកនៅរស់រានមានជីវិតដែលរៀបការដោយបង្ខំ* (ភ្នំពេញ ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០១២)

## សេចក្តីសង្ខេប

**ការរំលោភសេពសន្ថវៈ ៖** ទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះបានចងក្រងនូវរបាយការណ៍ របស់សាក្សីចំនួន៥៦នាក់ស្តីពីការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារីជនជាតិភាគតិច ដែលជាញឹកញាប់ការរំលោភសេពសន្ថវៈនេះ ធ្វើឡើងជាក្រុមដែលប្រព្រឹត្តដោយជនល្មើសច្រើននាក់។ ទោះបីជាករណីរំលោភសេពសន្ថវៈ ភាគច្រើនប្រព្រឹត្តលើជនរងគ្រោះតែម្នាក់ ប៉ុន្តែស្ទើរតែពាក់កណ្តាលនៃករណីនេះជាការរំលោភជាក្រុមលើជនរងគ្រោះច្រើននាក់។ ក្នុងករណីរំលោភសេពសន្ថវៈភាគច្រើន (រួមទាំងករណីរំលោភសេពសន្ថវៈជាក្រុមទាំងអស់) ជនរងគ្រោះត្រូវបានសម្លាប់បន្ទាប់ពីរំលោភរួច។ ក្នុងករណីមួយចំនួន ជនល្មើសបានកាត់ផ្តាច់រាងកាយរបស់ជនរងគ្រោះមុន និងក្រោយពេលសម្លាប់។ អ្នកផ្តល់បទសម្ភាសចំនួនបួននាក់បានរៀបរាប់អំពីករណីរំលោភសេពសន្ថវៈជាមួយវត្ថុប្លែកៗ ដូចជាពួកគេបានឃើញសាកសពស្ត្រីរងគ្រោះជាមួយបំណែកឈើឬបន្ទះឈើក្នុងយោនីរបស់ជនរងគ្រោះ។ ទិដ្ឋភាពនេះធ្វើឱ្យស្ត្រី និងកុមារីជនជាតិភាគតិចកាន់តែភ័យខ្លាចខ្លាំងឡើងពីការរំលោភសេពសន្ថវៈ និងការសម្លាប់គ្រប់ពេលវេលា។ អ្នកផ្តល់បទសម្ភាសទាំងអស់បានលើកឡើងថា កម្មាភិបាលខ្មែរក្រហមគឺជាអ្នករំលោភក្នុងករណីរំលោភសេពសន្ថវៈដែលពួកគេបានឃើញ ឬ បានឮហើយមានតែមួយករណីប៉ុណ្ណោះដែលអ្នករំលោភជាជនស៊ីវិល។ ក្នុងករណីអ្នកផ្តល់បទសម្ភាសដឹងពីភេទរបស់អ្នករំលោភ ពួកគេបានលើកឡើងថា ជនល្មើសជាស្ត្រីមានតែពីរនាក់ប៉ុណ្ណោះ ក្រៅពីនេះគឺជាបុរស។



*ចម្លាក់លៀននៃការរំលោភសេពសន្ថវៈនៅបាត់ដំបង*

**ការរួមភេទដើម្បីរស់រានមានជីវិត ៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អាហារត្រូវបានបែងចែកយ៉ាងតឹងរ៉ឹងក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម។ ប្រជាជនទូទៅទទួលបានអាហារតិចតួចបំផុតសម្រាប់បរិភោគ ហើយប្រជាជនភាគច្រើនទទួលរងការខ្វះអាហារូបត្ថម្ភ ឬ ភាពអត់ឃ្លាន។ ជាលទ្ធផលមនុស្សមួយចំនួនបានបង្ខំចិត្តរួមភេទ ដើម្បីប្តូរយកអាហារ ថ្នាំ ឬ ការបំពេញការងារងាយស្រួល។ ក្នុងករណីចំនួន២០នៃការរួមភេទដើម្បីរស់រានមានជីវិតដែលពាក់ព័ន្ធនឹងជនជាតិភាគតិច មានមួយករណីពាក់ព័ន្ធនឹងភ្នាក់ងារខ្មែរក្រហម។ ក្នុង១៥ករណី គេជឿជាក់ថា ជនល្មើសម្នាក់ឯងជាអ្នកប្រព្រឹត្ត។ ក្នុងករណីទាំងអស់ មានមួយករណីដែលជនរងគ្រោះជាស្ត្រី។ ក្នុងហេតុការណ៍ជាច្រើនបានបង្ហាញថា មានការដោះដូរការរួមភេទ ដើម្បីបានបាយហូប ឬបំពេញការងារងាយស្រួល។ ការដោះដូរទាំងអស់មានគ្រោះថ្នាក់ដល់ជនរងគ្រោះ និងក្នុងករណីខ្លះ ជនល្មើសអាចនឹងត្រូវបានសម្លាប់ចោលប្រសិនបើរកឃើញពីបទល្មើស។

**ទាសករផ្លូវភេទ ៖** អ្នកផ្ដល់បទសម្ភាសចំនួន៣៨នាក់បាននិយាយថា ពួកគេស្គាល់ជនរងគ្រោះដែលត្រូវពួកខ្មែរក្រហមបង្ខំរួមភេទជាទៀងទាត់ ដោយជនល្មើសប្រើសិទ្ធិជាម្ចាស់លើជនរងគ្រោះ។ ក្នុងករណីស្ទើរតែពាក់កណ្ដាលនៃករណីទាំងនេះ ជនរងគ្រោះគឺជាជនជាតិភាគតិច ហើយជនល្មើសគឺជាបុរស និងជាពួកខ្មែរក្រហម ហើយជនរងគ្រោះទាំងអស់ជាស្ត្រី។ សម្រាប់ករណីទាសករផ្លូវភេទលើជនជាតិភាគតិចចំនួន៩ករណី ក្នុងករណីនីមួយៗមានជនរងគ្រោះតែម្នាក់ និង៨ករណីទៀតមានជនរងគ្រោះច្រើននាក់។ មានករណីមួយ គេមិនដឹងអំពីចំនួនជនរងគ្រោះឡើយ។ ក្នុងករណីជាច្រើន ស្ត្រីត្រូវបានបង្ខំឱ្យរួមភេទជាមួយនឹងក្រុមបុរស និងក្នុងករណីមួយចំនួនដូចបានរៀបរាប់ ស្ត្រីត្រូវបានបង្ខាំងទុក និងជាចុងក្រោយត្រូវម្ចាស់ទាសករសម្លាប់ចោល។

**អំពើហិង្សាផ្លូវភេទដទៃទៀត ៖** ច្រើនជាងពាក់កណ្ដាលនៃអ្នកផ្ដល់បទសម្ភាសចំនួន១០៥នាក់ បានចែករំលែកបទពិសោធន៍របស់ខ្លួនពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទក្រៅពីទម្រង់អំពើហិង្សាដូចបានលើកឡើង ដែលពួកគេបានឆ្លងកាត់ បានឃើញ ឬ បានឮ។ អំពើហិង្សាទាំងនេះ រួមមាន ចាប់ពីការធ្វើកាយវិកលកម្មផ្លូវភេទ និងការបៀតបៀនផ្លូវភេទ រហូតដល់ការមាក់ងាយផ្លូវភេទ និងការបែងចែកឱ្យរស់នៅក្នុងក្រុមដែលខ្លួនមិនចូលចិត្ត។ អ្នកផ្ដល់បទសម្ភាសមួយចំនួនបានប្រាប់ថា ពួកគេបានឃើញ ឬ ឮអំពីករណីធ្វើកាយវិកលកម្មផ្លូវភេទលើស្ត្រីជនជាតិភាគតិច ដែលភាគច្រើនគឺបន្ទាប់ពីការរំលោភសេពសន្ថវៈ។ ករណីទាំងនេះរួមមាន ការកាត់ផ្ដាច់ដើមទ្រូងរបស់ស្ត្រី។ ក្នុងករណីមួយចំនួននៃករណីទាំងនេះ មិនមានការបង្ហាញជាក់លាក់ថា តើជនរងគ្រោះត្រូវបានធ្វើកាយវិកលកម្មមុន ឬក្រោយការសម្លាប់ឡើយ? ទោះបីយ៉ាងណា មានករណីមួយចំនួនដែលអ្នកផ្ដល់បទសម្ភាសបានដឹងថា ជនរងគ្រោះត្រូវបានគេធ្វើកាយវិកលកម្មផ្លូវភេទទាំងនៅមានជីវិត ហើយភាគច្រើនបានបាត់បង់ជីវិត។ អ្នកផ្ដល់បទសម្ភាសពីរនាក់បានប្រាប់ថា ពួកគេបានឃើញការបង្ហាញកេរ្ដិ៍ភេទជនរងគ្រោះជាសាធារណៈ។ អ្វីដែលកាន់តែឃោរឃៅជាងនេះទៀត អ្នកផ្ដល់បទសម្ភាសមួយចំនួន បានបង្ហាញភស្តុតាងដ៏គួរឱ្យខ្ពើមរអើមដែលជនល្មើសបានស៊ីសាច់ជនរងគ្រោះ បន្ទាប់ពីការរំលោភ និងសម្លាប់ជនរងគ្រោះ។

**ផលប៉ះពាល់សម្រាប់ជនរងគ្រោះ ៖** ក្នុងពេលដែលអ្នកផ្ដល់បទសម្ភាសជនជាតិភាគតិចមួយ ចំនួនបានបន្តទទួលរងការឈឺចាប់ពីរបួសរាងកាយ និងការឈឺចាប់ពីអំពើហិង្សាផ្លូវភេទដែលពួកគេបានឆ្លងកាត់ អ្នកផ្ដល់បទសម្ភាសច្រើននាក់ទៀតទទួលរងនូវបញ្ហាផ្លូវចិត្ត រួមទាំង ការពោរពេញដោយកំហឹង ទុក្ខព្រួយ ភាពភ័យខ្លាច សុបិន្តអាក្រក់



ការបាក់ទឹកចិត្ត និងគំនិតចង់ធ្វើអត្តឃាត។ ក្នុងករណីអំពើហិង្សាមួយ អ្នកផ្តល់បទសម្ភាសមួយចំនួនរស់នៅក្នុងទំនាក់ទំនងមិនសប្បាយចិត្ត ដោយសារតែការរៀបការដោយបង្ខំ។ ជនរងគ្រោះពីការរៀបការដោយបង្ខំជាច្រើននាក់ បន្តរស់នៅទាំងភាពសោកស្តាយ និងទុក្ខសោក ដោយសារពួកគេមិនអាចរៀបការតាមប្រពៃណី ឬ រៀបការជាមួយអ្នកខ្លួនស្រឡាញ់។

**ការស្វែងរកជំនួយ ៖** ក្នុងពេលដែលអ្នកផ្តល់បទសម្ភាសមួយចំនួន បានស្វែងរកជំនួយវេជ្ជសាស្ត្រសម្រាប់ព្យាបាលបញ្ហាសុខភាពផ្លូវចិត្ត ដែលពួកគេមានលទ្ធភាពចំណាយ អ្នកផ្តល់បទសម្ភាសចំនួនតែ១៨នាក់ ប៉ុណ្ណោះបានស្វែងរកជំនួយផ្សេងទៀត ដូចជា សេវាច្បាប់ ឬ ជំនួយចិត្តសាស្ត្រសង្គម។ អ្នកផ្តល់បទសម្ភាសជាច្រើនបានលើកឡើងថា ការមិនដឹងអំពីសេវាទាំងនេះគឺជាកត្តាសំខាន់មួយដែលធ្វើឱ្យពួកគេមិនអាចស្វែងរកជំនួយបាន។ សម្រាប់មនុស្សមួយចំនួនដែលបានទាក់ទងសុំជំនួយចិត្តសាស្ត្រសង្គម ឬ សេវាផ្លូវច្បាប់ ពួកគេបានទទួលចម្លើយវិជ្ជមាន។

**កត្តាប្រឈម ៖** ជនរងគ្រោះផ្ទាល់នៃអំពើហិង្សាផ្លូវភេទភាគច្រើនបាននិយាយអំពីការជួយលើកទឹកចិត្តពីសំណាក់ដៃគូ ឬ បងប្អូនឱ្យពួកគេបន្តរស់នៅរហូតមកដល់ពេលបច្ចុប្បន្ន និងប្រឈមមុខនឹងអតីតកាល។ សម្រាប់ជនរងគ្រោះផ្សេងទៀត កូនៗគឺជាមូលហេតុដែលធ្វើឱ្យពួកគេមានទឹកចិត្តរស់នៅបន្តទៀត។ ជនរងគ្រោះមួយចំនួនទៀតបានលើកឡើងថា សាសនា និងមេដឹកនាំសាសនាជួយពួកគេក្នុងការប្រឈមនឹងបញ្ហាទាំងនេះ ហើយអ្នកខ្លះទៀតបាននិយាយអំពីសេវាចិត្តសាស្ត្រសង្គម ដែលបានជួយពួកគេប្រឈមមុខនឹងបញ្ហាផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ដូចជា កំហឹង ការអស់សង្ឃឹម និងទុក្ខសោក។

តម្រូវការរបស់អ្នកនៅរស់រានមានជីវិត នៅពេលបានសួរអ្នកនៅរស់រានមានជីវិតថា តើអ្វីដែលអាចជួយពួកគេក្នុងការប្រឈមនឹងអតីតកាល ជនរងគ្រោះច្រើនជាងពាក់កណ្តាលបាននិយាយថា ពួកគេចង់ឃើញការកាត់ទោស និងការដាក់ទណ្ឌកម្មលើមេដឹកនាំខ្មែរក្រហម។ ជនរងគ្រោះជាច្រើន មានក្តីកង្វល់នឹងរយៈពេលនៃការជំនុំជម្រះរឿងក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងភ័យខ្លាចជនល្មើសស្លាប់មុននឹងចេញសាលក្រម។ អ្នកផ្តល់បទសម្ភាសមួយចំនួនបានបង្ហាញថា ការសាងសង់បូជនីយដ្ឋានសម្រាប់អ្នកដែលត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម ឬ អ្នកដែលស្លាប់ក្នុងរបបនោះ គឺជាការគោរពដល់ពួកគេ។ អ្នកផ្តល់បទសម្ភាសមួយចំនួនបានផ្តល់មតិយោបល់ឱ្យប្រាប់យុវជនជំនាន់ក្រោយអំពីអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ដើម្បីកុំឱ្យមានការប្រព្រឹត្តអំពើសាហាវយង់ឃ្នងនេះម្តងទៀត។ អ្នកខ្លះទៀតបានលើកឡើងអំពីតម្រូវការសេវាវេជ្ជសាស្ត្រ និងសេវាផ្សេងៗទៀត។

## តើជនជាតិភាគតិចទទួលរងអំពើហិង្សាផ្លូវភេទក្នុងអំឡុងរបបខ្មែរក្រហមមែនដែរឬទេ?

លទ្ធផលរកឃើញបង្ហាញយ៉ាងប្រាកដប្រជាថា ជនជាតិភាគតិចទាំងអស់ដែលស្ថិតក្រោមការស៊ើបអង្កេត ទទួលរងនូវអំពើហិង្សាផ្លូវភេទក្នុងទម្រង់ខុសៗគ្នា។ អំពើហិង្សាទាំងនេះ រួមមាន ការរៀបការដោយបង្ខំ និងការបង្ខំឱ្យរួមភេទ ការរំលោភសេពសន្ថវៈ (ការរំលោភជាក្រុម ការរំលោភទ្រង់ទ្រាយធំ និងការរំលោភរួចសម្លាប់) ការរួមភេទដើម្បីរស់រានមានជីវិត ទាសករផ្លូវភេទ កាយវិកលកម្ម ការមាក់ងាយផ្លូវភេទ និងការរំលោភបំពានដទៃទៀត។ អ្នកផ្ដល់បទសម្ភាសមួយចំនួនបានរៀបរាប់ថា មានជនរងគ្រោះខ្លះទទួលរងអំពើហិង្សាផ្លូវភេទជាច្រើនករណី និងជនល្មើសខ្លះបានប្រព្រឹត្តអំពើហិង្សាផ្លូវភេទជាច្រើនប្រភេទ។

## តើនរណាជាជនរងគ្រោះ និងជាជនល្មើស?

ជនរងគ្រោះជាស្ត្រីជនជាតិភាគតិចទទួលរងអំពើហិង្សាផ្លូវភេទនៃការរំលោភសេពសន្ថវៈ ការរួមភេទដើម្បីរស់រានមានជីវិត ទាសករផ្លូវភេទ និងការបៀតបៀនផ្លូវភេទ ច្រើនលើសលុបជាងបុរស។ ក្នុងករណីមួយចំនួននៃការរៀបការដោយបង្ខំ បុរសជាប្ដីក៏ជាជនល្មើសនៃអំពើហិង្សាផ្លូវភេទដែរ។ ក្រៅពីការរៀបការដោយបង្ខំ ស្ត្រីនៅលីវ ស្ត្រីរៀបការហើយ និងស្ត្រីមេម៉ាយក៏ទទួលរងអំពើហិង្សាផ្លូវភេទដែរ។ ស្ត្រីមានផ្ទៃពោះ និងគិលានុបដ្ឋានរួចផុតពីអំពើហិង្សាទាំងនេះ។ នៅពេលសាកសួរមិនផ្ទាល់ មិនមានអ្នកផ្ដល់បទសម្ភាសណាមួយលើកឡើងថា មានជនរងគ្រោះណាមួយជាភ្នាក់ងារខ្មែរក្រហមឡើយ ប៉ុន្តែបានបង្ហើបអោយដឹងថាជនរងគ្រោះទាំងអស់ភាគច្រើនសុទ្ធតែជាជនស៊ីវិល។ ទោះបីស្ត្រីគ្រប់វ័យត្រូវបានរំលោភបំពានក៏ដោយ ក៏ជនរងគ្រោះភាគច្រើនគឺជាស្ត្រីវ័យក្មេងជាជាងមនុស្សចាស់។ ក្នុងរបាយការណ៍ជាច្រើន ស្ត្រីមានរូបសម្បត្តិស្រស់ស្អាតគឺជាគោលដៅរងគ្រោះនៃអំពើហិង្សាផ្លូវភេទ។

ក្នុងករណីទាំងអស់ ករណីតែពីរប៉ុណ្ណោះដែលជនល្មើសប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ការរួមភេទដើម្បីរស់រានមានជីវិត និងទាសករផ្លូវភេទលើជនជាតិភាគតិចគឺជាស្ត្រី។ តាមការប៉ាន់ស្មានជនល្មើសក្នុងករណីជាច្រើនមានអាយុចន្លោះពី១៨ ដល់ ៣០ឆ្នាំ ឬចាស់ជាងនេះ។ តាមការលើកឡើងជាច្រើនបង្ហាញថា ភ្នាក់ងារខ្មែរក្រហមជាអ្នកទទួលខុសត្រូវលើអំពើហិង្សាផ្លូវភេទ។ លើសពីនេះ ការរៀបការដោយបង្ខំគឺជាអំពើហិង្សាមួយក្នុងរបបនេះ ដោយសារការរៀបការដោយបង្ខំ និងការបង្ខំរួមភេទ ជាទូទៅ ប្រព្រឹត្តដោយពួកខ្មែរក្រហម។ ជនល្មើសគឺជាបុរសដែលមានមុខតំណែងខុសៗគ្នា រួមទាំង កងឈ្លប ទាហាន ប្រធាន ឬ មន្ត្រីអង្គភាព។ ប្រវត្តិរបស់ជនល្មើសបង្ហាញអំពីអំពើហិង្សាផ្លូវភេទដែលជនល្មើសបានប្រព្រឹត្តលើប្រជាជនក្នុងគោលបំណងគ្រប់គ្រង បំភិតបំភ័យ និងបំបាក់មុខបុគ្គល និងក្រុមប្រជាជន។

# សេចក្ដីសង្ខេប

## តើព័ត៌មានលម្អិត និងលក្ខណៈនៃអំពើហិង្សាផ្លូវភេទដូចម្ដេចដែរ?

ទិន្នន័យនៃការសិក្សាស្រាវជ្រាវបង្ហាញថា បទល្មើសផ្លូវភេទត្រូវបានប្រព្រឹត្តឡើងដោយបុរសជាច្រើនក្នុងទីកន្លែងជាច្រើននៅទូទាំងប្រទេស។ ជនល្មើសបានប្រព្រឹត្តបទល្មើសក្នុងទីតាំងខុសៗគ្នា ដូចជា កន្លែងគេង កន្លែងធ្វើការ សហករណ៍ វាលស្រែ និងព្រៃ។ ទិន្នន័យបង្ហាញថា ជនរងគ្រោះត្រូវបានជនល្មើសជាក្រុមតូចៗ ឬ ជាទ្រង់ទ្រាយធំធ្វើបាបដោយគ្មានអ្នកជួយ ។

ពេលខ្លះ ជនល្មើសប្រព្រឹត្តបទល្មើសតែម្នាក់ឯង និងពេលខ្លះជាក្រុម។ ទាំងក្នុងករណីរំលោភសេពសន្ថវៈ និងករណីទាសករផ្លូវភេទលើជនជាតិភាគតិច ជាទូទៅ ជនល្មើសមិនប្រព្រឹត្តតែម្នាក់ឯងឡើយ។ សម្រាប់ការរួមភេទដើម្បីរស់រានមានជីវិត ជនល្មើសប្រព្រឹត្តតែម្នាក់ឯង។ ការប្រព្រឹត្តអំពើហិង្សាផ្លូវភេទជាក្រុម ទាមទារឱ្យមានការព្រមព្រៀងគ្នារវាងក្រុមជនល្មើស ដោយធ្វើការប្ដូរវេនគ្នារួមភេទលើជនរងគ្រោះ។ តាមការរាយការណ៍បង្ហាញថា ជនល្មើសមិនដែលទទួលទណ្ឌកម្មអ្វីឡើយសម្រាប់បទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ការបង្ហាញអវយវៈភេទដែលបានកាត់ផ្ដាច់ចេញពីសាកសពជនរងគ្រោះជាសាធារណៈ ការទុកសាកសពអាក្រាតកាយចោលក្នុងទីវាល និងពេលខ្លះគេឃើញមានវត្ថុចម្លែកជា ភស្តុតាងបន្សល់ទុកក្រោយពេលរំលោភ និងការស្ដាប់ឮការសន្ទនារវាងជនល្មើសអំពីអំពើហិង្សាដែលពួកគេបានប្រព្រឹត្ត ទាំងនេះគឺជាភស្តុតាងដែលជនល្មើសតែងតែនិយាយអួតប្រាប់គ្នាជាជាងលាក់ទុកជាការសម្ងាត់។

តាមរយៈការរៀបរាប់របស់អ្នកផ្ដល់បទសម្ភាស ជនរងគ្រោះតែងតែត្រូវបានសម្លាប់បន្ទាប់ពីការរំលោភសេពសន្ថវៈ និងការរួមភេទដើម្បីរស់រានមានជីវិត។ ករណីមួយក្នុងចំណោមករណីទាំងអស់ ស្ត្រីជនជាតិភាគតិចម្នាក់ដែលមានផ្ទៃពោះក្រៅចំណងអាពាហ៍ពិពាហ៍ត្រូវបានសម្លាប់ដោយជនល្មើស ឬ ដោយអង្គការ ដើម្បីជាទណ្ឌកម្មនៅពេលដឹងថាមានផ្ទៃពោះ។ ក្នុងករណីជាច្រើនមិនមានការដាក់ទណ្ឌកម្មលើជនល្មើស ហើយថែមទាំងមានភស្តុតាងបង្ហាញថា ជនល្មើសអាចប្រព្រឹត្តបទល្មើសដោយគ្មានការដាក់ទណ្ឌកម្មទៀតផង។ អ្នកផ្ដល់បទសម្ភាសបានលើកឡើងតែពីរបីករណីប៉ុណ្ណោះ ដែលជនល្មើសត្រូវបានសម្លាប់សម្រាប់អំពើហិង្សាដែលពួកគេបានប្រព្រឹត្ត នៅពេលបទល្មើសត្រូវបានខូរខ្វាយ។

តាមការរៀបរាប់របស់អ្នកផ្ដល់បទសម្ភាសបង្ហាញយ៉ាងច្បាស់ថា ពួកគេតែងតែមានភាពតក់ស្លុត នៅពេលបានឃើញភាពសាហាវយង់ឃ្នងនៃអំពើហិង្សាផ្លូវភេទដែលជនល្មើសបានប្រព្រឹត្តឡើង។ ក្រៅពីករណីនៃការរៀបការដោយបង្ខំ អ្នកផ្ដល់បទសម្ភាសពិតជាមានភាពភ័យខ្លាចត្រូវគេដឹង និងសម្លាប់ ដោយសារតែខ្លួនបានដឹងអំពីករណីអំពើហិង្សា។ ស្ត្រីមួយចំនួនដែលបានឃើញអំពើហិង្សាផ្លូវភេទបាននិយាយថា ពួកគេភ័យខ្លាចថានឹងក្លាយខ្លួនជាជនរងគ្រោះបន្ទាប់ ជាពិសេស ប្រសិនបើពួកគេមកពីក្រុមជនជាតិភាគតិចដូចគ្នា ឬ មានទំនាក់ទំនងជាមួយជនរងគ្រោះ។ អ្នកផ្ដល់បទ-

សម្ភាសជាច្រើនបាននិយាយថា ខ្លួនមិនមានលទ្ធភាពជួយជនរងគ្រោះឡើយ បើទោះបីជាដឹងថា ពួកគេនឹងទទួលរងអំពើហិង្សាផ្លូវភេទក៏ដោយ។

## តើការទទួលរងអំពើហិង្សាផ្លូវភេទរបស់ជនជាតិភាគតិចមានភាពខុសគ្នាពីក្រុមប្រជាជនដទៃទៀត ក្នុងប្រទេសកម្ពុជាដែរឬទេ?

ករណីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងការសិក្សាស្រាវជ្រាវនេះ មានលក្ខណៈស្រដៀងគ្នាជាច្រើន ទៅនឹងករណីអំពើហិង្សាផ្លូវភេទលើប្រជាជនទូទៅដែលមានបង្ហាញក្នុងការសិក្សាស្រាវជ្រាវផ្សេងមួយទៀត។ ការសិក្សាស្រាវជ្រាវដែលមានលក្ខណៈស្រដៀងគ្នានេះ ស្ដីពីអំពើហិង្សាផ្លូវភេទទៅលើប្រជាជនទូទៅក៏ត្រូវបានចងក្រងជាឯកសារផងដែរ។ ដូចបង្ហាញក្នុងការសិក្សានេះ ការសិក្សាសំខាន់ៗបានរកឃើញថា ជនល្មើសគឺជាភ្នាក់ងារតែមួយគត់របស់ខ្មែរក្រហម។ លើសពីនេះ ជនល្មើសភាគច្រើនគឺជាបុរស ហើយជនរងគ្រោះគឺជាស្ត្រី ដូចគ្នានឹងលទ្ធផលរកឃើញក្នុងការសិក្សានេះដែរ។

ទោះបីយ៉ាងណា ការសិក្សាទាំងនេះមានភាពខុសគ្នាសំខាន់ៗមួយចំនួនប៉ុណ្ណោះ។

ទីមួយ តាមភស្តុតាងបង្ហាញថា មានតែជនជាតិភាគតិចមួយចំនួនប៉ុណ្ណោះត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យរៀបការ ដើម្បីបំបែកសហគមន៍នេះទៅជាប្រជាជនខ្មែរ។ ការធ្វើបែបនេះត្រូវបានអន្តរជាតិចាត់ទុកថាជាអំពើប្រល័យពូជសាសន៍។ ទីពីរ ការរៀបរាប់របស់អ្នកផ្ដល់បទសម្ភាសបង្ហាញថា ស្ត្រី និងកុមារីជនជាតិភាគតិច តែងតែជាគោលដៅទទួលរងអំពើហិង្សាផ្លូវភេទ និងការរំលោភសេពសន្ថវៈពីសំណាក់អ្នកដែលធ្វើការឱ្យពួកខ្មែរក្រហម។ ទីបី ពេលខ្លះ និងក្នុងតំបន់មួយចំនួន ជនជាតិភាគតិចត្រូវបានកំណត់គោលដៅសម្រាប់កម្ទាត់ចោល។ ក្នុងករណីដែលស្ត្រីជនជាតិភាគតិចត្រូវបានសម្លាប់ អ្នកផ្ដល់បទសម្ភាសលើកឡើងថា ស្ត្រីរងគ្រោះតែងតែត្រូវបានរំលោភមុនពេលសម្លាប់។

## សេចក្ដីសន្និដ្ឋាន

លទ្ធផលរកឃើញនៃការសិក្សាស្រាវជ្រាវនេះ គឺជាភស្តុតាងបន្ថែមលើភស្តុតាងនៃការប្រព្រឹត្តអំពើហិង្សាលើផ្លូវភេទជាទូទៅ ដែលប្រព្រឹត្តដោយភ្នាក់ងារខ្មែរក្រហមលើប្រជាជនស៊ីវិលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លទ្ធផលរកឃើញនេះបង្ហាញបន្ថែមទៀតថា ជនជាតិភាគតិចគឺជាគោលដៅជាក់លាក់នៃការទទួលរងទម្រង់អំពើហិង្សាផ្លូវភេទមួយចំនួន រួមទាំង ការរំលោភសេពសន្ថវៈ ការរំលោភមុនពេលសម្លាប់ និងការរៀបការដោយបង្ខំជាមួយដៃគូជាជនជាតិខ្មែរ។

ទិន្នន័យនៃការសិក្សានេះ បង្ហាញពីភាពមិនពិតនៃគោលនយោបាយហាមឃាត់ការរួមភេទជាមួយអ្នកដទៃក្រៅពីប្ដីប្រពន្ធខ្លួនរបស់ខ្មែរក្រហម ដែលបានលើកឡើងអំពីការប្រឆាំងនឹងទម្រង់អំពើ

## សេចក្តីសង្ខេប

ហិង្សាផ្លូវភេទមួយចំនួន។ គោលនយោបាយនេះមិនបានការពារអំពើហិង្សាផ្លូវភេទជាច្រើនទម្រង់ខុសៗគ្នា ដែលភ្នាក់ងារខ្មែរក្រហមបានប្រព្រឹត្តជាចំហលើសហគមន៍ជនជាតិភាគតិច។ ជាក់ស្តែងលទ្ធផលមួយនៃលទ្ធផលទាំងឡាយនៃគោលនយោបាយនេះ គឺការលើកទឹកចិត្តដល់ជនល្មើសឱ្យសម្លាប់ជនរងគ្រោះ ដើម្បីរក្សាការសម្ងាត់នៃអំពើហិង្សាផ្លូវភេទដែលខ្លួនបានប្រព្រឹត្ត។ សាក្សីដែលបានឃើញអំពើហិង្សាផ្លូវភេទទាំងនេះក៏ប្រឈមនឹងគ្រោះថ្នាក់នៃការសម្លាប់ ដើម្បីរក្សាការសម្ងាត់ដែរ។

ទោះបីជាមានគោលនយោបាយហាមឃាត់ការរួមភេទជាមួយអ្នកដទៃក្រៅពីប្តីប្រពន្ធខ្លួនក៏ដោយ ក៏មានតែករណីមួយចំនួនប៉ុណ្ណោះ ដែលជនល្មើសប្រព្រឹត្តអំពើហិង្សាផ្លូវភេទទទួលទណ្ឌកម្ម។ ជាការពិត ជនល្មើសជាច្រើនបានប្រព្រឹត្តបទល្មើសជាមួយជនល្មើសដទៃទៀត ឬ ថ្នាក់លើរបស់ពួកគេបានដឹងច្បាស់ថា មានករណីអំពើហិង្សាផ្លូវភេទកើតឡើងក្នុងសហគមន៍មួយចំនួន ហើយជនល្មើសតែងតែអួតប្រាប់គ្នាអំពីបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ការណ៍នេះបង្ហាញឱ្យឃើញថា ទង្វើបែបនេះមិនត្រូវបានយកទោសភ័យ ព្រមទាំងត្រូវរបបនេះលើកទឹកចិត្តថែមទៀតផង។

តាមរយៈនិយមន័យនៃពាក្យអំពើហិង្សាផ្លូវភេទរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានឆ្លុះបង្ហាញថា អំពើហិង្សាដែលបានរៀបរាប់ក្នុងរបាយការណ៍នេះ ប្រវត្តិរបស់ជនល្មើស និងជនរងគ្រោះ និងនិរទណ្ឌភាព គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជាអំពើប្រល័យពូជសាសន៍។

តម្រូវការចាំបាច់របស់ជនជាតិភាគតិចនៅរស់រានមានជីវិត ចាំបាច់ត្រូវឆ្លើយតបជាបន្ទាន់ដើម្បីដោះស្រាយផលប៉ះពាល់ទាំងផ្លូវកាយ និងចិត្ត ដែលពួកគេបានជួបប្រទះ។ អ្នកនៅរស់រានមានជីវិតមួយចំនួនអាចទទួលបានសេវា និង វិធានការគាំទ្រផ្លូវកាយមកដល់ថ្ងៃនេះតែតាមរយៈលទ្ធភាពផ្ទាល់ខ្លួនប៉ុណ្ណោះ។ ក្រៅពីលទ្ធភាពទទួលបានសេវា និងការគាំទ្រទាំងនេះ ការផ្តន្ទាទោស និងការចេញសាលក្រមលើមេដឹកនាំខ្មែរក្រហមបានទាន់ពេលវេលា ក៏អាចជួយធ្វើឱ្យការឈឺចាប់របស់អ្នកនៅរស់រានមានជីវិតមានភាពស្រាកស្រាន្តផងដែរ។ ការចងចាំអ្នកដែលបានបាត់បង់ជីវិត និងសំណងក្នុងទម្រង់ផ្សេងៗក៏អាចជាការបំពេញតម្រូវការរបស់ជនរងគ្រោះផងដែរ។

ការទទួលរងអំពើហិង្សាផ្លូវភេទជាច្រើនរបស់ជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាមទារឱ្យមានការសិក្សាស្រាវជ្រាវប្រកបការយកចិត្តទុកដាក់ ដើម្បីយល់ដឹងឱ្យបានស៊ីជម្រៅអំពីការប្រព្រឹត្តរបស់របបនេះចំពោះក្រុមជនជាតិភាគតិច ព្រមទាំងផលវិបាករបស់ជនរងគ្រោះ និងសហគមន៍ជនជាតិភាគតិច។ ភាពជោគជ័យនៃការសិក្សាស្រាវជ្រាវក្នុងការជ្រើសរើសជនជាតិភាគតិចនៅរស់រានមានជីវិតឱ្យរៀបរាប់អំពីបទពិសោធន៍របស់ពួកគេបង្ហាញថា មានមនុស្សជាច្រើនមានបំណងចែករំលែកដំណើររឿងរបស់ខ្លួន នៅពេលពួកគេទទួលបានការរក្សាសុវត្ថិភាព និងការគាំទ្រ។

## អនុសាសន៍

សេចក្តីសន្និដ្ឋានដ៏សំខាន់មួយនៃការសិក្សាស្រាវជ្រាវនេះ គឺមានភាពខុសគ្នាសំខាន់ៗជាច្រើន រវាងការទទួលរងអំពើហិង្សាផ្លូវភេទរបស់ជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនដទៃទៀត។ សារៈសំខាន់នៃលទ្ធផលរកឃើញសម្រាប់ជាអនុសាសន៍នៃការសិក្សាស្រាវជ្រាវនេះ គឺការឆ្លើយតបតម្រូវការសម្រាប់ជនជាតិភាគតិចមិនគួររាប់បញ្ចូលទៅក្នុងការឆ្លើយតបតម្រូវការជាទូទៅសម្រាប់ជនរងគ្រោះទាំងអស់ឡើយ។ ទោះបីជាក្រុមជនជាតិភាគតិចត្រូវបានរាប់បញ្ចូលក្នុងការចាត់វិធានការផ្តល់ដំណោះស្រាយជាទូទៅ សម្រាប់ជនរងគ្រោះនៅរស់រានមានជីវិតនៃអំពើហិង្សាផ្លូវភេទក៏ដោយ ក៏ជាទូទៅ ក្រុមជនជាតិភាគតិចតែងតែមិនត្រូវបានយកចិត្តទុកដាក់ និងមើលរំលង។

អនុសាសន៍ខាងក្រោមត្រូវបានដកស្រង់ចេញពីលទ្ធផលរកឃើញ និងសេចក្តីសន្និដ្ឋាននៃការសិក្សាស្រាវជ្រាវ ដើម្បីឆ្លើយតបនឹងការទទួលរងអំពើហិង្សាផ្លូវភេទរបស់ជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អនុសាសន៍ទាំងនេះត្រូវបានបង្ហាញផ្អែកតាមអ្នកដែលមានកាតព្វកិច្ចឆ្លើយតបនឹងការទទួលរងអំពើហិង្សាផ្លូវភេទរបស់ជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

### *រដ្ឋាភិបាល*

គណៈកម្មាធិការអន្តរជាតិអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ បានផ្តល់ជាអនុសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ៖

> *ត្រូវផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពជូនជនរងគ្រោះនៃអំពើហិង្សាលើយេនឌ័រ ជាពិសេស អំពើហិង្សាផ្លូវភេទលើស្ត្រី ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម និងត្រូវរៀបចំកម្មវិធីផ្តល់យុត្តិធម៌អន្តរកាលក្រៅប្រព័ន្ធតុលាការដែលមានប្រសិទ្ធភាព រួមទាំង ការផ្តល់សំណងគ្រប់គ្រាន់ ការគាំទ្រផ្លូវចិត្ត និងការគាំទ្រសមស្របដទៃទៀត។*[2]

លទ្ធផលរកឃើញនៃការសិក្សាស្រាវជ្រាវនេះគាំទ្រទាំងស្រុងលើអនុសាសន៍នេះ។ លទ្ធផលរកឃើញនេះក៏ផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាល ៖

- ទទួលស្គាល់ និងផ្តន្ទាទោសជាផ្លូវការចំពោះបទល្មើសអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម។

[2] គណៈកម្មាធិការ CEDAW *ការអង្កេតបញ្ចប់លើរបាយការណ៍តាមដំណាក់កាលលើកទីបួន និងទីប្រាំរបស់កម្ពុជា* CEDAW/C/KHM/៤-៥, (ទីក្រុងហ្សឺណែវ ឆ្នាំ២០១៣), ១៥(ក)

## សេចក្ដីសង្ខេប

- គាំទ្រការអង្កេតទ្រង់ទ្រាយធំ/ថ្នាក់ជាតិអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម។
- បញ្ចូលការឆ្លើយតបនឹងអំពើហិង្សាផ្លូវភេទកើតមានកន្លងមកក្នុងពេលមានសង្គ្រាមទៅក្នុងគោលនយោបាយរដ្ឋាភិបាល ដូចជា ផែនការសកម្មភាពជាតិស្ដីពីអំពើហិង្សាលើស្ត្រី។
- ផ្ដល់សេវាគាំទ្រដល់ជនជាតិភាគតិចនៅរស់រានមានជីវិត ដែលទទួលរងអំពើហិង្សាផ្លូវភេទក្នុងពេលមានសង្គ្រាម។
- ផ្ដល់ឱកាសដល់ជនរងគ្រោះឱ្យទទួលបានយន្តការផ្ដល់យុត្តិធម៌អន្តរកាល រួមទាំង វេទិការៀបរាប់ការពិត ដូចជា ការស្ដាប់សំឡេងស្ត្រី និងការចងក្រងឯកសាររឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិត។
- ចងក្រងឯកសារស្ដីពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច និងផ្ដួចផ្ដើមឱ្យមានការចងចាំដល់អ្នកដែលទទួលរងអំពើហិង្សានេះ ដូចជា អំពើហិង្សានេះគឺជាផ្នែកមួយដ៏សំខាន់នៃការធ្វើទុក្ខបុកម្នេញដល់ជនជាតិភាគតិច។
- ផ្ដល់ដំណោះស្រាយដល់ជនជាតិភាគតិចនៅរស់រានមានជីវិត (និងអ្នកនៅរស់រានមានជីវិតដទៃទៀត) ដែលទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដំណោះស្រាយនេះអាចជាប្រាក់សំណង ការផ្ដល់សេវា ឬ ការគាំទ្រក្នុងទម្រង់ផ្សេងទៀតដល់អ្នកនៅរស់រានមានជីវិត។

### *អ.វ.ត.ក*

- ពង្រីកទំហំនៃការចោទប្រកាន់លើជនជាប់ចោទ ដើម្បីបញ្ចូលបទឧក្រិដ្ឋអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចឱ្យទូលំទូលាយទៅក្នុងសំណុំរឿង០០៣ និង០០៤។
- បង្កើតបរិយាកាសដែលអាចឱ្យជនជាតិភាគតិចវៀតណាមចូលរួមបានពេញលេញក្នុងវេទិកាផ្ដល់យុត្តិធម៌អន្តរកាល ដោយមិនមានការភ័យខ្លាចពីការសងសឹក និងការរើសអើង។
- ពិចារណាលើការផ្ដល់ឱ្យមាននូវព័ត៌មានអំពីអំពើហិង្សាផ្លូវភេទដែលប្រមូលបានដោយតុលាការសម្រាប់ការជំនុំជម្រះ បន្ទាប់ពីការបិទ អ.វ.ត.ក ។

### *ម្ចាស់ជំនួយ*

- ផ្ដល់ធនធានរយៈពេលវែងថេរ ដល់អង្គការសង្គមស៊ីវិលដែលគាំទ្រជនជាតិភាគតិចនៅរស់រានមានជីវិតទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

- ផ្តល់ធនធានសម្រាប់ការបន្តស៊ើបអង្កេតអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបនេះ។
- ដាក់សម្ពាធលើរដ្ឋាភិបាលឱ្យទទួលស្គាល់ និងដោះស្រាយបញ្ហានៃអំពើហិង្សាផ្លូវភេទកើតមានកន្លងក្នុងពេលមានសង្គ្រាម។

*អង្គការសង្គមស៊ីវិល*

- ផ្តល់កម្មវិធីសម្រាប់ជនជាតិភាគតិចនៅរស់រានមានជីវិតក្នុងរបបខ្មែរក្រហម រួមទាំងជំនួយផ្លូវច្បាប់ ជំនួយវេជ្ជសាស្ត្រ និងការព្យាបាលក្នុងសហគមន៍។
- ចុះជួបសហគមន៍ជនជាតិភាគតិច និងផ្តល់ការឆ្លើយតបពិសេសនឹងអំពើហិង្សាផ្លូវភេទកើតមានកន្លងមក។
- បង្កើតក្រុមគាំទ្រដល់ជនជាតិភាគតិចនៅរស់រានមានជីវិត និងគាំទ្រការផ្តល់សិទ្ធិអំណាចរបស់ពួកគេ តាមរយៈការផ្តល់ព័ត៌មានអំពីអំពើហិង្សាផ្លូវភេទកើតមានកន្លងមក ផ្តល់ឱកាសចែករំលែករឿងរ៉ាវរបស់ពួកគេ ការចងក្រងរឿងរ៉ាវរបស់ពួកគេជាឯកសារ និងគាំទ្រការលើកយកបញ្ហាទាំងនេះឡើងក្នុងសហគមន៍របស់ពួកគេ។
- សហការជាមួយអាជ្ញាធរអនុវត្តច្បាប់ និងអាជ្ញាធរមូលដ្ឋាន ដើម្បីធានាការពារដល់ជនជាតិភាគតិចនៅរស់រានមានជីវិតដែលបានចែករំលែកអំពីការទទួលរងអំពើហិង្សាផ្លូវភេទកន្លងមក។

*សាស្ត្រាចារ្យ និងស្ថាប័នអប់រំ*

- ផ្តល់ព័ត៌មានដល់សិស្សអំពីអំពើហិង្សាលើផ្លូវភេទ ដែលប្រព្រឹត្តលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម ផលប៉ះពាល់លើជនរងគ្រោះ និងតម្រូវការជាបន្តបន្ទាប់។
- ផ្តល់កម្មវិធីសិក្សាស្តីពីការការពារអំពើហិង្សាផ្លូវភេទ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ សិទ្ធិមនុស្ស និងទំនាក់ទំនងដែលមានការគោរពគ្នាទៅវិញទៅមក។

*ការសិក្សាស្រាវជ្រាវ និងអ្នកប្រវត្តិសាស្ត្រ*

- បន្តការស៊ើបអង្កេតលើការទទួលរងអំពើហិង្សាផ្លូវភេទរបស់ជនជាតិភាគតិច ជាពិសេស ផលប៉ះពាល់នៃការរៀបការដោយបង្ខំលើអត្តសញ្ញាណវប្បធម៌របស់ពួកគេ។
- ស៊ើបអង្កេតអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច និងទីតាំងដែលមិនទាន់បានបង្ហាញ

## សេចក្តីសង្ខេប

ក្នុងការសិក្សាស្រាវជ្រាវនេះ។ ការសិក្សាស្រាវជ្រាវ (ឧទាហរណ៍ ថ្នាក់ជាតិ) កាន់តែគ្រប់ជ្រុងជ្រោយក៏មានភាពចាំបាច់ដែរផ្តែកតាមទំហំ លក្ខណៈ និងវិសាលភាពនៃអំពើហិង្សាផ្លូវភេទកើតមានកន្លងមក រួមទាំង ប្រវត្តិជនរងគ្រោះ និងជនល្មើស ទិន្នន័យស្តីពីអន្តរាគមន៍មានប្រសិទ្ធ-ភាព ការវាយតម្លៃលើអន្តរាគមន៍ (រួមទាំង ការឆ្លើយតបប្រកបដោយយុត្តិធម៌) និងទិន្នន័យស្តីពីផលប៉ះពាល់ និងចំណាយលើជនរងគ្រោះ និងសហគមន៍។

- ស៊ើបអង្កេតអំពីទំនាក់ទំនងរវាងអំពើហិង្សាផ្លូវភេទកើតមានកន្លងមក និងអំពើហិង្សាផ្លូវភេទកើតមានបច្ចុប្បន្នលើជនជាតិភាគតិច ដើម្បីកំណត់អំពីទំនាក់ទំនង ឧបសគ្គក្នុងការរាយ-ការណ៍ និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងចំណុចដែលត្រូវអន្តរាគមន៍។

### *ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន*

- រាយការណ៍អំពីលទ្ធផលរកឃើញទាក់ទងនឹងអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម។
- សហការជាមួយអង្គការសង្គមស៊ីវិលដែលធ្វើការជាមួយជនជាតិភាគតិចនៅរស់រានមានជីវិតដើម្បីធានាថា ការរាយការណ៍មានភាពត្រឹមត្រូវ និងប្រសិទ្ធភាព។

### *សហគមន៍*

- អប់រំពួកគេ និង អ្នកដទៃទៀតអំពីរឿងរ៉ាវដែលជនជាតិភាគតិចទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំង ផលប៉ះពាល់សម្រាប់អ្នកនៅរស់រានមានជីវិត
- និយាយអំពីបញ្ហាទាំងនេះជាមួយអ្នកដទៃ (ឧទាហរណ៍ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម) ដើម្បីបង្ហាញអំពីអាថ៌កំបាំងនៃអំពើហិង្សាផ្លូវភេទ និងលុបបំបាត់ភាពអាម៉ាសពាក់ព័ន្ធការរងគ្រោះ។
- គាំទ្រជនជាតិភាគតិចនៅរស់រានមានជីវិតក្នុងការស្វែងរកជំនួយ និងសេវា។
- តស៊ូមតិជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកនយោបាយឱ្យទទួលស្គាល់បញ្ហានេះ និងបំពេញតម្រូវការរបស់ជនជាតិភាគតិចនៅរស់រានមានជីវិត។
- ទាមទារឱ្យជនល្មើសផ្តល់ការទទួលខុសត្រូវ។

# ១. សេចក្តីផ្តើម



## ១.១ អំពើហិង្សាផ្លូវភេទក្នុងប្រទេសកម្ពុជា


© Alexis Galon

បច្ចុប្បន្ន ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចឆាប់រហ័ស រួមជាមួយនឹងភាពប្រសើរឡើងនៃ វិស័យសុខាភិបាល និងវិស័យអប់រំ[3]។ ទន្ទឹមនឹងភាពរីកចម្រើននេះ បញ្ហាសង្គមដែលចាក់ស្រែះ និងវិសមភាពយេនឌ័រក៏កើតមានផងដែរ។ អ្វីដែលគួរឱ្យកត់សម្គាល់ អំពើហិង្សាក្នុងគ្រួសារ[4] ក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ ហើយប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសមានកម្រិតនៃការរំលោភជាក្រុមខ្ពស់ជាងគេបំផុតក្នុងទ្វីបអាស៊ី ដែលជាវិសមាមាត្រ ប្រព្រឹត្តឡើងដោយបុរសវ័យជំទង់[5]។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះ គឺមិនមានការយកចិត្តទុកដាក់បន្តិចណាសោះលើការពិនិត្យអង្កេតលើអំពើហិង្សាផ្លូវភេទដែលកើតមានកន្លងមក ក្នុងអំឡុងសង្គ្រាមដ៏យូរក្នុងប្រទេសនេះ[6] ដើម្បីជាមធ្យោបាយមួយសម្រាប់ស្វែងយល់អំពីអំពើហិង្សាផ្លូវភេទបច្ចុប្បន្ន ឬ ផលប៉ះពាល់ និងតម្រូវការរបស់អ្នកនៅរស់រានមានជីវិត។ ការសិក្សាស្រាវជ្រាវ នេះត្រូវបានធ្វើឡើង ដើម្បីបង្ហាញអំពីផ្នែកមួយនៃបញ្ហានេះ។

---

3 អង្គការសុខភាពពិភពលោក *ការក្រឡេកមើលយុទ្ធសាស្ត្រសហប្រតិបត្តិការរបស់ប្រទេស៖ ប្រទេសកម្ពុជា* (WHO ឆ្នាំ២០១១)។ ស្ថាប័នស្ថិតិរបស់ UNESCO។ បានមើលក្នុងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ <http://stats.uis.unesco.org/unesco/TableViewer/document.aspx?ReportId=121&IF_Language=en&BR_Country=4060>

4 អំពើហិង្សាលើស្ត្រីឆ្នាំ២០០៩ ការអង្កេតតាមដាន សេចក្តីសង្ខេប របាយការណ៍ស្រាវជ្រាវចុងក្រោយកម្ពុជា (ឆ្នាំ២០០៩)។ បានមើលក្នុងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ http://www.kh.undp.org/content/dam/cambodia/docs/DemoGov/Violence_Against_Women_2009_Follow-Up_Survey-Executive_Summary_Eng.pdf>

5 Fulu, E, Warner, X, Miedema, S, Jewkes, R, Roselli, T & Lang, J, *ហេតុអ្វីបានជាបុរសមួយចំនួនប្រើអំពើហិង្សាលើស្ត្រី និងតើយើងការពារបញ្ហានេះយ៉ាងដូចម្តេច? របាយការណ៍សង្ខេបនៃលទ្ធផលរកឃើញបែបបរិមាណវិស័យបានមកពីការសិក្សាស្រាវជ្រាវក្នុងច្រើនប្រទេសស្តីពីបុរស និងអំពើហិង្សាក្នុងទ្វីបអាស៊ី និងប៉ាស៊ីហ្វិក*(ទីក្រុងបាងកក ៖ UNDP, UNFPA, UN Women និង UNV ឆ្នាំ២០១៣)

6 ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ កម្ពុជាបានធ្លាក់ក្នុងសង្គ្រាមស៊ីវិលចំនួនប្រាំឆ្នាំ និងក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហមស្ទើររយៈពេល៤ឆ្នាំ បន្ទាប់មកស្ថិតក្រោមការគ្រប់គ្រងរបស់វៀតណាមរយៈពេល១០ឆ្នាំថែមទៀត។

# សេចក្តីផ្តើម

បក្សកុម្មុយនីស្តកម្ពុជា ជាទូទៅហៅថា ខ្មែរក្រហម ដែលបានកាន់អំណាចក្នុងចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ គឺជាអ្នកទទួលខុសត្រូវលើការបាត់បង់ជីវិតប្រជាជនកម្ពុជាច្រើនជាង១,៥លាននាក់[7] ដែលរងគ្រោះដោយសារតែភាពអត់ឃ្លាន ការសម្លាប់ ជំងឺ និងរបួស។

អំពើសាហាវយង់ឃ្នងមួយក្នុងចំណោមអំពើសាហាវយង់ឃ្នងជាច្រើនប្រព្រឹត្តឡើងក្នុងរបបនេះដែលគេបានចងក្រងទុក គឺអំពើហិង្សាផ្លូវភេទលើប្រជាជនសាមញ្ញ។ ភស្តុតាងនៃការសិក្សាស្រាវជ្រាវពីអ្នកនៅរស់រានមានជីវិត ពីតំបន់សង្គ្រាមនានានៅទូទាំងពិភពលោកបង្ហាញឱ្យឃើញពីការរីករាលដាល និង ភាពធ្ងន់ធ្ងរនៃអំពើហិង្សាផ្លូវភេទក្នុងពេលសង្គ្រាមលើស្ត្រី និង កុមារីដែលជាជនងាយរងគ្រោះបំផុត។ អំពើហិង្សាបែបនេះត្រូវបានអន្តរជាតិចាត់ទុកថា ជាយុទ្ធវិធីមួយនៃសង្គ្រាម និងជាមធ្យោបាយមួយនៃការបង្ក្រាប និងបំភិតបំភ័យប្រជាជនទាំងមូល ក៏ដូចជា ក្រុមប្រជាជនជាក់លាក់[8]។

ក្នុងចំណោមការសិក្សាស្រាវជ្រាវមានកម្រិតដែលស៊ើបអង្កេតលើអំពើហិង្សាផ្លូវភេទ និងយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[9] មានការសិក្សាស្រាវជ្រាវសំខាន់ពីរដែលអនុវត្តដោយ Kasumi Nakagawa[10] និង Katrina Natale[11] ជាមួយមិត្តរួមការងារនៅក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ។ អ្វីគួរឱ្យកត់សម្គាល់ ការសិក្សាស្រាវជ្រាវទាំងពីរបានបង្ហាញថា ក្រុមជនជាតិភាគតិចមួយចំនួនត្រូវបានកំណត់ជាគោលដៅនៃការទទួលរងអំពើហិង្សាផ្លូវភេទពីរបបនេះ។ ជាពិសេស ការសិក្សាស្រាវជ្រាវទាំងពីរបង្ហាញថា ស្ត្រី និងកុមារីនៃក្រុមជនជាតិភាគតិចត្រូវបានពួកខ្មែរក្រហមកំណត់មុខសញ្ញាសម្រាប់រំលោភសេពសន្ថវៈ ការរំលោភទ្រង់ទ្រាយធំ និងការសម្លាប់ ក៏ដូចជា ការរំលោភបំពានផ្លូវភេទជាប្រព័ន្ធទម្រង់ផ្សេងៗទៀត។ លទ្ធផលរកឃើញទាំងនេះគឺជាការលើកទឹកចិត្តដល់ការ

---

7 ចំនួនអ្នកស្លាប់នៅតែមិនទាន់ច្បាស់នៅឡើយ ដោយសារមិនមានព័ត៌មានគ្រប់គ្រាន់អំពីចំនួនប្រជាជនក្នុងប្រទេសកម្ពុជា មុននិងភ្លាមៗបន្ទាប់ពីចូលរបបខ្មែរក្រហម។ ទោះបីយ៉ាងណា តាមការប៉ាន់ស្មានជាមុន ចំនួនអ្នកស្លាប់មានចំនួនរហូតដល់១,៥លាននាក់។

8 ឧទាហរណ៍ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១៨២០ (ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨) ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។ បានមើលក្នុងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ <http://www.un.org/en/ga/search/view_doc.asp?symbol=S/RES/1820%202008%29>

9 ខ្មែរក្រហមបានផ្លាស់ប្តូរឈ្មោះប្រទេសកម្ពុជាទៅជារបបកម្ពុជាប្រជាធិបតេយ្យ នៅពេលពួកខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជា។ ពាក្យថា "របបកម្ពុជាប្រជាធិបតេយ្យ" និង "របបខ្មែរក្រហម" ត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមកក្នុងរបាយការណ៍នេះ។

10 Nakagawa, K, អំពើហិង្សាយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម។ *រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)* (ភ្នំពេញ ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០០៨)

11 Natale, K, *ខ្ញុំមានអារម្មណ៍ថាព្រលឹងខ្ញុំហោះហើរចេញពីរាងកាយខ្ញុំ។ ការសិក្សាស្រាវជ្រាវមួយអំពីអំពើហិង្សាយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងខេត្តបាត់ដំបង និងស្វាយរៀង* (ភ្នំពេញ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា៖ ឆ្នាំ២០១១)

ស៊ើបអង្កេតនៃការសិក្សាស្រាវជ្រាវនេះ។ ការសិក្សាស្រាវជ្រាវនេះបានព្យាយាមចងក្រងឯកសារស្តីពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចវៀតណាម ខ្មែរក្រោម ខ្មែរឥស្លាម និងជនជាតិចាមក្នុងរបបខ្មែរក្រហម ផលវិបាកលើជនរងគ្រោះ និងការឆ្លើយតបរបស់ពួកគេ។ អ្វីដែលសំខាន់នោះ ការសិក្សាស្រាវជ្រាវនេះមានបំណងកំណត់ថា តើជនជាតិភាគតិចទទួលរងអំពើហិង្សាផ្លូវភេទខុសពីប្រជាជនទូទៅដែរឬទេ?

មានករណីមួយចំនួនប៉ុណ្ណោះដែលជនជាតិភាគតិចនៅរស់រានមានជីវិតទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបនេះបានរៀបរាប់ដោយផ្ទាល់។ នៅពេលមានការបង្កើតឱ្យមានកិច្ចសន្ទនាជាសាធារណៈអំពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ជនជាតិភាគតិចនៅរស់រានមានជីវិតមានឱកាសក្នុងការចែករំលែករឿងរ៉ាវរបស់ខ្លួន ដើម្បីបង្ហាញពីការពិតជាប្រវត្តិសាស្រ្តនៃរបបនេះក្នុងប្រទេសកម្ពុជា។ ដោយសារតែជាជនជាតិភាគតិច ពួកគេត្រូវបានរើសអើង និងធ្វើទុក្ខបុកម្នេញតាំងពីអតីតកាលមក ព្រមទាំងប្រឈមមុខខ្ពស់នឹងការសម្លាប់បន្ទាប់ពីក្លាយជាជនរងគ្រោះ។ ហេតុដូច្នេះ ក្រុមជនជាតិភាគតិចទាំងនេះមិនសូវហ៊ានចែករំលែកអ្វីដែលខ្លួនជួបប្រទះ និងដឹងឮអំពីអំពើហិង្សាផ្លូវភេទជាមួយអ្នកដទៃឡើយ។ ដោយសារពេលវេលាកន្លងផុតទៅ និងអ្នកនៅរស់រានមានជីវិតមានអាយុកាន់តែច្រើន ឱកាសក្នុងការនិយាយជាមួយពួកគេកាន់តែតិច។


ចេតិយនៅជើងឯក

ការសិក្សាស្រាវជ្រាវនេះបានធ្វើឡើងដោយក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ដែលជាអង្គការមិនមែនរដ្ឋាភិបាលទទួលជំនួយស្របតាមច្បាប់ជាតិ (NGO)។ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ត្រូវបានជ្រើសរើសឱ្យធ្វើការសិក្សាស្រាវជ្រាវនេះ ដោយបានផ្តួចផ្តើមធ្វើការសិក្សាស្រាវជ្រាវដំបូងប្រកបការយកចិត្តទុកដាក់ និងការស៊ើបអង្កេតមួយចំនួនស្តីពីអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរ ក្រហម[12]។ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ក៏ជាតំណាងឱ្យអ្នកនៅរស់រានមានជីវិតទទួលរងអំពើហិង្សា

12 សូមមើល Nakagawa op. cit.; Natale op. cit.; Duong, S, *អាថ៌កំបាំងអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម* (ភ្នំពេញ ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០១១) Yim, S, *អតីតកាល និងបច្ចុប្បន្នភាពរបស់អ្នកនៅរស់រានមានជីវិតដែលត្រូវបានរៀបការដោយបង្ខំ* (ភ្នំពេញ ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០១២)

## សេចក្តីផ្តើម

យេនឌ័រក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនៅតុលាការកូនកាត់ ដែលស៊ើបអង្កេតលើ បទឧក្រិដ្ឋរបស់ខ្មែរក្រហម (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា/អ.វ.ត.ក)។ បទពិសោធន៍ និងជំនាញនេះមានសារៈប្រយោជន៍ក្នុងការជួយរៀបចំ និងការអនុវត្តការសិក្សាស្រាវជ្រាវនេះ។

ការសិក្សាស្រាវជ្រាវនេះ មានការចូលរួមពីក្រុមគោលដៅ ហើយជាចម្បង ការសិក្សានេះត្រូវបានរៀបចំឡើងសម្រាប់អ្នកធ្វើការសម្រេចចិត្តទាំងឡាយណា ដែលមានកាតព្វកិច្ចជួយដល់អ្នកនៅរស់រានមានជីវិតទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ដើម្បីស្វែងរកយុត្តិធម៌ និងដើម្បីនាំជនល្មើសមកទទួលទោស។ តាមការរំពឹងទុកអង្គការមិនមែនរដ្ឋាភិបាល និង អ្នកស្រាវជ្រាវដែលមានចំណាប់អារម្មណ៍ផ្តល់ការគាំទ្រដល់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ក៏នឹងទទួលបានការយល់ដឹងបន្ថែមតាមរយៈសក្ខីកម្មបង្ហាញក្នុងរបាយការណ៍នេះ។ របាយការណ៍នេះគឺជាការសិក្សាស្រាវជ្រាវមួយបន្ថែមលើចំនួនការសិក្សាស្រាវជ្រាវផ្សេងទៀត ដែលចងក្រងឯកសារអំពីអំពើហិង្សាយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់ជាកំណត់ត្រាប្រវត្តិសាស្ត្រជាតិ[13]។ ហេតុដូច្នេះ របាយ-ការណ៍នេះគឺជាផ្នែកមួយនៃការបង្ហាញអំពីការពិតដល់ប្រជាជនកម្ពុជាជំនាន់នេះ និង ជំនាន់ក្រោយ។

លើសពីនេះ គេសង្ឃឹមថា អ្នកនៅរស់រានមានជីវិតចាត់ទុករបាយការណ៍នេះជាភស្តុតាងមួយបង្ហាញពីភាពរឹងមាំ និងភាពជាសះស្បើយពីភាពឈឺចាប់របស់ខ្លួន ក្នុងការប្រឈមនឹងឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃនៃរបបខ្មែរក្រហម និងភាពក្លាហានរបស់ខ្លួនក្នុងការលាតត្រដាងរឿងរ៉ាវដែលត្រូវបានហាមឃាត់មិនឱ្យនិយាយ។ សំណៅរបាយការណ៍ពេញលេញជាភាសាខ្មែរ ក៏ដូចជា សេចក្តីសង្ខេបនៃលទ្ធផលរកឃើញសំខាន់ៗ សេចក្តីសន្និដ្ឋាន និងអនុសាសន៍នៃរបាយការណ៍នេះអាចរកបានតាមរយៈបណ្តាញខាងក្រោម។

http://gender-based violencekr.org/publications-and-materials/research-and-documentation/

## ១.២ រចនាសម្ព័ន្ធរបាយការណ៍

ផ្នែកដទៃទៀតនៃរបាយការណ៍នេះត្រូវបានបែងចែកចេញជាបួនជំពូក ៖

*ជំពូក២៖ សាវតា* ត្រូវបានដកស្រង់ចេញពីការសិក្សាស្រាវជ្រាវ និងសេចក្តីអត្ថាធិប្បាយកន្លងមក ដើម្បីផ្តល់បរិបទសង្គម និងប្រវត្តិសាស្ត្រ ដែលក្នុងនោះមានការពិចារណាលើការសិក្សាស្រាវជ្រាវ

13 ឧទាហរណ៍ ក្នុងពេលសរសេររបាយការណ៍នេះ ការសិក្សាស្រាវជ្រាវពីរកំពុងត្រូវបានអនុវត្ត ដោយពិនិត្យតាមដានលើអំពើហិង្សាយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ គម្រោងប្រវត្តិផ្ទាល់មាត់របស់ស្ត្រីកម្ពុជា ដែលដឹកនាំដោយ Theresa de Langis និងការសិក្សាអំពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ដឹកនាំដោយអង្គការអន្តរវប្បធម៌ចិត្តសង្គម។

នេះ។ របាយការណ៍នេះចាប់ផ្តើមពិភាក្សាពីការពណ៌នាអំពីការរីករាលដាលយ៉ាងឆាប់រហ័សនៃអំពើហិង្សាផ្លូវភេទក្នុងជម្លោះប្រដាប់អាវុធ និងផលប៉ះពាល់នៃការរើសអើងលើស្ត្រី និងកុមារី។ បន្ទាប់មករបាយការណ៍នេះនិយាយអំពីការត្រួតពិនិត្យលើគោលនយោបាយ និងការអនុវត្តរបស់ខ្មែរក្រហមពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រួសារ ការរៀបការ និងការរួមភេទជាមួយអ្នកដទៃមិនមែនជាប្តីឬប្រពន្ធខ្លួន។ សេចក្តីសន្និដ្ឋាននៃរបាយការណ៍នេះរៀបរាប់អំពីការស្វែងយល់អំពីការប្រព្រឹត្តនៃរបបនេះលើជនជាតិភាគតិច ដើម្បីផ្តល់បរិបទសម្រាប់វាយតម្លៃលើការទទួលរងអំពើហិង្សាផ្លូវភេទរបស់ជនរងគ្រោះ។

*ជំពូក៣ ៖ ការរៀបចំការសិក្សាស្រាវជ្រាវ* រៀបរាប់លម្អិតអំពីវិសាលភាព គោលដៅ និងសំណួរនៃការសិក្សាស្រាវជ្រាវ។ វិធីសាស្ត្រប្រមូល និងការវិភាគទិន្នន័យក៏ត្រូវបានពន្យល់ក្នុងរបាយការណ៍នេះ រួមទាំងការពិភាក្សាថាតើការសិក្សាស្រាវជ្រាវនេះបានលើកឡើងអំពីបញ្ហាក្រមសីលធម៌យ៉ាងដូចម្តេច? សេចក្តីសន្និដ្ឋាននៃជំពូកនេះ គឺការពិចារណាលើការកម្រិតលើការសិក្សាស្រាវជ្រាវផងដែរ។

*ជំពូក៤ ៖ លទ្ធផលរកឃើញ* បង្ហាញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ។ ជំពូកនេះចាប់ផ្តើមរៀបរាប់អំពីទិដ្ឋភាពទូទៅនៃប្រជាសាស្ត្ររបស់អ្នកផ្តល់បទសម្ភាស។ បន្ទាប់មកជំពូកនេះនិយាយអំពីទិន្នន័យស្តីពីប្រភេទអំពើហិង្សាផ្លូវភេទជាក់លាក់ដែលជនជាតិភាគតិចបានជួបប្រទះក្នុងរបបខ្មែរកម្ពុជាប្រជាធិបតេយ្យ រួមទាំង ការរៀបការដោយបង្ខំ ការរំលោភសេពសន្ថវៈ ការរួមភេទដើម្បីរស់រានមានជីវិត និងទាសករផ្លូវភេទ។ ជំពូកនេះក៏បង្ហាញអំពីទិន្នន័យស្តីពីផលប៉ះពាល់លើអ្នកនៅរស់រានមានជីវិត ការស្វែងរកជំនួយ កត្តាប្រឈម និងតម្រូវការជាបន្តបន្ទាប់ផងដែរ។ ជាចុងក្រោយ ទិន្នន័យនេះត្រូវបានវិភាគ ដើម្បីឆ្លើយតបនឹងសំណួរនៃការសិក្សាស្រាវជ្រាវ។

*ជំពូក៥ ៖ សេចក្តីសន្និដ្ឋានវាយតម្លៃលើ* អ្វីដែលសេចក្តីថ្លែងការណ៍ចុងក្រោយអាចទាញពីទិន្នន័យ និងការវិភាគលើលទ្ធផលរកឃើញ។

សម្រាប់អនុសាសន៍នៃការសិក្សាស្រាវជ្រាវនេះមានក្នុងសេចក្តីសង្ខេប។

# ២. សាវតា



## ២.១ អំពើហិង្សាផ្លូវភេទក្នុង និងក្រោយពេលសង្គ្រាម

ការកើតមានអំពើហិង្សាផ្លូវភេទក្នុងប្រទេសកម្ពុជាក្នុងពេលមានសង្គ្រាម គឺជារឿងធម្មតា។ អំពើហិង្សាផ្លូវភេទគឺជាលក្ខណៈពិសេសមួយនៃសង្គ្រាមដែលកើតមានក្នុងពិភពលោក។ ផ្អែកតាមសេចក្តីព្រាងនៃ *ពិធីសារអន្តរជាតិស្តីពីឯកសារ និងការស៊ើបអង្កេតលើអំពើហិង្សាផ្លូវភេទក្នុងពេលសង្គ្រាម*[14] អំពើហិង្សាបែបនេះត្រូវបានកំណត់និយមន័យថាជាការវាយប្រហារផ្លូវភេទលើស្ត្រី និងកុមារី បុរស និងកុមារា ដែលបណ្តាលឱ្យអ្នកនៅរស់រានមានជីវិតទទួលរងការប៉ះទង្គិចផ្លូវកាយ និងផ្លូវចិត្ត ក៏ដូចជា ការបង្កឱ្យមានផលប៉ះពាល់មិនចិតថេរដ៏ខ្លាំងលើសហគមន៍ និងប្រជាជន។





សង្គ្រាមជាឱកាសល្អមួយក្នុងការប្រព្រឹត្តអំពើហិង្សាផ្លូវភេទបានយ៉ាងឆាប់រហ័ស។ ក្នុងស្ថានភាពដែលអំពើហិង្សាមានកម្រិតខ្ពស់ជាទូទៅ កិច្ចគាំពារសង្គម និងការអនុវត្តច្បាប់មានភាពទន់ខ្សោយ ហើយស្ត្រី និងកុមារីប្រឈមនឹងភាពងាយរងគ្រោះកាន់តែធ្ងន់ធ្ងរឡើង ជនល្មើសមានឱកាសកាន់តែច្រើនក្នុងការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ ដោយមានកម្រិតទទួលរងការដាក់ទណ្ឌកម្មទាប។ ភាពអត់ឃ្លានខ្លាំងក៏អាចបង្ខំស្ត្រី និង កុមារីធ្លាក់ខ្លួនទៅជាទាសករផ្លូវភេទ ឬ ធ្វើការរួមភេទដូរយកអាហារបរិភោគ និងសិទ្ធិដទៃទៀត[15]។ ក្នុងស្ថានភាពនេះ ទាំងទាហាន និងអ្នកមិនមែនជាទាហានអាចឆក់ឱកាសក្នុងការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ[16]។

---

14 ពិធីសារអន្តរជាតិគឺជាការប្តេជ្ញាចិត្តរបស់សេចក្តីប្រកាស G៨ ស្តីពីការការពារអំពើហិង្សាផ្លូវភេទក្នុងពេលសង្គ្រាម ដែលបានប្រកាសនាថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣។

15 Kaufman, Michael និងមិត្តរួមការងារ *អំពើហិង្សាផ្លូវភេទក្នុង និងក្រោយពេលសង្គ្រាម៖ រួមទាំងបុរស និងកុមារា* សេចក្តីសង្ខេបការតស៊ូមតិអំពីការចូលរួមរបស់បុរស/UNFPA Advocacy Brief (ឆ្នាំ២០១២)។ បានមើលនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០១៤។ <http://unfpa.org/webdav/site/global/shared/documents/publications/2012/Advocacy%20Brief%20Sexual%20Violence%20FINAL.pdf>

16 សេចក្តីព្រាងនៃ *ពិធីសារអន្តរជាតិស្តីពីការចងក្រងឯកសារ និងការស៊ើបអង្កេតអំពើហិង្សាផ្លូវភេទក្នុងពេលសង្គ្រាម*

អ្វីដែលសំខាន់ជាងនេះ សេចក្តីព្រាងនៃពិធីសារខាងលើកំណត់ថា ទាហានក៏អាចប្រើអំពើហិង្សាផ្លូវភេទជាយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង ដាក់ទណ្ឌកម្ម បំបាក់មុខ ឬ បំផ្លាញក្រុមមនុស្សជាក់លាក់មួយ បំភិតបំភ័យពួកគេបន្តិចម្តងៗ ឬ ធ្វើឱ្យពួកគេជម្លៀសចេញពីទីតាំងមួយ[17]។ ការប្រើអំពើហិង្សាផ្លូវភេទជា "យុទ្ធវិធីនៃសង្គ្រាម" និងការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬ អំពើបណ្តាលឱ្យមានការប្រល័យពូជសាសន៍ ត្រូវបានចែងក្នុងលិខិតុបករណ៍ និងសេចក្តីសម្រេចអន្តរជាតិមួយចំនួន រួមទាំងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១៨២០[18] និងអនុសាសន៍ទូទៅលេខ៣០ របស់អនុសញ្ញា CEDAW ស្តីពីការការពារស្ត្រីក្នុង និងក្រោយពេលសង្គ្រាម III C (២៣)[19]។ ក្រុមប្រឹក្សាសន្តិសុខកត់សម្គាល់ថា អំពើហិង្សាផ្លូវភេទដែលបានប្រើជាយុទ្ធសាស្ត្របែបនេះ អាចមានបង្ហាញក្នុងអាកប្បកិរិយារបស់ជនល្មើស និងជនរងគ្រោះ បរិយាកាសនៃនិទណ្ឌភាព/ការដួលរលំរបបគ្រប់គ្រង វិសាលភាពនៃការឆ្លងដែន/ឬការពិតដែលពួកគេបំពានលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឈប់បាញ់គ្នា[20]។ កង្វល់មួយនៃការសិក្សាស្រាវជ្រាវនេះ គឺការកំណត់ថាតើខ្មែរក្រហមបានប្រើអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចជាយុទ្ធ-សាស្ត្រដែរឬទេ?

ដំណាក់កាលដំបូងក្នុងការវាយតម្លៃនេះ គឺការពិនិត្យមើលការឡើងកាន់កាប់អំណាចរបស់ខ្មែរក្រហម គោលបំណងរបស់ខ្មែរក្រហមលើប្រទេសកម្ពុជា និងការជិះជាន់នៃរបបនេះលើជនស៊ីវិល រួមទាំងការលើកទឹកចិត្តឱ្យប្រព្រឹត្តអំពើហិង្សាផ្លូវភេទ។

## ២.២ ខ្មែរក្រហម និងរបបកម្ពុជាប្រជាធិបតេយ្យ

នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលគ្រប់គ្រងរាជធានីភ្នំពេញ និងបន្ទាប់មកប្រទេសកម្ពុជាទាំងមូល ដោយបង្កឱ្យមានរបបមួយធ្វើឱ្យប្រជាជនកម្ពុជាមានភាពភ័យខ្លាច។ ការចូលកាន់កាប់របស់ខ្មែរក្រហមបានធ្វើឡើង បន្ទាប់ពីសង្គ្រាមស៊ីវិលរយៈពេលប្រាំឆ្នាំ ដែលក្នុងអំឡុងពេល

---

17 *Ibid.*

18 សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៨២០ *op. cit.*

19 បានមើលក្នុងថ្ងៃ១២ ខែកុម្ភៈ ឆ្នាំ២០១៤។ <http://www.ohchr.org/Documents/HRBodies/CEDAW/GComments/CEDAW.C.CG.30.pdf>

20 មហាសន្និបាតក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (A/60/657*-S/2012/33*), របាយការណ៍របស់អគ្គលេខាធិការស្តីពីអំពើហិង្សាផ្លូវភេទក្នុងពេលសង្គ្រាម (១៣ ខែមករា ឆ្នាំ២០១២) កថាខណ្ឌ៣។ ជាការឆ្លើយតប ក្រុមប្រឹក្សាសន្តិសុខបានជំរុញរដ្ឋជាប្រតិករ និងស្ថាប័នដទៃទៀតឱ្យការពារស្ត្រី និងកុមារីឱ្យបានកាន់តែប្រសើរ និងបានជំទាស់នឹងការលើកលែងទោសចំពោះបទឧក្រិដ្ឋអំពើហិង្សាផ្លូវភេទដែលបានប្រព្រឹត្តនៅពេលជិតផុតសង្គ្រាម។

នោះពួកខ្មែរក្រហមបានព្យាយាមផ្តួលរំលំរដ្ឋាភិបាលរបស់ លន់ នល់[21]។

ភ្លាមៗបន្ទាប់ពីទទួលបានអំណាច ខ្មែរក្រហមបានបង្ខំប្រជាជនជាច្រើនលាននាក់ឱ្យចាកចេញពីរាជធានី និងទីក្រុងមួយចំនួនទៀតទៅរស់នៅតាមជនបទ ដើម្បីបង្កើតជារបបធ្វើកសិកម្មតាមជនបទ។ ឈរលើទស្សនៈនៃការអភិវឌ្ឍប្រទេសចាប់ពី "ចំណុចសូន្យ" ខ្មែរក្រហមបានលុបបំបាត់ចោលនូវលុយ និងធនាគារ សាលារៀន អគារសាសនា បណ្តាញប្រៃសណីយ៍ និងទ្រព្យសម្បត្តិឯកជន[22]។ របបនេះបានបំផ្លាញប្រព័ន្ធទូរស័ព្ទ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈដទៃទៀត។ សាលារៀន និងមហាវិទ្យាល័យទាំងអស់ អគារសាសនា ផ្សារ និងអគាររដ្ឋាភិបាលភាគច្រើនត្រូវបិទ ឬ ប្រែក្លាយទៅជាមន្ទីរឃុំឃាំង ក្រោលសត្វ កន្លែងកសាង និងជង្រុកស្រូវ[23]។

ខ្មែរក្រហម បានដាក់ចេញជាបន្ទាន់នូវការគ្រប់គ្រងដ៏តឹងរ៉ឹងលើគ្រួសារគ្រប់ស្រទាប់វណ្ណៈសង្គម ដោយបង្គាប់បញ្ជាថា ប្រជាជនទាំងអស់មិនគួរមានគ្រួសារផ្ទាល់ខ្លួនក្រៅពីអង្គការឡើយ (តាមន័យត្រង់ "អង្គការ" ឬ ស្ថាប័នគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ)។ ប្តីប្រពន្ធ កុមារ និងសមាជិកគ្រួសាររបស់ប្រជាជនត្រូវបំបែកឱ្យរស់នៅដាច់ដោយឡែកពីគ្នា រួមទាំងទារកទើបនឹងកើត ក៏ត្រូវបានបំបែកពីម្តាយដែរ ដែលមើលថែទាំដោយមនុស្សដទៃទៀត[24]។ ប្រជាជនមិនត្រូវបានអនុញ្ញាតឱ្យជួបសួរសុខទុក្ខសមាជិកគ្រួសារញឹកញាប់ឡើយ ហើយការសួរសុខទុក្ខមានរយៈពេលខ្លី។ ប្រជាជនទូទៅត្រូវបានបង្ខំឱ្យរស់នៅក្នុងសហករណ៍ ដែលមានការគ្រប់គ្រងលើការគេង ហូបចុក និងការធ្វើ




*រូបភាពអ្នកជាប់ពន្ធនាគារនៅ ស២១*

21 សេនាប្រមុខ លន់ នល់ បានទទួលជោគជ័យក្នុងការធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះសីហនុដែលជាប្រមុខរដ្ឋក្នុងឆ្នាំ១៩៧០។ កងកម្លាំងកុម្មុយនីស្តវៀតណាមបានសហការជាមួយកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេលនោះ ធ្វើការវាយប្រហារកងកម្លាំងរបស់ លន់ នល់ ដែលទទួលបានជំនួយពីសហរដ្ឋអាមេរិក និងយុទ្ធនាការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់នៅទូទាំងប្រទេស។

22 Chandler, D, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា* ៤th ed. (ឈៀងម៉ៃ ៖ សៀវភៅដង្កូវនាង ឆ្នាំ២០០៨)

23 ការពិនិត្យតាមដានសាលាក្តីកម្ពុជា *ប្រវត្តិខ្មែរក្រហម (ឆ្នាំ២០១៣)* ផ្អែកលើ Khamboly D, *ប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) មជ្ឈមណ្ឌលឯកសារកម្ពុជា។ បានមើលនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩* <http://www.cambodiatribunal.org/history/cambodian-history/khmer-rouge-history/>

24 Mam, K, *របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ៖ ស្ត្រីជាមធ្យោបាយសម្រាប់ការផ្លាស់ប្តូរសង្គម (និក្ខេបបទថ្នាក់បរិញ្ញាបត្រ មហាវិទ្យាល័យ* Yale ឆ្នាំ២០០០)

ការ។ សេរីភាពផ្លាស់ទីមានតិចតួចប៉ុណ្ណោះ។

អ្នកធ្វើការបំពានចាប់ពីកម្រិតស្រាលដល់កម្រិតធ្ងន់ធ្ងរ ត្រូវទទួលទណ្ឌកម្មធ្ងន់ធ្ងរ ដូចជា ការវាយដំ ការដាក់ក្នុងមន្ទីរឃុំឃាំង ការជម្លៀស និងការផ្ទេរដោយបង្ខំ ការធ្វើទារុណកម្ម ការធ្វើកាយវិកលកម្ម និងការសម្លាប់។ បញ្ញវន្ត អ្នកមាន ជនបរទេស ឬ អ្នកគាំទ្ររបបមុនត្រូវបានចាត់ទុកជាសត្រូវនៃបដិវត្តន៍ និងត្រូវបានធ្វើទុក្ខបុកម្នេញ។ ក្នុងអំឡុងរបបនេះ ប្រជាជនជាច្រើនលាននាក់ទទួលរងនូវភាពអត់ឃ្លាន ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង ឈឺ ស្លាប់ និងត្រូវសម្លាប់ចោល[25]។

ចំណុចសំខាន់នៃការសិក្សាស្រាវជ្រាវនេះ គឺការផ្ដោតលើគោលនយោបាយរបស់ខ្មែរក្រហមក្នុងការគ្រប់គ្រងលើជីវិតគ្រួសារ និងទំនាក់ទំនងផ្លូវភេទដែលបានជំរុញឱ្យមានឱកាសក្នុងការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ។ គោលនយោបាយសំខាន់ពីរត្រូវបានរៀបរាប់ខាងក្រោម។

សំខាន់ជាងនេះទៀត របបនេះបានគ្រប់គ្រងអ្នកដែលអាចរៀបការបាន។ គោលនយោបាយនេះ អាចឱ្យខ្មែរក្រហមបង្ខំប្រជាជនឱ្យរៀបការជាមួយដៃគូដែលខ្មែរក្រហមជ្រើសរើសឱ្យ ដោយរៀបចំពិធីរៀបការជាក្រុមមានចំនួនរហូតដល់ជាច្រើនរយគូក្នុងពេលតែមួយ។ ប្រជាជនជាច្រើននៅទូទាំងប្រទេស ត្រូវបានបង្ខំឱ្យរៀបការខុសពីបំណងរបស់ពួកគេដោយសារការអនុវត្តតាមគោលនយោបាយនេះ។ អ្នកបដិសេធមិនអនុវត្តតាម នឹងទទួលរងទណ្ឌកម្មតាមរយៈការគំរាមកំហែង ការតម្រូវឱ្យបំពេញការងារលំបាក ការដាក់មន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ឬការសម្លាប់[26]។ De Langis និង Studzinsky[27] បានបង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទៅកាន់ អ.វ.ត.ក[28] ដោយបានលើកឡើងអំពីផលវិបាកធ្ងន់ធ្ងរនៃគោលនយោបាយនេះលើជនរងគ្រោះ។ អ្នកនិពន្ធលើកឡើងបន្ថែមទៀតថា មេធាវីនៃដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឱ្យចាត់ទុកការរៀបការដោយបង្ខំមានកម្រិតទោសតាមផ្លូវច្បាប់ស្មើនឹងការរំលោភសេពសន្ថវៈ ការធ្វើទាសភាព ការធ្វើទារុណកម្ម ក៏ដូចជា ចាត់ទុកជាបទឧក្រិដ្ឋដាច់ដោយឡែកមួយនៃការរៀបការដោយបង្ខំ និងការមានផ្ទៃពោះដោយមិនចង់បាន និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

25 *Ibid.*

26 De Langis, T &Studzinsky, S, *អ.វ.ត.ក បទឧក្រិដ្ឋផ្លូវភេទ និងវេទិកាស្ដាប់សំឡេងស្ត្រីកម្ពុជា (ខែឧសភា ឆ្នាំ២០១២)* ឯកសារសង្ខេបស្ដីពី អ.វ.ត.ក វេទិកាស្ដាប់សំឡេងស្ត្រីកម្ពុជា និងជំហានដោះស្រាយអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ៧។ បានមើលនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៤ <http://www.civilparties.org/?p=1304>

27 De Langis&Studzinsky op. cit. ៧

28 អ.វ.ត.ក គឺជាតុលាការកូនកាត់ជាតិ និងអន្តរជាតិសម្រាប់ជំនុំជម្រះលើឧក្រិដ្ឋកម្មសង្គ្រាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ



ចេតិយនៅខេត្តបាត់ដំបង

ការពិចារណាសំខាន់មួយ ដើម្បីយល់ដឹងអំពីអំពើហិង្សាផ្លូវភេទក្នុងបរិបទនេះ គឺថាតើអាជ្ញាធរខ្មែរក្រហមមានការឆ្លើយតបយ៉ាងដូចម្ដេចនៅពេលមានអំពើហិង្សាបែបនេះកើតឡើង? តាមរយៈការបកស្រាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលើ "ក្រមលេខប្រាំមួយ" នៃ "ក្រមប្រតិបត្តិទាំងដប់ពីររបស់ទាហាន" ខ្មែរក្រហមបានលើកឡើងថា មិនមាននរណាម្នាក់អាចរំលោភបំពានលើស្ត្រី បង្ខំស្ត្រីឱ្យរួមភេទ ឬ រួមភេទជាមួយស្ត្រីដែលមិនមែនជាប្រពន្ធខ្លួនឡើយ[29]។ ទណ្ឌកម្មសម្រាប់ការរំលោភបំពាននេះ រួមមាន ការកសាង ការធ្វើការងារដោយបង្ខំ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់។ វត្តមាននៃគោលនយោបាយនេះមានអត្ថន័យថា ទាំងការរួមភេទជាមួយ អ្នកដទៃក្រៅពីប្ដីប្រពន្ធខ្លួន និងអំពើហិង្សាផ្លូវភេទគឺជាករណីកម្រកើតមានក្នុងរបបនេះ ហើយជនល្មើសត្រូវបានដាក់ទណ្ឌកម្ម ប្រសិនបើអំពើបែបនេះពិតជាកើតឡើង។ ការសិក្សាស្រាវជ្រាវកន្លងមក និងការស៊ើបអង្កេតដទៃទៀត ក៏ដូចជា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដាក់ជូនទៅ អ.វ.ត.ក បង្ហាញពីភាពខុសគ្នាខ្លាំងទៅនឹងការពិត[30]។

ប្រសិនបើជនរងគ្រោះ និង ជនល្មើសត្រូវបានយកមកកាត់ទោសតាមក្រមលេខប្រាំមួយក្នុងករណីគេរកឃើញមានអំពើហិង្សាផ្លូវភេទ ដូច្នេះ គេអាចឃើញយ៉ាងច្បាស់ថាមិនមានការរៀបចំណាមួយឱ្យមានការការពារសិទ្ធិរបស់ស្ត្រីរងគ្រោះឡើយ។ ជាក់ស្ដែង de Langis និង Studzinsky[31] និងអ្នកដទៃទៀតបានជំទាស់ថា ផ្ទុយទៅវិញ គោលនយោបាយនេះត្រូវបានបង្កើត ដើម្បីគ្រប់គ្រងលើសកម្មភាពផ្លូវភេទទាំងអស់របស់ប្រជាជន ដែលឆ្លុះបង្ហាញឱ្យឃើញអំពីការគ្រប់គ្រងដ៏តឹងរ៉ឹងលើប្រជាជន។ De Langis និង Studzinsky បង្ហាញបន្ថែមថា (១) គោលនយោបាយនេះមិនបានការពារជនរងគ្រោះឡើយ ប្រសិនបើពួកគេត្រូវបានចាត់ទុកជាសត្រូវនៃរបបនេះ (២) មិនមានស្ថាប័នផ្លូវការ

29 Youk, C, *ក្រមប្រតិបត្តិទី៦។ ការស្រាវជ្រាវការពិត បញ្ហា* ១៥ (ឆ្នាំ២០០១)។ បានមើលនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣<http://d.dccam.org/Projects/Magazines/Previous%20Englis/Issue15.pdf>

30 Nakagawa, op. cit.; Natale op. cit.; ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដាក់ជូនទៅ អ.វ.ត.ក

31 De Langis&Studzinsky op. cit. ៥

ឬក្រៅផ្លូវការ (ដូចជា តុលាការ នគរបាល ។ល។) ផ្ដល់ដំណោះស្រាយជូនជនរងគ្រោះ ឬ ទទួលខុសត្រូវលើបទឧក្រិដ្ឋដែលប្រព្រឹត្តលើជនរងគ្រោះឡើយ និង(៣) ប្រសិនបើជនល្មើសមានប្រវត្តិចូលរួមក្នុង "បដិវត្តន៍បានយ៉ាងសកម្ម" ពួកគេអាចរួចផុតពីទណ្ឌកម្ម។ ចំណុចទាំងនេះពិតជាជួយការពារជនល្មើសយ៉ាងច្រើន ដោយអាចឱ្យជនល្មើសប្រព្រឹត្តអំពើហិង្សាផ្លូវភេទបន្ថែមទៀតដោយមិនទទួលរងទណ្ឌកម្ម។

ដោយបានលើកឡើងអំពីបរិយាកាសសង្គម និងនយោបាយសម្រាប់ប្រជាជនស៊ីវិលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បច្ចុប្បន្ន ការពិភាក្សាកំពុងស្វែងរកភស្តុតាងទាក់ទងនឹងការប្រព្រឹត្តអំពើហិង្សាផ្លូវភេទក្នុងរបបនេះ។

## ២.៣ អំពើហិង្សាផ្លូវភេទក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម

បទល្មើសអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានក្លាយជាប្រធានបទនៃការសិក្សាស្រាវជ្រាវដ៏មានតម្លៃមួយចំនួន និងការស៊ើបអង្កេតដទៃទៀត។ Natale[32] ផ្ដល់ការអង្កេតដ៏ល្អតតខ្ទោះមួយលើបញ្ហាទាំងនេះក្នុងរបាយការណ៍របស់នាងទាក់ទងនឹងអំពើហិង្សាយេនឌ័រ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សេចក្ដីសង្ខេបខាងក្រោមនៃឯកសារនេះដកស្រង់ចេញពីការអង្កេតនេះ និងបានបញ្ចូលក្នុងការសិក្សារបស់ Natale និងការស្រាវជ្រាវដែលអនុវត្តដោយ Savorn Duong និង Farina So ៖

- ក្នុងឆ្នាំ១៩៩០ Richard Mollica និងមិត្តរួមការងារមកពីកម្មវិធី Harvard ស្ដីពីការប៉ះទង្គិចផ្លូវចិត្តរបស់ជនភៀសខ្លួន (Harvard Program in Refugee Trauma) បានធ្វើបទសម្ភាសជនភៀសខ្លួនកម្ពុជាចំនួនជិត១០០០នាក់ក្នុងជំរំជិតព្រំដែនថៃ ដោយបានរកឃើញថា អ្នកផ្ដល់បទសម្ភាសចំនួន១៧% ត្រូវបានរំលោភសេពសន្ថវៈ ឬ រំលោភបំពានផ្លូវភេទ[33]។
- Kalyanee Mam មកពីមហាវិទ្យាល័យ Yale បានធ្វើបទសម្ភាសក្នុងខេត្តកណ្ដាលក្នុងឆ្នាំ១៩៩៩ និង ឆ្នាំ២០០០ ដោយផ្ដោតការពិនិត្យតាមដានលើគោលនយោបាយខ្មែរក្រហម ព្រមទាំងបានស្វែងរកភស្តុតាងអំពីការរៀបការដោយបង្ខំ ការរំលោភសេពសន្ថវៈ និងការរំលោភបំពានផ្លូវភេទ

[32] Natale, *op. cit.*

[33] Mollica,RF,Donelan,K,Tor,S,Lavelle,J,EliasC,Frankel,M,Blendon,RJ,"ផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តនិងការឃុំឃាំងខ្លួនលើសុខភាពនិងសុខភាពផ្លូវចិត្តរបស់ប្រជាជនកម្ពុជារស់នៅក្នុងជំរំតាមព្រំដែនកម្ពុជា-ថៃ" *ទស្សនាវដ្ដីសមាគមវេជ្ជសាស្ត្រអាមេរិក* ២៧០ ៥ (ឆ្នាំ១៩៩៣) ៖ ៥៨១-៥៨៦

លើស្ត្រី[34]។

- ក្នុងឆ្នាំ២០០៦ Kasumi Nakagawa និងមិត្តរួមការងារនៅក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានរៀបចំកម្រងសំណួរតាមវិធីសាស្ត្រមិនចៃដន្យចំនួន ១៥០០ កម្រងសំណួរ និងបានធ្វើបទសម្ភាសលម្អិតចំនួន ៩៦ បទសម្ភាសទាក់ទងនឹងរឿងរ៉ាវគួរឱ្យចាប់អារម្មណ៍បំផុតក្នុងកម្រងសំណួរ ដើម្បីដឹងថា តើអ្នកទទួលរងអំពើហិង្សាផ្លូវភេទដែលនៅរស់រានមានជីវិតពីរបបនេះត្រូវបានសម្លាប់ទាំងអស់ដែរឬទេ? នាងបានរកឃើញថា ជនរងគ្រោះនៅមានជីវិត និងបានចងក្រងឯកសារស្ដីពីករណីនៃការរៀបការដោយបង្ខំ ការរំលោភសេពសន្ថវៈ ការរំលោភអ្នកដទៃក្រៅពីប្ដីប្រពន្ធខ្លួន ការបៀតបៀនផ្លូវភេទក្នុងទម្រង់ផ្សេងទៀត រួមទាំង ការរំលោភបំពានផ្លូវភេទ ការធ្វើកាយវិកលកម្ម និងការបង្ខំឱ្យអាក្រាតកាយ[35]។

- Peg Le Vine បានបោះពុម្ពផ្សាយសៀវភៅមួយក្បាលក្នុងឆ្នាំ២០១០ ដែលផ្ដោតជាពិសេសលើការរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ផ្នែកនេះបានដកស្រង់ចេញពីការសិក្សាស្រាវជ្រាវរយៈពេល១០ឆ្នាំលើបុរសស្ត្រីចំនួន ១៩២ នាក់ដែលបានរៀបការក្នុងរបបនេះ ដោយរៀបរាប់លម្អិតថាតើពួកគេយល់ឃើញដូចម្ដេចចំពោះការរៀបការ និងការមិនមានការរៀបចំពិធីរៀបការ? ខណៈពេលអ្នកនិពន្ធបានចងក្រងឯកសារស្ដីពីភាពឈឺចាប់បង្កឡើងដោយខ្មែរក្រហមដែលបង្គាប់បញ្ជាឱ្យប្រជាជនរៀបការ រួមភេទ និងមានផ្ទៃពោះ នាងក៏បានបង្ហាញដែរថា ការរៀបការតាមការបង្គាប់បញ្ជាបានជួយប្ដីប្រពន្ធឱ្យរួចផុតពីការទទួលទោសដែលខ្លួនបានបំពាន និងការរំខានដទៃទៀត។ នាងមិនបានធ្វើចំណាត់ថ្នាក់ទំនាក់ទំនងទាំងនេះថាជា "ការរៀបការដោយបង្ខំ" ឡើយ[36]។

- Katrina Natale និងមិត្តរួមការងារនៅក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានធ្វើបទសម្ភាសតាមវិធីសាស្ត្រមិនចៃដន្យចំនួន១០៤ដងក្នុងខេត្តបាត់ដំបង និងស្វាយរៀងក្នុងឆ្នាំ២០១០។ ការសិក្សាស្រាវជ្រាវរបស់នាង ផ្ដោតលើការពិនិត្យអំពីប្រភេទនៃអំពើហិង្សាយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយការកំណត់អត្តសញ្ញាណជនរងគ្រោះ និងជនល្មើស ទីតាំង និងស្ថានភាពនៃអំពើហិង្សាយេនឌ័រ។ ការសិក្សាស្រាវជ្រាវបានរកឃើញភស្តុតាងនៃការរំលោភសេពសន្ថវៈ ការរំលោភជាក្រុម និងក្នុងទ្រង់ទ្រាយធំ ការរំលោភក្នុងស្ថាប័ន និងសហករណ៍ខ្មែរក្រហម ការរំលោភដោយប្រើវត្ថុចម្លែក ការកេងប្រវ័ញ្ចផ្លូវភេទ និងទាសករផ្លូវភេទ ការធ្វើកាយវិកល

---

34 Mam, *op. cit*

35 Nakagawa, *op. cit.*

36 Lavine, P, *សេចក្ដីស្រលាញ់ និងភាពភ័យខ្លាចក្នុងប្រទេសកម្ពុជា ៖ គ្រោះថ្នាក់នៃការរៀបការ ការកើត និងការប្រតិបត្តិសាសនាក្នុងរបបខ្មែរក្រហម* (ប្រទេសសឹង្ហបុរី ៖ សារព័ត៌មាន MIS ឆ្នាំ២០១០)

កម្មផ្លូវភេទ និងការធ្វើទារុណកម្ម ការរំលោភបំពាន និងការបំបាក់មុខ និងការរៀបការដោយបង្ខំ។ មានការផ្តល់អនុសាសន៍ជាច្រើនសម្រាប់ការផ្តល់យុត្តិធម៌អន្តរកាល ការកាត់សេចក្តីលើបទឧក្រិដ្ឋ និងការផ្តល់សំណង ការសិក្សាស្រាវជ្រាវ និងការចងក្រងឯកសារស្តីពីការរំលោភបំពានសិទ្ធិមនុស្ស និងការគាំទ្រជនរងគ្រោះ តាមរយៈការផ្តល់សេវា។[37]

- ក្នុងឆ្នាំ២០១១ Savorn Duong នៅក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានធ្វើបទសម្ភាសលម្អិតជាមួយបុរសស្ត្រីចំនួន១៨នាក់ ដែលទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម។ រឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានចងក្រងទុកក្នុងរបាយការណ៍លម្អិត ដោយចងក្រងអំពីករណីរំលោភសេពសន្ថវៈ ការរំលោភរួចសម្លាប់ ការរំលោភក្នុងមន្ទីរឃុំឃាំង ការរៀបការដោយបង្ខំ ទារុណកម្មផ្លូវភេទ និងទាសករផ្លូវភេទ[38]។
- ក្នុងឆ្នាំ២០១១ Farina So បានបោះពុម្ពផ្សាយឯកសារសិក្សាស្រាវជ្រាវលើប្រធានបទមួយផ្អែកលើការស្រាវជ្រាវសម្រាប់និក្ខេបបទថ្នាក់អនុបណ្ឌិតរបស់នាង ដោយក្នុងនោះ នាងក៏បានធ្វើបទសម្ភាសលម្អិតជាមួយស្ត្រីជនជាតិចាមមូស្លីមអំពីបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហម។ រឿងរ៉ាវរបស់ស្ត្រីទាំងនេះក៏បានបញ្ចូលក្នុងរបាយការណ៍ស្តីពីអំពើហិង្សាផ្លូវភេទដែលបានកំណត់គោលដៅ[39]។

លទ្ធផលរកឃើញនៃការសិក្សាស្រាវជ្រាវទាំងនេះផ្តល់ភស្តុតាងដ៏រឹងមាំថា ក្នុងរបបនេះទម្រង់នៃអំពើហិង្សាយេនឌ័រដែលកើតមានភាគច្រើនគឺពាក់ព័ន្ធនឹងផ្លូវភេទ។ ប្រជាជនទទួលរងអំពើហិង្សាផ្លូវភេទខុសៗគ្នាជាច្រើនក្នុងទីកន្លែងមួយចំនួននៅទូទាំងប្រទេស។ អំពើហិង្សាផ្លូវភេទទាំងនេះរួមមាន ការរំលោភសេព-សន្ថវៈ ទាសករផ្លូវភេទ ការរៀបការដោយបង្ខំ ការរួម



*ស្ត្រីជនជាតិចាមកំពុងធ្វើសក្ខីកម្មក្នុងកម្មវិធី ការស្តាប់សំឡេងស្ត្រីឆ្នាំ២០១៣ អំពីបទពិសោធន៍របស់គាត់ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ*

37 Natale, *op. cit.*

38 Duong, S, *អាថ៌កំបាំងនៃអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម* (ភ្នំពេញ ៖ ក្រុមអ្នកការពារសិទ្ធិកម្ពុជា ឆ្នាំ២០១១)

39 So, F, *ស្បៃគ្របមុខរបស់ស្ត្រីឥស្លាមក្នុងប្រទេសកម្ពុជា ៖ ការចងចាំរបស់ស្ត្រីចាមមូស្លីមបន្ទាប់ពីរបបខ្មែរក្រហមកម្រងឯកសារលេខ១៦* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០១១)

ភេទដើម្បីរស់[40] ការធ្វើកាយវិកលកម្មផ្លូវភេទ និងការធ្វើទារុណកម្ម និងការរំលោភបំពានផ្លូវភេទដទៃទៀត។ ជនល្មើសភាគច្រើនគឺជាភ្នាក់ងារខ្មែរក្រហម និងកម្រទទួលការដាក់ទណ្ឌកម្ម។ ជនរងគ្រោះ និងគ្រួសាររបស់ពួកគេទទួលរងផលវិបាកជាច្រើនពីអំពើហិង្សាផ្លូវភេទ។ អ្នកនៅរស់រានមានជីវិតជាច្រើនក្នុងចំណោមអ្នកនៅរស់រានមានជីវិតទាំងនេះ មានតម្រូវការជាបន្តបន្ទាប់ក្នុងការទទួលបានការគាំទ្រលើការដោះស្រាយបញ្ហាដែលពួកគេបានជួបប្រទះ និងការប៉ះទង្គិចផ្លូវចិត្ត។

ផ្អែកលើប្រធានបទស្តីពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកស្រាវជ្រាវនៃការសិក្សាស្រាវជ្រាវនេះ មិនអាចធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទជាក់លាក់ក្រៅពីករណី និងការស៊ើបអង្កេតដាច់ដោយឡែកពីគ្នា ដែលបានកត់ត្រាទុកក្នុងរបាយការណ៍មួយចំនួនក្នុងចំណោមរបាយការណ៍លើកឡើងខាងលើឡើយ។ ការណ៍នេះបង្ហាញឱ្យឃើញអំពីការខ្វះខាតនៃដំណើររឿងក្នុងរបបនេះ។ ការខ្វះខាតនេះបានជំរុញឱ្យមានការស៊ើបអង្កេតលើការទទួលរងអំពើហិង្សាផ្លូវភេទរបស់ជនជាតិភាគតិចក្នុងរបបនេះសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

ការពិភាក្សាខាងក្រោម បង្ហាញអំពីការយល់ឃើញ និងការឆ្លើយតបជាទូទៅរបស់ខ្មែរក្រហមលើជនជាតិភាគតិចវៀតណាម ខ្មែរក្រហម ខ្មែរឥស្លាម និងជនជាតិចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយចាត់ទុកពួកគេជាមធ្យោបាយសម្រាប់ប្រព្រឹត្តអំពើហិង្សាផ្លូវភេទ។

## ២.៤ ខ្មែរក្រហម និងជនជាតិភាគតិច

គោលនយោបាយខ្មែរក្រហមបង្ហាញថា មេដឹកនាំរបបនេះមានបំណងបង្កើតរបបខ្មែរមួយមានលក្ខណៈដូចគ្នាទាំងអស់ ដែលជារបបមិនអត់ឱនក្រុមជនជាតិភាគតិច។ ភស្តុតាងមានបង្ហាញជាក់ច្បាស់ក្នុងច្បាប់នៃរបបនេះដែលដាក់បម្រាមលើក្រុមជនជាតិភាគតិចនិងសាសនាច្រើនជាង២០ក្រុម រួមទាំង ជនជាតិភាគតិចវៀតណាម និងជនជាតិភាគតិចចាមមូស្លីម[41]។ លើសពីនេះ ទោះបីជារដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦នៃរបបកម្ពុជាប្រជាធិបតេយ្យបានធានាសិទ្ធិសេរីភាពនៃជំនឿសាសនាក៏ដោយ ក៏រដ្ឋធម្មនុញ្ញនេះបានហាមឃាត់យ៉ាងតឹងរ៉ឹងចំពោះ "សាសនាទាំងអស់ដែលប្រឆាំងនឹងបដិវត្តន៍ខ្លួន និងធ្វើឱ្យអន្តរាយដល់របបកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជា"[42]។ តាមរយៈសកម្មភាពនៃរបប

40 ហៅម៉្យាងទៀតថា ការដោះដូរអាហារ ថ្នាំ និងសិទ្ធិដទៃទៀតសម្រាប់ការរួមភេទ។

41 Gellately, R; Kiernan, B, *ព្រលឹងជនរងគ្រោះក្នុងអំពើប្រល័យពូជសាសន៍៖ការសម្លាប់រង្គាលក្នុងទិដ្ឋភាពប្រវត្តិសាស្ត្រ* (Cambridge, New York ៖ សារព័ត៌មានមហាវិទ្យាល័យ Cambridge) ៣១៣–៣១៤

42 រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) បានមកពី *រដ្ឋធម្មនុញ្ញកម្ពុជា* (ឆ្នាំ១៩៥៣-១៩៩៣) បានប្រមូល និងផ្តល់ដោយ RMJennar។ បានមើលនៅថ្ងៃទី១២ ខែមករា ឆ្នាំ ២០១៩ <http://www.d.dccam.org/Archives/Documents/DK_Policy/DK_Policy_DK_Constitution.htm>

នេះបង្ហាញថា ការពិត មេដឹកនាំរបបនេះប្រឆាំងយ៉ាងខ្លាំងនឹងសាសនា។ ក្នុងអំឡុងពេលកាន់អំណាច ខ្មែរក្រហមបានបំផ្លាញប្រាសាទវត្តអារាមវិហារឥស្លាម និងព្រះវិហារគ្រិស្តវត្ថុបុរាណ និងគម្ពីរសាសនា និងបានសម្លាប់មេដឹកនាំសាសនាជាច្រើននៅទូទាំងប្រទេសកម្ពុជា។ លោកសង្ឃត្រូវបានចាប់ផ្សឹក និងបញ្ជូនទៅជំរំការងារ។ សហគមន៍គ្រិស្ត និងមូស្លីមត្រូវបានកំណត់ជាគោលដៅពិសេស ដោយត្រូវបានចាត់ទុកជាពួកគាំទ្រលោកខាងលិច និងតម្រូវឱ្យប្រព្រឹត្តតាមវប្បធម៌ និងសង្គមកម្ពុជា[43]។

គោលនយោបាយខ្មែរក្រហមដែលកំណត់គោលដៅ ឬ មានផលប៉ះពាល់ជាច្រើនលើជនជនជាតិភាគតិច និងសាសនា ជាទូទៅ បានកំណត់ឱ្យអនុវត្ត ដូចជា (១) ការអនុវត្តតាមវប្បធម៌ខ្មែរ (ដូចជា អនុញ្ញាតឱ្យនិយាយតែភាសាខ្មែរ) (២) ការបំបែកចេញពីគ្រួសារ និងសហគមន៍ (៣) អំពើហិង្សាដែលមានការកំណត់គោលដៅ (៤) ការជម្លៀសចេញពីប្រទេស និង (៥) ការសម្លាប់[44]។

## ២.៤.១ ជនជាតិភាគតិចវៀតណាម

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភាពតានតឹងខាងយោធា និងនយោបាយកើតមានជាបន្តបន្ទាប់រវាងរដ្ឋាភិបាលខ្មែរក្រហម និងវៀតណាម។ ជាការឆ្លើយតប ខ្មែរក្រហម បានរើសអើងយ៉ាងខ្លាំង និងសម្លាប់ជនជាតិភាគតិចវៀតណាមដែលរស់នៅក្នុងប្រទេសម្ពុជាយ៉ាងរង្គាលនៅគ្រប់តំបន់ខុសៗគ្នានៃប្រទេសកម្ពុជា និងក្នុងពេលខុសៗគ្នា។

ភ្លាមៗបន្ទាប់ពីឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានព្យាយាមបណ្តេញប្រជាជន និងទាហានវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា។ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យមានការសង្ស័យយ៉ាងខ្លាំងលើវៀតណាមខាងជើង ដោយជឿជាក់ថា ពួកកុម្មុយនីស្តវៀតណាមមានបំណងកាន់កាប់ប្រទេសកម្ពុជា ដើម្បីបង្កើតបានជាផ្នែកនៃសម្ព័ន្ធមួយកាន់តែធំ ដែលដឹកនាំដោយប្រទេសវៀតណាម[45]។ ក្នុងខែឧសភា ឆ្នាំ១៩៧៥ ប៉ុល ពត និង នួន ជា បានប្រកាសផែនការបណ្តេញជនជាតិវៀតណាមពីប្រទេស ដោយជឿជាក់ថា ពួកវៀតណាមបាន "លួចចូលក្នុងប្រទេសកម្ពុជាជាសម្ងាត់ និងរស់នៅលាក់ខ្លួនជាមួយប្រជាជនខ្មែរ[46]"។ ហេតុដូច្នេះ កងកម្លាំងទាហានវៀតណាមខាងជើងទាំង

---

43 Thomas, SJ, *ការចោទប្រកាន់លើបទឧក្រិដ្ឋបំផ្លាញសម្បត្តិវប្បធម៌* ការឃ្លាំមើលអំពើប្រល័យពូជសាសន៍។ បានមើលនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ <http://www.genocidewatch.org/images/Cambodia_Prosecuting_the_Crime_of_Destruction_of_Cultural_Property.pdf>

44 Duong, L, *ការរើសអើងពូជសាសន៍នៃអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា* កម្មវិធីសិក្សាអំពីអំពើប្រល័យពូជសាសន៍ មជ្ឈមណ្ឌល MacMillan សម្រាប់ការសិក្សាជាអន្តរជាតិ និងតាមតំបន់ ឯកសារការងារ GSP លេខ៣៤ (New Haven ៖ មហាវិទ្យាល័យ Yale ឆ្នាំ២០០៦) ២២៦-២២៧

45 Farrell, EC, *សារធារណៈរដ្ឋសង្គមនិយមវៀតណាម និងច្បាប់សមុទ្រ ៖ ការវិភាគលើឥរិយាបថវៀតណាមស្ថិតក្នុងរបបគ្រប់គ្រងសមុទ្រអន្តរជាតិដែលទើបលេចជារូបរាងឡើង* ឆ្នាំ១៩៩៨)

46 Kiernan, B, *របបប៉ុលពត* (ឈៀងម៉ៃ ៖ សៀវភៅដង្កូវនាង ឆ្នាំ១៩៩៦) ១០៧

អស់ត្រូវបានបណ្តេញចេញពីទឹកដីកម្ពុជាភ្លាមៗ បន្ទាប់ពីរបបនេះចូលកាន់កាប់រាជធានីភ្នំពេញ[47]។ តាមការប៉ាន់ស្មាន ក្នុងរយៈពេលប៉ុន្មានខែប៉ុណ្ណោះ ជនជាតិវៀតណាមចំនួន១៥០.០០០នាក់ត្រូវបានបណ្តេញចេញពីប្រទេស ដោយមាននៅសេសសល់ចំនួន១០០.០០០នាក់ទៀត[48]។

ក្នុងពាក់កណ្តាលឆ្នាំ១៩៧៦ គោលនយោបាយទាំងនេះត្រូវបានផ្លាស់ប្តូរ ហើយខ្មែរក្រហមមិនឱ្យជនជាតិវៀតណាមចាកចេញទៀតឡើយ[49]។ បទបញ្ជានេះត្រូវបានដាក់ចេញក្នុងខែមេសា ឆ្នាំ១៩៧៧ ក្នុងគោលបំណងចាប់ខ្លួនជនជាតិវៀតណាម និងអ្នកដែលពាក់ព័ន្ធនឹងជនជាតិវៀត-ណាម។[50] បន្ទាប់មក របបនេះបានធ្វើការសម្លាប់យ៉ាងរង្គាលលើជនជាតិភាគតិចវៀតណាមដែលនៅសេសសល់។ របាយការណ៍ខ្លះបង្ហាញថា ខ្មែរក្រហមបានបង្ខំប្តីជនជាតិខ្មែរឱ្យសម្លាប់ប្រពន្ធខ្លួនជាជនជាតិវៀតណាមទៀតផង[51]។ សូម្បីតែជនជាតិខ្មែរដែលទទួលការបណ្តុះបណ្តាលពីទាហានវៀតណាមក៏ត្រូវសម្លាប់ចោលដែរ។ កម្មាភិបាលខ្មែរក្រហមមួយរូបបានលើកឡើងថា "ប្រសិនអ្នកជាជនជាតិភាគតិចវៀតណាម អ្នកច្បាស់ជាត្រូវសម្លាប់ចោល" នៅពេលដែលខ្មែរក្រហមដឹងថាអ្នកជាជនជាតិវៀតណាម"[52]។

## ២.៤.២ ខ្មែរក្រោម

ខ្មែរក្រោមជាជនជាតិភាគតិចកម្ពុជា ដែលបានរស់នៅតាមវាលទំនាបជុំវិញដីសណ្តទន្លេមេគង្គអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ។ ដោយការវាតទីរបស់វៀតណាម បច្ចុប្បន្ន ខ្មែរក្រោមភាគច្រើនរស់នៅផ្នែកខាងចុងនៃភាគខាងត្បូងប្រទេសវៀតណាម ប៉ុន្តែនៅតែរក្សាភាសាសាសនា និងវប្បធម៌ខ្មែរដដែល[53]។ នៅពេលខ្មែរក្រោមជាជនជាតិភាគតិចរបស់ប្រទេសកម្ពុជា ខ្មែរក្រហមបានចាត់ទុកពួកគេជា "ខ្មែរមិនសុទ្ធ" និងតែងតែសង្ស័យថាពួកគេមានភាពស្មោះត្រង់ ឬជាគិញសម្ងាត់របស់វៀតណាម[54]។ លើសពីនេះ ខ្មែរក្រហមព្រួយបារម្ភថា ពួកអាមេរិកាំងប្រើប្រាស់

47 *ibid.* ៥៨

48 Nayan C, *សត្រូវបងប្អូនប្រុស/Brother enemy* (San Diego ៖ រោងបោះពុម្ព Harcourt Brace Jovanovich ឆ្នាំ១៩៨៦) ១៦

49 Kiernan, B, *របបខ្មែរក្រហម op cit.* ២៩៦។ បទសម្ភាស កំពង់ត្រាច។

50 Kiernan, B, *របបខ្មែរក្រហម* ។ ២៩៧។ បានមកពីបទសម្ភាសរដ្ឋលេខាធិការដ្ឋានសហរដ្ឋអាមេរិក

51 Kiernan, B, *របបខ្មែរក្រហម* ។ ២៩៦។ បទសម្ភាសជាមួយ Heng Samrin

52 Hinton, AL *ហេតុអ្វីពួកគេស្លាប់?* (Berkely ៖ សារព័ត៌មានមហាវិទ្យាល័យកាលីហ្វ័រញ៉ា ឆ្នាំ២០០៥) ២១៩។ បទសម្ភាសរបស់អ្នកនិពន្ធជាមួយ Chlat

53 Ciorciari Shorenstein, JD *ការជំនុំជម្រះខ្មែរក្រោម និងខ្មែរក្រហម* (APARC, មហាវិទ្យាល័យ Stanford ឆ្នាំ២០០៨) ១

54 នរវិទូអូស្ត្រាលី Philip Taylor បានលើកឡើងក្នុង Vachon, M, "នរវិទូបង្ហាញអំពីគំហើញនៃស្ថានភាពអាក្រក់របស់ខ្មែរក្រហម" *កម្ពុជាដេលី* (ឆ្នាំ២០១៣) ថ្ងៃទី២៦ ខែសីហា

ខ្មែរក្រោម ដើម្បីផ្ដួលរំលំរបបខ្លួន[55]។ មានភស្តុតាងបង្ហាញថា ខ្មែរក្រោមមួយចំនួននៅតែមានភាពស្មោះត្រង់ជាមួយរបបលន់ នល់ ដូច្នេះហើយ ពួកគេត្រូវបានចាត់ទុកជាសត្រូវនៃបដិវត្តន៍នេះ[56]។

ក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានវាយប្រហារខេត្ត ជីអាង (Giang) ក្នុងប្រទេសវៀតណាម ដោយបានសម្លាប់ប្រជាជនវៀតណាមជាច្រើនពាន់នាក់ និងនាំយកខ្មែរក្រោមចំនួនប្រហែលជា ២០.០០០នាក់ដែលរស់នៅក្នុងប្រទេសវៀតណាមត្រឡប់មកប្រទេសកម្ពុជាវិញ[57]។ គោលបំណងនៃការចាប់ពង្រត់ខ្មែរក្រោមក្នុងទ្រង់ទ្រាយធំបែបនេះ គឺដើម្បីកាត់បន្ថយចំនួនប្រជាជនខ្មែរក្រោមដែលរស់នៅក្នុងតំបន់នេះ និងដើម្បីយកមកធ្វើជាកម្លាំងពលកម្មក្នុងជំរុំធ្វើការដោយបង្ខំក្នុងប្រទេសកម្ពុជា។

ស្ថានភាពកាន់តែអាក្រក់ឡើងចាប់ពីខែកក្កដា ឆ្នាំ១៩៧៨ នៅពេលដែលសង្គ្រាមកម្ពុជា-វៀតណាមបានកើតឡើង។ ខ្មែរក្រហមបានចាប់ផ្ដើមប្រមាញ់ភ្នាក់ងារ និងគិញសម្ងាត់វៀតណាម។ ឯកសារស្ដីពីពន្ធនាគារបានមកពីសម័យនោះបង្ហាញថា ខ្មែរក្រោមតែងតែត្រូវបានគេសង្ស័យ[58]។ ការសង្ស័យនេះកាន់តែខ្លាំងឡើង បន្ទាប់ពីអ្នកទោសខ្មែរក្រោមមួយចំនួនដែលត្រូវបានធ្វើទារុណកម្មនៅមន្ទីរឃុំឃាំងទួលស្លែង ឬមន្ទីរស២១ បានសារភាព (ការពិត ឬ មិនពិត) ថាខ្លួនជាគិញសម្ងាត់របស់ វៀតណាម។ ក្រោយមកទួលស្លែងត្រូវបានចាត់ទុកជាកន្លែងសម្រាប់ឃុំឃាំងខ្មែរក្រោមដោយត្រូវ គ្រប់គ្រងតាមបទប្បញ្ញត្តិទាំង ១០នៃមន្ទីរនេះ។ ខ្មែរក្រោមដែលត្រូវបានចាប់បញ្ជូនទៅមន្ទីរឃុំ ឃាំងនេះតែងតែត្រូវសម្លាប់ចោល។[59]



55 Ciorciari Shorenstein, JD, *op cit.* 2

56 Ciorciari Shorenstein, JD, *ibid.* 6

57 Taylor, P, ដូចបានលើកឡើងក្នុង Vachon, M, *op. cit.*

58 ឯកសារលម្អិតបានមកពី Kraing Ta Chan ជាសន្តិសុខពន្ធនាគារក្នុងខេត្តតាកែវ អាចរកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

59 Di Certo, B, "ជនជាតិភាគតិចខ្មែរក្រោមចូលរួមក្នុងតុលាការ" *ភ្នំពេញប៉ុស្តិ៍* (ឆ្នាំ២០១២) ថ្ងៃទី២២ ខែវិច្ឆិកា

## សារតា

ខ្មែរក្រោមក្នុងសហគមន៍ដែលត្រូវបានសង្ស័យជាគិញសម្ងាត់ ត្រូវបានគេចាប់ផ្តើមកំណត់មុខសញ្ញាសម្រាប់សម្លាប់ចោល។ គីម កែវកន្និដ្ឋា ផ្តល់ភស្តុតាងអំពី "កិច្ចប្រជុំស្តីពីការអប់រំនយោបាយ" ក្នុងចុងឆ្នាំ១៩៧៧ឬដើមឆ្នាំ១៩៧៨ ក្នុងអំឡុងពេលដែលប៉ុល ពត និយាយទៅកាន់ក្រុមខ្មែរក្រោមនៅ ស្តាតអូឡាំពិកក្នុងរាជធានីភ្នំពេញថា គាត់នឹង "ទុក" តែអ្នកដែលយល់ព្រមដើរតាមអង្គការប៉ុណ្ណោះ[60]។ ពេលខ្លះ ខ្មែរក្រោមត្រូវបានសម្លាប់ដោយគ្រាន់តែអាចនិយាយភាសាវៀតណាមបានប៉ុណ្ណោះ[61]។ ការសិក្សាស្រាវជ្រាវរបស់ James Roberts បានរកឃើញថា ក្នុងស្រុកគីរវង្ស មន្ត្រីមូលដ្ឋានបានអួតអំពីការសម្លាប់ខ្មែរក្រោមចំនួនច្រើនជាងពីរពាន់នាក់ ការអាចកំណត់ភិនភាគខ្មែរក្រោមតាមរយៈការមានសក់រួញ និងទម្លាប់ផឹកទឹកដោះគោ (ជាភេសជ្ជៈរបស់ពួកលោកខាងលិច និងពួកចក្រពត្តិ)[62] ។ "ពួកគេបាននិយាយថា ពួកគេត្រូវតែសម្លាប់អ្នកដែលមានខ្លួនខ្មែរតែក្បាលវៀតណាម" និងបានលើកឡើងបន្ថែមទៀតថា មានអ្នកអង្កេតម្នាក់លើការសម្លាប់បែបនេះ[63]។ ក្នុងចំណោមប្តីប្រពន្ធមានជាតិសាសន៍ខុសគ្នា ប្តីប្រពន្ធខ្មែរក្រោមត្រូវបានយកទៅសម្លាប់ចោល ដូចគ្នានឹងកុមារដែលជ្រើសរើសទៅរស់នៅជាមួយឪពុកម្តាយខ្លួនដែលជាជនជាតិខ្មែរក្រោម[64]។ តាមការប៉ាន់ស្មាន ខ្មែរក្រោមប្រហែលជា១២៥.០០០នាក់ត្រូវបានសម្លាប់ និងកប់ក្នុងរណ្តៅកប់ខ្មោចរួមក្នុងអំឡុងរបបខ្មែរក្រហម[65]។

## ២.៤.៣ សហគមន៍មូស្លីម - ចាម ជ្វា

សហគមន៍មូស្លីមក្នុងប្រទេសកម្ពុជា ខុសគ្នាពីប្រជាជនខ្មែរទូទៅទាំងជាតិសាសន៍ និងសាសនា។ ប្រជាជនខ្មែរភាគច្រើនគោរពប្រតិបត្តិតាមព្រះពុទ្ធសាសនា ចំណែកសហគមន៍មូស្លីមគោរពប្រតិបត្តិតាមសាសនាឥស្លាម និងមានដើមកំណើតមកពីក្រុមធំៗពីរ។

---

60 Keokanitha, K, "ឃុំរំលេច ៖ ខ្មែរក្រោមក្នុងរបបខ្មែរក្រហម" មិនបានបោះ ពុម្ពផ្សាយអត្ថបទដែលបានចងក្រងជាឯកសារទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ១០-១១

61 សូមមើល Carney, T, "អំណាចអង្គការ" ក្នុង in KD Jackson, ed., *ប្រទេសកម្ពុជា ១៩៧៥-១៩៧៨ ៖ ការជួបប្រទះសេចក្តីស្លាប់* (Princeton, NJ ៖ សារព័ត៌មានមហាវិទ្យាល័យ Princeton ឆ្នាំ១៩៨២) ៨៣ កំណត់សម្គាល់ ៣

62 Roberts, JC, "លទ្ធភាពរបស់ខ្មែរក្រោមក្នុងការធ្វើការចោទប្រកាន់លើអំពើប្រល័យពូជសាសន៍" *ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការស្រាវជ្រាវការពិត* (ឆ្នាំ២០១០) ខែកញ្ញា

63 O'Toole, J &Titthara, M, "ការធានាដល់ខ្មែរក្រហម" *ភ្នំពេញប៉ុស្ត៍* (ឆ្នាំ២០១០) ថ្ងៃទី១៨ ខែមិថុនា

64 Di Certo, B, *op. cit.*

65 Mak, K, *អំពើប្រល័យពូជសាសន៍ និងលទ្ធិទាមទារទឹកដីអាណានិគមមកវិញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)* ឯកសារការងារលេខ២៣ (មជ្ឈមណ្ឌល Yale សម្រាប់ការសិក្សាជាអន្តរជាតិ និងតាមតំបន់ កម្មវិធីសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍ ឆ្នាំ២០០៤) ២១

ជនជាតិជ្វាបានមកកាន់ប្រទេសកម្ពុជាលើកដំបូងក្នុងសតវត្សរ៍ទី១៤ ដែលមានប្រភពពីឧបទ្វីបម៉ាឡេ និងឥណ្ឌូនេស៊ី និងមានទឹកដីកំណើតនៅប៉ែកខាងត្បូងប្រទេសកម្ពុជា[66]។ ក្នុងសតវត្សរ៍ទី១៥ ជនជាតិចាមបានធ្វើចំណាកស្រុកមកពីប្រទេសចម្ប៉ា ដែលជាអាណាចក្រមួយមានដើមកំណើតស្ថិតនៅភាគខាងត្បូងប្រទេសវៀតណាម[67]។ ក្នុងពេលដែលអ្នកប្រាជ្ញមួយចំនួនបានលើកឡើងថា ការរៀបការជាមួយជាតិសាសន៍ខុសគ្នារវាងក្រុមជាតិសាសន៍ទាំងពីរបានបង្កើតជាសហគមន៍មូស្លីមមួយ[68] អ្នកប្រាជ្ញដទៃទៀតបានចាត់ទុកក្រុមជាតិសាសន៍ទាំងពីរជាជាតិសាសនខុសគ្នា។ អំឡុងពេលមានឯករាជ្យក្នុងឆ្នាំ១៩៥៣ សម្ដេចសីហនុបានព្យាយាមបង្រួបបង្រួមក្រុមជនជាតិភាគតិចទាំងអស់ជាប្រជាជនកម្ពុជា ដោយបន្ថែមពាក្យ "ខ្មែរ" ពីលើឈ្មោះជាតិសាសន៍របស់ពួកគេ។[69] សម្រាប់ជនជាតិមូស្លីម សម្ដេចសីហនុបានឱ្យឈ្មោះថា "ខ្មែរឥស្លាម" ដើម្បីបញ្ចូលជនជាតិចាម និងជ្វាក្នុងក្រុមជាមួយគ្នាក្រោមអត្តសញ្ញាណខ្មែរតែមួយ។ ការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញថា ពាក្យ "ខ្មែរឥស្លាម" ភាគច្រើនត្រូវបានជនជាតិជ្វាទទួលយកច្រើនជាងជនជាតិចាម[70]។ ក្រៅពីភាព ស្មុគស្មាញក្នុងកាដាក់ឈ្មោះឱ្យជាតិសាសន៍ទាំងនេះ ការសិក្សាមួយចំនួនប្រើពាក្យ "ចាម"





66 De Féo, A, "ចលនាឥស្លាមអន្តរកាលក្នុងប្រទេសកម្ពុជា"ក្នុង*ភាពសកម្មនៃការបង្កើតសាសនាឥស្លាមអន្តរកាល និងសេដ្ឋកិច្ចក្នុងអាស៊ីចាប់ពីពួកស្បែកសដល់ប្រទេសចិន* សន្និសីទអន្តរជាតិរៀបចំដោយមជ្ឈមណ្ឌលវិទ្យាសាស្ត្រមនុស្ស (CSH) និង មជ្ឈមណ្ឌលអន្តរជាតិឥណ្ឌា (IIC), (New Delhi, ឆ្នាំ២០០៧,២), ថ្ងៃទី១៦-១៧ ខែមេសា

67 *ibid*

68 Mus, P, ‛Cultesindiens et indigenes au Champa′,*Bulletin de l′ EcoleFrancaise d′ Extreme-Orient (BEFEO) XXXIII* (ឆ្នាំ១៩៩៣), ៣៦៧-៤១០។ បោះពុម្ពផ្សាយជាភាសាអង់គ្លេសដោយ I.W. Mabbett ក្រោមចំណងជើងថា India Seen from the East ៖ *វប្បធម៌ឥណ្ឌា និងវប្បធម៌ជនជាតិដើមភាគតិច* ក្នុងប្រទេសចម្ប៉ា IWMabbett&DP Chandler, eds. ឯកសារ Monash ស្ដីពីអាស៊ីអាគ្នេយ៍លេខ០៣ (Melbourne ឆ្នាំ១៩៧៥) ៥៣

69 អ្នកសិក្សាស្រាវជ្រាវ និងអ្នកផ្ដល់មតិមួយចំនួនចាត់ទុកការដាក់ឈ្មោះនេះជាយុទ្ធសាស្ត្របង្រួបបង្រួម។

70 De Féo, op. cit., ៣

តែមួយគត់សំដៅលើទាំងជនជាតិចាម និងជ្វា[71]។ នៅពេលក្រុមជាតិសាសន៍ទាំងពីរនេះត្រូវបានបែងចែកខុសគ្នាក្នុងអក្សរសាស្ត្រ និង ក្នុងជាតិសាសន៍ផ្ទាល់ ពួកគេបានជ្រើសរើសប្រើប្រាស់ពាក្យដែលពួកគេធ្លាប់ប្រើប្រាស់។

ពួកខ្មែរក្រហមមិនគោរពសាសនាឡើយ។ សហគមន៍មូស្លីមត្រូវបានកំណត់ជាគោលដៅពិសេស ដោយសារតែភាពខុសគ្នានៃភាសា អាហារ សម្លៀកបំពាក់ និងការបន់ស្រន់។ ក្នុងចំណោមមេដឹកនាំសាសនាមូស្លីម១១៣នាក់មានក្នុងភូមិមុនរបបខ្មែរក្រហម មានមេដឹកនាំសាសនាមូស្លីមតែ២១នាក់ប៉ុណ្ណោះនៅរស់រានមានជីវិត ហើយវិហារចាមចំនួន៨៥% ត្រូវបានបំផ្លាញ។ ជនជាតិមូស្លីមមិនត្រូវបានអនុញ្ញាតឱ្យធ្វើការបន់ស្រន់ឡើយ។ ពួកគេត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ដែលជាសាច់ពួកគេតមមិនបរិភោគ ហារាម (ḥarām)[72] ក្នុងសាសនានេះ និងអ្នកខ្លះទៀតត្រូវបានបង្ខំធ្វើការជាមួយជ្រូក[73]។ ខ្មែរក្រហមបានបំផ្លាញ ឬ ប្រមាថគម្ពីរសាសនាឥស្លាម ដូចជា ការបោះគម្ពីរនេះចោល ឬ យកគម្ពីរនេះប្រើប្រាស់ក្នុងបន្ទប់ទឹក[74]។ ស្ត្រីមូស្លីមត្រូវបានបង្ខំឱ្យកាត់សក់ខ្លីតាមរបៀបខ្មែរ និងហាមមិនឱ្យពាក់ក្រណាត់ជួតក្បាល និងសំពត់ពណ៌[75]តាមប្រពៃណីមូស្លីម។ ដើម្បីធ្វើឱ្យប្រជាជនកម្ពុជាមានលក្ខណៈតែមួយ ខ្មែរក្រហមបានបំបែកពួកមូស្លីមឱ្យរស់នៅជាមួយសហគមន៍ខ្មែរ។ ឧទាហរណ៍ ឯកសារចុះខែកុម្ភៈ ឆ្នាំ១៩៧៤ ពាក់ព័ន្ធនឹងការសម្រេចចិត្តលើបណ្តាញសហករណ៍របស់បក្សក្នុងតំបន់៣១ លើកឡើងថា "...វាមានភាពចាំបាច់ក្នុងការបំបែកក្រុមនេះ (ខ្មែរឥស្លាម) ចេញពីគ្នាក្នុងទំហំណាមួយ។ ក្រុមនេះមិន គួរត្រូវបានអនុញ្ញាតឱ្យរស់នៅផ្តុំគ្នាច្រើនក្នុងកន្លែងតែមួយឡើយ"[76]។

ជាញឹកញាប់ អ្នកដែលបដិសេធមិនអនុវត្តតាមការណែនាំរបស់របបខ្មែរក្រហមនឹងត្រូវសម្លាប់ចោល។ Lee Seyla ដែលជាជនជាតិភាគតិចចាមនៅរស់រានមានជីវិត បានឃើញខ្មែរក្រហមវាយ

---

71 ឧទាហរណ៍ វិទ្យាស្ថានអាមេរិកសម្រាប់ការសិក្សាស្រាវជ្រាវ ការអប់រំពិភពលោក សកម្មភាពកម្ពុជាសម្រាប់ការអប់រំកម្រិតបឋមសិក្សា (KAPE) ការយកចិត្តទុកដាក់ជាអន្តរជាតិ ឆ្នាំ២០០៨ (Care International 2008) *ការវាយតម្លៃលើការរើសអើងសហគមន៍ជនជាតិចាមមូស្លីមក្នុងប្រទេសកម្ពុជា* ESCUP, Washington

72 Kiernan, B, *របបខ្មែរក្រហម ៖ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម* ឆ្នាំ១៩៧៥-៧៩ (New Haven ៖ មហាវិទ្យាល័យ Yale ឆ្នាំ១៩៩៦) ៥

73 ១៩៨៣ ជនជាតិភាគតិចចាម – សាសនាជ្វា មជ្ឈមណ្ឌលឯកសារកម្ពុជា

74 So, F, *ស្បៃគ្របមុខរបស់ស្ត្រីឥស្លាមក្នុងប្រទេសកម្ពុជា ៖ ការចងចាំរបស់ស្ត្រីចាមមូស្លីមបន្ទាប់ពីរបបខ្មែរក្រហម*កម្រងឯកសារលេខ១៦ (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០១១) ៥៥

75 Kiernan B, "កុមារកំព្រាពីអំពើប្រល័យពូជសាសន៍ ៖ ជនជាតិចាមមូស្លីមកម្ពុជាក្នុងរបបប៉ុលពត" *ព្រឹត្តិបត្ររបស់អ្នកប្រាជ្ញអាស៊ីដែលពាក់ព័ន្ធ* (១៩៨៨) លេខចេញផ្សាយ២០ លេខ៤ ថ្ងៃទី១២ ខែតុលា–ធ្នូ

76 Kiernan, B, (ឆ្នាំ១៩៨៨), *op. cit.* ៩

ប្រជាជនចាម១០នាក់រហូតដល់ស្លាប់ ដោយសារតែការបដិសេធមិនបរិភោគសាច់ជ្រូក[77]។ ទោះបីជាមានគ្រោះថ្នាក់ក៏ដោយ ក៏មានភស្តុតាងបង្ហាញថា ជនជាតិចាមជាច្រើនបានបះបោរប្រឆាំងនឹងគោលនយោបាយនៃរបបនេះ ដែលជាញឹកញាប់បណ្តាលឱ្យមានការសម្លាប់យ៉ាងរង្គាល[78]។ នៅពេលដែលមានការសម្លាប់ប្រជាជនទូទៅយ៉ាងរង្គាលនៅទូទាំងប្រទេស សហគមន៍មូស្លីមត្រូវបានកំណត់ជាគោលដៅពិសេសសម្រាប់ការសម្លាប់។ Alexander Hinton ដែលជានរវិទូ បានលើកឡើងថា មន្ត្រីខ្មែរក្រហមមួយចំនួនចង់សម្លាប់ពួកមូស្លីមជាជាង "ប្រជាជនខ្មែរថ្មី"[79]។ ចំពោះថាតើហេតុអ្វី នៅក្នុងភូមិតាខុង គ្រួសារខ្មែរតែពីរគ្រួសារប៉ុណ្ណោះដែលត្រូវបានសម្លាប់ប៉ុន្តែគ្រួសារចាមរហូតដល់៥០គ្រួសារត្រូវបានសម្លាប់ មន្ត្រីខ្មែរក្រហមម្នាក់បាននិយាយថា "ខ្ញុំមានការលំបាកណាស់ដោយសារតែខ្ញុំទទួលបញ្ជាឱ្យសម្លាប់ខ្មែរ ប៉ុន្តែខ្ញុំមិនដាច់ចិត្ត និងធ្វើបែបនេះបានឡើយ។ ដូច្នេះយើងបានសម្លាប់ជនជាតិចាមជំនួសវិញ ទោះបីជនជាតិចាមមិនមានច្រើននាក់ក៏ដោយ"[80]។ ជនជាតិចាមទទួលរងការធ្វើទុក្ខបុកម្នេញជាប្រចាំ និងកាន់តែច្រើនឡើងក្នុងអំឡុងឆ្នាំ១៩៧៧ និង១៩៧៨។

តាមការប៉ាន់ស្មាន ចំនួនជនជាតិមូស្លីមដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហមមានចំនួនច្រើនគួរកត់សម្គាល់ចាប់ពី១០០.០០០នាក់[81] ដល់ ៧០០.០០០នាក់[82]។ ចំនួនប៉ាន់ស្មាននេះគឺការប៉ាន់ស្មានដំបូង ដោយសារតែលើចំនួនជនជាតិមូស្លីមរស់នៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥ មានចំនួនខុសគ្នាទៅតាមការប៉ាន់ស្មានខុសៗគ្នា។

## ២.៤.៤ អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច

ដោយសារការមិនចូលចិត្តជនបរទេស អំពើហិង្សាផ្លូវភេទទំនងជាវិធីសាស្ត្រមួយផ្សេងទៀតរបស់ខ្មែរក្រហមសម្រាប់ធ្វើទុកបុកម្នេញលើជនជាតិភាគតិច។

77 Lee Seyla។ បទសម្ភាសដោយ Nate Thayer។ ខែសីហា (ឆ្នាំ១៩៨៩) លេខ៧។

78 Kiernan B, ឆ្នាំ១៩៨៨, *op. cit.*

79 ប្រជាជនថ្មីគឺជាប្រជាជនរស់នៅជាមួយអ្នកដើរតាមលន់នល់ក្នុងតំបន់ក្រៅការគ្រប់គ្រងរបស់ខ្មែរក្រហមក្នុងអំឡុងសង្គ្រាមស៊ីវិល និងជាប្រជាជនដែលថ្មីថ្មោងជាមួយនឹងបដិវត្តន៍ បន្ទាប់មកត្រូវបានរួមបញ្ចូលទាំងអ្នកដែលមកពីទីក្រុង បញ្ញវន្ត ឬ អ្នកដែលមានជាតិសាសន៍ខុសពីខ្មែរ។

80 Hinton, AL,*op. cit.,* ១៦

81 ឧទាហរណ៍ Ben Kiernan ផ្តល់តួលេខចំនួន៩០.០០០ ក្នុង Kiernan (ឆ្នាំ១៩៨៨), op. cit., ៣០

82 So, F, *ប្រវត្តិផ្ទាល់មាត់របស់ស្ត្រីជនជាតិចាមមូស្លីមក្នុងរបបខ្មែរក្រហម* និក្ខេបបទថ្នាក់អនុបណ្ឌិតបានបង្ហាញដល់មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិនៃមហាវិទ្យាល័យ Ohio (ឆ្នាំ២០១១)។ សូមមើលចំនួនអ្នកស្លាប់ប៉ាន់ស្មាន ៥០០.០០០នាក់ ក្នុង Ysa O, Oukoubah ៖ *យុត្តិធម៌សម្រាប់ជនជាតិចាមមូស្លីមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០២)។

## សារតា

ក្នុងការសិក្សាស្រាវជ្រាវរបស់ Farina So ជាមួយស្ត្រីជនជាតិចាមមូស្លីម[83] អ្នកផ្តល់បទសម្ភាសបានរៀបរាប់អំពីការបង្ខំពួកគេឱ្យរៀបការជាមួយបុរសខ្មែរ ដើម្បីលុបបំបាត់ប្រពៃណី និងបំបែកក្រុមជនជាតិភាគតិច។ អ្នកផ្តល់បទសម្ភាសបានរៀបរាប់ថា ការរំលោភបំពានផ្លូវភេទ និងការរំលោភសេពសន្ថវៈលើស្ត្រីជនជាតិចាមគឺជារឿងកើតឡើងជាទូទៅនៅកន្លែងធ្វើការ និងក្នុងសហករណ៍។ លើសពីនេះ ជនរងគ្រោះជនជាតិចាមត្រូវបានជនល្មើសគំរាមកំហែងមិនឱ្យនិយាយ ដោយគំរាមសម្លាប់ចោល ឬ រំលោភមុននឹងសម្លាប់។

អ្នកចូលរួមផ្តល់បទសម្ភាសក្នុងការសិក្សាស្រាវជ្រាវរបស់ Natale បានលើកឡើងថា ជនជាតិភាគតិចត្រូវបានកំណត់ជាគោលដៅសម្រាប់ការរំលោភបំពានផ្លូវភេទ រួមទាំង ជនជាតិចាម ចិន និងវៀតណាម (ជាពិសេស ជនជាតិវៀតណាមដែលមានស្បែកស)[84]។ ក្នុងការសិក្សានេះ ការរំលោភបំពានផ្លូវភេទមានដូចជាការរំលោភទ្រង់ទ្រាយធំការរំលោភសេពសន្ថវៈនិងការបង្ខំឱ្យអាក្រាតកាយ។ អ្នកផ្តល់បទសម្ភាសមួយចំនួនបានរៀបរាប់អំពីករណីនៃការរំលោភទ្រង់ទ្រាយធំបន្ទាប់មកសម្លាប់ចោល ដែលប្រព្រឹត្តលើជនជាតិភាគតិចវៀតណាម[85]។ អ្នកផ្តល់បទសម្ភាសទាំងអស់ដែលរៀបរាប់អំពីអំពើហិង្សាលើក្រុមជនជាតិភាគតិចបានអះអាងថា អត្តសញ្ញាណជាតិសាសន៍របស់ជនរងគ្រោះគឺជាកត្តាជំរុញឱ្យមានអំពើហិង្សានេះ[86]។

ការសិក្សាស្រាវជ្រាវផ្សេងទៀត បានចងក្រងករណីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច។ ឧទាហរណ៍ ការសិក្សាស្រាវជ្រាវរបស់ Savorn Duong ជាមួយជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទចំនួន១៨នាក់ បានកត់ត្រាករណីមួយនៃការរំលោភសេពសន្ថវៈ និងការរំលោភដោយចេតនាលើស្ត្រីខ្មែរឥស្លាម។[87] Nakagawa បានចងក្រងឯកសារស្តីពីករណីរបស់ស្ត្រីមេម៉ាយជនជាតិចាមដែលកម្មាភិបាលខ្មែរក្រហមបង្ខំឱ្យអាក្រាតកាយ[88]។ ករណីបែបនេះក៏មានក្នុងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់ជូនទៅកាន់ អ.វ.ត.ក ផងដែរ។

ការសិក្សាស្រាវជ្រាវលើអ្នកនៅរស់រានមានជីវិត និងសមាជិកខ្មែរក្រហម ក៏ដូចជា ឯកសារនៃរបបនេះបានលើកឡើងអំពីការរីករាលដាលនៃការរើសអើង និងការធ្វើទុកបុកម្នេញលើជនជាតិភាគ

---

83 So, F, *ស្បែកគ្របមុខរបស់ស្ត្រីឥស្លាមក្នុងប្រទេសកម្ពុជា ៖ ការចងចាំរបស់ស្ត្រីចាមមូស្លីមបន្ទាប់ពីរបបខ្មែរក្រហម*, op. cit. កត់សម្គាល់ថា So កំណត់និយមន័យពាក្យ "ចាម" ដោយរួមបញ្ចូលទាំងជនជាតិជ្វាផងដែរ។

84 Natale, *op. cit.*, 42

85 *Ibid.* 29

86 *Ibid.* 45

87 Duong, S, *op. cit.*,30-31, 52-53

88 Nakagawa, K, *op. cit.*, 26-27

តិច និងសាសនា រួមទាំង ការរីករាលដាលនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ។ ទោះបីយ៉ាងណា ព័ត៌មានអំពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រមិនមានគ្រប់គ្រាន់ឡើយ។ នៅតែមានភាព ងឿងឆ្ងល់ពាក់ព័ន្ធថាតើការប្រព្រឹត្តអំពើទាំងនេះមានការរីករាលដាលយ៉ាងដូចម្តេច? និងថាតើក្រុមជនជាតិភាគតិចពិតជាត្រូវបានរបបនេះកំណត់ជាគោលដៅសម្រាប់ប្រព្រឹត្តអំពើទាំងនេះដែរឬទេ? គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីលាតត្រដាងអំពីបញ្ហាទាំងនេះ ដោយផ្តោតលើរឿងរ៉ាវដែលជនជាតិភាគតិចនៅរស់រានមានជីវិត វៀតណាម ខ្មែរក្រោម និងមូស្លីមបានជួបប្រទះ។ ជំពូកខាងក្រោមលើកឡើងលម្អិតអំពីការអនុវត្តការសិក្សាស្រាវជ្រាវនេះ ការប្រមូលទិន្នន័យ និងដំណើរការវិភាគ និងដែនកម្រិតនៃការសិក្សាស្រាវជ្រាវ។

# ៣. ការរៀបចំការសិក្សាស្រាវជ្រាវ



## ៣.១ ទំហំ និងគោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវកន្លងមកដែលស៊ើបអង្កេតលើបទពិសោធន៍របស់បុរសស្ត្រី ដែលទទួលរងអំពើហិង្សាយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានផ្តល់នូវព័ត៌មានជាច្រើនដល់ការរៀបចំការសិក្សាស្រាវជ្រាវនេះ។ ការសិក្សាស្រាវជ្រាវកន្លងមកបានជួយកំណត់សំណួរនៃការសិក្សាស្រាវជ្រាវ ក្រុមគោលដៅ ការប្រមូលទិន្នន័យ និងវិធីសាស្ត្រវិភាគ។

លទ្ធផលរកឃើញនៃការសិក្សាស្រាវជ្រាវកន្លងមកទាំងនេះបានបង្ហាញថា អំពើហិង្សាផ្លូវភេទគឺជាទម្រង់នៃអំពើហិង្សាយេនឌ័រកើតមានជាទូទៅបំផុតក្នុងរបបខ្មែរក្រហម ដែលបង្កើតបានជាចំណុចផ្តោតចិត្តទុកដាក់សម្រាប់ការសិក្សាស្រាវជ្រាវនេះ។ ជនជាតិភាគតិចវៀតណាម ខ្មែរក្រោម ខ្មែរឥស្លាម និងចាមទទួលរងអំពើហិង្សាផ្លូវភេទ ដែលត្រូវបានកំណត់ក្នុងការសិក្សាស្រាវជ្រាវមុនៗ ត្រូវបានជ្រើសរើសជាក្រុមគោលដៅក្នុងការសិក្សាស្រាវជ្រាវនេះ។

ថ្នាក់ដឹកនាំតាមមូលដ្ឋាន ដើរតួនាទីជាអន្តរការីក្នុងការកំណត់អ្នកដែលអាចក្លាយជាអ្នកផ្តល់បទសម្ភាសក្នុងការសិក្សាស្រាវជ្រាវនេះ។ លេខទំនាក់ទំនង និងការប្រាស្រ័យទាក់ទងរបស់អ្នកផ្តល់បទសម្ភាសទាំងនេះក្នុងសហគមន៍ គឺជាមធ្យោបាយក្នុងការកំណត់ទីតាំងរបស់អ្នកផ្តល់បទសម្ភាស និងការបង្រួមទីតាំងនៃការសិក្សាស្រាវជ្រាវមកត្រឹមតែប្រាំមួយខេត្តក្នុងចំណោម២៤ខេត្តក្រុងក្នុងប្រទេសកម្ពុជា ៖ បាត់ដំបង កំពត កំពង់ឆ្នាំង ភ្នំពេញ ពោធិ៍សាត់ និងតាកែវ។

### ៣.១.១ គោលដៅ និងសំណួរនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងប្រមូលព័ត៌មានអំពីទំហំ និងលក្ខណៈនៃអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងផលប៉ះពាល់ ដើម្បីយល់ដឹងឱ្យបានកាន់តែប្រសើរអំពីតម្រូវការរបស់អ្នកនៅរស់រានមានជីវិត ដើម្បីគាំទ្រពួកគេ (និងសហគមន៍) ឱ្យមានភាពប្រសើរឡើងវិញ។ តាមការរំពឹងទុក



*ការអនុវត្តការសម្ភាសន៍*

ការចងក្រងរឿងរ៉ាវអ្នកនៅរស់រានមានជីវិតក្នុងកំណត់ត្រាប្រវត្តិសាស្ត្រ អាចជំរុញឱ្យមានកិច្ចប្រឹងប្រែងក្នុងការតស៊ូមតិសម្រាប់យន្តការផ្តល់យុត្តិធម៌អន្តរកាល និងការគាំទ្រ។

ការរៀបចំការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលបំណងឆ្លើយតបនឹងសំណួរនៃការសិក្សាស្រាវជ្រាវដូចខាងក្រោម ៖

១. តើជនជាតិភាគតិចទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរដែរឬទេ?
២. តើនរណាជាជនរងគ្រោះ និងជាជនល្មើស?
៣. តើព័ត៌មានលម្អិត និងលក្ខណៈនៃអំពើហិង្សានេះយ៉ាងដូចម្តេចដែរ?
៤. តើជនជាតិភាគតិចទទួលរងអំពើហិង្សាផ្លូវភេទខុសគ្នាពីក្រុមដទៃទៀតក្នុងប្រទេសកម្ពុជាដែរឬទេ?

## ៣.២ វិធីសាស្ត្រ

### ៣.២.១ សំណាកគំរូ

ការសិក្សាស្រាវជ្រាវនេះ បានប្រឹងប្រែងធ្វើបទសម្ភាសបុរសស្ត្រីចំនួនប្រហែលជា១០០នាក់ដែលបានឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ។ ការសិក្សាស្រាវជ្រាវបានជ្រើសរើសអ្នកផ្តល់បទសម្ភាសដែលដឹងព័ត៌មានមួយចំនួនអំពីអំពើហិង្សាផ្លូវភេទក្នុងរបបនេះ ដូចជា ជនរងគ្រោះផ្ទាល់ សាក្សី ឬ អ្នកដែលបានដឹងអំពីអំពើហិង្សាបែបនេះពីនរណាម្នាក់។ ក្នុងពេលដែលការសិក្សាស្រាវជ្រាវផ្តោតលើប្រជាជនគោលដៅ ដូចជា ខ្មែរក្រោម ខ្មែរឥស្លាម ឬ ចាម និងជនជាតិភាគតិច អ្នកសិក្សាស្រាវជ្រាវក៏ចាប់អារម្មណ៍លើការសម្ភាសជាមួយជនជាតិភាគតិចដទៃទៀត ដែលបានឃើញ ឬ ដឹងអំពីអំពើហិង្សាផ្លូវភេទលើក្រុមជាក់លាក់ទាំងនេះ។

ដូចបានលើកឡើងខាងលើ អ្នកផ្តល់បទសម្ភាសត្រូវបានជ្រើសរើសតាមរយៈថ្នាក់ដឹកនាំមូលដ្ឋានក្នុងសហគមន៍។ វិធីសាស្ត្រនេះជ្រើសរើសបានអ្នកផ្តល់បទសម្ភាសយ៉ាងច្រើន។ ការសិក្សាស្រាវជ្រាវនេះក៏បានប្រើប្រាស់វិធីសាស្ត្រជ្រើសរើសដោយការបោះកូនបាល់ផងដែរ។ នៅចុងបញ្ចប់នៃបទសម្ភាស អ្នកផ្តល់បទសម្ភាសនីមួយៗត្រូវបានសួរថា តើពួកគេស្គាល់នរណាផ្សេងទៀត ដែលដឹងអំពីអំពើហិង្សាផ្លូវភេទដោយការបង្ខិតបង្ខំលើក្រុមណាមួយនៃក្រុមជនជាតិភាគតិចទាំងបួននេះដែរឬទេ? ប្រសិនជាអាច ក្រុមការងារសិក្សាស្រាវជ្រាវនឹងបញ្ជូនមនុស្សឱ្យធ្វើការពិនិត្យតាមដាន។

វិធីសាស្ត្រជ្រើសរើសទាំងពីរនេះត្រូវបានយកមកប្រើប្រាស់ប្រកបដោយការយកចិត្តទុកដាក់ ឬអាចនិយាយបានថា គោលបំណងនៃការជ្រើសរើស គឺជ្រើសរើសជនជាតិភាគតិចនៅរស់រានមាន

## ការរៀបចំការសិក្សាស្រាវជ្រាវ

ជីវិតពីរបបខ្មែរក្រហមដែលដឹងព័ត៌មានមួយចំនួនអំពីអំពើហិង្សាផ្លូវភេទឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ពីព្រោះវិធីសាស្រ្តទាំងពីរមិនមែនជាវិធីសាស្រ្តជ្រើសរើសតាមភាពចៃដន្យ ឬ តំណាងឡើយ។ ព័ត៌មានដែលប្រមូលបានមិនអាចប្រើជាមូលដ្ឋានសម្រាប់កំណត់ចំនួនប្រជាជនកម្ពុជាទាំងអស់ឡើយ។ គុណតម្លៃនៃវិធីសាស្រ្តជ្រើសរើសទាំងនេះគឺការប្រមូលព័ត៌មានជាក់លាក់អំពីជនជាតិភាគតិច ដែលក្នុងការសិក្សាស្រាវជ្រាវនេះមានចំនួនអ្នកផ្តល់បទសម្ភាសជាជនជាតិភាគតិចតិចតួចរហូតមកដល់ពេលនេះ។

សំណាកគំរូចុងក្រោយនៃការសិក្សាស្រាវជ្រាវនេះ មានអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមជាបុរសស្រ្តីចំនួន១០៥នាក់ដែលរកបាននៅទូទាំងខេត្តទាំងប្រាំមួយក្នុងប្រទេសកម្ពុជា។

### ៣.២.២ ការប្រមូលទិន្នន័យ

ទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវនេះ ត្រូវបានប្រមូលតាមរយៈបទសម្ភាសផ្ទាល់ជាមួយ អ្នកផ្តល់បទសម្ភាស ដែលមានរយៈពេលជាមធ្យមមួយម៉ោង។ បទសម្ភាសទាំងនេះធ្វើឡើងដោយមានការរក្សាការសម្ងាត់ ឬ នៅជិតផ្ទះរបស់អ្នកផ្តល់បទសម្ភាស ព្រមទាំងមានការថតជាសំឡេងផងដែរ បន្ទាប់ពីមានការអនុញ្ញាតពីអ្នកផ្តល់បទសម្ភាស។



*ការបណ្តុះបណ្តាលអ្នកសម្ភាស*

អ្នកផ្តល់បទសម្ភាស ត្រូវបានសួរអំពីបទពិសោធន៍របស់ពួកគេក្នុងរបបខ្មែរក្រហម ក៏ដូចជាព័ត៌មាន និងការទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបនេះ។ សំណួរត្រូវបានបែងចែកទៅតាមប្រភេទ៖ សំណួរអំពីប្រជាសាស្រ្ត ជីវិតក្នុងរបបខ្មែរក្រហម ការរៀបការដោយបង្ខំ ការរំលោភសេពសន្ថវៈ ការរួមភេទដើម្បីរស់រានមានជីវិត ឬ ការរួមភេទដើម្បីបានបាយហូប ថ្នាំ ឬ សិទ្ធិដទៃទៀត ទាសករផ្លូវភេទ ទម្រង់ផ្សេងទៀតនៃការបៀតបៀនកេរ្តិ៍ភេទ និងការរំលោភបំពាន ផលប៉ះពាល់ កត្តាប្រឈម ការស្វែងរកជំនួយ និងតម្រូវការបន្តបន្ទាប់។

អ្នកផ្ដល់បទសម្ភាស ត្រូវបានសួរថាតើពួកគេបានឃើញ ឬ ឮអំពីអំពើហិង្សាផ្លូវភេទ ឬ បានឃើញភស្តុតាងនៃអំពើហិង្សាបែបនេះបន្ទាប់ពីរឿងជាក់ស្តែងកើតឡើងដូចជាសាកសពអាក្រាតកាយ ឬ បំណែកសាកសព។ អ្នកផ្ដល់បទសម្ភាសប្រហែលបានស្ដាប់អំពីករណីអំពើហិង្សានេះពីជនរងគ្រោះ ឬ ពីនរណាម្នាក់ដែលជិតស្និទ្ធជាមួយជនរងគ្រោះ ឬ ជាសាក្សីនៃបទឧក្រិដ្ឋនេះ។ អ្នកផ្ដល់បទសម្ភាសក៏ត្រូវបានសួរថាតើពួកគេជាជនរងគ្រោះផ្ទាល់នៃអំពើហិង្សាផ្លូវភេទដែរឬទេ?

បទសម្ភាស ធ្វើឡើងដោយប្រើប្រាស់រចនាសម្ព័ន្ធកម្រងសំណួរ ដែលមានសំណួរបើកមួយចំនួននៅវគ្គបញ្ចប់។ ដើម្បីផ្ដល់ព័ត៌មានកាន់តែមានគុណភាពក្នុងពេលពិភាក្សាអំពីករណីអំពើហិង្សាផ្លូវភេទ អ្នកសម្ភាសបានលើកទឹកចិត្តអ្នកផ្ដល់បទសម្ភាសឱ្យផ្ដល់ចម្លើយឱ្យបានច្រើន និង ផ្ដល់ព័ត៌មានបន្ថែម ដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវនេះ។ ដំបូង កម្រងសំណួរនេះត្រូវបានរៀបចំជាភាសាអង់គ្លេស និងបន្ទាប់មកត្រូវបានបកប្រែជាភាសាខ្មែរ និងបានត្រួតពិនិត្យដោយអ្នកជំនាញក្នុងស្រុកដើម្បីពិនិត្យមើលភាពត្រឹមត្រូវ។ កម្រងសំណួរនេះត្រូវបានរៀបចំឡើងផ្អែកតាមឯកសាររបស់ Natale និងមិត្តរួមការងារនៅក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា[៨៩]។ ការធ្វើបែបនេះ គឺដើម្បីធ្វើការប្រៀបធៀបទិន្នន័យរវាងការសិក្សានីមួយៗឱ្យបានកាន់តែច្រើន។

ក្រុមការងារមួយក្រុមដែលមានអ្នកសម្ភាសចំនួន១០នាក់ បានប្រមូលទិន្នន័យនេះ។ អ្នកសម្ភាសម្នាក់គឺជានិយោជិតរបស់ CDP ដែលមានបទពិសោធន៍យ៉ាងច្រើនក្នុងការធ្វើបទសម្ភាសជាមួយអ្នកនៅរស់រានមានជីវិតដែលទទួលរងអំពើហិង្សាផ្លូវភេទ និងយេនឌ័រក្នុងរបបខ្មែរក្រហម។ អ្នកផ្ដល់បទសម្ភាសប្រាំបួននាក់ផ្សេងទៀតត្រូវបានជ្រើសរើស ផ្អែកលើបទពិសោធន៍នៃការសិក្សាស្រាវជ្រាវ/ការធ្វើបទសម្ភាសកន្លងមករបស់ពួកគេ ការយល់ដឹងអំពីអំពើហិង្សាផ្លូវភេទ និងការបំពេញការងាររបស់ពួកគេក្នុងពេលទទួលការបណ្ដុះបណ្ដាលមុនពេលចុះធ្វើបទសម្ភាសតាមមូលដ្ឋាន។

អ្នកសម្ភាសទទួលបានការបណ្ដុះបណ្ដាលរយៈពេលមួយថ្ងៃកន្លះលើប្រធានបទ ដូចជាការសិក្សាស្រាវជ្រាវ និងគោលបំណង អំពើហិង្សាផ្លូវភេទ និងរបបខ្មែរក្រហម សីលធម៌ក្នុងការសិក្សាស្រាវជ្រាវ (រួមទាំង ការយល់ព្រមបន្ទាប់ពីទទួលបានព័ត៌មានគ្រប់គ្រាន់ ការរក្សាការសម្ងាត់ និងការចូលរួមដោយស្ម័គ្រចិត្ត) បច្ចេកទេសធ្វើបទសម្ភាស (រួមទាំង ការសម្ភាសអំពីការយល់ដឹងអំពីយេនឌ័រ និងបច្ចេកទេសកាត់បន្ថយភាពលម្អៀង) ការគ្រប់គ្រងកម្រងសំណួរ និងការថែទាំខ្លួនឯងក្នុងអំឡុង និងក្រោយពេលសម្ភាស។ វគ្គសិក្សាតាមដានលើអ្នកសម្ភាសចំនួនពីរត្រូវបានរៀបចំឡើងមុនពេលចាប់ផ្ដើមការចុះធ្វើបទសម្ភាសតាមមូលដ្ឋាន ដើម្បីឱ្យពួកគេបានអនុវត្តបន្ថែមទៀតក្នុងការគ្រប់គ្រងកម្រងសំណួរ។

---

89 Natale *op cit.*

## ការរៀបចំការសិក្សាស្រាវជ្រាវ

អ្នកសម្ភាសបានធ្វើការងារជាគូក្នុងការចុះធ្វើបទសម្ភាសតាមមូលដ្ឋាន។ ការធ្វើការងារជាគូបែបនេះ អាចឱ្យមនុស្សម្នាក់ទៀតជួយរក្សាទីកន្លែងឯកជនសម្រាប់ធ្វើបទសម្ភាស និងធ្វើការពិនិត្យបទសម្ភាសឡើងវិញនៅនឹងទីកន្លែង។ អ្នកសម្របសម្រួល និងជំនួយការនៃការសិក្សាស្រាវជ្រាវជាអ្នកគ្រប់គ្រងលើអ្នកសម្ភាសនៅពេលចុះបំពេញការងារតាមមូលដ្ឋាន។ អ្នកគ្រប់គ្រងជាអ្នកធានាថាអ្នកសម្ភាសអនុវត្តការងារដោយប្រកាន់ខ្ជាប់តាមគោលការណ៍បទសម្ភាស និងបានត្រួតពិនិត្យលើកម្រងសំណួរជាលើកទីពីរក្នុងពេលបំពេញការងារតាមមូលដ្ឋាន ដើម្បីការពារកំហុសឆ្គងក្នុងការប្រមូលទិន្នន័យ។

### ៣.២.៣ ការវិភាគទិន្នន័យ

ដោយសារសំណាកគំរូនៃអ្នកផ្តល់បទសម្ភាសមានទំហំតូច ហើយការជ្រើសរើសធ្វើឡើងតាមវិធីសាស្ត្រមិនចៃដន្យ ការយកលទ្ធផលរកឃើញបានមកពីទិន្នន័យនេះធ្វើជាមូលដ្ឋានសម្រាប់កំណត់ចំនួនប្រជាជនកម្ពុជាទូទៅ ឬ កំណត់កម្រិតកើតមានជាញឹកញាប់នៃអំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺមិនអាចទៅរួចឡើយ។ ទោះបីយ៉ាងណា វាអាចទៅរួចទេក្នុងការកំណត់ប្រភេទអំពើហិង្សាផ្លូវភេទដែលជនជាតិភាគតិចបានឆ្លងកាត់ មិនថាមានមនុស្សច្រើន ឬ មួយចំនួនបានឆ្លងកាត់បទពិសោធន៍ទាំងនោះឡើយ។ រឿងរ៉ាវនៃអំពើហិង្សាផ្លូវភេទត្រូវបានយកមកវិភាគស្រាប់ជាគំរូ និងជាប្រធានបទក្នុងបង្កើនការយល់ដឹងទូទៅអំពីអំពើហិង្សានេះ។ ទិន្នន័យនេះក៏ត្រូវបានពិនិត្យពិច័យសម្រាប់បទពិសោធន៍ខុសៗគ្នារបស់បុគ្គលនីមួយៗ។

ទិន្នន័យបានមកពីបទសម្ភាស ត្រូវបានវិភាគដោយប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ និងបរិមាណវិស័យ។ ចំនួននៃការផ្តល់ចម្លើយត្រូវបានកត់ត្រាទុក ហើយតួលេខទាំងនេះមានបង្ហាញក្នុងលទ្ធផលរកឃើញ ដើម្បីផ្តល់ព័ត៌មានអំពីបទពិសោធន៍រួមនៅក្នុងសំណាកគំរូ។ ទោះបីយ៉ាងណា ចាំបាច់ត្រូវកត់សម្គាល់ថា សំណាកគំរូនេះមិនតំណាងឱ្យចំនួនជនជាតិភាគតិចច្រើនឡើយ។ លើសពីនេះ ចំនួនអ្នកផ្តល់បទសម្ភាសដែលបានជ្រើសរើសពីក្រុមជនជាតិភាគតិចខុសៗគ្នាគឺមិនស្មើគ្នាឡើយ។

កំណត់ត្រាជាសំឡេងនៃបទសម្ភាស ត្រូវបានសរសេរជាភាសាខ្មែរ និងបានបកប្រែទៅជាភាសាអង់គ្លេស។ ទាំងសំណៅជាភាសាខ្មែរ និងអង់គ្លេសត្រូវបានវិភាគសម្រាប់ជាប្រធានបទ និងបទពិសោធន៍ប្លែកៗខុសពីគ្នា។ ជាពិសេស ការវិភាគនេះធ្វើឡើង ដើម្បីដឹងពីទំហំនៃអំពើហិង្សាផ្លូវភេទដែលបានប្រព្រឹត្ត បរិបទដែលអំពើហិង្សាកើតឡើង ផលប៉ះពាល់លើបុគ្គលនីមួយៗ និងគ្រួសាររបស់ពួកគេ កត្តាប្រឈមរបស់អ្នកនៅរស់រានមានជីវិត និងតើពួកគេបានស្វែងរកជំនួយដែរឬទេ? ការវិភាគនេះក៏បានផ្តោតលើការប្រៀបធៀបរវាងបទពិសោធន៍របស់ជនជាតិភាគតិច និងបទពិសោធន៍របស់

ប្រជាជនទូទៅ។

## ៣.២.៤ សីលធម៌ក្នុងការសិក្សាស្រាវជ្រាវ



*ក្រុមសម្ភាស*

នៅពេលការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ ផ្តល់នូវគ្រោះថ្នាក់ចំពោះអ្នកផ្តល់បទសម្ភាស និងអ្នកសម្ភាសក្រុមសិក្សាស្រាវជ្រាវបានផ្តោតការយកចិត្តទុកយ៉ាងខ្លាំងលើការកាត់បន្ថយគ្រោះថ្នាក់ទាំងនេះ។

ប្រសិនបើគ្មានការស៊ើបអង្កេតដោយប្រុងប្រយ័ត្ន និងប្រកបដោយការយល់ដឹង អ្នកផ្តល់បទសម្ភាសអាចនឹងទទួលរងការប៉ះទង្គិចផ្លូវចិត្តជាថ្មី តាមរយៈការរៀបរាប់រឿងពិតរបស់ខ្លួនក្នុងការទទួលរងអំពើហិង្សា។ ការខកខានមិនបានរក្សាភាពជាឯកជន និងការសម្ងាត់របស់អ្នកផ្តល់បទ សម្ភាស អាចធ្វើឱ្យគេដឹងថាអ្នកផ្តល់បទសម្ភាសគឺជាអ្នកនៅរស់រានមានជីវិតទទួលរងអំពើហិង្សាផ្លូវភេទក្នុងសហគមន៍របស់ពួកគេ និងធ្វើឱ្យមានការរើសអើង ការបំបាក់មុខ ការរំលោភបំពានបន្ថែម ឬ ការសងសឹកពីនរណាម្នាក់លើអ្នកផ្តល់បទសម្ភាស។ អ្នកសិក្សាស្រាវជ្រាវខ្លួនឯងផ្ទាល់ ក៏អាចទទួល រងការប៉ះទង្គិចផ្លូវចិត្តបន្ទាប់បន្សំ តាមរយៈការស្តាប់ការរៀបរាប់អំពីអំពើហិង្សានេះ ប្រសិនបើពួកគេមិនចេះថែទាំខ្លួនឯង និងមិនចេះសួរយកការណ៍។

ក្នុងកម្រងសំណួរមានអត្ថបទស្តង់ដារមួយ ដែលពន្យល់អំពីលក្ខណៈ និងគោលបំណងនៃការសិក្សាស្រាវជ្រាវ វិធីអនុវត្តបទសម្ភាស និងលទ្ធផលរំពឹងទុក។ បន្ទាប់មក អ្នកសម្ភាសសួរអ្នកផ្តល់បទសម្ភាសអំពីការយល់ព្រមដោយផ្ទាល់មាត់ក្នុងការចូលរួមផ្តល់បទសម្ភាស បន្ទាប់ពីបានជ្រាបព័ត៌មានគ្រប់គ្រាន់។ ការយល់ព្រមចូលរួមផ្តល់បទសម្ភាសរបស់អ្នកផ្តល់បទសម្ភាសត្រូវបានថតសម្លេងទុក។ បន្ទាប់ពីអានអត្ថបទជូនអ្នកផ្តល់បទសម្ភាសរួច ទាំងអ្នកសម្ភាស និងដៃគូសម្ភាសរបស់ពួកគេបានចុះហត្ថលេខាក្នុងសេចក្តីប្រកាសថា ខ្លួនបានយល់ព្រមផ្តល់បទសម្ភាស។

ការចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះគឺជាការស្ម័គ្រចិត្តទាំងស្រុង។ អ្នកផ្តល់បទសម្ភាសត្រូវបានជម្រាបថា ពួកគេមិនត្រូវបានបង្ខំឱ្យចូលរួម និងមានសិទ្ធិផ្អាក ឬ បញ្ឈប់បទសម្ភាស សុំឱ្យរំលង

សំណួរ ឬ បដិសេធមិនយល់ព្រមចូលរួមក្នុងដំណើរការសិក្សាស្រាវជ្រាវនេះបានគ្រប់ពេលវេលា។

ដោយមានការពិភាក្សាប្រកបដោយការយល់ដឹងអំពីអំពើហិង្សាផ្លូវភេទ ជាពិសេសសម្រាប់ជនរងគ្រោះផ្ទាល់ អ្នកសម្ភាសបានសម្ភាសអ្នកផ្តល់បទសម្ភាសដែលមានភេទដូចខ្លួន។ អ្នកផ្តល់បទសម្ភាសទាំងអស់ ទទួលបានព័ត៌មានទំនាក់ទំនងសម្រាប់សេវាគាំទ្រផ្លូវចិត្តដែលមានតាមប្រព័ន្ធទូរស័ព្ទ។ អ្នកផ្តល់បទសម្ភាសដែលមានការប៉ះទង្គិចផ្លូវចិត្តខ្លាំងក្នុងអំឡុងពេលផ្តល់បទសម្ភាសមានឱកាសនិយាយអំពីក្រុមការងារស្រាវជ្រាវជាមួយអ្នកចិត្តសាស្ត្រជំនាញ។ អ្នកសម្ភាសទទួលបានការបណ្តុះបណ្តាលអំពីបច្ចេកទេសធ្វើបទសម្ភាសប្រកបដោយការយល់ដឹង រួមទាំង សញ្ញាបង្ហាញអំពីអារម្មណ៍ឈឺចាប់ និងអនុញ្ញាតឱ្យអ្នកផ្តល់បទសម្ភាសផ្អាក ឬ បញ្ឈប់បទសម្ភាសបានគ្រប់ពេលដែលពួកគេចង់។ ក្នុងការបណ្តុះបណ្តាលមុនពេលចុះធ្វើបទសម្ភាសតាមមូលដ្ឋាន អ្នកសម្ភាសបានសិក្សាអំពីការអាចកើតមានការប៉ះទង្គិចផ្លូវចិត្តបន្ទាប់បន្សំ និងសិក្សាអំពីបច្ចេកទេសក្នុងការថែទាំខ្លួនឯង។ ក្នុងពេលប្រមូលទិន្នន័យ អ្នកសម្ភាសមានឱកាសធ្វើការរៀបរាប់ជាមួយដៃគូ និងអ្នកគ្រប់គ្រង។

ដើម្បីរក្សាការសម្ងាត់នៃព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកផ្តល់បទសម្ភាស កិច្ចសម្ភាសនីមួយៗត្រូវបានផ្តល់ជាលេខសម្រាប់សម្គាល់។ មិនមានការកំណត់ដោយខ្លួនឯងលើព័ត៌មានរបស់អ្នកផ្តល់បទសម្ភាស ដូចជា ឈ្មោះ អាសយដ្ឋាន ឬ រូបថត ត្រូវបានកត់ត្រាទុកក្នុងរបាយការណ៍ ឬ សៀវភៅបោះពុម្ពផ្សាយផ្សេងទៀតទាក់ទងនឹងការសិក្សាស្រាវជ្រាវនេះឡើយ។ នៅពេលមានឯកសារយោងក្នុងករណីរបស់អ្នកផ្តល់បទសម្ភាស ដើម្បីកំណត់ទីតាំង ឬ មនុស្ស ឈ្មោះរបស់អ្នកផ្តល់បទសម្ភាសត្រូវបានលុបចោល។ រាល់ព័ត៌មានត្រូវបានកំណត់ដោយខ្លួនឯងដែលប្រមូលបានក្នុងអំឡុងពេលធ្វើការសិក្សាស្រាវជ្រាវនេះ នឹងត្រូវបំផ្លាញចោលក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីការសិក្សាស្រាវជ្រាវបានបញ្ចប់។ អ្នកសម្ភាស អ្នកបើកបរ អ្នកបកប្រែ និងអ្នកវិភាគទិន្នន័យទាំងអស់ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀង ឬ ខសន្យាក្នុងកិច្ចសន្យារបស់ពួកគេពាក់ព័ន្ធនឹងការរក្សាការសម្ងាត់នូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកផ្តល់បទសម្ភាស។

## ៣.៣ ការកម្រិត

កិច្ចប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើង ដើម្បីអនុវត្តតាមបច្ចេកទេសសិក្សាស្រាវជ្រាវដ៏តឹងរ៉ឹង និងការអនុវត្តដ៏ល្អនៃការសិក្សាស្រាវជ្រាវយល់ដឹងអំពីយេនឌ័រ បើទោះបីមានការកម្រិតមួយចំនួនលើការសិក្សាស្រាវជ្រាវនេះក៏ដោយ។

ទីមួយ ដូចបានលើកឡើងខាងលើ សំណាកគំរូដែលមានទំហំតូចសម្រាប់ការសិក្សាស្រាវជ្រាវនេះ និងការប្រើប្រាស់សំណាកគំរូមិនចៃដន្យ ឬ សំណាកគំរូតំណាងមានន័យថា លទ្ធផលរកឃើញមិនអាចយកមកធ្វើជាមូលដ្ឋានក្នុងការកំណត់ចំនួនប្រជាជនកម្ពុជាទូទៅ ឬ សូម្បីចំនួនជនជាតិភាគ

តិចកាន់តែច្រើន។ ទោះបីយ៉ាងណា ទិន្នន័យនេះផ្តល់ព័ត៌មានអំពីអំពើហិង្សាផ្លូវភេទជាច្រើនសម្រាប់ក្រុមជនជាតិភាគតិចជាក់លាក់ដែលនៅរស់រានមានជីវិត ផលប៉ះពាល់ និងការឆ្លើយតបរបស់ពួកគេ។

ទីពីរ ករណីដែលត្រូវបានស៊ើបអង្កេតក្នុងការសិក្សាស្រាវជ្រាវនេះ បានកើតឡើងស្ទើរតែជិត ៤០ឆ្នាំមកហើយ។ ដូច្នេះ ព័ត៌មានប្រមូលបានពីអ្នកផ្តល់បទសម្ភាសមិនមានគ្រប់គ្រាន់ឡើយ ដោយសារតែការចងចាំមិនល្អ ការចងចាំខុស និងភាពលម្អៀងដោយសារដំណើរផ្លាស់ប្តូរនៃពេលវេលា។ ទោះបីជាមានការកម្រិតទាំងនេះក៏ដោយ ក៏រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតមានតម្លៃយ៉ាងខ្លាំងសម្រាប់ដំណើរការរៀបចំឯកសារស្តីពីរបបមហាអន្តរាយនេះក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ព័ត៌មានស្តីពីរឿងរ៉ាវរបស់ជនជាតិភាគតិចក្នុងរបបនេះមិនមានគ្រប់គ្រាន់ឡើយ ហើយព័ត៌មានស្តីពីអំពើហិង្សាផ្លូវភេទដែលពួកគេបានជួបប្រទះក៏មានកាន់តែតិច។ អ្នកនៅរស់រានមានជីវិតទទួលរងអំពើហិង្សាផ្លូវភេទជាច្រើននាក់មិនដែលនិយាយអំពីរឿងរ៉ាវដែលខ្លួនជួបប្រទះ សូម្បីតែប្រាប់គ្រួសារខ្លួនផ្ទាល់។ លើសពីនេះ ដោយសារអ្នកនៅរស់រានមានជីវិតកាន់តែចាស់ និងទន់ខ្សោយ តម្រូវការនៃព័ត៌មានទាក់ទងនឹងរឿងរ៉ាវរបស់ពួកគេកាន់តែមានភាពចាំបាច់។

ទីបី ទោះបីមានកិច្ចប្រឹងប្រែងដាក់អ្នកផ្តល់បទសម្ភាសជាជនជាតិភាគតិចខុសៗគ្នាឱ្យមានចំនួនស្មើគ្នាបញ្ចូលទៅក្នុងការស៊ើបអង្កេត ប្រហែលជាជនជាតិវៀតណាមមួយចំនួនអាចនឹងត្រូវសម្ភាស ដោយកម្រិតលើចំនួនករណីទទួលរងអំពើហិង្សាផ្ទាល់របស់ពួកគេ។ អន្តរការី និងអ្នកផ្តល់បទសម្ភាសបានជម្រាបក្រុមសិក្សាស្រាវជ្រាវថា ជនជាតិវៀតណាមជាច្រើនមានភាពស្ទាក់ស្ទើរក្នុងការនិយាយជាមួយអ្នកសិក្សាស្រាវជ្រាវ ឬ ការកំណត់អារម្មណ៍ប្រឆាំងយ៉ាងខ្លាំងនឹងជនកាជាតិវៀតណាមក្នុងប្រទេសកម្ពុជាក្នុងពេលធ្វើការសិក្សាស្រាវជ្រាវ។ នៅពេលកត្តានេះគឺជាការម្រិតយ៉ាងខ្លាំងមួយ ការសិក្សាស្រាវជ្រាវបានបញ្ចូលករណីជាច្រើននៃអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចវៀតណាម ដែលអ្នកផ្តល់បទសម្ភាសដទៃទៀតបានឃើញ ឬ ដឹងឮអំពីករណីទាំងនេះ។ អ្វីដែលគួរកត់សម្គាល់ ការសិក្សាស្រាវជ្រាវនេះក៏អនុញ្ញាតឱ្យអ្នកផ្តល់បទសម្ភាសជនជាតិមូស្លីមធ្វើការកំណត់អត្តសញ្ញាណរបស់ខ្លួនថាជាខ្មែរឥស្លាម ឬ ចាមផងដែរ។ អ្នកផ្តល់បទសម្ភាសភាគច្រើនបានកំណត់អត្តសញ្ញាណខ្លួនជាខ្មែរឥស្លាម។

ចុងក្រោយ ក្នុងពេលដែលមានការយកចិត្តទុកដាក់ខ្លាំងក្នុងការបណ្តុះបណ្តាលអ្នកសម្ភាស ការរៀបចំកម្រងសំណួរ និងការវិភាគ ដើម្បីកាត់បន្ថយការយល់ច្រឡំអត្ថន័យ អ្នកផ្តល់បទសម្ភាសអាចនឹងមានការយល់ខុសអំពីគោលបំណងនៃសំណួរ ដោយសារតែភាពខុសគ្នានៃវប្បធម៌ ឬ ភាសា។ នៅពេលមានភាពមិនច្បាស់លើអត្ថន័យក្នុងប្រតិចារិតជាភាសាអង់គ្លេស ឬ លើក្រដាសកម្រងសំណួរ ក្រុមសិក្សាស្រាវជ្រាវត្រឡប់មកមើលប្រតិចារិតជាភាសាខ្មែរ កំណត់ត្រាដើម និងសួរបញ្ជាក់ទៅកាន់អ្នកសម្ភាស។



# ៤. លទ្ធផលរកឃើញ

## ៤.១ ប្រជាសាស្ត្រ

ការសិក្សាស្រាវជ្រាវនេះ បានសម្ភាសមនុស្សចំនួន១០៥នាក់ ដែលរស់នៅក្នុងរបបខ្មែរក្រហម និងត្រូវបានគេគិតថា បានដឹងអំពីអំពើហិង្សាផ្លូវភេទដែលកើតឡើងក្នុងរបបនេះ។ តារាងខាងក្រោមបង្ហាញពីលក្ខណៈប្រជាសាស្ត្រទូទៅមួយរបស់ក្រុមនេះ។

*តារាង១ ៖ លក្ខណៈប្រជាសាស្ត្ររបស់អ្នកផ្ដល់បទសម្ភាស*

| ភេទ | | អាយុ | | ទីតាំងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ | |
|---|---|---|---|---|---|
| ស្ត្រី | ៧០% | ៤០-៤៩ | ៧% | បន្ទាយមានជ័យ | ៣% |
| បុរស | ៣០% | ៥០-៥៩ | ៥៨% | បាត់ដំបង | ២២% |
| | | ៦០-៦៩ | ៣០% | កំពង់ចាម | ៤% |
| | | ៧០-៧៩ | ៣% | កំពង់ឆ្នាំង | ៥% |
| | | ៨០+ | ២% | កំពង់សោម | ៥% |
| | | | | កំពង់ស្ពឺ | ១% |
| | | | | កំពង់ធំ | ៤% |
| | | | | កំពត | ១៦% |
| | | | | កណ្ដាល | ១% |
| | | | | កោះកុង | ២% |
| | | | | ក្រចេះ | ១% |
| | | | | ភ្នំពេញ | ១% |
| | | | | ពោធិ៍សាត់ | ២៣% |
| | | | | តាកែវ | ១១% |
| | | | | មិនដឹង | ១% |

## ៤.១.១ ភេទ និងអាយុ

អ្វីគួរកត់សម្គាល់ ក្នុងការសិក្សាស្រាវជ្រាវនេះមានស្ត្រី (៧០%) ចូលរួមផ្តល់បទសម្ភាសច្រើនជាងបុរស (៣០%)។

អ្នកផ្តល់បទសម្ភាសមានអាយុចន្លោះចាប់ពី៤០ឆ្នាំ ដល់ ៨០ឆ្នាំជាង។ ប្រជាជនភាគច្រើនដែលផ្តល់បទសម្ភាស (៨៨%) មានអាយុចន្លោះចាប់ពី៥០ឆ្នាំ ដល់ ៦៩ ឆ្នាំ។ នេះមានន័យថា អ្នកផ្តល់បទសម្ភាសភាគច្រើនមានអាយុចន្លោះចាប់ពី១១ឆ្នាំ ដល់ ៣១ឆ្នាំ នៅពេលខ្មែរក្រហមកាន់កាប់អំណាចក្នុងឆ្នាំ១៩៧៥។

## ៤.១.២ ជាតិពន្ធុ

ដើម្បីជ្រើសរើសអ្នកផ្តល់បទសម្ភាសឱ្យបានតាមដែលអាចធ្វើទៅបានពីក្នុងចំណោមជនជាតិភាគតិចវៀតណាម ខ្មែរក្រោម ខ្មែរឥស្លាម និងចាម ក្រុមសិក្សាស្រាវជ្រាវបានសហការជាមួយអន្តរការីក្នុងសហគមន៍ក្នុងគោលបំណងជ្រើសរើសសំណាកគំរូក្រុមទាំងនេះ និងប្រើបច្ចេកទេសជ្រើសរើសដោយការបោះកូនបាល់ ដើម្បីកំណត់អ្នកផ្តល់បទសម្ភាសបន្ថែមទៀត។ ដំណើរការជ្រើសរើសបានបញ្ចូលទាំងសាក្សីជនជាតិខ្មែរ និងសាក្សីដទៃទៀតដែលបានឃើញ ឬ ដឹងឮអំពើហិង្សាផ្លូវភេទលើនរណាម្នាក់ពីបុគ្គលណាមួយក្នុងក្រុមជនជាតិភាគតិចទាំងនេះ។

*រូបលេខ១ ដ្យាក្រាមបែងចែកសំណាកគំរូតាមជាតិពន្ធុ*




សំណាកគំរូចុងក្រោយរួមមាន អ្នកផ្តល់បទសម្ភាសជាខ្មែរក្រោម៤៧នាក់ ខ្មែរឥស្លាម ៣៩នាក់ ជនជាតិវៀតណាម ៦ នាក់ និងចាម២នាក់ រួមជាមួយអ្នកផ្តល់បទសម្ភាស ១១នាក់បន្ថែមទៀត ដែលត្រូវបានកំណត់ជា "អ្នកផ្តល់បទសម្ភាសមានជាតិសាសន៍ផ្សេងទៀត" ដែលទំនងជាខ្មែរ (សូមមើលរូបលេខ១)។

## លទ្ធផលរកឃើញ

## ៤.១.៣ ទីតាំងរបស់អ្នកផ្តល់បទសម្ភាសក្នុងពេលបច្ចុប្បន្ន និងក្នុងអំឡុងរបបខ្មែរក្រហម

បទសម្ភាសជាមួយអ្នកផ្តល់បទសម្ភាសត្រូវបានធ្វើឡើងក្នុងខេត្តប្រាំមួយក្នុងប្រទេសកម្ពុជា ដូចជា ពោធិ៍សាត់ (២៦%) កំពត (២៦%) បាត់ដំបង (១៩%) ភ្នំពេញ (១២%) តាកែវ (១១%) និងកំពង់ឆ្នាំង (៦%)។

*រូបលេខ២ ផែនទីខេត្តដែលធ្វើបទសម្ភាស*




ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកផ្តល់បទសម្ភាសស្ថិតនៅរាយប៉ាយក្នុងភូមិសាស្ត្រដ៏ធំ។ ហេតុដូច្នេះ វាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ នៅពេលខ្មែរក្រហមធ្វើការជម្លៀសប្រជាជនចេញពីទីក្រុង និងបញ្ជូនទៅធ្វើការតាមជំរំការងារ។ លើសពីនេះ មនុស្សជាច្រើនត្រូវបានបង្ខំឱ្យចាកចេញពីកន្លែងរស់នៅក្នុងរបបនេះ ដោយសារតែជាតិសាសន៍ តម្រូវការកម្លាំងពលកម្ម ដើម្បីជាទណ្ឌកម្ម ឬ ដើម្បីបំបែកគ្រួសារ និងសហគមន៍។

*រូបលេខ៣ ផែនទីខេត្តដែលអ្នកផ្តល់បទសម្ភាសបានរស់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ*




នៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ អ្នកផ្តល់បទសម្ភាសក្នុងការសិក្សាស្រាវជ្រាវនេះ បានរស់នៅក្នុង ១៤ខេត្តផ្សេងគ្នា ដូចបានបង្ហាញក្នុងតារាងលេខ១។ ខេត្តទាំងនេះរួមមាន បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់សោម កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល កោះកុង ក្រចេះ ភ្នំពេញ ពោធិ៍សាត់ និងតាកែវ (សូមមើលរូបលេខ៣សម្រាប់ផែនទីកំណត់ទីតាំងខេត្តទាំងនេះ)។

## ៤.១.៤ ស្ថានភាពក្នុងរបបខ្មែរក្រហម

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមមិនផ្តល់តម្លៃដល់ទំនាក់ទំនងគ្រួសារឡើយ។ ឧទាហរណ៍ ខ្មែរក្រហមបានបំបែកសមាជិកគ្រួសារឱ្យរស់នៅផ្សេងពីគ្នា។ ខ្មែរក្រហមបានបង្កើត

ប្រព័ន្ធក្រុមថ្មីមួយបន្ថែមទៀត ផ្អែកតាមភក្តីភាពរបស់ប្រជាជននឹងរបបខ្លួន ប្រវត្តិសង្គម ជាតិពន្ធ និង កត្តាផ្សេងទៀត[90]។ ក្រុមទីមួយគឺជាក្រុម "ប្រជាជនចាស់" ដែលរស់នៅក្នុងតំបន់គ្រប់គ្រងដោយខ្មែរក្រហមក្នុងអំឡុងសង្គ្រាមស៊ីវិលជាមួយអ្នកគាំទ្រលន់ នល់ និង "ប្រជាជនថ្មី" ដែលរស់នៅក្រៅតំបន់គ្រប់គ្រងដោយខ្មែរក្រហម។ ប្រជាជនថ្មីជាច្រើនត្រូវបានបង្ខំឱ្យចាកចេញ បន្ទាប់ពីរបបនេះបានគ្រប់គ្រងប្រទេស។ "ប្រជាជនបម្រុង" គឺជាប្រជាជនដែលរស់នៅក្នុងតំបន់គ្រប់គ្រងដោយខ្មែរក្រហម ប៉ុន្តែសាច់ញាតិរបស់ពួកគេរស់នៅក្នុងតំបន់គ្រប់គ្រងដោយលន់ នល់ ឬ ជាគ្រួសារជាន់ខ្ពស់ នគរបាល ឬ ទាហាន។ ខ្មែរក្រហមមានភាពសង្ស័យលើប្រជាជនទាំងនេះ។ ខ្មែរក្រហមបានបង្កើតឱ្យមានក្រុមប្រជាជនខុសគ្នាជាច្រើន ដូចជា ជាប្រជាជនស៊ីវិល (កសិករ ឬ កម្មករ) ឬ អ្នកធ្វើការឱ្យខ្មែរក្រហមជាកម្មាភិបាល (ទាហាន) ឬ អ្នកស្ម័គ្រចិត្ត (ចូលរួមក្នុងការងារមួយចំនួនក្នុងការគ្រប់គ្រងសហករណ៍ដើម្បីទទួលបានការចាត់តាំងឱ្យបំពេញការងារស្រាល និងអាហារបរិភោគ[91]។ ក្រៅពីកម្មាភិបាលខ្មែរក្រហម កងឈ្លបតាមមូលដ្ឋានក៏មានអំណាចដែរ។ ក្នុងនាមជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា អាជ្ញាធរខ្មែរក្រហមតាមមូលដ្ឋាននឹងចាត់តាំងពួកគេឱ្យបំពេញការងារជាក់លាក់ ដូចជា ការឃ្លាំមើល។

អ្នកផ្តល់បទសម្ភាសក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានសួរថា តើខ្មែរក្រហមបានបែងចែកពួកគេទៅក្នុងក្រុមមួយណាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? អ្នកផ្តល់បទសម្ភាសចំនួន៨៥នាក់បានរៀបរាប់ថា ពួកគេត្រូវបានបែងចែកជាប្រជាជនថ្មី ១១នាក់ជាប្រជាជនមូលដ្ឋាន ១នាក់ជាកម្មាភិបាលខ្មែរក្រហម និងអ្នកនៅសល់មិនដឹង។

## ៤.១.៤ ព័ត៌មានអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច

ការប្រើវិធីសាស្ត្រកំណត់សំណាកគំរូប្រកបដោយការយកចិត្តទុកដាក់ក្នុងការសិក្សាស្រាវជ្រាវនេះ (សំណាកគំរូជ្រើសរើស និងសំណាកគំរូជ្រើសរើសដោយការបោះកូនបាល់) គឺដើម្បីបង្កើនចំនួនអ្នកផ្តល់បទសម្ភាស ដែលដឹងព័ត៌មានមួយចំនួនអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ វិធីសាស្ត្រទាំងនេះបង្ហាញពីភាពជោគជ័យក្នុងការជ្រើសរើសអ្នកផ្តល់បទសម្ភាស ដែលអ្នកផ្តល់បទសម្ភាសភាគច្រើនដឹងអំពីអំពើហិង្សាទាំងនេះ។ អ្នកផ្តល់បទសម្ភាសទាំងនេះរួមបញ្ចូលទាំងអ្នកផ្តល់បទសម្ភាសដែលបានឃើញអំពើហិង្សាផ្លូវភេទផ្ទាល់ ដឹងអំពីអំពើហិង្សា បែបនេះដោយសារគេប្រាប់បន្ទាប់ពីរឿងពិតកើតឡើង ឬ ខ្លួនឯងឆ្លងកាត់ដោយផ្ទាល់។ តារាង

90 Becker, E, *នៅពេលសង្គ្រាមបានបញ្ចប់៖* កម្ពុជា និងបដិវត្តន៍ខ្មែរក្រហម (New York ៖ កិច្ចការសាធារណៈ) Duong L (២០០៦), *op. cit.*

91 Becker, *op. cit.*, ២២៧

## លទ្ធផលរកឃើញ

លេខ២បង្ហាញអំពីភាគរយនៃអ្នកផ្តល់បទសម្ភាស១០៥នាក់ ដែលដឹងព័ត៌មានខ្លះៗអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (សូមមើលតារាងលេខ២)។

*តារាងលេខ២៖ ការដឹងអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហមរបស់អ្នកផ្តល់បទសម្ភាស*

| | បទពិសោធន៍ផ្ទាល់ខ្លួន | សាក្សី | ដឹងពីជនរងគ្រោះ | ដឹងពីអ្នកដទៃ | សរុប |
|---|---|---|---|---|---|
| ការរៀបការដោយបង្ខំ | ៦០%* | - | - | - | ៦០% |
| ការរំលោភសេពសន្ថវៈ | - | ៥៥% | ៤% | ២៩% | ៨៨% |
| ការរួមភេទដើម្បីរស់រានមានជីវិត | ១% | ១១% | ២% | ៧% | ២១% |
| ទាសករផ្លូវភេទ | - | ១១% | ៥% | ៧% | ២៣% |
| សរុប | ៦១% | ៧៧% | ១១% | ៤៣% | |

** អ្នកផ្តល់បទសម្ភាសគ្រាន់តែត្រូវបានសួរថា តើខ្មែរក្រហមបានបង្ខំពួកគាត់ឱ្យរៀបការជាមួយនរណាដែរឬទេ? និងមិនបានសួរថា តើពួកគេបានស្គាល់នរណាផ្សេងទៀតដែលត្រូវបានបង្ខំឱ្យរៀបការដែរឬទេ?*

ដូចបានឃើញក្នុងតារាងលេខ២ ជិតពីរភាគបីនៃអ្នកផ្តល់បទសម្ភាស១០៥នាក់បានឆ្លងកាត់ដោយផ្ទាល់ក្នុងទម្រង់អំពើហិង្សាផ្លូវភេទមួយចំនួន ឬ ការរំលោភបំពានក្នុងរបបនេះ ហើយស្ទើរគ្រប់ករណីទាំងអស់ជាករណីរៀបការដោយបង្ខំ (៦០%)។

អ្នកផ្តល់បទសម្ភាសភាគច្រើន (៧៧%) បានឃើញទម្រង់អំពើហិង្សាផ្លូវភេទមួយចំនួនលើមនុស្សម្នាក់ដែលជាជនជាតិភាគតិច ហើយជាទូទៅ អំពើហិង្សាផ្លូវភេទភាគច្រើនគឺការរំលោភសេពសន្ថវៈ។ ក្នុងករណីមួយចំនួន អ្នកផ្តល់បទសម្ភាសបានឃើញករណីអំពើហិង្សាផ្លូវភេទចម្រុះ និង/ឬ ប្រភេទអំពើហិង្សាផ្លូវភេទខុសៗគ្នា។

ក្រៅពីការទទួលរងអំពើហិង្សាផ្លូវភេទដោយផ្ទាល់ ការឃើញ ឬ ដឹងឮអំពើហិង្សាផ្លូវភេទលើនរណាម្នាក់ជាជនជាតិភាគតិច អ្នកផ្តល់បទសម្ភាសមួយចំនួនបានដឹងអំពីករណីបែបនេះពីអ្នកដទៃ។ ក្នុងករណីមួយចំនួន ជនរងគ្រោះផ្ទាល់បានប្រាប់ករណីអំពើហិង្សាផ្លូវភេទដែលខ្លួនបានជួបប្រទះទៅកាន់អ្នកផ្តល់បទសម្ភាស ឬ ក៏អាចជាសាច់ញាតិ ឬ អ្នកជិតខាងរបស់អ្នកផ្តល់បទសម្ភាស ឬ មិត្តរួមការងារ ឬ មនុស្សជិតស្និទ្ធនឹងជនរងគ្រោះ ដែលបានឃើញករណីអំពើហិង្សាផ្លូវភេទ។ ក្នុងករណីមួយចំនួន អ្នកផ្តល់បទសម្ភាសបានឮករណីអំពើហិង្សាផ្លូវភេទពីជនល្មើស។ ក្នុងសហគមន៍មួយចំនួន ករណីអំពើហិង្សាផ្លូវភេទត្រូវបានដឹងឮជាទូទៅ ជាពិសេស ក្នុងករណីការរំលោភទ្រង់ទ្រាយធំ

និងការសម្លាប់ ឬ ការរំលោភសេពសន្ថវៈកើតមានដដែលៗ តាមរយៈការជជែកគ្នារវាងអ្នកភូមិៗ ទោះបីយ៉ាងណា ក្នុងករណីជាច្រើនអ្នកផ្តល់បទសម្ភាសបានបង្ហាញថា ពួកគេមានភាពភ័យខ្លាចខ្លាំង ក្នុងការនិយាយអំពីករណីអំពើហិង្សាផ្លូវភេទជាមួយអ្នកដទៃ ព្រោះពួកគាត់នឹងត្រូវប្រឈមនឹងការ សម្លាប់ចោលដោយជនល្មើស ដើម្បីរក្សាការសម្ងាត់។ អារម្មណ៍ភ័យខ្លាចនេះដែលបង្កឡើងដោយ ជនល្មើសខ្មែរក្រហមធ្វើឱ្យប្រជាជនរក្សាភាពស្ងប់ស្ងាត់ពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ។

ខាងក្រោម គឺជាសេចក្តីលម្អិតនៃព័ត៌មានអំពីអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបប ខ្មែរក្រហមរបស់អ្នកផ្តល់បទសម្ភាស។ អត្ថបទនៃព័ត៌មាននេះត្រូវបានបែងចែកជាប្រភេទអំពើហិង្សា ផ្លូវភេទសំខាន់ៗដែលបានលើកឡើងក្នុងបទសម្ភាស ៖ ការរៀបការដោយបង្ខំ ការរំលោភសេពសន្ថវៈ ការរួមភេទដើម្បីរស់រានមានជីវិត ទាសករផ្លូវភេទ និងទម្រង់រំលោភបំពានផ្លូវភេទដទៃទៀត។ អត្ថបទ នៃព័ត៌មានក៏បញ្ចូលព័ត៌មានស្តីពីផលប៉ះពាល់លើអ្នកនៅរស់រានមានជីវិត និងការឆ្លើយតបរបស់ ពួកគេ កត្តាប្រឈម និងតម្រូវការជាបន្តបន្ទាប់។ គំរូ និងប្រធានបទដែលបានមកពីទិន្នន័យនេះ ក៏ដូច ជាករណីអំពើហិង្សាប្លែកៗក៏ត្រូវបានពិភាក្សាក្នុងលទ្ធផលរកឃើញដែរ។

## ៤.២ ការរៀបការដោយបង្ខំ

ការសិក្សាស្រាវជ្រាវកន្លងមក និងឯកសារផ្ទាល់នៃរបបខ្មែរក្រហមបង្ហាញថា របបនេះបាន បង្ខំប្រជាជននៅលីវ ឬ មេម៉ាយជាច្រើននាក់ឱ្យរៀបការដើម្បី "អង្គការ"។ ពេលខ្លះ ប្តីប្រពន្ធដែលត្រូវ បានបង្ខំរៀបការនេះត្រូវបានសម្លាប់ដោយអតីតប្តីប្រពន្ធដែលជាខ្មែរក្រហម ជាពិសេស ប្រសិនបើពួក គេត្រូវបានចាត់ទុកជាសត្រូវនៃបដិវត្តន៍។ ដើម្បីគ្រប់គ្រងតួនាទីសាសនា និងគ្រួសារក្នុងជីវិតប្រជាជន របបនេះបានគ្រប់គ្រងទាំងស្រុងលើការជ្រើសរើសគូប្តីប្រពន្ធសម្រាប់រៀបការ ការរៀបចំពិធីរៀបការ ទីន្លែងដែលប្តីប្រពន្ធរស់នៅ និងការរួមដំណេករបស់ប្តីប្រពន្ធ។ តាមរយៈការគ្រប់គ្រងបែបនេះ ខ្មែរ ក្រហមបានបង្កើនការគ្រប់គ្រងជាប្រព័ន្ធបែបនេះកាន់តែធំលើប្រជាជន។

ការរៀបការដោយបង្ខំ ត្រូវបានអន្តរជាតិចាត់ទុកជាការរំលោភសិទ្ធិមនុស្ស ដោយសេចក្តី ប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា "ការរៀបការត្រូវធ្វើឡើងដោយមានការព្រមព្រៀងពេញ លេញ និងដោយស្ម័គ្រចិត្តរវាងប្តីប្រពន្ធ"[92]។ លើសពីនេះ នៅពេលការរៀបការដោយបង្ខំត្រូវបានចាត់ ទុកជាអំពើហិង្សាយេនឌ័រ[93]។ សម្រាប់ខ្មែរក្រហម ការរៀបការគឺធ្វើឡើងសម្រាប់ការរួមភេទរវាង

[92] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ១៦(២)។ បានមើលក្នុងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ <http://www.claiminghuman-rights.org/udhr_article_16.html>

[93] វាគឺជាអំពើហិង្សាយេនឌ័រ ពីព្រោះវាបង្ខំប្រជាជនក្នុងតួនាទីយេនឌ័រឱ្យធ្វើតាមសង្គម ឧទាហរណ៍ ស្ត្រីក្នុងនាមជាម្តាយ ដែលកាត់បន្ថយតួនាទីរបស់ស្ត្រីក្នុងការបន្តពូជ។

## លទ្ធផលរកឃើញ

ប្តីប្រពន្ធ ដើម្បីបង្កើតកូន។ ទង្វើបែបនេះគឺជាអំពើហិង្សាផ្លូវភេទ ដែលមិនគោរពសិទ្ធិផ្លូវភេទ និងបន្តពូជរបស់ជនរងគ្រោះ។ ការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបការដោយបង្ខំអាចបង្កឱ្យមានផលវិបាកពេញមួយជីវិត ឧទាហរណ៍ ការប៉ះទង្គិចផ្លូវចិត្តដោយសារការរំលោភសេពសន្ថវៈ ឬ ផលវិបាកចំពោះអ្នកដែលមានកូនជាមួយគ្នាដោយសារលទ្ធផលនៃការរៀបការដោយបង្ខំ។ ហេតុដូច្នេះ ការរៀបការដោយបង្ខំគឺជាបញ្ហាកង្វល់ដ៏ធំមួយក្នុងការសិក្សាស្រាវជ្រាវនេះ។

ផ្នែកខាងក្រោម ពិភាក្សាអំពីបទពិសោធន៍ខុសៗគ្នានៃការរៀបការដោយបង្ខំ ដូចជា ការបង្ខំឱ្យរៀបការដោយអង្គការ ការទទួលយកការរៀបការ ឬ ការបដិសេធមិនរៀបការ ការរៀបចំពិធីរៀបការ និងការបង្ខំឱ្យរួមភេទជាមួយគ្នាពេលក្លាយជាប្តីប្រពន្ធ កូន និងការបំបែកឱ្យរស់នៅផ្សេងគ្នា។

### ៤.២.១ ការបង្ខំ ការទទួលយក ឬ បដិសេធមិនរៀបការ

ភាគច្រើននៃអ្នកផ្តល់បទសម្ភាសទាំង១០៥នាក់ ត្រូវបានខ្មែរក្រហមបង្ខំឱ្យរៀបការ រួមទាំងអ្នកផ្តល់បទសម្ភាសជាច្រើននាក់ទៀតក្នុងចំណោមអ្នកផ្តល់បទសម្ភាសជាជនជាតិភាគតិច៩៤នាក់ ៖ ខ្មែរក្រោម៤០នាក់ ខ្មែរឥស្លាម២១នាក់ ជនជាតិផ្សេងទៀត៣នាក់ ចាម១នាក់ និងជនជាតិវៀតណាម ១នាក់ (សូមមើលរូបលេខ៤)[94]។

*រូបលេខ៤ អ្នកផ្តល់បទសម្ភាសជាជនជាតិភាគតិចដែលត្រូវបានបង្ខំឱ្យរៀបការ*




ក្នុងករណីបង្ខំឱ្យរៀបការដោយខ្មែរក្រហម ជាធម្មតាមានមនុស្សទៅប្រាប់សាមីខ្លួនក្នុងពេលកំពុងធ្វើការថា អ្នកនឹងត្រូវរៀបការជាមួយប្តីឬប្រពន្ធដែលត្រូវបានជ្រើសរើសឱ្យរួចហើយ។ ជាញឹកញាប់ សាមីខ្លួនទទួលបានដំណឹងយ៉ាងយូរបំផុតពីរបីម៉ោង ឬ ពីរបីថ្ងៃ ដែលក្នុងរយៈពេលនេះពួកគេត្រូវពិចារណាថារៀបការ ឬ មិនរៀបការ? (ដូចបានរៀបរាប់

[94] សម្រាប់ជនរងគ្រោះជនជាតិចាម និងវៀតណាម ដែលមានតួលេខទាបជាងគេទំនងជាឆ្លុះបញ្ចាំងឱ្យឃើញពីចំនួនអ្នកឆ្លើយតបមកពីក្រុមជនភាគតិច។

ខាងក្រោម មនុស្សមួយចំនួនត្រូវបានហៅមកចូលរួមប្រជុំ ដែលបន្ទាប់មកទើបដឹងថា ខ្លួនត្រូវបានគេរៀបចំពិធីរៀបការឱ្យ)។

មួយភាគបីនៃអ្នកផ្តល់បទសម្ភាសទាំងនេះ ទទួលសំណើរៀបការនេះនៅពេលត្រូវបានប្រាប់អំពីការរៀបការ។ អ្នកផ្តល់បទសម្ភាសទាំងនេះយល់ស្របដូចគ្នាថា ពួកគេភ័យខ្លាច ឬ សមាជិកគ្រួសាររបស់ខ្លួនត្រូវបានសម្លាប់ ឬ ពួកគេត្រូវចាត់តាំងឱ្យបំពេញការងារលំបាក ឬ ឱ្យផ្លាស់ប្តូរទីលំនៅ ប្រសិនបើពួកគេបដិសេធមិនរៀបការ។ ស្ត្រីម្នាក់បានរៀបរាប់អំពីភាពភ័យខ្លាចរបស់ខ្លួនដែលធ្វើឱ្យគាត់លាក់រឿងសម្ងាត់ នៅពេលខ្លួនត្រូវបានបង្ខំឱ្យរៀបការក្នុងវ័យក្មេង ៖

*ខ្ញុំត្រូវបានបង្ខំឱ្យធ្វើការប្តេជ្ញាចិត្ត [រៀបការ]... ពេលនោះខ្ញុំនៅតូចណាស់។ ខ្ញុំមានអាយុប្រហែលជាង១០ឆ្នាំ... តើខ្ញុំអាចតវ៉ាដូចម្តេច? ខ្ញុំភ័យខ្លាច ដូច្នេះ ខ្ញុំមិនបានបដិសេធអ្វីឡើយ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរតស្លាម

ស្ត្រីម្នាក់ទៀតបានរៀបរាប់ពីការចាត់ទុកជាសត្រូវនៃរបបនេះ ដោយសារការបដិសេធមិនរៀបការ ៖

*ខ្ញុំមិនហ៊ានឆ្លើយថា "ទេ" ឡើយ។ ប្រសិនបើខ្ញុំបដិសេធមិនរៀបការ ខ្ញុំនឹងត្រូវយកទៅសម្លាប់ចោល។ នៅពេលនោះ ប្រសិនខ្ញុំនៅតែចចេស យើងនឹងត្រូវសម្លាប់ចោលដោយសារការចោទប្រកាន់ថាជា "ខ្មាំង" [ន័យត្រង់ "សត្រូវ"នៃរបបខ្មែរក្រហម]*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ទោះបីមានគ្រោះថ្នាក់ក៏ដោយ ក៏ប្រជាជនជាច្រើនបានបដិសេធមិនរៀបការនៅពេលដំបូង។ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសជាជនជាតិភាគតិចចំនួន៦៣នាក់ ដែលត្រូវបានបង្ខំឱ្យរៀបការមានចំនួន៤២នាក់បដិសេធនៅពេលដំបូង។ ក្នុងចំណោមអ្នកដែលបដិសេធមិនរៀបការនៅទីបំផុតអ្នកទាំងអស់នោះលើកលែងតែពីរនាក់ប៉ុណ្ណោះបានរៀបការជាមួយប្តីប្រពន្ធដែលជ្រើសរើសឱ្យដំបូង ឬ ប្តីប្រពន្ធជ្រើសរើសឱ្យបន្ទាប់ទៀតដោយរបបនេះ។ ប្រជាជនមួយចំនួនដែលបដិសេធមិនរៀបការនៅពេលដំបូងបានរៀបរាប់ថា ពួកគេមានភាពភ័យខ្លាចជាខ្លាំងបន្ទាប់ពីបដិសេធ ដូច្នេះ នៅពេលពួក



*ចម្លាក់នៃការបង្ខំរៀបការនៅខេត្តបាត់ដំបង*

## លទ្ធផលរកឃើញ

គេត្រូវបានបង្ខំឱ្យរៀបការលើកក្រោយទៀត ពួកគេទទួលយកសំណើនេះ។ ក្នុងករណីខាងក្រោម បុរសខ្មែរឥស្លាមម្នាក់រៀបរាប់អំពីការបដិសេធរបស់គាត់មិនរៀបការជាមួយស្ត្រីជនជាតិខ្មែរ ប៉ុន្តែគាត់បានយល់ព្រមទាំងបង្ខំលើសំណើលើកទីពីរ ដោយសាររបបនេះកាន់តែមានភាពឃោរឃៅក្នុងការបង្ខំឱ្យរៀបការបែបនេះ៖

*ដំបូង ពួកគេបង្ខំខ្ញុំឱ្យរៀបការជាមួយស្ត្រីជនជាតិខ្មែរម្នាក់ ប៉ុន្តែខ្ញុំបានប្រាប់ពួកគេថា ខ្ញុំមិនចង់រៀបការជាមួយស្ត្រីម្នាក់នោះទេ្បីយ... មិនមានរឿងអ្វីកើតឡើងឡើយ។ ពួកគេមិនបាននិយាយអ្វីឡើយពីព្រោះស្ថានភាពមិនសូវតានតឹងឡើយនៅពេលដំបូង... បន្ទាប់មកទៀត យើងមិនអាចបដិសេធបានទៀតឡើយ... ក្នុងចិត្តរបស់ខ្ញុំ ខ្ញុំមានការខឹងសម្បារ នៅពេលដែលត្រូវបានបង្ខំឱ្យរៀបការនៅពេលនោះ...យើងមិនសប្បាយចិត្តឡើយ។*

\- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរឥស្លាម

ជាការត្រឹមត្រូវណាស់ដែលអ្នកផ្តល់បទសម្ភាសមានភាពភ័យខ្លាច ដោយសារពួកគេនឹងជួបផលវិបាកដ៏ធ្ងន់ធ្ងរ ប្រសិនបើពួកគេបដិសេធមិនរៀបការ។ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសជាជនជាតិភាគតិចចំនួន៤២នាក់ ដែលបដិសេធមិនរៀបការក្នុងពេលដំបូង មាន៣៥នាក់ត្រូវបានគំរាមកំហែង ឬ ដាក់ទណ្ឌកម្មតាមមធ្យោបាយមួយចំនួន។ ប្រជាជនត្រូវបានគំរាមកំហែងឱ្យផ្លាស់ប្តូរទៅរស់នៅក្នុងទីកន្លែងមានគ្រោះថ្នាក់ជាងមុន ឱ្យបំពេញការងារលំបាកជាងមុន យកទៅកសាង[95] ឬសម្លាប់ពួកគេ និង/ឬសមាជិកគ្រួសារពួកគេ ដូចក្នុងករណីខាងក្រោមនេះ ៖

*នៅពេលខ្ញុំកំពុងស្ទូងស្រូវ វា [កម្មាភិបាលខ្មែរក្រហម និងទាហានរបស់វា] បានមករកខ្ញុំ និងបង្ខំខ្ញុំឱ្យរៀបការ។ ដំបូង ខ្ញុំបដិសេធមិនរៀបការ ដោយប្រាប់ថា ខ្ញុំនៅក្មេងពេក ខ្ញុំមិនទាន់ចង់រៀបការទេ។ នៅពេលអង្គការដឹងរឿងនេះ ពួកគេបានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំនៅតែបដិសេធមិនរៀបការ ឪពុកម្តាយ និងខ្ញុំនឹងត្រូវយកទៅសម្លាប់ចោល។ ដោយសារខ្ញុំភ័យខ្លាច ចុងក្រោយ ខ្ញុំបានសម្រេចចិត្តរៀបការ។*

\- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ក្នុង១០ករណី អ្នកផ្តល់បទសម្ភាសត្រូវបានធ្វើទារុណកម្មដោយសារការបដិសេធមិនរៀបការ។ ក្នុងករណីខាងក្រោម ប្តីរបស់ស្ត្រីម្នាក់ដែលខ្មែរក្រហមទើបបង្ខំឱ្យរៀបការត្រូវបានសម្លាប់ចោល។ នៅពេលនាងបដិសេធមិនរៀបការ នាងត្រូវបានឃុំឃាំង និងធ្វើទារុណកម្ម ៖

[95] ការកសាងគឺជាការដាក់ទណ្ឌកម្មរបស់ខ្មែរក្រហម ដែលរួមមានចាប់ពីការស្តីបន្ទោសរហូតដល់សម្លាប់។

*ប្ដីរបស់ខ្ញុំត្រូវបានសម្លាប់ ហើយខ្ញុំទើបតែឆ្លងទន្លេរួច... ខ្ញុំត្រូវបានបង្ខំឱ្យរៀបការ ដូច្នេះ ខ្ញុំបានអង្វរករសុំមិនរៀបការ... ខ្ញុំត្រូវបានដាក់ទណ្ឌកម្មនៅមន្ទីរឃុំឃាំង។ ពួកគេឃុំឃាំង និងព្រមានខ្ញុំ... ខ្ញុំត្រូវបានគេធ្វើទារុណកម្មម្ដងហើយម្ដងទៀត។ ពួកគេបានប្រព្រឹត្តអំពើឃោរឃៅមកលើរូបខ្ញុំ ប៉ុន្តែខ្ញុំនៅតែបដិសេធមិនរៀបការ ហើយខ្ញុំបានព្យាយាមទ្រាំទ្រនឹងភាពឈឺចាប់ទាំងអស់... បន្ទាប់មកខ្ញុំត្រូវបានដោះលែងវិញមួយ ឬ ពីរថ្ងៃបន្ទាប់... បន្ទាប់ពីពេលនោះមកប្រទេសយើងត្រូវបានរំដោះហើយខ្ញុំមានសេរីភាពឡើងវិញ។*

- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ក្នុងចំណោមអ្នកផ្ដល់បទសម្ភាសជនជាតិភាគតិច៣៥នាក់ ដែលត្រូវបានគំរាមកំហែង ឬ ទទួលទណ្ឌកម្មដោយការបដិសេធមិនរៀបការក្នុងពេលដំបូង មាន២២នាក់ចុងក្រោយបានរៀបការជាមួយប្ដីប្រពន្ធដែលរៀបចំឱ្យសម្រាប់ពួកគេ។

## ៤.២.២ ការរៀបចំពិធីរៀបការ

ក្នុងការរៀបការទាំងអស់ ប៉ុន្តែមានករណីរៀបការមួយដែលរៀបរាប់ដោយអ្នកផ្ដល់បទសម្ភាសជនជាតិភាគតិច ដែលការរៀបការចាត់ចែង និងរៀបចំដោយខ្មែរក្រហមជាជាងសាមីខ្លួន ដែលត្រូវរៀបការបានបង្ហាញថា ការរៀបការដោយបង្ខំជាការអនុវត្តរបស់របបនេះ។ ក្នុងករណីពិសេសមួយមានគ្រួសាររបស់អ្នកផ្ដល់ បទសម្ភាសបានរៀបចំពិធីរៀបការជាមួយគ្រួសារជន្លងរបស់ខ្លួន។ មិនមានករណីណាបង្ហាញថា បំណងរបស់បុគ្គលសាមីខ្លួនត្រូវបានយកមកពិចារណាក្នុងការជ្រើសរើសដៃគូសម្រាប់រៀបការឡើយ។ តាមរយៈការរៀបរាប់របស់អ្នកផ្ដល់បទសម្ភាសបង្ហាញថា ជាទូទៅប្រជាជនដែលត្រូវបានខ្មែរក្រហមបង្ខំឱ្យរៀបការហាក់ដូចជាមិនស្រឡាញ់ និងចូលចិត្តគ្នាឡើយ ឬក្នុងករណីជាច្រើន ពួកគេមិនដែលជួបគ្នាពីមុនមកឡើយ។

អ្នកផ្ដល់បទសម្ភាសជាច្រើន មិនត្រូវបានជូនដំណឹងសូម្បីតែបន្តិចអំពីការត្រូវរៀបការឆាប់ៗរបស់ខ្លួន។ ពេលខ្លះ ពួកគេទទួលបានដំណឹងមួយសប្ដាហ៍ មុន ពេលខ្លះ មួយ ឬ ពីរថ្ងៃមុន។ ក្នុងករណីមួយចំនួន អ្នកផ្ដល់បទសម្ភាសត្រូវបានហៅឱ្យចូលរួមប្រជុំនៅចុងថ្ងៃធ្វើការ ដែលក្នុងពេលនោះពួកគេត្រូវបានបង្ខំឱ្យរៀបការ។ ស្ត្រីម្នាក់បានរំឭកអំពីភាពតក់ស្លុតរបស់នាងដែលត្រូវបានបង្ខំឱ្យរៀបការបែបនេះដោយមិនបានជូនដំណឹងជាមុន ៖

*ខ្ញុំមិនបានដឹងអំពីការរៀបការឡើយ។ ពួកគេមិនបានប្រាប់ខ្ញុំជាមុនអំពីការរៀបការនេះឡើយ... ពួកគេគ្រាន់តែហៅប្រជាជនចំនួន២០ ទៅ ៣០នាក់... ដំបូង ពួកគេឱ្យយើងឈរ និងឱ្យយើងនិយាយពីរបីម៉ាត់ក្នុងកិច្ចប្រជុំ ហើយពួកគេបានប្រាប់យើងឱ្យកាន់ដៃគ្នា។ ពួកគេឱ្យយើងនិយាយ*

# លទ្ធផលរកឃើញ

*ពីរបីម៉ាត់ ដើម្បីធ្វើការប្តេជ្ញាចិត្តក្នុងការរៀបការ ដូច្នេះ ពួកយើងបានដឹងថា ពួកគេឱ្យយើងរៀបការជាមួយគ្នា។ បន្ទាប់ពីរៀបការរួច ប្រជាជនជាច្រើនបានសម្លាប់ខ្លួន ដោយការចងក និងប្រជាជនមួយចំនួនបានរត់គេចដោយសារតែភាពស្មុគស្មាញ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ស្ត្រីពីរនាក់បានរៀបរាប់អំពីការរៀបការដោយបង្ខំក្រោមការភ្ជង់កាណុងកាំភ្លើង និងភាពភ័យខ្លាចរបស់ពួកគេ ៖

*ខ្ញុំភ័យខ្លាច នៅពេលធ្វើការប្តេជ្ញាចិត្ត។ ខ្ញុំបានអានតាមអក្សរដែលសរសេរឱ្យ។ ចុងកាំភ្លើងបានភ្ជង់លើរូបយើងមុនពេលធ្វើការប្តេជ្ញាចិត្ត... ពួកគេបានប្រាប់យើងអំពីអ្វីដែលយើងត្រូវនិយាយក្នុងពេលធ្វើការប្តេជ្ញាចិត្ត។ ដូច្នេះ យើងថាតាមដូចអ្វីដែលពួកគេបានប្រាប់យើង ដើម្បីរស់រានមានជីវិតប៉ុណ្ណោះ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

*ខ្ញុំភ័យខ្លាចយ៉ាងខ្លាំង ពីព្រោះពួកគេមានកាំភ្លើងក្នុងដៃ នៅពេលមកចូលរួមការរៀបការរបស់យើងនាពេលនោះ។ ពួកគេមកក្នុងគោលបំណងគំរាមកំហែងយើង។ ខ្ញុំពិតជាភ័យខ្លាចណាស់នាពេលនោះ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

អ្នកផ្តល់បទសម្ភាសមានភាពភ្ញាក់ផ្អើលប្រហាក់ប្រហែលគ្នាសម្រាប់ដំណឹងរៀបការរបស់ខ្លួន។ ជាធម្មតា ពិធីរៀបការមានរយៈពេលខ្លីមែនទែន និងមិនមានកម្មវិធីអ្វីឡើយ។ បុរស និងស្ត្រីត្រូវបានហៅមកក្នុង ឬ ពេលខ្លះនៅក្រៅរោងប្រជុំ។ ពួកគេត្រូវបានចាប់ជាគូ ហើយគូនីមួយៗត្រូវធ្វើ "ការប្តេជ្ញា" ថា ពួកគេប្តេជ្ញាចិត្តជាមួយគ្នា និងខំប្រឹងធ្វើការដើម្បីអង្គការ។ ពិធីរៀបការនេះត្រូវបានគ្រប់គ្រងដោយកម្មាភិបាលខ្មែរក្រហម។ប្រជាជនចាប់ពីបី ឬ បួនគូរហូតដល់រាប់រយគូមកពីគ្រប់ទីកន្លែងបានរៀបការជាមួយគ្នាក្នុងពេលតែមួយ។ ជាញឹកញាប់ ពិធីរៀបការត្រូវបានរៀបចំឡើងនៅពេលយប់ បន្ទាប់ពីធ្វើការនាពេលថ្ងៃរួច។ ប្រជាជនជាច្រើនដែលត្រូវរៀបការមានតែសម្លៀកបំពាក់គត្រិចសម្រាប់ស្លៀកពាក់។ នៅពេលមានស្ត្រីពីរនាក់ប្រាប់ថា ពួកគេទទួលបានមាន់ និងទាជាអាហារនៅពេលរៀបការ (មួយឱ្យទៅទាហានម្នាក់) អ្នកផ្តល់បទសម្ភាសផ្សេងទៀតនិយាយថា ពួកគេមិនទទួលបានអាហារអ្វីឡើយ ឬ គ្រាន់តែអាហារធម្មតាប៉ុណ្ណោះ។ ក្នុងគ្រប់ករណីរៀបការទាំងអស់ មិនមានគ្រួសារចូលរួមឡើយ លើកលែងតែមួយករណីប៉ុណ្ណោះ។ អ្នកផ្តល់បទសម្ភាសជាច្រើនមានការអាក់អន់ចិត្តជាខ្លាំង។ ជាញឹកញាប់ កម្មាភិបាលចូលរួមក្នុងការរៀបការ និងពេលខ្លះមានកម្មាភិបាល

ច្រើននាក់ចូលរួម។ នៅពេលពិធីរៀបការបាបញ្ចប់ ប្តីប្រពន្ធទើបរៀបការហើយត្រូវបានបញ្ជូនឱ្យទៅផ្ទះ។

រឿងរ៉ាវខាងក្រោមរបស់ស្ត្រីពីរនាក់ គឺមានក្ខណៈដូចគ្នានឹងការរៀបរាប់របស់អ្នកផ្តល់បទសម្ភាសអំពីពីធីរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖

*[សម្រាប់] ពិធីរៀបការ - មិនមានការរៀបចំពិសេសអ្វីឡើយ។ ឧទាហរណ៍ ក្នុងរយៈពេលមួយថ្ងៃ ពួកគេហៅប្រជាជនចំនួន២០ ឬ ៣០គូមកធ្វើការប្តេជ្ញាចិត្តជាមួយគ្នា។ ពួកគេបានឱ្យយើងអង្គុយចុះទល់មុខគ្នាជាពីរក្រុម៖ មួយក្រុមជាបុរសនិងមួយក្រុមទៀតជាស្ត្រី។ពួកគេឱ្យយើងប្តេជ្ញាចិត្តជាមួយគ្នា៖ "ខ្ញុំសន្យាយកសមមិត្តនេះជាប្តីប្រពន្ធរៀងរហូតទៅ និងខិតខំធ្វើបង្កបង្កើនផល"។ បន្ទាប់មក អ្នកទាំងអស់គ្នាទះដៃ ហើយពិធីរៀបការក៏បានបញ្ចប់។ មានកម្មាភិបាលខ្មែរក្រហមពីរ ឬ បីនាក់ចូលរួមក្នុងពិធីរៀបការនេះ។ ពួកគេឱ្យយើងអង្គុយចុះក្នុងតុដែលយើងនឹងត្រូវញ៉ាំអាហារដូចគូនសិស្ស។ ពួកគេឱ្យយើងអង្គុយចុះជិតដៃគូរបស់យើងរួចធ្វើការប្តេជ្ញា។ មិនមានអាហារអ្វីផ្តល់ជូនឡើយ សូម្បីតែឪពុកម្តាយយើងក៏មិនបានចូលរួមដែរ។ មិនមានអ្នកភូមិចូលរួមឡើយក្រៅពីដៃគូជាប្តីប្រពន្ធ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

*ហើយក្នុងពេលព្រឹក ខ្ញុំទទួលបានក្រមាថ្មី និងសម្លៀកបំពាក់ពណ៌ខ្មៅថ្មីមួយសម្រាប់សម្រាប់ពិធីរៀបការនេះ។ មានប្តីប្រពន្ធប្រហែលជា៣០០គូរៀបការក្នុងពេលតែមួយជាមួយគ្នា។ ខ្ញុំបានជួបមនុស្សជាច្រើននៅកន្លែងរៀបការ ហើយខ្ញុំមានអារម្មណ៍អាណិតខ្លួនឯងខ្លាំងណាស់។ ពួកគេរង់ចាំដល់វេនរបស់ខ្លួនក្នុងការប្តេជ្ញា។ ប្តីប្រពន្ធមួយគូៗបានធ្វើការប្តេជ្ញាម្តងមួយគូៗរហូតដល់ពេលព្រឹកព្រលឹម ហើយក្នុងពិធីរៀបការមិនការផ្តល់អាហារឡើយ គឺមានតែនំគមប៉ុណ្ណោះ [នំម៉្សាងធ្វើពីអង្ករតំណើប]។ ពិធីរៀបការរៀបចំឡើងក្នុងទីវាលចាប់ពីពេលរសៀលរហូតដល់យប់ជ្រៅ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

ការរៀបការបែបនេះ គឺមានភាពខុសគ្នាខ្លាំងពីប្រពៃណីរៀបការរបស់ខ្មែរ ដែលជាធម្មតាមានរយៈពេលពីរទៅបីថ្ងៃ និងការចូលរួមពីគ្រួសារ និងមិត្តភក្តិ និងមានការរៀបចំពិធីសាសនា និងប្រពៃណីជាច្រើន និងជាចុងក្រោយមានពិធីពិសារភោជនាហារ។ អ្នកផ្តល់បទសម្ភាសជាច្រើនដែលត្រូវបានបង្ខំឱ្យរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានបង្ហាញពីការអាក់អន់ចិត្ត និងមិនសប្បាយចិត្ត ដោយពួកគេមិនបានរៀបការតាមប្រពៃណី។

## ៤.២.៣ ការបង្ខំឱ្យរួមភេទក្នុងចំណងអាពាហ៍ពិពាហ៍ និងការបំបែកក្លូន

ដោយសារគោលបំណងនៃការរៀបការដោយបង្ខំ គឺដើម្បីបង្កើតកូនសម្រាប់អង្គការ ប្ដីប្រពន្ធដែលទើបរៀបការ ភាគច្រើនត្រូវបានបង្ខំឱ្យរួមភេទដោយមានការឃ្លាំមើលពីខ្មែរក្រហម។

ក្នុងចំណោមអ្នកផ្ដល់បទសម្ភាសជនជាតិភាគតិច៤០នាក់ ដែលបានរៀបការនៅពេលខ្មែរក្រហមបង្ខំឱ្យរៀបការដំបូង មាន៣៦នាក់បាននិយាយថា ពួកគេមានអារម្មណ៍ថាខ្លួនត្រូវបានបង្ខំឱ្យរួមភេទ ពីព្រោះកម្មាភិបាលខ្មែរក្រហមដែលយាមល្បាតក្នុងតំបន់ស្នាក់នៅរបស់ខ្លួនក្នុងពេលយប់បានឃ្លាំមើលយើង។ ប្ដីប្រពន្ធមួយចំនួនត្រូវបានខ្មែរក្រហមគំរាមកំហែង ប្រសិនបើពួកគេមិនរួមភេទជាមួយគ្នា។ រឿងរ៉ាវខាងក្រោមគឺជារឿងរបស់បុរសម្នាក់ដែលត្រូវបានគំរាមកំហែងដោយសារការមិនរួមភេទ បន្ទាប់ពីការរៀបការដោយបង្ខំរួច។ រឿងនេះមានលក្ខណៈដូចគ្នានឹងរឿងរ៉ាវរបស់អ្នកផ្ដល់បទសម្ភាស៖

> *ទាហានខ្មែរក្រហមបានឃ្លាំមើលយើងដោយសម្ងាត់។ ប្រសិនបើយើងមិនរួមភេទជាមួយគ្នាពេលព្រឹកឡើង ពួកគេនឹងហៅយើងទៅប្រជុំកសាង [ការប្រជុំកសាង] ចំនួនបីដង។ ប្រសិនបើពួកយើងនៅតែមិនរួមភេទជាមួយគ្នាទៀត យើងនឹងត្រូវសម្លាប់ចោល។ ប្ដីប្រពន្ធជាច្រើនគូត្រូវបានសម្លាប់...*
>
> - អ្នកផ្ដល់បទសម្ភាសជាបុរសខ្មែរក្រោម

ស្ត្រីមួយចំនួនក៏ត្រូវបានប្ដីថ្មីរបស់ខ្លួនគំរាមកំហែង ឬ បង្ខំរួមភេទជាមួយដែរ។ ស្ត្រីម្នាក់បានរៀបរាប់ពីការគំរាមកំហែងរបស់ប្ដីគាត់ក្នុងការប្រាប់ទៅខ្មែរក្រហម ប្រសិនបើនាងមិនរួមភេទជាមួយ៖

> *ប្ដីរបស់ខ្ញុំបានបង្ខំខ្ញុំឱ្យរួមភេទជាមួយគាត់ ដោយនិយាយគំរាមថា ប្រសិនបើខ្ញុំមិនព្រមរួមភេទជាមួយគាត់ទេគាត់នឹងប្រាប់អង្គការដែលជាប្រធានអង្គភាព។*
>
> - អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ទាំងបុរស និងស្ត្រីដែលត្រូវបានបង្ខំឱ្យរួមភេទបន្ទាប់ពីការរៀបការដោយបង្ខំ បានរៀបរាប់ថា នេះគឺជាបទពិសោធន៍ដ៏ឈឺចាប់ដែលខ្លួនបានឆ្លងកាត់។

ទោះបីយ៉ាងណា មិនមែនប្រជាជនគ្រប់គ្នាសុទ្ធតែបានរួមភេទជាមួយប្ដីប្រពន្ធថ្មីរបស់ខ្លួនឡើយ។ ដោយមានការព្រមព្រៀងជាមួយគ្នា ប្ដីប្រពន្ធមួយចំនួនធ្វើពុតជារួមភេទជាមួយគ្នា ដើម្បីបន្លំភ្នែកអាជ្ញាធរខ្មែរក្រហម។ ខាងក្រោមគឺជារឿងរ៉ាវរបស់ស្ត្រីពីរនាក់ ដែលលើកឡើងអំពីការបំភ័ន្តភ្នែកខ្មែរក្រហមជាមួយប្ដីរបស់ខ្លួន៖

*យើងត្រូវបានគេឃ្លាំមើល [បន្ទាប់ពីបានដឹងថាមានអ្នកឃ្លាំមើល] ថាយើងបានរួមភេទជាមួយគ្នាដែរឬទេ? យើងធ្វើពុតជារួមភេទជាមួយគ្នា ដើម្បីឱ្យពួកគេគិតថាយើងបានរួមភេទប៉ុន្តែយើងគ្រាន់តែចាត់ទុកគ្នាជាបងប្អូនប៉ុណ្ណោះ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

*ខ្ញុំដឹងថា ពួកគេបានតាមដានខ្ញុំ ប៉ុន្តែពួកគេមិនបង្កបញ្ហាដល់យើងឡើយ។ យើងគ្រាន់តែធ្វើពុតជា [រួមភេទ] ជាមួយគ្នាអស់រយៈពេលជាច្រើនខែ ប៉ុន្តែការពិតវាគ្រាន់តែជាការបន្លំភ្នែកប៉ុណ្ណោះ។*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរក្រោម

សម្រាប់ប្តីប្រពន្ធមួយចំនួន ពួកគេចាំបាច់ធ្វើពុតជារួមភេទក្លែងក្លាយជាមួយគ្នាតែក្នុងមួយរយៈពេលដំបូង បន្ទាប់ពីរៀបការហើយប៉ុណ្ណោះ។ បន្ទាប់មកទៀត ប្តីប្រពន្ធមួយចំនួនរស់នៅបែកពីគ្នា និងអនុញ្ញាតឱ្យជួបគ្នាជារៀងរាល់ពីរខែម្តង។ បុរសម្នាក់បានរៀបរាប់អំពីការរៀបចំសម្រាប់គាត់និង ប្រពន្ធគាត់ ៖

*យើងរស់នៅជាមួយគ្នាម្តងម្កាលប៉ុណ្ណោះ បន្ទាប់ពីរៀបការរួច។ យើងរវល់ធ្វើការងារ។ យើងជួបគ្នារៀងរាល់ពីរខែម្តង។*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរឥស្លាម

ក្នុងករណីមួយចំនួន ប្តីប្រពន្ធដែលត្រូវបានបង្ខំឱ្យរៀបការ ជាចុងក្រោយ ស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះគ្នា៖ ឧទាហរណ៍ ស្ត្រីម្នាក់បាននិយាយអំពីសេចក្តីស្រឡាញ់ចំពោះប្តីរបស់ខ្លួនបន្ទាប់ពីការរៀបការដោយបង្ខំ។ ប្តីប្រពន្ធនេះមានកូន និងនៅតែរស់នៅជាមួយគ្នារហូតមកដល់ពេលសព្វថ្ងៃនេះ។

*ក្នុងករណីរបស់ខ្ញុំ បន្ទាប់ពីពិធីរៀបការ យើងមិនបានរួមភេទជាមួយគ្នាទេ ប៉ុន្តែយើងធ្វើពុតជារួមភេទជាមួយគ្នា ដើម្បីកុំឱ្យខ្មែរក្រហមសង្ស័យយើង។ ប៉ុន្តែបន្ទាប់មក យើងបានស្រឡាញ់គ្នានិងបានគេងជាមួយគ្នាពិតប្រាកដ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ក្នុងចំណោមអ្នកផ្តល់បទសម្ភាសជាជនជាតិភាគតិច៤០នាក់ ដែលបានរៀបការជាមួយគ្នានៅពេលបង្ខំឱ្យរៀបការក្នុងពេលដំបូង មាន២៩នាក់មានកូនជាមួយគ្នា ទាំងក្នុង ឬ ក្រោយរបបនេះ។

## លទ្ធផលរកឃើញ

ការដួលរំលំរបបខ្មែរក្រហម គឺជាការផ្តល់ឱកាសមួយដល់ប្តីប្រពន្ធដែលមិនពេញចិត្តគ្នាដើម្បីរស់នៅបែកគ្នា។ ការសម្រេចចិត្តក្នុងការបន្តរស់នៅ ឬ បែកគ្នាគឺមានភាពស្មុគស្មាញណាស់ ប្រសិនបើពួកគេមានកូនជាមួយគ្នា និងប្រសិនបើប្តីប្រពន្ធមានភាពក្រីក្រ ឬ បាត់បង់សមាជិកគ្រួសារ ឬមិនមានមធ្យោបាយផ្សេងទៀតក្នុងការផ្គត់ផ្គង់ជីវិតខ្លួន[៩៦]។ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសជាជនជាតិភាគតិច៤០នាក់ ដែលបានរៀបការជាមួយគ្នានៅពេលបង្ខំឱ្យរៀបការក្នុងពេលដំបូង មាន២៦នាក់បន្តរស់នៅជាមួយគ្នាបន្ទាប់ពីការដួលរំលំរបបនេះ។ ក្នុងចំណោមប្តីប្រពន្ធបន្តរស់នៅជាមួយគ្នា មាន២៣នាក់មានកូនជាមួយគ្នា។

បុរសម្នាក់បានរៀបរាប់អំពីអារម្មណ៍របស់គាត់ដែលសម្រេចចិត្តបន្តរស់នៅជាមួយប្រពន្ធគាត់ បន្ទាប់ពីរបបខ្មែរក្រហមដួលរំលំ ទោះបីជាគាត់មិនពេញចិត្តនឹងចំណងអាពាហ៍ពិពាហ៍គាត់ក៏ដោយ៖

> *ខ្ញុំត្រូវបានបង្ខំឱ្យរៀបការបានបីខែ បន្ទាប់ពីកងទ័ពវៀតណាមជួយរំដោះប្រទេស... [ទេ] មិនមាននរណាម្នាក់ហ៊ានបដិសេធឡើយ។ ប្រសិនបើយើងបដិសេធមិនរៀបការ យើងនឹងត្រូវស្លាប់... បន្ទាប់ពីរៀបការ ខ្ញុំដឹងថា កងឈ្លបបានឃ្លាំមើលយើងនៅពេលយប់។ ប្រសិនបើយើងមិនរួមភេទជាមួយគ្នា យើងនឹងត្រូវសម្លាប់...ខ្ញុំមិនស្រឡាញ់ប្រពន្ធខ្ញុំឡើយ។ ខ្ញុំបានទៅរស់នៅក្នុងជំរំថ្មី បន្ទាប់ពីកងទ័ពវៀតណាមរំដោះប្រទេស។ ខ្ញុំបានគិតថា ខ្ញុំចង់បោះបង់ប្រពន្ធខ្ញុំចោល ប៉ុន្តែខ្ញុំបានគិតយ៉ាងល្អិតល្អន់ថា ខ្ញុំបានរៀបការជាមួយនាងហើយ។ ខ្ញុំមិនអាចចាកចេញដោយទុកឱ្យនាងនៅតែឯងឡើយ។ នាងជាជនពិការ ហើយឪពុកម្តាយនាងបានស្លាប់ចោលអស់ហើយ ដូច្នេះ នាងគ្មានអ្នកជួយផ្គត់ផ្គង់ឡើយ។ ខ្ញុំមិនអាចរត់ចោលនាងឡើយ។ ខ្ញុំបានត្រឡប់មកផ្ទះវិញ ...*
>
> - អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរក្រោម

អ្នកផ្តល់បទសម្ភាសប្រាំមួយនាក់ បានរស់បែកពីប្តីប្រពន្ធខ្លួន បន្ទាប់ពីការដួលរំលំរបបនេះ ទោះបីជាមានកូនជាមួយគ្នាក៏ដោយ។ ក្នុងករណីខាងក្រោម ស្ត្រីពីរនាក់រៀបរាប់អំពីការចិញ្ចឹមបីបាច់កូនតែម្នាក់ឯង បន្ទាប់ពីការរស់នៅបែកគ្នា៖

> *បន្ទាប់ពីយើងមានកូនអាយុបីខែជាមួយគ្នា យើងបានរស់នៅបែកគ្នា។ ខ្ញុំមានកូនតែមួយគត់... [បន្ទាប់ពីប្រទេសត្រូវបានរំដោះមក] ប្តីរបស់ខ្ញុំមានមិត្តស្រី ដូច្នេះ គាត់បានវិលត្រឡប់ទៅរកនាងវិញ។*
>
> - អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

---

[96] សម្រាប់ការពិភាក្សាអំពីមូលហេតុប្តីប្រពន្ធដែលរៀបការដោយបង្ខំបន្តរស់នៅជាមួយគ្នា សូមមើល Levine, op. cit.

*ប្រាំទៅប្រាំមួយថ្ងៃបន្ទាប់ពីយើងរៀបការ យើងយល់ព្រមរួមភេទជាមួយគ្នា... ខ្ញុំមានកូនម្នាក់... អូហ! ខ្ញុំបានរស់នៅបែកគ្នាពីប្តីរបស់ខ្ញុំរហូតមកដល់ឥឡូវនេះ ចាប់តាំងពីកងទ័ពវៀតណាមបានចូលមកប្រទេស។ ខ្ញុំបានចិញ្ចឹមកូនខ្ញុំរហូតមកដល់ពេលឥឡូវនេះ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

## ៤.៣ ការរំលោភសេពសន្ថវៈ



ការសិក្សាស្រាវជ្រាវនេះបានធ្វើការស៊ើបអង្កេតថាតើជនជាតិភាគតិចទទួលរងការរំលោភសេពសន្ថវៈក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? និងតើពួកគេត្រូវបានកំណត់ជាគោលដៅនៃការរំលោភសេពសន្ថវៈ ដោយសារតែជាតិសាសន៍របស់ខ្លួនមែនដែរឬទេ? និយមន័យនៃការរំលោភសេពសន្ថវៈត្រូវបានកំណត់ដូចខាងក្រោម៖

*ជនល្មើសបានបំពានលើរាងកាយរបស់បុគ្គលម្នាក់ដោយបញ្ចូលអង្គជាតិទៅក្នុងផ្នែកណាមួយនៃរាងកាយរបស់ជនរងគ្រោះ ឬ ជនល្មើស ទោះបីជាមិនជ្រៅ ឬបញ្ចូលវត្ថុអ្វីមួយទៅក្នុងអវយវៈភេទ រន្ធគូទ ឬ រន្ធភេទរបស់ជនរងគ្រោះ ឬ ផ្នែកផ្សេងទៀតនៃរាងកាយ[97]។*

*ការបំពានលើរាងកាយធ្វើឡើងដោយការបង្ខំ ឬ ដោយការគំរាមកំហែង ឬ បញ្ចុះបញ្ចូលដោយបង្ខំ ដូចជា បង្កឱ្យមានភាពភ័យខ្លាចនឹងអំពើហិង្សា ការបង្ខិតបង្ខំ ការឃុំឃាំង ការគៀបសង្កត់ផ្លូវចិត្ត ឬ ការរំលោភបំពានសិទ្ធិអំណាចជនរងគ្រោះ ឬ មនុស្សផ្សេងទៀត ឬ ការទាញផលប្រយោជន៍ពីបរិយាកាសបង្ខិតបង្ខំ ឬ ការបំពានលើបុគ្គលដែលមិនអាចផ្តល់ការព្រមព្រៀងពិតប្រាកដ[98]។*

រូបភាពដែលបានមកពីទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះ បង្ហាញពីករណីរំលោភសេពសន្ថវៈនៅគ្រប់ទីកន្លែងលើស្ត្រី និងកុមារី ដែលប្រព្រឹត្តដោយបុរសកម្មាភិបាលខ្មែរក្រហមយ៉ាងច្រើនលើសលុប ដែលជាញឹកញាប់ គឺការរំលោភជាក្រុម។ ក្នុងករណីភាគច្រើន ជនរងគ្រោះត្រូវបានសម្លាប់បន្ទាប់

[97] មាត្រា ៧(១)(g)-១(១) ឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិនៃការរំលោភសេពសន្ថវៈ ធាតុផ្សំនៃបទឧក្រិដ្ឋ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ បានមើលនាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ <http://www.icc-cpi.int/NR/rdonlyres/336923D8-A6AD-40EC-AD7B-45BF9DE73D56/0/ElementsOfCrimesEng.pdf>

[98] មាត្រា ៧(១)(g)- ១(១) *ibid*

## លទ្ធផលរកឃើញ

ពីរំលោភរួច និងក្នុងករណីមួយចំនួន ជនល្មើសបានកាត់ផ្ដាច់សាកសពជនរងគ្រោះទាំងមុន ឬបន្ទាប់ពីការសម្លាប់។ ក្នុងបរិយាកាសបែបនេះ ធ្វើឱ្យស្ត្រី និងកុមារីជនជាតិភាគតិចមានភាពភ័យខ្លាចយ៉ាងខ្លាំងថាខ្លួននឹងត្រូវបានរំលោភ និងសម្លាប់គ្រប់ពេលវេលាដោយកម្មាភិបាលខ្មែរក្រហម។

ច្រើនជាងពីរភាគបីនៃអ្នកផ្ដល់បទសម្ភាស១០៥នាក់ក្នុងការសិក្សាស្រាវជ្រាវនេះ បានឃើញ ឬ ឮអំពីការរំលោភសេពសន្ថវៈដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកដែលទទួលរងការរំលោភសេពសន្ថវៈជាច្រើនដែលជាជនជាតិភាគតិចមានដូចជា ជាតិសាសន៍ដទៃទៀត៣៤នាក់ ខ្មែរក្រោម២៥នាក់ ជនជាតិភាគតិចវៀតណាម១៤នាក់ ខ្មែរឥស្លាម១៤នាក់ ចាម៣នាក់ (សូមមើលរូបលេខ៤)[99]។

ចំណុចពិសេសពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈលើជនជាតិភាគតិច អ្នកផ្ដល់បទសម្ភាសត្រូវបានសួរអំពីអ្វីដែលពួកគេបានដឹងអំពីជនល្មើស និង ជនរងគ្រោះ។

អ្នកផ្ដល់បទសម្ភាសទាំងអស់បានលើកឡើងថា កម្មាភិបាលខ្មែរក្រហមជាជនល្មើស ក្នុងករណីដែលពួកគេបានឃើញ ឬ ឮអំពីការរំលោភសេពសន្ថវៈ ហើយមានតែមួយករណីប៉ុណ្ណោះដែលជនល្មើសជាប្រជាជនស៊ីវិល។ នៅពេលអ្នកផ្ដល់បទសម្ភាសដឹងអំពីភេទរបស់ជនល្មើស ពួកគេបានលើកឡើងថា ជនល្មើសជាស្ត្រីមានតែពីរនាក់ប៉ុណ្ណោះ ក្រៅពីនេះគឺជាបុរស។ នៅពេលអ្នកផ្ដល់បទសម្ភាសអាចប៉ាន់ស្មានអាយុរបស់ជនល្មើស ជនល្មើសភាគច្រើនគឺជាបុរសដែលមានអាយុចន្លោះចាប់ពីម្ភៃឆ្នាំ ឬ ចាស់ជាងនេះ។ ក្នុង៣៤ករណី តាមការប៉ាន់ស្មាន ជនល្មើសប្រហែលមានអាយុចន្លោះចាប់ពី១៨ និង៣០ឆ្នាំ និងក្នុង១៩ករណីផ្សេងទៀត ជនល្មើសមានអាយុលើសពី៣០ឆ្នាំ។ មានតែប្រាំពីរករណីប៉ុណ្ណោះដែលជនល្មើសមានអាយុក្រោម១៨ឆ្នាំ។

*រូបលេខ៤ បង្ហាញពីការរំលោភសេពសន្ថវៈលើជនរងគ្រោះជាជនជាតិភាគតិច*




---

[99] សម្រាប់ជនរងគ្រោះជនជាតិចាម និងវៀតណាម ដែលមានតួលេខទាបជាងគេទំនងជាឆ្លុះបញ្ចាំងឱ្យឃើញពីចំនួនអ្នកឆ្លើយតបមកពីក្រុមជនភាគតិច។ ចំណុចត្រង់នេះ គឺអ្នកផ្ដល់បទសម្ភាសបានរៀបរាប់អំពីការរំលោភសេពសន្ថវៈលើប្រជាជនជាក្រុមជនជាតិភាគតិចទាំងបួនក្រុម ក៏ដូចជា ការរំលោភសេពសន្ថវៈលើប្រជាជនដទៃទៀត។

ក្នុងចំណោមជនរងគ្រោះជាជនជាតិភាគតិច មានករណីតែមួយប៉ុណ្ណោះដែលជនរងគ្រោះជាបុរស។ ជនល្មើសកំណត់គោលដៅរំលោភសេពសន្ថវៈលើនារីវ័យក្មេង។ នៅពេលអ្នកផ្ដល់បទសម្ភាសអាចប៉ាន់ស្មានអាយុរបស់ជនរងគ្រោះ ក្នុង៣៤ករណីជនរងគ្រោះមានអាយុចន្លោះចាប់ពី១៨ឆ្នាំ ដល់៣០ឆ្នាំ និងក្នុង១៥ករណីផ្សេងទៀត ជនរងគ្រោះមានអាយុក្រោម១៨ឆ្នាំ។ ក្នុងប្រាំករណី តាមការប៉ាន់ស្មាន ជនរងគ្រោះមានអាយុលើសពី៣០ឆ្នាំ។

ទាក់ទងនឹងការរំលោភសេពន្ថវៈ មាន៣៧ករណីជាការរំលោភជាក្រុមដែលប្រព្រឹត្តដោយជនល្មើសច្រើននាក់លើស្ត្រីជនជាតិភាគតិច។ ជាធម្មតា ការរំលោភជាក្រុមនេះមានជនល្មើសជាបុរសចំនួន២ទៅ៦នាក់។ ជាញឹកញាប់ ជនល្មើសត្រូវបានកម្មាភិបាលខ្មែរក្រហមចាប់យកទៅកន្លែងឆ្ងាយ និងរំលោភក្នុង ឬ ខាងក្រោយអគារ ក្នុងព្រៃ ឬ វាលស្រែ។

ក្នុងពេលដែលមានជនរងគ្រោះតែម្នាក់ក្នុងករណីភាគច្រើននៃការរំលោភសេពសន្ថវៈលើជនជាតិភាគតិច មាន២២ករណីដែលជាការរំលោភទ្រង់ទ្រាយធំលើជនរងគ្រោះច្រើននាក់។ តាមការរៀបរាប់អំពីការរំលោភទ្រង់ទ្រាយធំរបស់អ្នកផ្ដល់បទសម្ភាសទាំងអស់ ជនរងគ្រោះត្រូវបានសម្លាប់។ អ្នកផ្ដល់បទសម្ភាសម្នាក់បានរៀបរាប់អំពីការរំលោភទ្រង់ទ្រាយធំលើក្មេងស្រីកូនកាត់ខ្មែរ-វៀតណាមស្រស់ស្អាតបីនាក់ ដែលមានអាយុប្រហែល១៧ឆ្នាំ ឬ ១៨ឆ្នាំ ដែលធ្វើការជាមួយនាងក្នុងអង្គភាពជាមួយគ្នា ៖

> *ពួកប៉ុលពតបានហៅពួកគេឱ្យទៅប្រជុំ។ បន្ទាប់ពីពួកគេបានទៅប្រជុំ ពួកគេមិនបានត្រឡប់មកវិញទេឡើយ។ ខ្ញុំដឹងថា ពួកខ្មែរក្រហមបានរំលោភពួកគេ ពីព្រោះខ្ញុំត្រូវបានចាត់តាំងឱ្យដើរយាមល្បាតក្នុងពេលយប់។ ជនល្មើសបានវិលត្រឡប់មកវិញ និងសួររកម្ហូបបរិភោគ។ ពួកជនល្មើសបានជជែកគ្នាអំពីការរំលោភនេះ។ ពួកជនល្មើសបាននិយាយថា នារីម្នាក់នោះមានសាច់សខ្ចី ហើយចុងសុដន់របស់នាងរឹង ហើយបាននិយាយអ្វីផ្សេងទៀតអំពីការរំលោភនេះ។ តាមរយៈការជជែកគ្នានេះ ខ្ញុំអាចដឹងថា ពួកនាងត្រូវបានរំលោភ និងសម្លាប់ចោល។ … [ជនល្មើស]គឺជាកម្មាភិបាលខ្មែរក្រហម។ជនល្មើសគឺជាពួកគេដែលមានអាយុប្រហែល២០ឆ្នាំ។*
>
> - អ្នកផ្ដល់បទសម្ភាសជាស្ត្រី (មានជាតិសាសន៍ផ្សេងទៀត)

អ្នកផ្ដល់បទសម្ភាសម្នាក់ទៀតបានរៀបរាប់អំពីការរំលោភទ្រង់ទ្រាយធំលើស្ត្រីវ័យក្មេងជនជាតិខ្មែរ និងវៀតណាម ដែលរស់នៅក្នុងអង្គភាពជាមួយនាង។ ជារៀងរាល់យប់ ស្ត្រីបួន ឬ ប្រាំនាក់ត្រូវបានកម្មាភិបាលខ្មែរក្រហមប្រាំ ឬ ប្រាំមួយនាក់នាំយកទៅរំលោភ និងសម្លាប់។ នាងបានដឹងរឿងនេះពីជនល្មើសម្នាក់ក្នុងចំណោមជនល្មើសទាំងនេះ។

## លទ្ធផលរកឃើញ

*ខ្មែរក្រហម [ម្នាក់] បានហៅខ្ញុំឱ្យទៅកន្លែងវា និងបានប្រាប់ខ្ញុំថា យប់នេះ វាត្រូវការស្ត្រីប្រាំនាក់ថែមទៀត ដើម្បី [សម្លាប់ចោល]។ វាបានបន្ថែមទៀតថា ខ្ញុំមិនគួរភ័យខ្លាចឡើយ ពីព្រោះខ្ញុំនឹងក្លាយជាជនរងគ្រោះដូចពួកគេដែរ។ វាបាននិយាយដែរថា មុននឹងវានាំនរណាមួយក្នុងចំណោមស្ត្រីទាំងនេះទៅសម្លាប់ចោល ស្ត្រីទាំងនេះតែងតែត្រូវបានរំលោភ។ វាបានប្រាប់រឿងរ៉ាវទាំងអស់ដល់ខ្ញុំបន្ទាប់ពីវានិងមិត្តរបស់វាបាននាំស្ត្រីប្រាំនាក់ទៅក្រៅដោយបង្ហាញថង់ប្រមាត់ប្រាំ [របស់ស្ត្រីទាំងនេះ] ដែលវានាំយកមកជាមួយ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រី (មានជាតិសាសន៍ផ្សេងទៀត)


*ការបញ្ចូលទិន្នន័យ*

ការសិក្សាស្រាវជ្រាវនេះ មិនបានសួរសំណួរជាក់លាក់អំពីការរំលោភដោយប្រើវត្ថុចម្លែក ប៉ុន្តែអ្នកផ្តល់បទសម្ភាសបួននាក់បានលើកឡើងដោយមិនច្បាស់លាស់អំពីទម្រង់អំពើហិង្សាផ្លូវភេទបែបនេះ ដែលកើតមានលើជនជាតិភាគតិចម្នាក់។ ក្នុងករណីទាំងបួន អ្នកផ្តល់បទសម្ភាសបានឃើញ សាកសពរបស់ស្ត្រីរងគ្រោះមានបន្ទះឈើឫស្សី ឬ មែកឈើនៅក្នុងយោនីរបស់ជនរងគ្រោះ។ ក្នុងករណីទាំងនេះ ជនរងគ្រោះបានស្លាប់បាត់ទៅហើយ មុនពេលអ្នកផ្តល់បទសម្ភាសមកដល់ឃើញសាកសព។ ក្នុងករណីមួយនៃការរំលោភដោយប្រើវត្ថុចម្លែក ជនរងគ្រោះនៅរស់នៅឡើយ។ ក្នុងករណីនេះ ស្ត្រីផ្តល់បទសម្ភាសបានឃើញកម្មាភិបាលខ្មែរក្រហមប្រើកាំបិត "លេង" ជាមួយ អវយវៈភេទរបស់ស្ត្រីរងគ្រោះមុនពេលសម្លាប់នាង។ ជនល្មើសដដែល ក៏បានកាត់អវយវៈភេទរបស់កុមារាម្នាក់ មុនពេលសម្លាប់កុមារនោះ។ ជនរងគ្រោះទាំងពីរគឺជាខ្មែរក្រោម។

អ្វីដែលសំខាន់ជាងនេះ ក្នុងករណីរំលោភសេពសន្ថវៈ ជនរងគ្រោះកម្រនឹងរួចផុតពីសេចក្តីស្លាប់ណាស់។ ក្នុង៩០ករណីនៃការរំលោភលើជនជាតិភាគតិច មានស្ត្រី២នាក់ស្លាប់ជាបន្តបន្ទាប់ដោយតែរបួស និងស្ត្រី២នាក់ទៀតបានបាត់ខ្លួន (ប្រហែលជាអាចត្រូវគេសម្លាប់ចោល)។ ប្រាំករណីគឺមិនច្បាស់លាស់ថាមានអ្វីកើតឡើងចំពោះជនរងគ្រោះបន្ទាប់ពីត្រូវបានរំលោភ។ ក្នុងករណីដំបូងនៃការរំលោភលើស្ត្រីចាម ប្តីរបស់នាងត្រូវបានសម្លាប់ចោលមុនៈ

*នៅពេលនោះ នាងបានធ្វើការនៅរោងតម្បាញក្នុងឆ្នាំ១៩៧៦ ដល់ ១៩៧៧។ នាងជាជនជាតិចាមមានរូបសម្បត្តិស្រស់ស្អាត។ នាង និងប្តីរបស់នាងមានវ័យក្មេង។ ពួកគេមិនមានកូនឡើយ។ គណៈកម្មាភិបាល [កម្មាភិបាលខ្មែរក្រហមនៃគណៈកម្មាធិការមួយ] ចង់បានរូបនាង នៅពេលវាបានឃើញនាង។ ប្តីរបស់នាងត្រូវបានយកទៅសម្លាប់។ បុរសបួននាក់បានរំលោភនាង... ហើយនាងត្រូវបានយកទៅសម្លាប់ចោល...[ជនល្មើស]ទាំងអស់សុទ្ធតែមានប្រពន្ធរៀងខ្លួន។ ពួកគេមានអាយុច្រើនជាង៣០ឆ្នាំ។*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរឥស្លាម

*តាមដែលខ្ញុំដឹង នាងស្រស់ស្អាតណាស់... នាងត្រូវបានសម្លាប់ ប៉ុន្តែមុនពេលស្លាប់ នាងត្រូវបានបុរសបីនាក់រំលោភ។ ខ្ញុំដឹងរឿងនេះតាមរយៈអ្នកដែលសម្លាប់នាង មិនមែនតាមអ្នកភូមិនិយាយឡើយ។ បន្ទាប់ពីសម្លាប់នាងរួច វាស្រវឹងស្រា និងបាននិយាយអំពីការសម្លាប់នេះថា... នាងត្រូវបានបុរសបីនាក់ចាប់ដាក់កង់យកទៅ។ ពួកគេបានយកនាងទៅក្នុងព្រៃនៅម្តុំនេះ... ចាស៎! អ្នកដែលសម្លាប់នាងបាននិយាយថា ស្ត្រីដែលពួកគេសម្លាប់មានស្បែកស្អាត។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីចាម រៀបរាប់អំពីការរំលោភ និងសម្លាប់មីងរបស់នាង

*ប្រធានអង្គភាពស្ត្រីបានហៅស្ត្រីស្រស់ស្អាតម្នាក់ ហើយកងឈ្លបបុរសបីនាក់ក៏បានចាប់ខ្លួននាង។ កងឈ្លបទាំងបីនាក់មានវ័យក្មេង អាយុប្រហែលជា [២០-៣០ឆ្នាំ]។ ពួកគេបាននាំនាងទៅទួលមួយក្បែររណ្តៅ ដើម្បីចាប់ត្រី។ នាងដឹងថា ពួកគេនឹងសម្លាប់នាង ដូច្នេះ នាងបានអង្វរករក្តីមេត្តា "កុំឱ្យសម្លាប់នាង"។ នាងបានប្រាប់ពួកគេថា សូមពួកលោកធ្វើអ្វីតាមចិត្តចុះ។ កងឈ្លបបានរំលោភនាងក្រោមដើមសង្កែ [ឈ្មោះដើមឈើមួយប្រភេទ] ក្នុងពេលភ្លៀង។ ពួកវាបានដោះសម្លៀកបំពាក់នាងចេញ និងបានរំលោភនាង។ ពួកវាមិនបានឱ្យនាងរួចខ្លួនឡើយ។ ពួកគេបានវាយនាងនឹងដំបងឈើ។ ពួកវាបានកប់នាងក្នុងរណ្តៅ...*

- អ្នកផ្តល់បទសម្ភាសជាបុរស (មានជាតិសាសន៍ផ្សេងទៀត) រៀបរាប់អំពីការរំលោភសេពសន្ថវៈ និងការសម្លាប់ស្ត្រីកូនកាត់ខ្មែរ-វៀតណាម ដែលប្រពន្ធរបស់គាត់បានឃើញករណីនេះ

## ៤.៤ ការរួមភេទដើម្បីរស់រានមានជីវិត

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការបែងចែកអាហារត្រូវបានគ្រប់គ្រងយ៉ាងតឹងរឹងដោយខ្មែរក្រហម ហើយអ្នកដែលទទួលបានអាហារក្រៅពីខ្មែរក្រហមផ្តល់ជូន (រួមទាំង ការស្វែងរកសត្វក្នុងព្រៃ ឬទន្លេជាអាហារ ឬ ការលួចអាហារ) ក៏អាចត្រូវដាក់ទណ្ឌកម្ម ឬ សម្លាប់ផងដែរ។ ប្រជាជនទូទៅទទួលបានអាហារតិចតួចសម្រាប់បរិភោគ។ ប្រជាជនភាគច្រើនទទួលរងការខ្វះខាតអាហារូបត្ថម្ភ និងប្រជាជន

## លទ្ធផលរកឃើញ

ជាច្រើនទៀតអត់ឃ្លានរហូតដល់ស្លាប់។ អ្នកផ្តល់បទសម្ភាសមួយចំនួនក្នុងការសិក្សាស្រាវជ្រាវនេះ បានរៀបរាប់អំពីភាពហេវហត់ និងអស់កម្លាំងដែលពួកគេជួបប្រទះក្នុងរបបនេះ។ ជាលទ្ធផល មនុស្សមួយចំនួនបានរួមភេទ ដើម្បីបានបាយហូប បានថ្នាំសង្កូវ ឬ បំពេញការងារងាយស្រួល ដែលទាំងនេះហៅថា ការរួមភេទដើម្បីរស់រានមានជីវិត។

*រូបលេខ៥ បង្ហាញពីការរួមភេទដើម្បីរស់រានមានជីវិតរបស់ជនជាតិភាគតិច*




មួយភាគបីនៃអ្នកផ្តល់បទសម្ភាស១០៥នាក់បាននិយាយថា ពួកគេស្គាល់អ្នកដែលធ្វើការរួមភេទដើម្បីរស់រានមានជីវិត។ ក្នុងករណីជាច្រើន មានម្នាក់ជាជនជាតិភាគតិច ៖ ជាតិសាសន៍ផ្សេងទៀត១៧នាក់ ខ្មែរក្រោម ១២នាក់ ខ្មែរឥស្លាម៦នាក់ ចាម ១នាក់ និងវៀតណាម១នាក់ (សូមមើលតារាងលេខ៦)[100]។

ក្នុងករណីនៃការរួមភេទដើម្បីរស់រានមានជីវិតរបស់ជនជាតិភាគតិច មានជនល្មើស១៨នាក់ជាកម្មាភិបាលខ្មែរក្រហម។ ជនល្មើសម្នាក់ត្រូវបានគិតថាជាប្រជាជនស៊ីវិល និងក្នុងករណីដទៃទៀត គេមិនដឹងអំពីអត្តសញ្ញាណរបស់ជនល្មើសឡើយ។ ក្នុង១៥ករណី ត្រូវបានគេជឿជាក់ថា មានជនល្មើសតែម្នាក់ប៉ុណ្ណោះ។ តាមការប៉ាន់ស្មាន ជនល្មើសភាគច្រើនជាបុរសចំណាស់។ តាមការប៉ាន់ស្មាន ជនល្មើសមានអាយុលើសពី៣០ឆ្នាំក្នុង១២ករណីនៃករណីទាំងនេះ មានអាយុចន្លោះចាប់ពី១៨ឆ្នាំ ដល់ ៣០ឆ្នាំក្នុងប្រាំមួយករណី និងជាបុរសវ័យក្មេងអាយុក្រោម១៨ឆ្នាំក្នុងមួយករណី។

ក្នុងករណីទាំងអស់លើកលែងតែមួយករណី ជនល្មើសគឺជាបុរស និងជនរងគ្រោះជាស្ត្រី។ ក្នុងករណីពិសេស ប្រធានអង្គភាពមួយចំនួនដែលជាស្ត្រីមានអំណាចបាន "ហៅ" បុរសខ្មែរក្រោមដែលមានរូបរាងសង្ហារទៅរួមភេទជាមួយ។ បុរសមួយចំនួនដែលមានរូបរាងសង្ហារបានរួមភទជាមួយស្ត្រីទាំងនេះ ដើម្បីបានបាយ និងអាហារផ្សេងទៀតសម្រាប់ឱ្យកូនពួកគេបរិភោគ។ ជាចុងក្រោយ បុរសទាំងនេះត្រូវបានប្រធានអង្គភាពសម្លាប់ចោល។

100 សម្រាប់ជនរងគ្រោះជនជាតិចាម និងវៀតណាម ដែលមានតួលេខទាបជាងគេទំនងជាឆ្លុះបញ្ចាំងឱ្យឃើញពីចំនួនអ្នកឆ្លើយតបមកពីក្រុមជនភាគតិច។ តាមការរៀបរាប់ ជនរងគ្រោះជាក្រុមជនជាតិភាគតិចទាំងអស់បានធ្វើការរួមភេទដើម្បីរស់រានមានជីវិត។

តាមការប៉ាន់ស្មានលើអាយុ ជនរងគ្រោះមានអាយុចន្លោះចាប់ពី១៨ឆ្នាំ ដល់ ៣០ឆ្នាំ ក្នុងដប់បួនករណី អាយុក្រោម១៨ឆ្នាំក្នុងបួនករណី និងអាយុលើសពី៣០ឆ្នាំក្នុងបីករណី។

ដប់បួនករណីក្នុងចំណោម២០ករណីនៃការរួមភេទ ដើម្បីរស់រានមានជីវិតរបស់ជនរងគ្រោះជាជនជាតិភាគតិច មានជនរងគ្រោះតែម្នាក់ប៉ុណ្ណោះ។

មានអ្នកផ្ដល់បទសម្ភាសម្នាក់ដែលបានឆ្លងកាត់ការរួមភេទ ដើម្បីរស់រានមានជីវិតដោយផ្ទាល់។ នាងគឺជាស្ត្រីខ្មែរក្រោម ដែលត្រូវបានទាហានខ្មែរក្រហមបង្ខំឱ្យរៀបការ។ ក្នុងករណីខាងក្រោម ស្ត្រីនេះរៀបរាប់ថា នាងបានរួមភេទជាមួយប្ដីរបស់នាង ដើម្បីបានបាយហូប ៖

*ទោះបីខ្ញុំមានភាពលំបាកក្នុងការរស់នៅក៏ដោយ ក៏ខ្ញុំត្រូវខំប្រឹងប្រែងដើម្បីរស់។ ដើម្បីបានអាហារគ្រប់គ្រាន់ ខ្ញុំបានរួមភេទជាមួយគាត់។ ប្រសិនបើខ្ញុំមិនព្រមរួមភេទជាមួយប្ដីរបស់ខ្ញុំទេ គាត់នឹងមិនឱ្យអាហារដល់ខ្ញុំឡើយ នៅពេលគាត់ត្រឡប់មកផ្ទះពីធ្វើការវិញ។ ខ្ញុំបានរួមភេទជាមួយគាត់ គាត់បានឱ្យត្រី សាច់ និងពោតដល់ខ្ញុំ។ ខ្ញុំបានរួមភេទជាមួយប្ដីខ្ញុំ ដើម្បីបានអាហារគ្រប់គ្រាន់សម្រាប់បរិភោគបើទោះបីជាខ្ញុំអស់កម្លាំងក៏ដោយ។*

- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ក្នុងករណីមួយផ្សេងទៀត ស្ត្រីម្នាក់រៀបរាប់អំពីកម្មាភិបាលមករកនាង ដើម្បីសុំនាងរួមភេទជាមួយ ដោយឱ្យជាអាហារដល់នាង ប៉ុន្តែនាងបានបដិសេធ ៖

*[កម្មាភិបាលខ្មែរក្រហម] ជិះសេះមកជួបខ្ញុំ។ វាបានព្យាយាមបញ្ចុះបញ្ចូលខ្ញុំ ប៉ុន្តែខ្ញុំមិនដែលយល់ព្រម [រួមភេទ] ជាមួយវាឡើយ។ ខ្ញុំសុខចិត្តស្លាប់។ វាបានសួរខ្ញុំមួយចំនួនអំពីរឿងនេះរឿងនោះ។ វាបានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំយល់ព្រមទៅជាមួយវា ខ្ញុំនឹងមានអាហារសម្រាប់ហូប និងសម្រាប់ផ្គត់ផ្គង់គ្រួសារ ហើយគ្រួសាររបស់ខ្ញុំនឹងមិនរស់នៅក្នុងភាពលំបាកទៀតឡើយ។ ពេលនោះខ្ញុំមានអាយុ១៧ឆ្នាំឬ១៨ឆ្នាំ។*

- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

ស្ត្រីម្នាក់បាននិយាយអំពីក្ដីអស់សង្ឃឹមរបស់មិត្តនាង (ស្ត្រីខ្មែរក្រោម) ក្នុងការរួមភេទដើម្បីរស់រានមានជីវិត ៖

*នាងជាប្រជាជនសាមញ្ញ និងជាស្ត្រីក្រមុំព្រហ្មចារី។ មុនពេលរបបប៉ុលពត នាងជាមិត្តរួមថ្នាក់របស់ខ្ញុំ។ នាងស្រស់ស្អាតណាស់... មិត្តរបស់ខ្ញុំទាំងអស់ដែលធ្វើការជាមួយនាងនៅក្នុងរោងកាត់ដេរបានប្រាប់ខ្ញុំថា នាងរួមភេទជាមួយប្រធានអង្គភាព។ នាងមានអាយុប្រហែល២០ឆ្នាំ...*

## លទ្ធផលរកឃើញ

*ពួកគេគ្រាន់តែប្រាប់ខ្ញុំថា នាងបានរួមភេទជាមួយប្រធានអង្គភាព ប៉ុន្តែវាមិនមែនជាការស្ម័គ្រចិត្តឡើយ។ នាងគ្រាន់តែចង់បានអាហារគ្រប់គ្រាន់សម្រាប់ហូប និងលាក់រឿងនេះដោយសម្ងាត់។*
- អ្នកផ្តល់បទសម្ភាសជាស្រ្តីខ្មែរក្រោម

ការរួមភេទដើម្បីរស់រានមានជីវិត អាចផ្តល់អាហារ និងសិទ្ធិដទៃទៀតដល់អ្នកដែលអស់សង្ឃឹម ដូចស្រ្តីម្នាក់ទៀតលើកឡើងដូចខាងក្រោម ៖

*ខ្ញុំដឹងពីគេថា ពួកនាងស្រស់ស្អាតណាស់។ ពួកនាងរស់នៅជាមួយទាហាន។ ពួកនាងមានបាយហូប មានម្សៅផាត់មុខ និងក្រែមលាបមាត់។ ជីវិតរបស់ពួកនាងមានភាពល្អប្រសើរ។ ពួកនាងមានបាយហូប និងមានសារុងសូត្រល្អស្លៀក។ គេប្រាប់ខ្ញុំថាពួកនាងរួមភេទជាមួយទាហានទាំងនោះ។ ស្រ្តីមួយចំនួន [ចាកចេញ] ពីប្តីរបស់ខ្លួនដោយសារតែពួកនាង [មិនមាន] អាហារគ្រប់គ្រាន់សម្រាប់ហូប [បុរសទាំងនេះ] គឺជាទាហានខ្មែរក្រហម។*
- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

ទោះបីយ៉ាងណា ការប្តូរការរួមភេទដើម្បីរស់រានមានជីវិតប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ ហើយជនរងគ្រោះ និង/ឬ ជនល្មើសអាចត្រូវគេសម្លាប់ចោល ប្រសិនបើគេស្វែងរកឃើញករណីនេះ។ ក្នុងករណីលើកឡើងខាងលើអំពីស្រ្តីធ្វើការក្នុងរោងកាត់ដេរដែលបានរួមភេទដើម្បីប្តូរយកបាយហូបទាំងនាង និងប្រធានអង្គភាពត្រូវបានសម្លាប់ នៅពេលនាងមានផ្ទៃពោះ។ បុរសម្នាក់ផ្សេងទៀតក៏ជាប់ពាក់ព័ន្ធនឹងករណីមួយនៃការសម្លាប់ទាំងស្ត្រី និងបុរសដែលរួមភេទដើម្បីប្តូរយកអាហារ ៖

*នៅពេលនោះ [ការរួមភេទ] ធ្វើឡើងដើម្បីប្តូរយកអង្ករប្រាំកំប៉ុង... [ជនរងគ្រោះគឺជា] ស្ត្រីខ្មែរកម្ពុជាក្រោម... នាងមានអាយុ២០ឆ្នាំជាង។ នាងមិនមានកូនឡើយ។ ១០ថ្ងៃបន្ទាប់ ទាំងបុរស និងស្ត្រីនោះត្រូវបានយកទៅសម្លាប់ចោល...*
- អ្នកផ្តល់បទសម្ភាសជាបុរស (មានជាតិសាសន៍ផ្សេងទៀត)

## ៤.៩ ទាសករផ្លូវភេទ

អ្នកផ្តល់បទសម្ភាស៣៨នាក់ក្នុងចំណោម១០៥នាក់នៅក្នុងការសិក្សានេះបាននិយាយថាខ្លួនបានស្គាល់ជនរងគ្រោះដែលត្រូវបានពួកខ្មែរក្រហមបង្ខំឱ្យរួមភេទជាទៀងទាត់ ពោលគឺទាសករផ្លូវភេទ។ ទាសករផ្លូវភេទជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលមានចែងក្នុងច្បាប់អន្តរជាតិដូចក្នុងករណីខាងក្រោម៖

*ជនល្មើសបានប្រើប្រាស់សិទ្ធិអំណាចជាម្ចាស់កម្មសិទ្ធិណាមួយ ឬ ទាំងស្រុងលើមនុស្សម្នាក់ ឬច្រើននាក់ ដូចជា តាមរយៈការទិញ ការលក់ ការឱ្យខ្ចីឬ ការដោះដូរមនុស្សម្នាក់ឬ ច្រើននាក់ ឬដោយការដកហូតសិទ្ធិសេរីភាពស្រដៀងគ្នានេះពីជនរងគ្រោះ [ហើយ] ជនល្មើសបង្ខំឱ្យជនរងគ្រោះម្នាក់ ឬច្រើននាក់ ចូលរួមក្នុងសកម្មភាពរួមភេទមួយដង ឬ ច្រើនដង។*[101]

ក្នុងចំណោមករណីទាសករផ្លូវភេទដែលបានលើកឡើង ស្ទើតែ៥០%នៃករណីទាំងនេះបានប្រព្រឹត្តលើជនជាតិភាគតិច ៖ ករណីផ្សេងៗមានចំនួន២១ករណី ខ្មែរក្រោមមានចំនួន៦ករណី ខ្មែរឥស្លាមមានចំនួន៤ករណី ចាមមានចំនួន៤ករណី និងករណីជនជាតិភាគតិចវៀតណាមមានចំនួន២ករណី។[102]

*រូបភាពទី៨ទាសករផ្លូវភេទបែងចែកទៅតាមជនរងគ្រោះជាជនជាតិភាគតិច*




ក្នុងករណីទាសករផ្លូវភេទលើជនរងគ្រោះ ជាជនជាតិភាគតិច ដែលស្គាល់អត្តសញ្ញាណរបស់ជនល្មើស ជនល្មើសគឺជាបុរស និងជាភ្នាក់ងារនៃរបបខ្មែរក្រហម។ នៅពេលធ្វើការវាយតម្លៃលើអាយុរបស់ជនល្មើស ជនល្មើសជាមនុស្សចាស់។ ជនល្មើសក្នុងប្រាំបីករណី ត្រូវបានប៉ាន់ស្មានថា មានអាយុចន្លោះពី១៨ឆ្នាំ ដល់ ៣០ឆ្នាំ ក្នុងប្រាំពីរករណីមានអាយុលើសពី៣០ឆ្នាំ និង ក្នុងបីករណីទៀតមានអាយុក្រោម១៨ឆ្នាំ។

ជនរងគ្រោះជនជាតិភាគតិចនៃទាសករផ្លូវភេទទាំងអស់ គឺសុទ្ធសឹងជាស្ត្រីភេទ។ នៅពេលធ្វើការវាយតម្លៃលើអាយុជនរងគ្រោះទំនងជាស្ថិតក្នុងវ័យ២០ឆ្នាំ។ ក្នុង១២ករណី ជនរងគ្រោះត្រូវបានប៉ាន់ស្មានថា មានអាយុចន្លោះពី១៨ឆ្នាំ ដល់ ៣០ឆ្នាំ ក្នុងប្រាំករណីមានអាយុក្រោម១៨ឆ្នាំ និង ក្នុង ១ករណីមានអាយុលើសពី៣០ឆ្នាំ។

101 មាត្រា៧ (១) (g)-២ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃទាសករផ្លូវភេទ ធាតុផ្សំនៃឧក្រិដ្ឋកម្ម តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ៨។ បានមើលនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥<http://www.icc-cpi.int/nr/rdonlyres/336923d8-a6ad-40ec-ad7b-45bf9de73d56/0/elementsofcrimeseng.pdf>

102 សម្រាប់ជនរងគ្រោះជនជាតិចាម និងវៀតណាម ដែលមានតួលេខទាបជាងគេទំនងជាឆ្លុះបញ្ចាំងឱ្យឃើញពីចំនួនអ្នកឆ្លើយតបមកពីក្រុមជនភាគតិច។

## លទ្ធផលរកឃើញ

ក្នុងប្រាំបួនករណីនៃទាសករផ្លូវភេទលើជនជាតិភាគតិច មានជនរងគ្រោះតែម្នាក់ និងប្រាំបីករណីមានជនរងគ្រោះច្រើននាក់។ មានករណីមួយគេមិនបានដឹងថា ជនរងគ្រោះមានចំនួនប៉ុន្មាននាក់នោះទេ។ ភាគច្រើននៃករណីទាំងនេះស្ត្រីត្រូវបានបង្ខំឱ្យរួមភេទជាមួយបុរសជាក្រុម។ ឧទាហរណ៍ ស្ត្រីម្នាក់បានរៀបរាប់អំពីទាសករផ្លូវភេទ ដែលកម្មាភិបាលខ្មែរក្រហមបានប្រព្រឹត្តិលើស្ត្រីខ្មែរក្រោមពីរនាក់ និងស្ត្រីខ្មែរបួនឬប្រាំនាក់៖



*ការសម្ភាស ការស្រាវជ្រាវនៅក្នុងសហគមន៍*

*ស្ត្រីម្នាក់ៗដែលត្រូវបានជ្រើសរើស ត្រូវបម្រើផ្លូវភេទយ៉ាងតិចឱ្យមនុស្សប្រុសបីទៅបួននាក់ក្នុងមួយលើក។ ស្ត្រីទាំងនេះបម្រើផ្លូវភេទឱ្យមនុស្សប្រុសទាំងនោះអស់រយៈពេលជាច្រើនខែ ហើយសឹងតែត្រូវគេសម្លាប់ចោលទៀតផងកុំតែពួកគេបានដឹងខ្លួនជាមុន ទើបពួកគេអាចរត់ចេញគេចខ្លួនទៅរស់នៅជាមួយសាច់ញាតិរបស់ពួកគេវិញ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ស្រដៀងគ្នានេះដែរ ស្ត្រីម្នាក់ផ្សេងទៀតបាននិយាយថា ស្ត្រីខ្មែរឥស្លាមជាមិត្តរួមការងារម្នាក់ត្រូវបានពួកកងឈ្លបមួយក្រុមបង្ខំឱ្យរួមភេទជាមួយ។ មនុស្សប្រុសទាំងនោះ ក៏បានបង្ខំឱ្យស្ត្រីផ្សេងទៀតរួមភេទជាមួយខ្លួនផងដែរ៖

*នាងគឺជាខ្មែរឥស្លាម ហើយនាងធ្វើការជាមួយខ្ញុំនៅក្នុងក្រុមតែមួយ...។ ទាហានភូមិម្នាក់ជាក្មេងជំទង់កាលពីអំឡុងរបបខ្មែរក្រហម បានចាប់អារម្មណ៍នឹងសម្រស់របស់នាង ក៏ចង់បាននាងកំដរអារម្មណ៍មិនមែនចង់រៀបការជាមួយនាងឡើយ។ ទាហានម្នាក់នោះចង់រួមភេទជាមួយនាងដូច្នេះ នៅពេលយប់គាត់បានបញ្ជានាងឱ្យទៅតាមខ្លួន។ នាងមិនបានដឹងថា ទាហានរូបនោះចង់ឱ្យនាងធ្វើអ្វីនោះទេ ប៉ុន្តែយើងទាំងអស់គ្នាដឹងច្បាស់ថា គាត់ចង់បានអ្វីពីនាង ប៉ុន្តែយើងមិនហ៊ានប្រាប់នាងពីការពិតនេះទេ។ ជារៀងរាល់យប់ ទាហានពីរបីនាក់តែងតែមកអង្គភាពនារី ហើយបញ្ជាឱ្យស្ត្រីមួយចំនួនទៅជាមួយខ្លួន លុះក្រោយមកទើបមេទាហានបានដឹងពីសកម្មភាពរបស់កូនចៅខ្លួន... ដូច្នេះ មេទាហានរូបនោះក៏សម្រេចបញ្ជូននាងទៅ [កសាងខ្លួន] ប៉ុន្តែការពិត នាងត្រូវបានបញ្ជូនទៅសម្លាប់។ [អ្នកសម្ភាស៖ តើសកម្មភាពរំលោភកើតឡើងជារៀងរាល់យប់ដែរឬ*

*ទេ?] យើងមិនដឹងដែរ ប៉ុន្តែនៅពេលស្ត្រីដែលត្រូវបានបញ្ជាឱ្យទៅជាមួយទាហានទាំងនោះ ពេលត្រឡប់មកវិញ មើលទៅនាងមានទឹកមុខក្រៀមក្រំ។ ខ្ញុំសង្ស័យថាមានអ្វីកើតឡើងចំពោះនាង ប៉ុន្តែខ្ញុំមិនហ៊ានសួរនាងទេ ហើយក្រោយមកទើបខ្ញុំដឹងថានាងត្រូវបានគេរំលោភជារៀងរាល់យប់។ ទាហានពីរបីនាក់ចង់បាននាងដូចគ្នា ប៉ុន្តែពួកគេបានរំលោភនាងម្នាក់ម្តងៗ... ទាហានទាំងនោះជាក្មេងជំទង់អាយុប្រហែល១៨ឆ្នាំទៅ២០ឆ្នាំប៉ុណ្ណោះ។ យើង [ជនរងគ្រោះ និងអ្នកផ្តល់បទសម្ភាស] បានស្នាក់នៅជាមួយគ្នា ហើយជាញឹកញាប់ខ្ញុំបានសាកសួរអំពីរឿងនេះ នៅពេលចូលគេង។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

ស្ត្រីត្រូវបានយកមកបម្រើផ្លូវភេទជាច្រើនថ្ងៃ ឬ ជាច្រើនខែ ដូចរៀបរាប់ខាងក្រោម៖

*បុរសមួយចំនួនក្នុងចំណោមពួកគេ [ខ្មែរក្រហម] បាននាំស្ត្រីទៅរួមភេទ និងចាត់ទុកពួកគេដូចជាប្រពន្ធរបស់ខ្លួន មុនពេលស្ត្រីទាំងនោះត្រូវបានអនុញ្ញាតឱ្យត្រឡប់មកវិញ... ជាច្រើនខែ... កាលពីជំនាន់នោះយើងរស់នៅក្នុងផ្ទះជិតៗគ្នាជាជួរ ដូច្នេះ ខ្ញុំអាចឃើញហេតុការណ៍នោះផ្ទាល់នឹងភ្នែករបស់ខ្ញុំ។*

- អ្នកផ្តល់បទសម្ភាសជាជនជាតិភាគតិចវៀតណាម

ស្ត្រីមួយចំនួនត្រូវបានឃុំខ្លួនដើម្បីរួមភេទ រីឯស្ត្រីមួយចំនួនទៀតអាចត្រឡប់ទៅកាន់កន្លែងស្នាក់នៅវិញ បន្ទាប់ពីត្រូវបានបំពានផ្លូវភេទម្តងៗ។ ក្នុងករណីមួយចំនួនដូចបានរៀបរាប់ ស្ត្រីដែលត្រូវបានបង្ខាំងទុកឱ្យធ្វើជាទេសករផ្លូវភេទចុងបញ្ចប់ត្រូវបានគេសម្លាប់ (ក្នុងបួនករណី គេមិនដឹងច្បាស់ថា ចុងក្រោយមានអ្វីកើតឡើងចំពោះស្ត្រីនោះទេ)។ ក្នុងករណីបន្ទាប់ អ្នកផ្តល់បទសម្ភាសជាស្ត្រីម្នាក់បានរៀបរាប់ថា ស្ត្រីដែលត្រូវបង្ខាំងទុកឱ្យធ្វើជាទាសករផ្លូវភេទនោះ ត្រូវបានគេសម្លាប់បំបិទមាត់៖

*ស្ត្រីស្អាតៗប្រហែល១០នាក់ [ខ្មែរ និងខ្មែរឥស្លាម] ត្រូវបានបង្ខាំងទុកដើម្បីរំលោភ...[ជនល្មើស] មានគ្នាប្រហែលបួនប្រាំនាក់ សុទ្ធសឹងតែជាបុរសមានអាយុចន្លោះពី៣០ឆ្នាំដល់៣៥ឆ្នាំ... [ជនរងគ្រោះ] គឺជាស្ត្រីស្អាតៗ អាយុចន្លោះពី១៨ឆ្នាំដល់២០ឆ្នាំ។ បន្ទាប់ពីត្រូវគេចាប់រំលោភពីបីទៅប្រាំពីរថ្ងៃរួចមក ស្ត្រីទាំងនោះត្រូវបានសម្លាប់ចោល ដោយសារ[ជនល្មើស] ខ្លាចបែកធ្លាយរឿងនេះ។*

## លទ្ធផលរកឃើញ

### ៤.៦ អំពើហិង្សាផ្លូវភេទផ្សេងទៀត

អ្នកផ្ដល់បទសម្ភាស ក៏ត្រូវបានសាកសួរអំពីការយល់ដឹងអំពីទម្រង់ផ្សេងៗនៃអំពើហិង្សាផ្លូវភេទផងដែរ។ អ្នកផ្ដល់បទសម្ភាស៥៨នាក់ក្នុងចំណោម១០៥នាក់ ដឹងអំពីអំពើហិង្សាផ្លូវភេទក្រៅពីទម្រង់ដែលបានរៀបរាប់ខាងលើ ដោយនិយាយថា ខ្លួនធ្លាប់ជួបប្រទះ ឃើញផ្ទាល់ភ្នែក ឬ ធ្លាប់ស្ដាប់ឮអំពើហិង្សាផ្លូវភេទកន្លងមក។ ទម្រង់ទាំងនេះមានដូចជាការធ្វើកាយវិកលកម្មផ្លូវភេទ និងការបៀតបៀនផ្លូវភេទរហូតដល់ការមាក់ងាយផ្លូវភេទ និងការរំលោភជាក្រុមដោយបង្ខំជាដើម។

### ៤.៦.១- ការធ្វើកាយវិកលកម្មផ្លូវភេទ



តំបន់សិក្សា

សម្រាប់គោលបំណងនៃការសិក្សានេះ ការធ្វើកាយវិកលកម្មផ្លូវភេទត្រូវបានស្គាល់ថាជាការកាត់ ឬ ការបំផ្លាញអវៈយវៈភេទដោយការចាប់បង្ខំលើបុគ្គលម្នាក់ដោយគ្មានការយល់ព្រម។

អ្នកផ្ដល់បទសម្ភាសប្រាំពីរនាក់បានប្រាប់ថា ខ្លួនបានឃើញ ឬ បានស្ដាប់ឮអំពីការធ្វើកាយវិកលកម្មផ្លូវភេទលើជនរងគ្រោះជនជាតិភាគតិចទាំងនោះ ដែលភាគច្រើនធ្វើឡើងបន្ទាប់ពីរំលោភរួច។ ប្រាំករណីក្នុងចំណោមករណីធ្វើកាយវិកលកម្មគឺការកាត់ដោះស្ត្រី។ (ក្នុងករណីមួយចំនួនស្ត្រីត្រូវបានវះពោះបារយកគ្រឿងក្នុងចេញ)។ ករណីភាគច្រើន គេមិនដឹងថាតើការកាត់អវៈយវៈនេះ ធ្វើឡើងបន្ទាប់ពីសម្លាប់ជនរងគ្រោះ ឬ យ៉ាងណានោះទេ? អ្នកផ្ដល់បទសម្ភាសគ្រាន់តែបានឃើញសាកសពដែលបាន កាត់អវៈយវៈនោះប៉ុណ្ណោះ។

ទោះជាយ៉ាងណា មានករណីបីដែលជនរងគ្រោះទំនងជានៅរស់ ហើយត្រូវបានគេកាត់អវៈយវៈរហូតដល់ស្លាប់។ ឧទាហរណ៍ស្ត្រីម្នាក់បាននិយាយថាខ្លួនបានឃើញប្អូនប្រុសបង្កើតរបស់ខ្លួននិងស្ត្រីម្នាក់ទៀតត្រូវបានគេកាត់អវៈយវៈភេទ៖

> *នាងជាខ្មែរកម្ពុជាក្រោមអាយុប្រហែល១៤ឆ្នាំឬ១៥ឆ្នាំប៉ុណ្ណោះ។ នាងត្រូវបានបង្ខំឱ្យស្រាតខោអាវ បន្ទាប់មក [កម្មាភិបាលខ្មែរក្រហម] បានយកកាំបិតផ្ទឹះលេងប្រដាប់ភេទនាង បន្ទាប់មកក៏វះពោះនាងញាត់ស្មៅ។ កម្មាភិបាលរូបនោះមិនបានរំលោភនាងទេគ្រាន់តែចង់វះពោះនាងលេងតែប៉ុណ្ណោះ... ប្អូនប្រុសរបស់ខ្ញុំត្រូវបានគេសម្លាប់ ប៉ុន្តែនៅមុនពេលគេសម្លាប់ក៏ត្រូវបានគេ*

*វះពោះញាត់ស្មៅដូចគ្នាដែរ មិនតែប៉ុណ្ណោះ ថែមទាំងត្រូវបានគេកាត់ប្រដាប់ភេទចោលទៀត។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

បុរសម្នាក់បានសម្គាល់ឃើញថា ការធ្វើកាយវិកលកម្មផ្លូវភេទក៏ធ្វើឡើងនៅក្នុងមន្ទីរឃុំឃាំង ដោយគ្មានទោសពៃផងដែរ៖

*ការដាក់ទោសទណ្ឌធ្ងន់ធ្ងរត្រូវបានធ្វើឡើងតែនៅក្នុងមន្ទីរឃុំឃាំងប៉ុណ្ណោះ ដូចជា ការដកក្រចកដៃ ការកាត់ដោះស្ត្រីដោយប្រើដង្កៀបចាប់ទាញជាដើម។ ការធ្វើទារុណកម្មត្រូវបានធ្វើឡើងតាមតែអំពើចិត្តរបស់គេ។*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរឥស្លាម

អ្នកផ្តល់បទសម្ភាសជាបុរសម្នាក់ បានរៀបរាប់អំពីករណីនៃការធ្វើកាយវិកលកម្មផ្លូវភេទរបស់ម្តាយមីងខ្លួនជាស្ត្រីខ្មែរក្រោមវ័យចំណាស់ម្នាក់ ដែលជាការដាក់ទោសសម្រាប់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ចំពោះគាត់ ៖

*ក្នុងមូលដ្ឋានយោធាខ្មែរក្រហម មានបណ្តាញទូរស័ព្ទមួយខ្សែ ហើយម្តាយមីងរបស់ខ្ញុំត្រូវបានគេចោទប្រកាន់ថាបានកាត់ផ្តាច់ខ្សែរទូរស័ព្ទនោះចោល...ម្តាយមីងរបស់ខ្ញុំជាស្រីក្រមុំចាស់។ ខ្ញុំបានឮថា ដោះរបស់គាត់ត្រូវបានគេកាត់ចោល មុននឹងយកគាត់ទៅសម្លាប់ ប៉ុន្តែខ្ញុំមិនបានឃើញហេតុការណ៍នោះផ្ទាល់ភ្នែកទេ។ មនុស្សចាស់ៗបានលបមើលឃើញម្តាយមីងរបស់ខ្ញុំត្រូវគេសម្លាប់និងត្រូវបានគេធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ។ ខ្ញុំមិនដឹងថាគេរំលោភគាត់ឬក៏អត់នោះទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា គេកាត់ដោះរបស់គាត់ដោយកាំបិទចំពុះទុង។ ភ្នែករបស់គាត់ក៏ត្រូវបានខ្វះចេញមកក្រៅ ដោយកាំបិទចំពុះទុងនេះដែរ មិនតែប៉ុណ្ណោះ គាត់ត្រូវបានគេចាប់ស្រាតខោអាវចេញអស់។*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរក្រោម

អ្នកផ្តល់បទសម្ភាសពីរនាក់បាននិយាយថា ខ្លួនបានឃើញប្រដាប់ភេទទាំងនេះតាំងព្យួរជាសាធារណៈ។ ករណីទី១ អ្នកផ្តល់បទសម្ភាសជាស្ត្រីម្នាក់បានរៀបរាប់ថាកម្មាភិបាលខ្មែរក្រោមពីរបីនាក់បានចាប់រំលោភបងប្អូនជីដូនមួយរបស់នាងដែលជាស្ត្រីខ្មែរក្រោម៖

*ពួកគេរំលោភនាង និងកាត់ក្បាលដោះរបស់នាងដាក់លើចុងកាណុងកាំភ្លើង។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

## លទ្ធផលរកឃើញ

ករណីទី២ អ្នកផ្តល់បទសម្ភាសជាស្ត្រីម្នាក់ទៀតបានប្រាប់ថា ទាហានម្នាក់បានកាត់អវៈយវៈភេទរបស់មិត្តម្នាក់ ដែលជាស្ត្រីខ្មែរក្រោមបន្ទាប់ពីបានរំលោភនិងសម្លាប់នាង ៖

*[ក្រោយមក]នាងត្រូវបានគេសម្លាប់។ នាងត្រូវបានធ្វើទារុណកម្មយ៉ាងព្រៃផ្សៃបន្ទាប់មកដៃជើងរបស់នាងត្រូវបានគេកាត់ចោល។ នាងត្រូវបានគេយកទៅបោះចោលបន្ទាប់ពីរំលោភរួច។ ខ្ញុំបានឃើញអវៈយវៈភេទរបស់នាងដែលត្រូវបានគេកាត់ជាបំណែកតូចៗ ប៉ុន្តែខ្ញុំមិនឃើញគេរំលោភនាងផ្ទាល់ភ្នែកនោះទេ។ យើងគ្រាន់តែឃើញបំណែកតូចៗនៃអវៈយវៈភេទរបស់នាងនៅពេលដើរតាមផ្លូវប៉ុណ្ណោះ...យើងមិនហ៊ាននិយាយអំពីរឿងនេះដោយបើកចំហនោះទេ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

រឿងដែលអាក្រក់ជាងនេះទៀតនោះគឺថា អ្នកផ្តល់បទសម្ភាសពីរនាក់បាននិយាយអំពីសកម្មភាពស៊ីសាច់មនុស្សរបស់កម្មាភិបាលខ្មែរក្រហម។ ស្ត្រីម្នាក់បានប្រាប់ថាសកម្មភាពនេះពាក់ព័ន្ធនឹងក្មេងម្នាក់ បន្ទាប់ពីពួកទាហានបានរំលោភនិងសម្លាប់ម្តាយរបស់ក្មេងនោះ៖

*នាង[ជនរងគ្រោះនៃអំពើរំលោភរួចសម្លាប់ចោល] មានកូនម្នាក់អាយុប្រហែល១០ឆ្នាំ។ កូនរបស់នាងគួរឱ្យស្រឡាញ់ណាស់... ពួកទាហានបាននាំក្មេងនោះទៅជួបម្តាយ ហើយក្មេងនោះដឹងថាម្តាយខ្លួនបានស្លាប់បាត់ទៅហើយ ដូច្នេះ ក៏បានសុំអង្វរករពួកទាហានឱ្យទុកជីវិតរបស់ខ្លួន។ ក្មេងនោះមិនចង់ស្លាប់ទេ ហើយទាហាននោះក៏បានប្រាប់ក្មេងនោះថាម្តាយឯងនៅ [មន្ទីរពេទ្យ] ហើយក៏បាននាំក្មេងនោះទៅបាត់... នៅពេលល្ងាចពួកគេប្រាប់ទាហានផ្សេងទៀតថាថ្លើមរបស់ក្មេងនោះឆ្ងាញ់ណាស់។ ខ្ញុំបានស្តាប់ឮដោយចៃដន្យអំពីសកម្មភាពដ៏ព្រៃផ្សៃទាំងនេះនៅពេលពួកគេកំពុងផឹកទឹកត្នោតជូរ ហើយនិយាយថា បានស៊ីថ្លើមកូនក្មេង។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

គេមិនដឹងអំពីគោលបំណងពិតប្រាកដនៃការស៊ីសាច់មនុស្សជាអាហារនោះទេ។ អ្នកផ្តល់បទសម្ភាសពីរបីនាក់បាននិយាយថា កម្មាភិបាលបានខ្វេះយកថង់ទឹកប្រមាត់មនុស្សដែលខ្លួនបានសម្លាប់ដើម្បីត្រាំស្រា។ ទោះជាហេតុផលណាក៏ដោយ ការធ្វើបែបនេះគឺពិតជាគួរឱ្យរន្ធត់ណាស់សម្រាប់អ្នកដែលបានឃើញឬបានស្តាប់ឮអំពីរឿងនេះ ហើយធ្វើឱ្យពួកគេកាន់តែព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនកាន់តែខ្លាំងឡើង។

## ៤.៦.២ ការរំលោភបំពានផ្លូវភេទ

អ្នកផ្ដល់បទសម្ភាសពីរបីនាក់បានរៀបរាប់អំពីទម្រង់នៃការរំលោភបំពានផ្លូវភេទផ្សេងៗក្រៅពីទម្រង់ដែលបានរៀបរាប់ខាងលើ។ ករណីពាក់ព័ន្ធនឹងការលូកស្ទាប ឬ ការមាក់ងាយផ្លូវភេទមានពីរករណី។ ស្ត្រីម្នាក់បាននិយាយថា បុរសពីរនាក់បានព្យាយាមលូកលាន់នាងនិងប្អូនស្រីរបស់នាងបន្ទាប់ពីពួកនាងមុជទឹករួចៈ

*ថ្ងៃមួយ យើងកំពុងមុជទឹកស្រាប់តែបុរសពីរនាក់បានដើរមកដល់ យើងក៏ប្រញាប់ស្លៀកពាក់។ ពួកគេបានដើរតាមយើងពីក្រោយហើយព្យាយាមលូកច្របាច់ដោះយើង ប៉ុន្តែខ្ញុំមិនព្រមឡើយ។ ដូច្នេះ ពួកគេក៏ដាល់ខ្ញុំពីរបីដៃទាល់តែឃើញមនុស្សចាស់ៗដើរកាត់ទើបឈប់។ ពួកគេមានវ័យជំទង់អាយុប្រហែល២០ឆ្នាំ។ បើកុំតែមនុស្សចាស់ៗដើរក្បែរៗនេះម្ល៉េះពួកយើងត្រូវគេចាប់រំលោភ បាត់ទៅហើយ។*

- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

បន្ទាប់ពីរៀបរាប់អំពីសកម្មភាពចាប់រំលោភរបស់ប្រធានអង្គភាពលើស្ត្រីខ្មែរឥស្លាម ដែលត្រូវជាមិត្តជិតស្និទ្ធរបស់ខ្លួនរួចមក អ្នកផ្ដល់បទសម្ភាសជាស្ត្រីម្នាក់នេះក៏បាននិយាយអំពីការប្រើប្រាស់ពាក្យមាក់ងាយផ្លូវភេទ ដែលប្រធានអង្គភាព និងជនល្មើសដទៃទៀត និយាយទៅកាន់ស្ត្រីជាមិត្តភក្តិរបស់ខ្លួននៅក្នុងភូមិៈ

*[អ្នកសម្ភាសៈតើប្រធានអង្គភាពបានចាប់រំលោភស្ត្រីផ្សេងទៀតដែរឬទេ?] មានច្រើនណាស់ពីព្រោះប្រធានអង្គភាពប្រុសនោះនិយាយថា គ្មានអ្វីឆ្ងាញ់ជាងព្រហ្មចារីស្រីក្រមុំនោះទេ។ ពួកគេបានប្រាប់យើងដូច្នេះនៅក្នុងភូមិ។ អំឡុងពេលម៉ោងធ្វើការ ក៏ដូចជា ពេលសម្រាក ពួកគេប្រាប់យើងដូច្នេះឯង។ យើងស្ងាត់មាត់ឈឹង ហើយគ្មាននរណាម្នាក់ហ៊ាននិយាយអ្វីឡើយ។ យើងខ្លាចខ្លាំងណាស់។*

- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

ការសិក្សាកន្លងមក អំពើហិង្សាយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានដកស្រង់ករណីដែលស្ត្រីត្រូវបានបង្ខំឱ្យស្រាតខោអាវចេញដើម្បីកំដរអារម្មណ៍កម្មាភិបាលខ្មែរក្រហម។[103] ការ

[103] Nakagawa op. cit.; Natale op. cit.

## លទ្ធផលរកឃើញ

បង្ខំឱ្យដោះសម្លៀកបំពាក់ចេញនេះ មិនត្រូវបានលើកឡើងក្នុងការសិក្សាស្រាវជ្រាវនេះទេ ទោះបីជាអ្នកផ្ដល់បទសម្ភាសដែលបានឃើញការចាប់រំលោភជាទូទៅនិយាយថា ដំបូងជនរងគ្រោះត្រូវបានចាប់ស្រាតខោអាវចេញក៏ដោយ។ ឧទាហរណ៍ បុរសម្នាក់បានរៀបរាប់អំពីការរំលោភជាក្រុម ដែលដំបូងស្ត្រីត្រូវបានចាប់ស្រាតខោអាវរួចរំលោភ បន្ទាប់មកសម្លាប់ចោល៖

*ស្ត្រីមួយចំនួនដែលត្រូវបានគេស្រាតខោអាវចេញ ត្រូវបានចាប់ចងជាជួរ។ ស្ត្រីទាំងនោះរួមមានជនជាតិចិន និងខ្មែរកម្ពុជាក្រោម... បុរសដែលជាជនរងគ្រោះត្រូវបានចាប់ចង រីឯស្ត្រីភាគច្រើននៅលីវ ត្រូវបានស្រាតខោអាវចេញ ហើយពួកគេ [ទាហាន] សំឡឹងមើលស្ត្រីអាក្រាតកាយដោយញាក់ភ្នែកម្ដងហើយម្ដងទៀត...[ជនល្មើស] គឺជាប្រធានអង្គភាព និងជាទាហាន។ អូ! មានជនរងគ្រោះច្រើននាក់ណាស់។*

\- អ្នកផ្ដល់បទសម្ភាសជាបុរសខ្មែរក្រោម

លើសពីនេះ មនុស្សដែលបានឃើញសាកសពស្ត្រីជារឿយៗ និយាយថា សាកសពទាំងនោះជាសាកសពអាក្រាតកាយ។

## ៤.៧ ឥទ្ធិពលនៃអំពើហិង្សាផ្លូវភេទលើជនរងគ្រោះ និងការឆ្លើយតប

ការសិក្សានេះ ស្រាវជ្រាវស្វែងរកផលប៉ះពាល់រយៈពេលវែងលើជនរងគ្រោះដែលទទួលរងអំពើហិង្សាផ្លូវភេទកើតឡើងអំឡុងពេលរបបខ្មែរក្រហម ក៏ដូចជា កត្តាប្រឈម និងវិធានការដោះស្រាយសម្រាប់អ្នកនៅរស់រានមានជីវិត ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ។ ការសិក្សានេះផ្ដោតសំខាន់លើការកំណត់កត្តាទាំងឡាយ ដែលជួយឱ្យអ្នកនៅរស់រានមានជីវិតសព្វថ្ងៃអាចប្រឈមមុខនឹងអំពើហិង្សាដែលបានជួបប្រទះនៅអតីតកាល។

### ៤.៧.១ ផលប៉ះពាល់នៃអំពើហិង្សាផ្លូវភេទ

អំពើហិង្សាផ្លូវភេទត្រូវបានគេដឹងច្បាស់ថា អាចបណ្ដាលឱ្យមានផលវិបាកធ្ងន់ធ្ងរដល់ជនរងគ្រោះជាច្រើននាក់អស់រយៈពេលរាប់សិបឆ្នាំបន្ទាប់ពីហេតុការណ៍នោះកើតឡើង ហើយជួនកាលផលវិបាកនេះអាចបន្តរ៉ាំរ៉ៃពេញមួយជីវិតរបស់ជនរងគ្រោះទៀតផង។ អ្នកផ្ដល់បទសម្ភាសជាជនជាតិភាគតិច ដែលជួបប្រទះអំពើហិង្សាផ្លូវភេទនេះផ្ទាល់ ត្រូវបានសួរថា តើពួកគេសព្វថ្ងៃនេះមានបញ្ហាសុខភាពផ្លូវកាយ/ផ្លូវចិត្តដែរឬទេ។

ជាទូទៅ អ្នកផ្តល់បទសម្ភាស៥៤នាក់បាននិយាយថា ខ្លួនមានបញ្ហាផ្លូវចិត្ត រីឯអ្នកផ្តល់បទសម្ភាសប្រាំបីនាក់ទៀតឆ្លើយថា ខ្លួននៅតែមានការឈឺចាប់ផ្លូវកាយ (ឧទាហរណ៍ ជាលទ្ធផលនៃការវាយដំ ឬធ្វើទារុណកម្មដោយសារបដិសេធមិនព្រមរៀបការ)។ បញ្ហាផ្លូវចិត្ត រួមមាន ការពោរពេញដោយកំហឹង កើតទុក្ខក្រៀមក្រំ ភ័យខ្លាច សុបិន្តអាក្រក់ ការធ្លាក់ទឹកចិត្ត និងគំនិតចង់សម្លាប់ខ្លួនជាដើម។ ចំពោះអ្នកផ្តល់បទសម្ភាសពីរបីនាក់ទៀតវិញ បញ្ហាផ្លូវកាយ និង/ឬ បញ្ហាផ្លូវចិត្តនេះ ធ្វើឱ្យពួកគេពិបាកប្រកបការងារ។ ខាងក្រោមគឺជាមតិយោបល់ទាក់ទងនឹងផលប៉ះពាល់ផ្លូវចិត្ត៖

*ខ្ញុំនិយាយអ្វីមិនចេញនោះទេ ពីព្រោះខ្ញុំឈឺចាប់ពេក។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាមម្នាក់ដែលឆ្លងកាត់ការរៀបការដោយបង្ខំ

*ខ្ញុំមានអារម្មណ៍ភ័យខ្លាចនៅពេលនឹកឃើញដល់អំពើដ៏សាហាវយង់ឃ្នងទាំងនោះ។ ខ្ញុំតក់ស្លុតណាស់... ជីវិតរបស់ខ្ញុំគ្មានន័យអ្វីទៀតទេ។ ជីវិតរបស់ខ្ញុំជួបប្រទះតែភាពសៅហ្មងនិងការខកចិត្ត។ សព្វថ្ងៃ ប្រទេសជាតិយើងមានសន្តិភាពក៏ពិតមែន ប៉ុន្តែនៅពេលខ្ញុំនឹកឃើញការឈឺចាប់របស់ខ្ញុំម្តងៗ ខ្ញុំចង់តែផឹកថ្នាំសម្លាប់ខ្លួន។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម ដែលរងទារុណកម្មដោយសារបដិសេធមិនព្រមរៀបការនៅពេលប្តីរបស់នាងត្រូវបានគេសម្លាប់។

*ខ្ញុំឈឺក្បាលជារៀងរាល់ថ្ងៃ។ ខ្ញុំមិនអាចគិតពីអ្វីដែលបានកើតឡើងនោះទេ។ ការឈឺចាប់នេះនៅតែបន្តរហូតមកដល់សព្វថ្ងៃនេះ... សុខភាពផ្លូវចិត្តរបស់ខ្ញុំគឺមិនអាចព្យាបាលបាននោះទេ បើទោះជាខ្ញុំផឹកថ្នាំជារៀងរាល់ថ្ងៃក៏ដោយ។ ខ្ញុំមិនអាចធ្វើការរាល់ថ្ងៃបានទេ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោមម្នាក់ ដែលជួបប្រទះការរៀបការដោយបង្ខំ។

ជនរងគ្រោះផ្សេងទៀតមានអារម្មណ៍ថា ខ្លួនរស់នៅក្នុងទំនាក់ទំនងដែលគ្មានសុភមង្គល និងជួនកាលមានអំពើហិង្សា ដែលនេះជាលទ្ធផលនៃការរៀបការដោយបង្ខំ។ អ្នកផ្តល់បទសម្ភាសទាំងនេះបន្តរស់នៅដោយមានវិប្បដិសារី និងទុក្ខសោកសៅ ដោយសារខ្លួនមិនអាចរៀបការតាមប្រពៃណី ឬរៀបការជាមួយនឹងមនុស្សដែលខ្លួនស្រឡាញ់។ឧទាហរណ៍បីខាងក្រោមបង្ហាញថាអ្នកផ្តល់បទសម្ភាសមួយចំនួនគ្មានសុភមង្គលក្នុងអាពាហ៍ពិពាហ៍ដោយការចាប់បង្ខំ។ ឧទាហរណ៍ចុងក្រោយ អ្នកផ្តល់បទសម្ភាសជួបប្រទះអំពើហិង្សា និងការរួមភេទដោយបង្ខំពីសំណាក់ស្វាមីរបស់ខ្លួន៖

*ខ្ញុំខកចិត្តខ្លាំងណាស់ដោយសារតាំងពីកើតមករហូតដល់ធំពេញវ័យ ខ្ញុំមិនអាចរៀបការស្របច្បាប់ទៅតាមប្រពៃណីដូចមនុស្សដទៃទៀតបាន។ ខ្ញុំពិតជាឈឺចាប់ណាស់!*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

# លទ្ធផលរកឃើញ

*ការរស់នៅរបស់យើងហាក់ដូចជាស្ថិតក្នុងភាពងងឹតក្រោមពន្លឺព្រះច័ន្ទ ដូច្នេះយើងបានព្យាយាមរស់នៅជាមួយគ្នា ដោយសារតែយើងមានកូន... ខ្ញុំបានដាក់ពាក្យបណ្ដឹងទៅអង្គការ ADHOC អំពីការបំពានសិទ្ធិពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ។ យើងមានសិទ្ធិពេញលេញក្នុងការជ្រើសរើសគូស្រករ ប៉ុន្តែពួកគេបានបំបិទសិទ្ធិរបស់យើង។ នៅពេលខ្ញុំនឹកឃើញហេតុការណ៍ដែលបានកើតឡើងអំឡុងរបបនោះ ខ្ញុំមានអារម្មណ៍ខឹងយ៉ាងខ្លាំង ពីព្រោះយើងក៏ជាមនុស្សដែរ។ យើងមិនបានរៀបការតាមប្រពៃណី... ហេតុអ្វីយើងមិនអាចបំពេញភាពជាបុរសដូចក្មេងជំនាន់ក្រោយដែលទើបនឹងកើត?*

- អ្នកផ្ដល់បទសម្ភាសជាបុរសខ្មែរក្រោម

*ខ្ញុំមានកូនប្រាំពីរនាក់... ខ្ញុំនៅតែរស់នៅជាមួយគាត់... ទោះបីជាខ្ញុំរស់នៅជាមួយប្ដីខ្ញុំរហូតមកដល់សព្វថ្ងៃនេះមែន ប៉ុន្តែយើងមានបញ្ហាជាច្រើន។ គាត់តែងតែសម្លុតកូនៗ។ ចំពោះរឿងរួមភេទវិញ ខ្ញុំយល់ព្រមរួមភេទជាមួយគាត់ តែនៅពេលដែលគាត់គំរាមខ្ញុំតែប៉ុណ្ណោះ។ យើងតែងតែមានបញ្ហាជាច្រើនទាក់ទងនឹងកូនៗ។ គាត់តែងតែប្រើប្រាស់អំពើហិង្សាលើកូនៗ។ ខ្ញុំមានអារម្មណ៍អាណិតកូនៗខ្ញុំណាស់ ដូច្នេះខ្ញុំតែងតែការពារកូនៗរបស់ខ្ញុំ នៅពេលដែលគាត់ប្រើប្រាស់ហិង្សាលើពួកវា ដែលបណ្ដាលឱ្យយើងមានជម្លោះនឹងគ្នា។ វាប៉ះពាល់ដល់ផ្លូវចិត្តពួកវា។ កូនមួយចំនួនស្ទើរតែវិកលចរិកទៅហើយ។ គាត់ជាមនុស្សប្រុសដ៏អាក្រក់ម្នាក់។*

- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

អ្នកផ្ដល់បទសម្ភាមួយចំនួនបាននិយាយដោយឥតលាក់លៀមអំពីកំហឹង និងភាពឈឺចាប់របស់ពួកគេ រួមទាំងបំណងចង់សងសឹក។ ស្ត្រីម្នាក់ ដែលប្ដីរបស់គាត់ត្រូវបានសម្លាប់ក្នុងរបបនោះ បាននិយាយអំពីការមានបំណងចង់ធ្វើទារុណកម្ម និងសម្លាប់ជនល្មើស និងបំផ្លាញសាកសពពួកគេ៖

*ខ្ញុំចង់សម្លាប់ពួកគេ ប៉ុន្តែអង្គការនឹងមិនអនុញ្ញាតឱ្យយើងធ្វើដូច្នេះទេ។ ខ្ញុំមាន [ចិត្ត] ចង់សងសឹកដោយសារប្ដីរបស់ខ្ញុំត្រូវបានគេសម្លាប់ ខ្ញុំក៏ហ៊ានសម្លាប់ពួកគេដែរ។ ខ្ញុំចង់កាត់កពួកគេ ហើយទុកឱ្យពួកគេស្លាប់យ៉ាងអណោចអធម៌ ដូចពួកវាធ្វើចំពោះប្ដីរបស់ខ្ញុំអីចឹង។*

- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

## ៤.៧.២ ការស្វែងរកជំនួយ

ជនរងគ្រោះដោយផ្ទាល់ពីអំពើហិង្សាផ្លូវភេទត្រូវបានសួរថា តើពួកគេធ្លាប់ស្វែងរកជំនួយជាផ្លូវការសម្រាប់ផលប៉ះពាល់ផ្នែកផ្លូវកាយ និងផ្លូវចិត្តដែលខ្លួនបានទទួលរងក្នុងរបបខ្មែរក្រហមដែរឬ

ទេ? ហើយប្រសិនបើមិនធ្លាប់ ហេតុអ្វី? សំណួរនេះត្រូវបានរៀបចំឡើង ដើម្បីកំណត់អំពីឧបសគ្គក្នុងការស្វែងរកជំនួយរបស់អ្នកនៅរស់រានមានជីវិត។



*ការព្យាបាលតាមបែបសក្ខីកម្មសម្រាប់អ្នកនៅរស់រានមានជីវិតពីការរំលោភផ្លូវភេទ*

ទោះបីជាអ្នកផ្តល់បទសម្ភាសមួយចំនួនបានស្វែងរកការព្យាបាលវេជ្ជសាស្ត្រ សម្រាប់បញ្ហាសុខភាពរាងកាយនៅពេលពួកគេអាចមានលទ្ធភាពក៏ដោយ មានតែ ១៨នាក់ទេដែលស្វែងរកជំនួយផ្សេងៗទៀត ដូចជា សេវាផ្លូវច្បាប់ ឬជំនួយចិត្តសាស្ត្រសង្គម។ អ្នកផ្តល់បទសម្ភាសចំនួនសាមសិបបីនាក់បានលើកឡើងថា ការមិនដឹងអំពីសេវានានា គឺកត្តាដ៏សំខាន់មួយ ដែលរារាំងដល់ការស្វែងរកជំនួយ។ មនុស្សពីរនាក់បាននិយាយថា ពួកគេមិនមានលទ្ធភាពប្រើប្រាស់សេវាទេ ម្នាក់គ្មានមធ្យោបាយធ្វើដំណើរដើម្បីទៅរកសេវា ហើយពីរនាក់ទៀតបង្ហាញអំពីអារម្មណ៍ហាក់ដូចជាយឺតពេលក្នុងការស្វែងរកជំនួយចំពោះអ្វី ដែលបានកើតឡើងជិតសែសិបឆ្នាំមុន។

ចំពោះមនុស្សពីរបីនាក់ ដែលមិនមានអាសយដ្ឋានទំនាក់ទំនងសេវា ពួកគេបានយល់ឃើញថា នេះជាបទពិសោធន៍វិជ្ជមានមួយ។ អ្នកផ្តល់បទសម្ភាសទាំងបីខាងក្រោមបាននិយាយអំពីតម្លៃនៃការទទួលបានជំនួយផ្លូវចិត្ត និងច្បាប់៖

> *បន្ទាប់មក TPO បានចូលមកកន្លែងនេះ។ ពួកគេបានផ្តល់ការប្រឹក្សាដល់យើងអំពីបញ្ហាសុខភាពផ្លូវចិត្ត ដែលយើងទទួលរងពីមុនមក។ យើងបានបង្ហាញអំពីភាពឈឺចាប់ ដែលយើងមានពីមុនមក។ យើងបានទទួលការអប់រំ និងការផ្តល់ប្រឹក្សាទាក់ទងនឹងបញ្ហាសុខភាពផ្លូវចិត្តរបស់យើង ដូច្នេះពួកគេអាចរំងាប់កំហឹងរបស់យើងបាន... CDP បានហៅយើងឱ្យចូលរួមក្នុងកិច្ចប្រជុំជាមួយជនរងគ្រោះនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ ពួកគេជួយអប់រំយើងឱ្យមានអារម្មណ៍ធូរស្រាល។*
>
> - អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរក្រោម

> *ខ្ញុំក៏បានចូលរួមក្នុងការបណ្តុះបណ្តាលសុខភាពផ្លូវចិត្តដែរ។ បន្ទាប់ពីការបណ្តុះបណ្តាលនោះ ខ្ញុំក៏បានចែករំលែកចំណេះដឹងរបស់ខ្ញុំជាមួយអ្នកដទៃ។ ចាប់តាំងពីខ្ញុំបានទទួលការបណ្តុះ*

## លទ្ធផលរកឃើញ

*បណ្តាលសុខភាពផ្លូវចិត្តមក ខ្ញុំមិនដែលមានអារម្មណ៍ស្មុគស្មាញខ្លាំងឡើយ។ ការបណ្តុះបណ្តាលនេះក៏បានធ្វើឱ្យខ្ញុំមានអារម្មណ៍ធូរស្បើយដែរ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

*បន្ទាប់ពីបានដាក់ពាក្យបណ្តឹង [ទៅ អ.វ.ត.ក] ខ្ញុំបានទទួលសេវានេះពី TPO។ ពួកគេបានឱ្យខ្ញុំប្រាប់ពួកគេអំពីភាពក្រៀមក្រំ និងភាពភ័យរន្ធត់របស់ខ្ញុំ។ ពួកគេបានស្នើឱ្យខ្ញុំធ្វើតាមអ្វីដែលពួកគេបាននិយាយ ហើយខ្ញុំមានអារម្មណ៍គ្រាន់បើហើយ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

### ៤.៧.៣ កត្តាប្រឈម

ភាពក្លៀវក្លាក្នុងការប្រឈមនឹងការបាក់ទឹកចិត្ត និងការប្តេជ្ញារស់ គឺជាយុទ្ធសាស្ត្រដោះស្រាយដ៏សំខាន់បំផុតមួយសម្រាប់អ្នកដែលបានឆ្លងកាត់របបខ្មែរក្រហម។ អ្នកផ្តល់បទសម្ភាសត្រូវបានសួរអំពីមនុស្ស និងអ្វីៗជាច្រើនដែលជួយពួកគេឱ្យនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងអាចប្រឈមមុខនឹងការប៉ះទង្គិចផ្លូវចិត្តដែលពួកគេបានជួបប្រទះ។

អ្នកផ្តល់បទសម្ភាសចំនួនហុកសិបមួយនាក់បាននិយាយអំពីប្តីប្រពន្ធ ឬសាច់ញាតិរបស់ពួកគេ ដែលជួយពួកគេឱ្យរស់ និងប្រឈមមុខនឹងបញ្ហាអតីតកាល។ នៅក្នុងសាច់រឿងពីរខាងក្រោម ស្ត្រីបាននិយាយអំពីកូនៗរបស់ពួកគេថា ជាកម្លាំងចិត្ត ដើម្បីរក្សាជីវិតឱ្យរស់ និងតម្រូវការក្នុងការផ្តល់និងមើលថែទាំពួកគេ៖

*បន្ទាប់ពីរបបនេះ ឪពុកម្តាយខ្ញុំជាកម្លាំងចិត្តដល់ខ្ញុំ ប៉ុន្តែឥឡូវពួកគាត់បានស្លាប់បាត់ទៅហើយ... ខ្ញុំជាស្ត្រីមេម៉ាយជាយូរមកហើយ និងត្រូវមើលថែទាំកូនៗទៀត... ខ្ញុំព្យាយាមធ្វើការដើម្បីផ្តល់ឱ្យកូនៗរបស់ខ្ញុំនូវប្រាក់កាសមួយចំនួន ទោះបីជាជួនកាលគ្មានលុយសម្រាប់ពួកគេក៏ដោយ។ ខ្ញុំត្រូវតែព្យាយាមរស់បន្ត មិនថាវាលំបាកប៉ុណ្ណាទេ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

ស្ត្រីពីរនាក់និយាយអំពីសាសនា និងមេដឹកនាំសាសនា ដែលជួយពួកគេដោះស្រាយ ដោយរម្ងាប់កំហឹង និងការឈឺចាប់របស់ពួកគេ ហើយទុកអារម្មណ៍សងសឹកជាច់ដោយឡែក ៖

*ខ្ញុំតែងតែសុំជំនួយពីព្រះ ដើម្បីគេចពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ យើងក៏សុំជំនួយពីព្រះដើម្បីឱ្យសមាជិកគ្រួសាររបស់យើង និងបងប្អូនយើងរួបរួមគ្នា។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

*សព្វថ្ងៃ ទោះបីជាខ្ញុំមានឆ្លងកាត់ភាពលំបាកជាច្រើននៅអតីតកាល ក៏ខ្ញុំមានពិធីបុណ្យសាសនា វត្ត និងជាពិសេសព្រះធម៌ អ្នកជិតខាង អាចារ្យ និងព្រះសង្ឃ ដែលជួយសម្រួលអារម្មណ៍ខ្ញុំដែរ។*
- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

មនុស្សពីរបីនាក់បានទទួលបានសេវា ដែលជួយឱ្យពួកគេដោះស្រាយបញ្ហាផ្លូវចិត្ត និងអារម្មណ៍ជ្រួលច្របល់របស់ពួកគេ។ ស្ត្រីម្នាក់បានទទួលជំនួយ ដើម្បីចូលរួមនៅ អ.វ.ត.ក ដែលជួយសម្រាលកំហឹងរបស់គាត់៖

*សាច់ញាតិមួយចំនួនបានជួយខ្ញុំ ហើយរាជរដ្ឋាភិបាល និងអង្គការនានាបានជួយខ្ញុំឱ្យចូលរួមសាលាក្ដីខ្មែរក្រហមពីរបីដង។ ខ្ញុំមានអារម្មណ៍ប្រសើរហើយ ដែលបានឃើញមេដឹកនាំខ្មែរក្រហមត្រូវបានកាត់ទោស... អង្គការនានាបានជួយខ្ញុំច្រើនណាស់។*
- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

## ៤.៧.៤ តម្រូវការរបស់អ្នកនៅរស់រានមានជីវិត

អ្នកផ្ដល់បទសម្ភាសជាជនជាតិភាគតិច ដែលជាជនរងគ្រោះដោយផ្ទាល់ពីអំពើហិង្សាផ្លូវភេទត្រូវបានសួរអំពីអ្វីដែលអាចជួយពួកគាត់នាពេលបច្ចុប្បន្ននេះ ដើម្បីដោះស្រាយផលប៉ះពាល់នៃអំពើហិង្សានេះ។ អ្នកផ្ដល់បទសម្ភាសហាសិបមួយនាក់ចង់ឃើញមេដឹកនាំខ្មែរក្រហមត្រូវបានកាត់ទោស និងដាក់ទោស។ ពួកគេជាច្រើនមានការព្រួយបារម្ភអំពីរយៈពេលដែលត្រូវចំណាយ ដើម្បីកាត់សេចក្ដីលើករណីនានា នៅ អ.វ.ត.ក ហើយពួកគេមានការព្រួយបារម្ភថា អ្នកដែលត្រូវបានកាត់ទោសទាំងនោះនឹងស្លាប់ មុនពេលត្រូវបានដាក់ទោស ដូចបានបញ្ជាក់នៅក្នុងការរៀបរាប់ខាងក្រោម៖

*ខ្ញុំចង់ឃើញពួកគេត្រូវបានដាក់ទោស។ វាអាចជួយបន្ធូរភាពឈឺចាប់របស់ប្រជាជនយើង... សាលាក្ដីខ្មែរក្រហមអាចបន្ធូរអារម្មណ៍ឈឺចាប់របស់យើង។ ខ្ញុំនៅតែមានអារម្មណ៍ឈឺចាប់ដែលហាក់ដូចជាទើបតែកើតឡើងមកលើរូបខ្ញុំប៉ុន្មានឆ្នាំមុននេះប៉ុណ្ណោះ។ ការដាក់ទោសមេដឹកនាំខ្មែរក្រហមពិតជាសំខាន់ណាស់។ យើងមិនចង់ឃើញសាលាក្ដីពន្យារពេលពីពេលមួយទៅពេលមួយដូច្នេះទេ។*
- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

*ខ្ញុំចង់ឱ្យការកាត់ទោសធ្វើទៅឱ្យបានឆាប់ ពីព្រោះមេដឹកនាំខ្មែរក្រហមចាស់ណាស់ហើយ ឥឡូវហ្នឹង។*
- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

## លទ្ធផលរកឃើញ

អ្នកផ្តល់បទសម្ភាសចំនួនដប់ពីរនាក់បានបង្ហាញថា ការគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលត្រូវបានសម្លាប់ដោយខ្មែរក្រហម ឬអ្នកដែលស្លាប់ក្នុងអំឡុងរបបនោះ នឹងបង្ហាញពីការគោរពដល់ពួកគេ ដូចបានបញ្ជាក់ក្នុងការបញ្ចេញមតិរបស់ស្ត្រីដូចខាងក្រោម៖

*ខ្ញុំចង់ឱ្យមានការចងក្រងជាឯកសារ និងមានកន្លែងសម្រាប់រក្សាឯកសារទាំងនេះ សម្រាប់សាងសង់ប្ញូជនីយដ្ឋាន រៀបចំពិធីរំឭកវិញ្ញាណក្ខន្ធអ្នកដែលត្រូវបានគេសម្លាប់ និងកាត់ទោសខ្មែរក្រហម។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

មានតែមនុស្សប្រាំពីរនាក់ប៉ុណ្ណោះ ដែលនិយាយអំពីតម្រូវការសេវាសុខភាពផ្លូវចិត្ត។ នេះប្រហែលជាបណ្តាលមកពីការខ្វះចំណេះដឹងអំពីសេវា និងវិធីដែលពួកគេអាចទទួលបានសេវា។ អ្នកផ្តល់បទសម្ភាសតិចតួចប៉ុណ្ណោះ (អ្នកផ្តល់បទសម្ភាសតែ ៥ នាក់ប៉ុណ្ណោះ) បានលើកឡើងអំពីតម្រូវការក្នុងការផ្តល់សំណងហិរញ្ញវត្ថុ។ ស្ត្រីម្នាក់មានភាពច្បាស់លាស់អំពីបំណងចង់បានសំណងជាលុយចំពោះការសម្លាប់សាច់ញាតិរបស់គាត់៖

*ប្រាកដណាស់ ខ្ញុំចង់បានសំណង។ ខ្ញុំចង់ឱ្យពួកគេសងយើងចំពោះការឈឺចាប់ និងការបាត់បង់ដោយសារការស្លាប់របស់បងប្អូនប្រុសខ្ញុំពីរនាក់។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

អ្នកផ្តល់បទសម្ភាសពីរបីនាក់បាននិយាយអំពីតម្រូវការក្នុងការផ្តល់ព័ត៌មានដល់មនុស្សជំនាន់ក្រោយអំពីអ្វីដែលបានកើតឡើងនៅក្នុងអំឡុងរបបខ្មែរក្រហម ដើម្បីកុំឱ្យភាពព្រៃផ្សៃបែបនេះកើតឡើងម្តងទៀត។ ការព្រួយបារម្ភដ៏ធំមួយ ដែលបានលើកឡើងនោះគឺ ប្រសិនបើគ្មានកំណត់ត្រាប្រវត្តិសាស្ត្រនោះទេ ព័ត៌មានអំពីអំពើព្រៃផ្សៃរបស់ខ្មែរក្រហមនឹងត្រូវបាត់បង់ បន្ទាប់ពីអ្នកនៅរស់រានមានជីវិតទាំងប៉ុន្មានបានស្លាប់៖

*ចំពោះខ្ញុំ ខ្ញុំត្រូវតែប្រាប់ក្មេងជំនាន់ក្រោយអំពីព្រឹត្តិការណ៍នានា ដើម្បីឱ្យពួកគេដឹងថា ពួកវាព្រៃផ្សៃណាស់នៅក្នុងរបបខ្មែរក្រហម។ មានការចាប់រំលោភ ការប្រើកម្លាំងបាយ និងការសម្លាប់មនុស្ស។ ប្រសិនបើយើងមិនផ្តល់ព័ត៌មានទាក់ទងនឹងព្រឹត្តិការណ៍ដែលយើងបានជួបប្រទះក្នុងអំឡុងរបបខ្មែរក្រហមដល់ពួកគេនោះទេ មនុស្សជំនាន់ក្រោយនឹងមិនមានឯកសារ ហើយអ្វីៗទាំងអស់ត្រូវបញ្ចប់។*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរក្រោម

## ៤.៨ ការឆ្លើយតបនឹងសំណួរសិក្សាស្រាវជ្រាវ

ទិន្នន័យសិក្សាស្រាវជ្រាវជាច្រើន មានឥទ្ធិពលដោយផ្ទាល់លើសំណួរស្រាវជ្រាវដើមទាំងបួន។ សំណួរទាំងនេះត្រូវបានពិភាក្សាដូចខាងក្រោម។

### ៤.៨.១ អំពើហិង្សាលើផ្លូវភេទ ដែលជនជាតិភាគតិចជួបប្រទះ និងការដាក់ទណ្ឌកម្មលើជនល្មើស



សំណួរសិក្សាស្រាវជ្រាវទីមួយនៃការសិក្សានេះសួរថា តើជនជាតិភាគតិចបានទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមដែរឬទេ? ទិន្នន័យនេះបង្ហាញយ៉ាងច្បាស់ថា អំពើហិង្សាផ្លូវភេទត្រូវបានប្រព្រឹត្តលើក្រុមជនជាតិភាគតិចទាំងបួនក្រុម ដែលត្រូវបានធ្វើការស៊ើបសួរ។ ដោយសារតែសំណាកគំរូនៃការសិក្សាស្រាវជ្រាវមានទំហំតូច និងមិនមែនជាសំណាកគំរូតំណាង យើងមិនអាចប៉ាន់ប្រមាណអំពីទំហំនៃអំពើហិង្សា ដែលបានកើតឡើងនោះទេ។ ទោះជាយ៉ាងណា យើងអាចនិយាយថា ការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈលើជនជាតិភាគតិច គឺត្រូវបានរាយការណ៍យ៉ាងទូលំទូលាយដោយអ្នកផ្តល់បទសម្ភាសនៅទូទាំងសំណាកគំរូទាំងអស់ ជាមួយនឹងការរួមភេទដើម្បីរស់រានមានជីវិត ទាសករផ្លូវភេទ ការធ្វើកាយវិកលកម្មផ្លូវភេទ ការមាក់ងាយផ្លូវភេទ និងការលួចលាន់ដោយបំពាន ត្រូវបានរាយការណ៍ក្នុងចំនួនតិចជាង។ ជនរងគ្រោះមួយចំនួនត្រូវបានរាយការណ៍ថាបានទទួលរងអំពើហិង្សាផ្លូវភេទច្រើនដង ហើយជនល្មើសមួយចំនួនត្រូវបានរាយការណ៍ថា បានប្រព្រឹត្តសកម្មភាពបែបនេះច្រើនដង។

### ៤.៨.២. ជនល្មើស និងជនរងគ្រោះ

សំណួរសិក្សាស្រាវជ្រាវទីពីរសួរថា តើនរណាជាជនល្មើស និងជាជនជាតិភាគតិចដែលរងគ្រោះពីអំពើហិង្សាផ្លូវភេទ?

*ជនល្មើស*

ផ្អែកលើទិន្នន័យសិក្សាស្រាវជ្រាវនេះ យើងអាចកំណត់ចរិកលក្ខណៈមួយចំនួនរបស់ជនល្មើស។

## លទ្ធផលរកឃើញ

ទាក់ទងនឹងការរំលោភសេពសន្ថវៈ ការរួមភេទដើម្បីរស់រានមានជីវិត និងទាសករផ្លូវភេទលើជនជាតិភាគតិច ករណីអំពើហិង្សាផ្លូវភេទទាំងអស់លើកលែងតែពីរករណីជនល្មើសជាបុរស។ នៅពេលអាចកំណត់អាយុជនល្មើសបាន តាមការប៉ាន់ស្មាន ជនល្មើសមានអាយុម្ភៃឆ្នាំ ឬចាស់ជាងនេះ។ ក្នុងករណីចំនួនហាសិបពីរ ជនល្មើសមានអាយុចាប់ពី ១៨ឆ្នាំដល់ ៣០ឆ្នាំ ហើយក្នុងករណីចំនួនសែសិប ពួកគេមានអាយុលើសពី ៣០ឆ្នាំ និងក្នុងករណីចំនួនម្ភៃ ពួកគេត្រូវបានប៉ាន់ប្រមាណថា មានអាយុក្រោម ១៨ ឆ្នាំ។

អ្វីដែលច្បាស់ទទួលបានពីទិន្នន័យនេះ គឺថាអ្នកដែលធ្វើការឱ្យខ្មែរក្រហមជាអ្នកទទួលខុសត្រូវទាំងស្រុងលើអំពើហិង្សាផ្លូវភេទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងករណីទាំងអស់លើកលែងតែពីរករណី អ្នកផ្តល់បទសម្ភាសបានរាយការណ៍ថា ភ្នាក់ងារខ្មែរក្រហម ជាអ្នកប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ការរួមភេទដើម្បីរស់ និងទាសករផ្លូវភេទ។ លើសពីនេះ គោលនយោបាយរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំនៅក្នុងការរៀបការនេះគឺជាលទ្ធផលនៃរបបនេះ។ ទោះបីជាមានករណីដ៏កម្រទាក់ទងនឹងការមានទំនាក់ទំនងផ្លូវភេទរបស់ប្រជាជនស៊ីវិលជាមួយមនុស្សដទៃក្រៅពីប្តីប្រពន្ធខ្លួន ករណីទាំងនេះហាក់ដូចជាធ្វើឡើងដោយមានការព្រមព្រៀងគ្នា។

អ្នកផ្តល់បទសម្ភាសមួយចំនួនបានសង្កត់ធ្ងន់ថា ប្រជាជនសាមញ្ញគ្មានកម្លាំង ហេវហត់ ឬភ័យខ្លាចពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ។ អ្នកផ្តល់បទសម្ភាសបានសង្កេតឃើញថា មានតែខ្មែរក្រហមទេ ដែលមានធនធាន និងអំណាចក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ។

*ភាគច្រើន អ្នកដែលប្រព្រឹត្តការរំលោភសេពសន្ថវៈគឺពួកកម្មាភិបាល។*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរក្រោម

*មិនមានប្រជាជនសាមញ្ញណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទទេ។*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរក្រោម

*[ជនល្មើសនៃការរំលោភសេពសន្ថវៈគឺ] កម្មាភិបាលខ្មែរក្រហម ពីព្រោះមានតែពួកគេទេដែលហ៊ានធ្វើបែបនេះ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

*ខ្មែរក្រហម។ នរណាហ៊ានធ្វើបែបនេះ ក្រៅពីពួកគេ? គ្មាននរណាទេ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម ដែលកំណត់អត្តសញ្ញាណជនល្មើសនៃការរំលោភជាក្រុមលើស្ត្រីខ្មែរក្រហមម្នាក់

ជនល្មើសរួមមានមនុស្សប្រុសដែលមានតួនាទីខុសៗគ្នា រួមទាំងទាហានក្នុងតំបន់ ទាហានប្រធានអង្គភាព និងមន្ត្រី។

ប្រវត្តិរូបជនល្មើសនេះ គឺជាកត្តាចង្អុលបង្ហាញអំពីអំពើហិង្សាលើផ្លូវភេទមកលើប្រជាជនដោយមានចេតនាគ្រប់គ្រង ធ្វើឱ្យភិតភ័យ និងបំបាក់មុខជនរងគ្រោះ។

### *ជនរងគ្រោះ*

ចរិតលក្ខណៈជនរងគ្រោះទូទៅមួយចំនួន ក៏ត្រូវអាចកត់សម្គាល់បានតាមរយៈការរៀបរាប់របស់អ្នកផ្តល់បទសម្ភាសផងដែរ។

គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ស្ត្រីជនជាតិភាគតិចទំនងជាជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទក្នុងករណីរំលោភសេពសន្ថវៈ ការរួមភេទដើម្បីរស់ ទាសករផ្លូវភេទ និងការរំលោភបំពានផ្លូវភេទច្រើនជាងបុរស។ សូម្បីតែស្ថិតនៅក្នុងការរៀបការដោយបង្ខំ ដែលទាំងស្ត្រីទាំងបុរសអាចជាជនរងគ្រោះ ស្ត្រីផ្តល់បទសម្ភាសមួយចំនួនបានរាយការណ៍ថា ប្តីរបស់ខ្លួនបានរៀបចំការរៀបការឡើងដោយសារពួកគេជាទាហាន ឬមន្ត្រីខ្មែរក្រហម។ ពុំមានអ្នកផ្តល់បទសម្ភាសជាបុរសរាយការណ៍ថាប្រពន្ធរបស់ខ្លួនបានរៀបចំការរៀបការឡើងទេ។ មានករណីរាយការណ៍ថា ប្តីរបស់ខ្លួនបានគំរាមកំហែងថា នឹងរាយការណ៍ទៅអង្គការដើម្បីបង្ខំប្រពន្ធឱ្យរួមភេទជាមួយខ្លួន។ នេះមិនមែនចាត់ទុកថាជាការខកចិត្ត និងការបាក់ទឹកចិត្តឡើយ ដែលបុរសក៏ត្រូវបានបង្ខំការរៀបការ និង បង្ខំឱ្យរួមភេទជាមួយប្រពន្ធខ្លួន។ ផ្ទុយទៅវិញ គឺដើម្បីចង្អុលបង្ហាញថា ការឆ្លងកាត់មួយចំនួនរបស់ស្ត្រី និងបុរស ដែលត្រូវបានបង្ខំឱ្យរៀបការ ឬបង្ខំឱ្យរួមភេទជាមួយប្តីប្រពន្ធខ្លួនអាចមានភាពខុសគ្នា។ អ្វីគួរឱ្យកត់សម្គាល់ទាំងស្ត្រី និងបុរសគឺជាសាក្សីនៃអំពើហិង្សាផ្លូវភេទ ដែលពួកគេបានទទួលរងការប៉ះទង្គិចទឹកចិត្ត។

ទោះបីជាយ៉ាងណា ប្រវត្តិជនរងគ្រោះមានភាពធំទូលាយ។ ក្រៅពីករណីរៀបការដោយបង្ខំ ស្ត្រីនៅលីវ ស្ត្រីរៀបការហើយ និងស្ត្រីមេម៉ាយទទួលរងអំពើហិង្សាផ្លូវភេទ។ ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូនមិនរងផលប៉ះពាល់នោះទេ។ ទោះបីជាមិនបានសួរដោយផ្ទាល់ក៏ដោយ ពុំមានអ្នកផ្តល់បទសម្ភាសណាបានលើកឡើងថា មានជនរងគ្រោះណាម្នាក់ជាភ្នាក់ងាររបស់ខ្មែរក្រហមឡើយ ប៉ុន្តែលើកឡើងថា ជនរងគ្រោះភាគច្រើនបើទោះបីជាមិនមែនទាំងអស់ក៏ដោយ គឺជាជនស៊ីវិល។

នៅពេលផ្តោតតែលើការរំលោភសេពសន្ថវៈ ការរួមភេទដើម្បីរស់រានមានជីវិត និងទាសករផ្លូវភេទ ទិន្នន័យបង្ហាញថា តាមការប៉ាន់ស្មានលើអាយុជនរងគ្រោះ ជនរងគ្រោះជាជនជាតិភាគតិចទំនងជាស្ថិតនៅក្នុងអាយុខ្ទង់ម្ភៃ ឬក្មេងជាងនេះ។ តាមការប៉ាន់ស្មាន ក្នុងហុកសិបប្រាំករណី ជនរងគ្រោះមានអាយុចាប់ពី១៨ឆ្នាំ ដល់ ៣០ឆ្នាំ ក្នុងម្ភៃប្រាំមួយករណីជនរងគ្រោះមានអាយុក្រោម ១៨ឆ្នាំ ហើយ

## លទ្ធផលរកឃើញ

ក្នុងប្រាំបួនករណីជនរងគ្រោះមានអាយុលើសពី៣០ឆ្នាំ។ ប្រហែលមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ទិន្នន័យ បែបគុណវិស័យក៏បង្ហាញថា ស្ត្រីដែលស្រស់ស្អាត ដែលជាគោលដៅនៃការទទួលរងអំពើហិង្សាផ្លូវភេទ៖

*ពួកគេសុទ្ធតែជាស្ត្រីស្អាត។ ប្រសិនបើពួកគេមិនមែនជាស្ត្រីស្អាតទេនោះ ទាហានខ្មែរក្រហម មិនស្រឡាញ់ពួកគេទេ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម និយាយអំពីស្ត្រីចាមទទួលរងការរួមភេទដើម្បីរស់រានមានជីវិត។

*ពួកវារំលោភស្ត្រីស្អាតៗទាំងអស់ ទោះបីជាស្ត្រីទាំងនោះនៅលីវ ឬរៀបការរួចក៏ដោយ ឱ្យតែពួកវាត្រូវការ... ក៏មានស្ត្រីពោះធំដែលត្រូវយកទៅចាប់រំលោភ ដោយសារតែពួកនាងស្អាត។*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរក្រោមរៀបរាប់អំពីការរំលោភទ្រង់ទ្រាយធំរបស់ទាហាន។

*អ្នកខ្លះ ដូចជាស្ត្រីដែលរាងចំណាស់ប៉ុន្តែស្អាតក៏ត្រូវចាប់រំលោភដែរ។ ប៉ុន្តែពួកវាមិនរំលោភស្ត្រីមិនស្អាតទេ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម ពិពណ៌នាអំពីការរំលោភទ្រង់ទ្រាយធំ និងការសម្លាប់ខ្មែរក្រោម និងស្ត្រីខ្មែរដោយកម្មាភិបាលខ្មែរក្រហម។

*ពួកគេចាត់ទុកយើងជាសត្វ។ ស្ត្រីស្អាតៗទាំងអស់ត្រូវបានចាប់រំលោភ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាមពិពណ៌នាអំពីការចាប់រំលោភស្ត្រីខ្មែរឥស្លាមម្នាក់ទៀតដោយប្រធានអង្គភាព

## ៤.៨.៣ ព័ត៌មានលម្អិត និងចរិតលក្ខណៈនៃអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច

សំណួរសិក្សាស្រាវជ្រាវទីបីសួរអំពីព័ត៌មានលម្អិត និងចរិតលក្ខណៈនៃអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិច។ ព័ត៌មានជាច្រើននៃព័ត៌មានលម្អិតនោះត្រូវបាន បង្ហាញរួចទៅហើយនៅក្នុងលទ្ធផលរកឃើញ ប៉ុន្តែចំណុចបន្ថែមមួយចំនួនទៀត ត្រូវបានកត់បញ្ចូល។

ទិន្នន័យសិក្សាស្រាវជ្រាវបង្ហាញថា បទល្មើសទាំងនេះត្រូវបានប្រព្រឹត្តនៅតាមកន្លែងជាច្រើននៅទូទាំងប្រទេស។ បទល្មើសនេះត្រូវបានធ្វើឡើងនៅកន្លែងផ្សេងៗគ្នា ដូចជានៅកន្លែងគេង កន្លែងធ្វើការ នៅក្នុងសហករណ៍ នៅចំការ និងព្រៃ។ បទល្មើសទាំងអស់ត្រូវបានធ្វើឡើងដោយបុរសជាច្រើន។



*ស្ត្រីកំពុងធ្វើសក្ខីកម្មនៅក្នុងការស្តាប់សំឡេងស្ត្រីឆ្នាំ២០១៣ អំពីការបង្ខំរៀបការ*

ជួនកាល ជនល្មើសធ្វើតែម្នាក់ឯង ហើយជួនកាលទៀតធ្វើជាក្រុម។ ទាំងក្នុងករណីរំលោភសេពសន្ថវៈ និងទាសករផ្លូវភេទលើជនជាតិភាគតិច គឺជាករណីកើតឡើងជាទូទៅ ដោយជនល្មើសមានការព្រមព្រៀងការក្នុងប្រព្រឹត្តអំពើហិង្សាបែបនេះ។ ជនល្មើសបានប្រព្រឹត្តការរំលោភជាក្រុមចំនួន ៧៣% នៃករណីរំលោភសេពសន្ថវៈទាំងអស់ និងបានរំលោភជាក្រុមចំនួន ៧៨% នៃករណីទាសករផ្លូវភេទទាំងអស់។ ចំពោះការរួមភេទដើម្បីរស់រានមានជីវិត ជនល្មើសប្រព្រឹត្តតែម្នាក់ឯងក៏មានដែរ។ ប្រាំបីភាគរយនៃករណីទាំងនោះប្រព្រឹត្តដោយជនល្មើសតែម្នាក់ប៉ុណ្ណោះ។ ករណីនេះអាចឆ្លុះបញ្ចាំងអំពីការពិតថា មានការចរចារគ្នាក្នុងការរួមភេទដើម្បីរស់រានមានជីវិត ដែលអាចងាយស្រួលប្រព្រឹត្តដោយភាគីមានគ្នាតែម្នាក់។

ការរំលោភជាក្រុមបង្ហាញឱ្យឃើញអំពីការព្រមព្រៀងគ្នារវាងជនល្មើសក្នុងការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ ដែលជនល្មើសអាចប្រើប្រាស់ការរួមភេទសម្រាប់បង្កទំនាក់ទំនងជិតស្និទ្ធរវាងគ្នានិងគ្នា។ មានការលើកឡើងថា ជនល្មើសទទួលបានការលើកលែងទោសចំពោះបទល្មើសទាំងនេះ។

ទិន្នន័យបង្ហាញថា ជនជាតិភាគតិចបានក្លាយជាជនរងគ្រោះតែមួយគត់ក្នុងការរំលោភជាក្រុមតូច ឬទ្រង់ទ្រាយធំ។

ជាញឹកញាប់ បន្ទាប់ពីទទួលរងការរំលោភសេពសន្ថវៈ ទាសករផ្លូវភេទ និងការរួមភេទដើម្បីរស់រានមានជីវិត ជនរងគ្រោះត្រូវបានសម្លាប់ក្នុងករណីមួយចំនួន ដើម្បីរក្សាការសម្ងាត់។ ក្នុងរឿងរ៉ាវរបស់អ្នកផ្តល់បទសម្ភាសទាំងអស់ លើកលែងតែមួយគត់ ស្ត្រីជនជាតិភាគតិចម្នាក់ ដែលមានគភ៌ដោយមិនបានរៀបការ ត្រូវបានសម្លាប់ដោយជនល្មើស ឬដោយអង្គការ ដើម្បីជាការដាក់ទោស នៅពេលដែលសម្រាលកូនរួចហើយ។ ក្នុងករណីពិសេស អ្នកផ្តល់បទសម្ភាសមិនបានដឹងអ្វីដែលបានកើតឡើងចំពោះស្ត្រីមានគភ៌ទេ បន្ទាប់ពីគាត់បានសម្រាលកូនរួចហើយ។ ក្នុងករណីខ្លះ ខ្មែរក្រហមបានជ្រើសរើសស្ត្រីសម្រាប់រំលោភ បន្ទាប់មកសម្លាប់ចោលដូចបានគ្រោងទុក។

អ្នកផ្តល់បទសម្ភាសបានរាយការណ៍អំពីករណីមួយចំនួន ដែលជនល្មើសត្រូវបានសម្លាប់ តដោយសារការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ នៅពេលបទល្មើសរបស់ពួកគេត្រូវបានគេដឹង។ ក្នុងករណី

## លទ្ធផលរកឃើញ

ដែលស្ត្រីខ្មែរក្រោមម្នាក់ទទួលរងការរួមភេទដើម្បីរស់រានមានជីវិតជាមួយប្រធានអង្គភាព ដើម្បីប្តូរយកអាហារ និងបន្ទាប់មកនាងក៏មានផ្ទៃពោះ អ្នកទាំងពីរក៏ត្រូវបានសម្លាប់ដោយខ្មែរក្រហមជាការដាក់ទោស។ ក្នុងករណីមួយទៀត អ្នកផ្តល់បទសម្ភាសបានរាយការណ៍អំពីការសម្លាប់ជនល្មើសម្នាក់បន្ទាប់ពីជនរងគ្រោះបានស្លាប់៖

> *នៅពេលនោះ ម្តាយខ្ញុំក៏បានស្លាប់ ពីព្រោះគាត់ឈឺធ្ងន់ ក្រោយត្រូវបានចាប់រំលោភ... គាត់ស្អាតស្បែកភ្លឺថ្លា ជាកូនចិនកាត់វៀតណាម... គាត់ត្រូវបានចាប់រំលោភនៅកណ្តាលវាលស្រែ។ បន្ទាប់ពីការចាប់រំលោភ គាត់មិនបានស្លាប់ភ្លាមៗនោះទេ។ គាត់បានត្រឡប់មកផ្ទះ ហើយហូរឈាមរហូតទាល់តែស្លាប់។ អ្នករំលោភត្រូវបានសម្លាប់ នៅពេលគេដឹងថាជននោះបានប្រព្រឹត្តអំពើនោះ។*
>
> -អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ទោះជាយ៉ាងណា ក្នុងករណីភាគច្រើនដែលត្រូវបានរាយការណ៍ គ្មានការដាក់ទណ្ឌកម្មលើជនល្មើសឡើយ លើសពីនេះភស្តុតាងបង្ហាញទៀតថា ជនល្មើសអាចប្រព្រឹត្តដោយមានការលើកលែងទោស។ ជនល្មើសមួយចំនួនបន្តប្រើអំពើហិង្សាផ្លូវភេទទៅលើជនរងគ្រោះដទៃទៀត។ ការបង្ហាញជាសាធារណៈនូវប្រដាប់ភេទដែលត្រូវបានកាត់ចេញ សាកសពអាក្រាតកាយទុកទីវាល ជូនកាលមានភស្តុតាងអំពីការរំលោភដោយប្រើវត្ថុចម្លែក និងការស្តាប់ឮការជជែកគ្នារវាងជនល្មើសអំពីសកម្មភាពរបស់ពួកគេ បង្ហាញថា ជនល្មើសតែងតែអួតប្រាប់គ្នាអំពីបទល្មើសរបស់ខ្លួនជាជាងលាក់ទុកជាការសម្ងាត់។

ការរៀបរាប់របស់អ្នកផ្តល់បទសម្ភាសបង្ហាញយ៉ាងច្បាស់ថា ពួកគេជាញឹកញាប់មានភាពភ័យរន្ធត់ដោយសារតែភាពសាហាវព្រៃផ្សៃរបស់ជនល្មើសក្នុងការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ។ ពាក្យ "ព្រៃផ្សៃ" ជាញឹកញាប់ ត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាអំពីអត្តចរិករបស់ជនល្មើសទាំងនេះ។ ស្ត្រីម្នាក់បានរាយការណ៍អំពីការស្តាប់ឮកម្មាភិបាលអួតអំពីការចាប់រំលោភ និងការសម្លាប់ស្ត្រីថា៖

> *ពួកគេនិយាយអំពីអ្វីដែលពួកគេបានធ្វើលើស្ត្រីទាំងអស់នោះ។ បុរសម្នាក់បាននិយាយថា គាត់បានរួមភេទដេកចំហៀងជាមួយស្ត្រីម្នាក់ និងបានសម្លាប់ស្ត្រីម្នាក់ទៀតដែលរត់គេចតាមវាលស្រែ។ នាងបានស្លាប់នៅកន្លែងនោះ។ ពួកគេនិយាយថា ពួកគេសប្បាយនឹងការរំលោភ និងសម្លាប់ណាស់។ ពួកគេស្រវឹង ហើយពួកគេសម្លៀងកាំបិតរបស់ពួកគេសម្រាប់សម្លាប់។*
>
> -អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

អំពើហិង្សាផ្លូវភេទបានធ្វើឱ្យប្រជាជនមានការភ័យខ្លាចយ៉ាងខ្លាំង ដូចបានបង្ហាញក្នុងការពិពណ៌នាអំពីជនល្មើស និងការសម្លាប់ស្ត្រីខ្មែរក្រោម៖

*យប់មួយ វាបានមកភូមិនេះ។ ខ្ញុំបានឃើញខ្លួនវាពោរពេញដោយស្នាមឈាម ពីព្រោះវាទើបតែបានសម្លាប់មនុស្ស។ បន្ទាប់ពីវាត្រឡប់មកភូមិវិញ វាគ្រាន់តែលាងដៃ ហើយបន្ទាប់មកមកគំរាមខ្ញុំ។ ខ្ញុំភ័យស្ទើរស្លាប់ទៅហើយ...*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ក្រៅពីករណីរៀបការដោយបង្ខំ អ្នកផ្តល់បទសម្ភាសពិតជាភ័យខ្លាចយ៉ាងខ្លាំងថា គេដឹងនិងសម្លាប់ដោយសារខ្លួនបានតាមដានករណីអំពើហិង្សាផ្លូវភេទ។ ស្ទើរតែគ្រប់គ្នា ដែលបានឃើញករណីអំពើហិង្សាផ្លូវភេទនិយាយអំពីភាពភ័យខ្លាចនេះ។ ទោះបីជាមានគ្រោះថ្នាក់ក៏ដោយ ក៏អ្នកផ្តល់បទសម្ភាសមួយចំនួនបានព្យាយាមស៊ើបថាតើមានអ្វីកើតឡើង។ ការរៀបរាប់របស់អ្នកផ្តល់បទសម្ភាសខាងក្រោមពិពណ៌នាអំពីគ្រោះថ្នាក់ ដែលបានឃើញអំពើហិង្សាបែបនេះ៖

*ប្រសិនបើអ្នកចង់ឃើញ ឬ លបមើលពួកគេ នោះអ្នកនឹងមិនអាចរួចខ្លួនទេ។ អ្នកនឹងត្រូវសម្លាប់។ ឬប្រសិនបើអ្នកចាកចេញពីផ្ទះក្នុងអំឡុងពេលល្ងាច និងតាមដានពួកគេ អ្នកអាចនឹងស្លាប់ដែរ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម រៀបរាប់អំពីភាពភ័យខ្លាចអំពីការដឹងអំពីការរំលោភនិងការសម្លាប់

*វាបានរំលោភស្ត្រីម្នាក់នៅក្នុងភូមិ។ ខ្ញុំបានឃើញនៅពេលនោះ។ ប៉ុន្តែ ខ្ញុំធ្វើជាមិនឃើញអ្វីទាំងអស់ ដើម្បីសុវត្ថិភាព។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

*ប៉ុន្តែខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែកខ្ញុំអំពីការដែលពួកគេរំលោភនាង ឬចងដៃនាងឡើងលើឡើយ។ ខ្ញុំដឹងពីព្រោះពួកគេប្រាប់ខ្ញុំ។ ទោះបីជាដឹងថានាងបានស្លាប់ហើយក៏ដោយ យើងមិនហ៊ានទៅយកសាកសពនាងទេ។ គ្រួសាររបស់ខ្ញុំមិនហ៊ានប្រឆាំងនឹងពួកគេទេ សូម្បីតែមើលមុខក៏មិនហ៊ានដែរ...*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីជនជាតិភាគតិចវៀតណាមរៀបរាប់អំពីការរំលោភសេពសន្ថវៈ និងការសម្លាប់បងប្អូនជីដូនមួយរបស់គាត់

*ពួកវាជាទាហានរបស់ប៉ុល ពត។ ពួកវាព្រៃផ្សៃណាស់។ ខ្ញុំបានឃើញព្រឹត្តិការណ៍នោះម្តងគត់... ប្រសិនបើពួកវាដឹងថា យើងដឹងអំពីរឿងនោះ ពួកវាប្រាកដជាសម្លាប់ពួកយើង។ ជនរងគ្រោះបានបាត់ខ្លួន បន្ទាប់ពីនាងត្រូវបានរំលោភ។*

- អ្នកផ្តល់បទសម្ភាសជាបុរសជនជាតិចាម

## លទ្ធផលរកឃើញ

អ្នកផ្តល់បទសម្ភាសជាស្ត្រីមួយចំនួនបាននិយាយអំពីភាពភ័យខ្លាចរបស់ពួកគេក្នុងការក្លាយជាជនរងគ្រោះបន្ទាប់ ដូចដែលស្ត្រីម្នាក់រៀបរាប់ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ និងការសម្លាប់ស្ត្រីម្នាក់ទៀតដោយពួកទាហាន។

*នៅពេលនោះ ខ្ញុំភ័យខ្លាចណាស់... ហើយបន្ទាប់មក គាត់ត្រូវបានយកចេញក្រៅ។ ខ្ញុំបានលបមើលគាត់ នៅពេលដែលគាត់ត្រូវបានគេចាប់ខ្លួន... ខ្ញុំបានគិតថា គាត់ត្រូវបានគេចាប់នៅលើកនេះ ហើយខ្ញុំអាចត្រូវគេចាប់នៅលើកក្រោយ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីជនជាតិភាគតិចវៀតណាម

ប្រាកដណាស់ សាក្សីមកពីក្រុមជនជាតិភាគតិចដូចគ្នាជាជនរងគ្រោះ ឬមានជាប់ពាក់ព័ន្ធនឹងជនរងគ្រោះមានភាពភ័យខ្លាចកាន់តែខ្លាំងឡើងអំពីការក្លាយជាមុខសញ្ញាបន្ទាប់។ អ្នកផ្តល់បទសម្ភាសម្នាក់ បាននិយាយអំពីការបដិសេធថាមិនស្គាល់ជនរងគ្រោះដែលទទួលរងការរំលោភសេពសន្ថវៈ និងការសម្លាប់ ៖

*...នាងត្រូវបានបុរសបីនាក់ចាប់រំលោភ តាមខ្ញុំដឹង ខ្មែរម្នាក់សួរថាតើខ្ញុំស្គាល់ស្ត្រីចាមដែលត្រូវបានសម្លាប់នោះទេ ហើយថាតើម្នាក់ហ្នឹងជាសាច់ញាតិរបស់ខ្ញុំមែនទេ? ខ្ញុំបាននិយាយថាខ្ញុំអត់ស្គាល់នាងទេ។ នៅពេលនោះ ប្រសិនបើយើងនិយាយថា យើងស្គាល់ [ជនរងគ្រោះ] ពួកវានឹងសម្លាប់យើងចោលទាំងអស់... [អ្នកសម្ភាស៖ តាមពិត អ្នកស្គាល់គាត់មែនទេ?] ចាស គាត់ជាសាច់ញាតិរបស់ខ្ញុំ។ គាត់ជាមីងរបស់ខ្ញុំ មីងរបស់ជីតាទួតខ្ញុំ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីជនជាតិចាម

អ្នកផ្តល់បទសម្ភាសជាច្រើនបាននិយាយអំពីការគ្មានសិទ្ធិក្នុងការអន្តរាគមន៍ នៅពេលដែលពួកគេដឹងអំពីអំពើហិង្សាផ្លូវភេទ ដែលនឹងកើតឡើងលើនរណាម្នាក់ ដូចបានបញ្ជាក់ក្នុងការរៀបរាប់អំពីការចាប់ខ្លួន ការរំលោភសេពសន្ថវៈ និងការសម្លាប់ស្ត្រីក្មេងជនជាតិភាគតិចវៀតណាមម្នាក់ដូចខាងក្រោម៖

*ខ្ញុំបានឃើញពួកវាចាប់នាងនៅម៉ោង១១ព្រឹក។ ខ្ញុំបានឃើញ ប៉ុន្តែខ្ញុំគ្រាន់តែធ្វើដូចជាគ្មានអ្វីកើតឡើង ដើម្បីសុវត្ថិភាព។ នៅពេលដែលគាត់ត្រូវបានគេចាប់ខ្លួន គាត់យំខ្លាំងណាស់... គាត់ស្រែកយំ ប៉ុន្តែគ្មាននរណាម្នាក់ជួយគាត់ឡើយ។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

ស្ត្រីម្នាក់រៀបរាប់អំពីលទ្ធផល ដែលឪពុកគាត់ទៅជួយកូនស្រីច្បងរបស់គាត់ ដែលត្រូវគេរំលោភ៖

*ខ្ញុំក៏បានទៅប្រាប់ឪពុករបស់ខ្ញុំថា បងស្រីរបស់ខ្ញុំត្រូវគេរំលោភ។ នៅពេលដែលឪពុកខ្ញុំទៅដល់កន្លែង ដែលបងស្រីខ្ញុំត្រូវគេរំលោភនោះ ពួកវា [ជនល្មើស] សួរឪពុកខ្ញុំថាតើឪពុកខ្ញុំចង់ធ្វើអ្វី។ ពួកវាបាននិយាយថា ពួកវារំលោភបងស្រីរបស់ខ្ញុំ ហើយបន្ទាប់មកពួកវាចងឪពុករបស់ខ្ញុំ។ ដៃរបស់ឪពុកខ្ញុំត្រូវវាកាត់។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

## ៤.៨.៤ ភាពខុសគ្នានៃការទទួលរងអំពើហិង្សាផ្លូវភេទរបស់ជនជាតិភាគតិច

សំណួរសិក្សាស្រាវជ្រាវទីបួនសួរថាតើជនជាតិភាគតិចទទួលរងអំពើហិង្សាផ្លូវភេទខុសគ្នាពីប្រជាជនទូទៅដែរឬទេ?

ប្រការសំខាន់ត្រូវកត់សម្គាល់ជាដំបូងសិនថា មានភាពស្រដៀងគ្នាជាច្រើនរវាងរឿងរ៉ាវអំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចនៅក្នុងការសិក្សានេះ និងរឿងរ៉ាវអំពើហិង្សាផ្លូវភេទលើប្រជាជនទូទៅ ដែលត្រូវបានរាយការណ៍នៅក្នុងការសិក្សាផ្សេងទៀត។ ដូចបានរៀបរាប់លម្អិតនៅក្នុងជំពូកសាវតា ការសិក្សាលើប្រជាជនទូទៅបានចងក្រងស្រដៀងគ្នានូវរបាយការណ៍ស្តីពីអំពើហិង្សាផ្លូវភេទនៅក្នុងតំបន់ជាច្រើននៅទូទាំងប្រទេសកម្ពុជា។ អំពើហិង្សាផ្លូវភេទប្រភេទនេះដែលកើតឡើងលើប្រជាជនទូទៅ ឆ្លុះបញ្ចាំងពីលើអំពើហិង្សាទាំងឡាយដែលរកឃើញក្នុងការសិក្សានេះដែលប្រព្រឹត្តលើជនជាតិភាគតិច។ ដូចគ្នាក្នុងការសិក្សានេះ ជនល្មើសដែលប្រព្រឹត្តអំពើហិង្សាផ្លូវភេទលើប្រជាជនទូទៅ គឺភាគច្រើនសុទ្ធតែជាភ្នាក់ងារខ្មែរក្រហម។ លើសពីនេះ ការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាផ្លូវភេទលើប្រជាជនទូទៅបានរកឃើញថា ជនល្មើសភាគច្រើនជាបុរស ហើយជនរងគ្រោះជាស្ត្រី ដូចគ្នាក្នុងការសិក្សាស្រាវជ្រាវនេះដែរ។

ទោះបីជាមានភាពស្រដៀងគ្នាក៏ដោយ ក៏ទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះពិតជាបានបង្ហាញចំណុចខុសគ្នាសំខាន់ៗមួយចំនួន។

មានភស្តុតាងមួយចំនួនមកពីទិន្នន័យនេះបង្ហាញថា ការអនុវត្តការរៀបការដោយបង្ខំរបស់ខ្មែរក្រហមត្រូវបានប្រើប្រាស់ ដើម្បីបំបែកប្រជាជនជនជាតិភាគតិច។ ស្ត្រីម្នាក់បានលើកឡើងថា អ្នកកាន់សាសនាឥស្លាមត្រូវបានចាត់តាំងឱ្យរៀបការជាមួយប្តីប្រពន្ធខ្មែរ ក្នុងគោលបំណងលុបបំបាត់ក្រុមនេះដោយបញ្ចូលទៅក្នុងចំណោមប្រជាជនខ្មែរដែលមានទំហំធំជាង៖

## លទ្ធផលរកឃើញ

*នៅអំឡុងពេលនោះ ពួកវាបង្ខំមិនឱ្យយើងរៀបការជាមួយជនជាតិចាមដូចគ្នាទេ។ ពួកវាបញ្ជាឱ្យយើងរៀបការជាមួយខ្មែរ ប៉ុន្តែមិនមែនចាមទេ... ពួកវាប្រាប់ខ្ញុំមុនថា មិនអនុញ្ញាតឱ្យអ្នក [ឈ្មោះអ្នកផ្តល់បទសម្ភាស] មានប្តីជាចាមទេ។ អ្នកត្រូវមានប្តីជាខ្មែរ ពីព្រោះអ្នកមករស់នៅ [កម្ពុជា]។ ឥឡូវប្រជាជនទាំងអស់ជាខ្មែរ ហើយជាទូទៅ គ្មានចាមគ្មានខ្មែរឡើយ។ ពួកគេនិយាយអីចឹង...*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីជនជាតិចាមរៀបរាប់អំពីការដែលខ្មែរក្រហមបង្ខំឱ្យរៀបការ

អ្នកផ្តល់បទសម្ភាសបានបង្ហាញថា ស្ត្រី និងក្មេងស្រីជនជាតិភាគតិចមិនមែនត្រឹមតែជាគោលដៅនៃអំពើហិង្សាផ្លូវភេទរបស់ខ្មែរក្រហមជាញឹកញាប់នោះទេ ប៉ុន្តែក៏ត្រូវបានជ្រើសរើសសម្រាប់រំលោភ ដូចការរៀបរាប់ខាងក្រោម៖

*ពួកវាស្អប់ខ្មែរឥស្លាម។ ពួកវាគ្រាន់តែចង់រំលោភពួកឥស្លាមប៉ុណ្ណោះ។ ពួកវានិយាយថា ពួកវានឹងរំលោភស្ត្រីខ្មែរឥស្លាមដែលស្អាតៗ។ ប៉ុន្តែខ្ញុំមិនដែលឃើញផ្ទាល់ទេ ខ្ញុំគ្រាន់តែបានឮអ្វីដែលពួកវានិយាយប៉ុណ្ណោះ។ ពួកវាធ្វើបាបខ្មែរឥស្លាម។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាមរៀបរាប់អំពីការរំលោភស្ត្រីខ្មែរឥស្លាមម្នាក់ ដោយកម្មាភិបាលខ្មែរក្រហម

*ខ្មែរឥស្លាម ពួកវារំលោភ ហើយសម្លាប់។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរឥស្លាម

*ស្ត្រីជនជាតិវៀតណាមត្រូវបានរំលោភ។ ស្ត្រីខ្មែរមិនត្រូវបានរំលោភនៅកន្លែងខ្ញុំទេ ប៉ុន្តែត្រូវបានសម្លាប់... ស្ត្រីវៀតណាមត្រូវបានរំលោភ ខណៈបុរសវៀតណាមត្រូវបានបាញ់សម្លាប់។*

- អ្នកផ្តល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

*នៅពេលប្រធានអង្គភាពឃើញថានរណាម្នាក់ស្អាតក្នុងចំណោមស្ត្រីខ្មែរកម្ពុជាក្រោម វានឹងយកនាងទៅរំលោភ។ គ្មាននរណាម្នាក់ហ៊ាននិយាយអ្វីអំពីរឿងហ្នឹងទេ ប្រសិនបើនិយាយ ពួកវានឹងសម្លាប់ចោល...*

- អ្នកផ្តល់បទសម្ភាសជាបុរសខ្មែរក្រោម

អ្នកផ្តល់បទសម្ភាសក៏បានរាយការណ៍ដែរថា ជួនកាល និងនៅកន្លែងមួយចំនួន ជនជាតិភាគតិចត្រូវបានកំណត់ជាគោលដៅនៃការកម្ទាត់ចោល។ ក្នុងករណីទាំងនោះ ស្ត្រីមួយចំនួន ឬទាំងអស់

ត្រូវបានជ្រើសរើសយកមករំលោភសិន ហើយបន្ទាប់មកសម្លាប់ចោល ៖

*នៅពេលក្រុមជនជាតិភាគតិចខ្មែរកម្ពុជាក្រោមត្រូវបានយកចេញពីប្រជាជនទូទៅ នាងត្រូវបានបំបែកឱ្យរស់នៅបែកពីប្ដី។ នាងស្អាតណាស់។ ស្ត្រីខ្មែរក្រោមសស្អាតណាស់!... នៅពេលមេទាហានបានឃើញនាង វាសម្រេចបញ្ជូននាងទៅវាលពិឃាតសិន។ វារំលោភ និងសម្លាប់នាងដោយបាញ់សម្លាប់ក្រោមដើមរការនៅភាគខាងជើងនៃកន្លែងនោះ។*

- អ្នកផ្ដល់បទសម្ភាសជាបុរស (ជនជាតិផ្សេងទៀត)

*ពួកគេទាំងអស់គឺជាស្ត្រីក្មេងៗដែលនៅលីវ។ ពួកនាងត្រូវបានគេរំលោភ ហើយសម្លាប់ចោលនៅទីបញ្ចប់... ស្ត្រីក្មេងៗទាំងនេះគឺជាខ្មែរកម្ពុជាក្រោម... តាមខ្ញុំដឹង ពួកវា [ខ្មែរក្រហម] ចាប់ស្ត្រីទាំងនេះ ហើយបន្ទាប់មកដោះអ្វីៗចេញទាំងអស់ សម្លៀកបំពាក់ និងអាវទ្រនាប់របស់ពួកនាង... ពួកវាបានសម្លាប់ស្ត្រីទាំងអស់នេះដោយគ្មានលើកលែងនរណាម្នាក់ដោយប្រើកាំបិតអារក។ មានស្ត្រីចំនួនប្រមាណ៤០០-៥០០នាក់ ដែលរស់នៅជាមួយខ្ញុំ។ ពួកគេទាំងអស់ត្រូវបានយកទៅសម្លាប់ក្នុងរយៈពេលបីថ្ងៃ។ ខ្ញុំបានឃើញស្ត្រីជាច្រើនត្រូវបានយកចេញពីអង្គភាពការងាររបស់ខ្ញុំទៅកន្លែងមួយ ហើយបន្ទាប់មកពួកនាងត្រូវបានរំលោភទាំងអស់មុនពេលសម្លាប់។*

- អ្នកផ្ដល់បទសម្ភាសជាស្ត្រីខ្មែរក្រោម

# ៩. សេចក្ដីសន្និដ្ឋាន





លទ្ធផលរកឃើញនៃការសិក្សាស្រាវជ្រាវនេះ បានផ្ដល់ភស្តុតាងបន្ថែមទៀតអំពីការប្រើប្រាស់អំពើហិង្សាផ្លូវភេទជាទូទៅដោយភ្នាក់ងារខ្មែរក្រហមលើប្រជាជនស៊ីវិលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទិន្នន័យបង្ហាញថា ជនជាតិភាគតិចទទួលរងប្រភេទអំពើហិង្សាផ្លូវភេទដូចគ្នានឹងប្រជាជនទូទៅដែរក្នុងបរិយាកាស និងស្ថានភាពស្រដៀងគ្នា ដូចត្រូវបានកត់ត្រាទុកជាឯកសារនៅក្នុងការសិក្សាស្រាវជ្រាវមុនៗ។ អ្វីដែលសំខាន់សម្រាប់សំណួរដែលលើកឡើងក្នុងការសិក្សាស្រាវជ្រាវនេះ ទិន្នន័យនេះបង្ហាញថា ជនជាតិភាគតិចត្រូវបានកំណត់ជាគោលដៅនៃការទទួលរងអំពើហិង្សាផ្លូវភេទក្នុងទម្រង់មួយចំនួនដូចជាការរំលោភសេពសន្ថវៈ និងការរំលោភមុនសម្លាប់។ លើសពីនេះ មានភស្តុតាងថា គោលនយោបាយរៀបការដោយបង្ខំរបស់ខ្មែរក្រហមត្រូវបានរបបនេះប្រើប្រាស់ជាយុទ្ធសាស្ត្រក្នុងការ “រំលាយ” ជនជាតិភាគតិចបញ្ចូលទៅក្នុងប្រជាជនទូទៅ។

ទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះ បង្ហាញពីភាពមិនពិតនៃការប្រឆាំងរបស់ខ្មែរក្រហមលើ “ការប្រព្រឹត្តអសីលធម៌” ដែលមានចែងក្នុងគោលនយោបាយហាមឃាត់ការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ និងការរួមភេទជាមួយអ្នកដទៃក្រៅពីប្ដីប្រពន្ធខ្លួនរបស់ខ្មែរក្រហម។ ទិន្នន័យក្នុងការសិក្សាស្រាវជ្រាវនេះ និងនៅក្នុងការសិក្សាលើកមុនបង្ហាញថា គោលនយោបាយនេះមិនបានបង្ការអំពើហិង្សាផ្លូវភេទជាច្រើនប្រភេទ ដែលត្រូវបានកើតឡើងយ៉ាងទូលំទូលាយលើសហគមន៍ជនជាតិភាគតិចប្រព្រឹត្តដោយភ្នាក់ងារខ្មែរក្រហមជាច្រើន។ ជាការពិត លទ្ធផលមួយក្នុងចំណោមលទ្ធផលនៃគោលនយោបាយនេះ គឺការលើកទឹកចិត្តដល់ជនល្មើសមួយចំនួនឱ្យសម្លាប់ជនរងគ្រោះ ដើម្បីរក្សាអំពើហិង្សាផ្លូវភេទជាការសម្ងាត់។ សាក្សីនៃអំពើហិង្សាផ្លូវភេទក៏ប្រឈមនឹងគ្រោះថ្នាក់នៃការសម្លាប់ ដើម្បីរក្សាការសម្ងាត់ដែរ។ គេអាចនិយាយបានថា តើការរំលោភសេពសន្ថវៈលើស្ត្រីជនជាតិភាគតិច បន្ទាប់មកសម្លាប់ចោល គឺជាយុទ្ធសាស្ត្រមួយរបស់ជនល្មើស ដើម្បីលាក់កំបាំងបទល្មើសផ្លូវភេទរបស់ខ្លួន ឬថាតើការរំលោភសេពសន្ថវៈ គឺគ្រាន់តែជាការដាក់ទោសបន្ថែមមកលើស្ត្រីជនជាតិភាគតិចឬយ៉ាងណា? ការលើកទឹកចិត្តទាំងនេះអាចមិនមែនធ្វើបានតែមួយនោះទេ។ ប្រសិនបើជនរងគ្រោះរួចផុតពីការសម្លាប់

បន្ទាប់ពីទទួលរងអំពើហិង្សាផ្លូវភេទ ពួកគេត្រូវប្រឈមគ្រោះថ្នាក់កាន់តែខ្លាំង ប្រសិនបើពួកគេមានផ្ទៃពោះ ពីព្រោះវានឹងក្លាយជាភស្តុតាងនៃសកម្មភាពផ្លូវភេទ និងជាកត្តាបណ្តាលឱ្យមានការសម្លាប់ពួកគេចោល។

ទោះបីជាមានគោលនយោបាយហាមឃាត់ការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ និងការរួមភេទជាមួយអ្នកដទៃក្រៅពីប្តីប្រពន្ធខ្លួនក៏ដោយ ក៏ជនល្មើសជាច្រើនពុំមានបារម្ភអំពីការជាប់ទោសឡើយ។ មានតែករណីមួយចំនួនប៉ុណ្ណោះដែលរាយការណ៍ថា ជនល្មើសត្រូវបានដាក់ទោស។ ក្រៅពីនេះ ពុំមានការស៊ើបអង្កេត ឬការដាក់ទណ្ឌកម្មលើជនល្មើសឡើយ។ របាយការណ៍អំពីជនល្មើសប្រព្រឹត្តអំពើហិង្សាផ្លូវភេទរួមគ្នា ធ្វើសកម្មភាពដោយមានការដឹងឮពីថ្នាក់លើរបស់ពួកគេ ធ្វើសកម្មភាពដោយមានការដឹងឮពីសហគមន៍ក្នុងតំបន់ ការអួតប្រាប់គ្នាអំពីសាកសពរបស់ជនរងគ្រោះ និងការនិយាយអំពីឧក្រិដ្ឋកម្មរបស់ពួកគេ គឺជាភស្តុតាងបង្ហាញឱ្យឃើញការមិនយកទោសពៃលើជនល្មើសដែលប្រព្រឹត្តអំពើហិង្សាផ្លូវភេទ។

អំពើដែលបានរៀបរាប់ក្នុងរបាយការណ៍នេះ ប្រវត្តិរបស់ជនល្មើស និងជនរងគ្រោះ និងបរិយាកាសនិទណ្ឌភាព ត្រូវបានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិកំណត់និយមន័យថាជាអំពើហិង្សាផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជាអំពើប្រល័យពូជសាសន៍[104]។ ឬអាចនិយាយបានថា របបនេះបានឯកភាពឱ្យមានការប្រើប្រាស់អំពើហិង្សាផ្លូវភេទ ជាយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង "ដាក់ទណ្ឌកម្ម មាក់ងាយ ឬបំផ្លាញក្រុមណាមួយ ធ្វើឱ្យភ័យខ្លាចបន្តិចម្តងៗ ឬធ្វើឲ្យប្រជាជនភៀសខ្លួនទៅកន្លែងមួយ"។ ការអះអាងនេះជាភស្តុតាងបន្ថែម នៅពេលពិចារណាអំពីការប្រព្រឹត្តរបស់ខ្មែរក្រហមលើជនជាតិភាគតិច ដែលត្រូវបានសិក្សាស្រាវជ្រាវក្នុងការស្រាវជ្រាវនេះ។ ភាពព្រៃផ្សៃខ្លាំងឡើងៗមកលើជនជាតិភាគតិចវៀតណាម និងខ្មែរក្រោម ដែលបណ្តាលឱ្យមានការកម្ចាត់ចោលកាន់ច្រើនឡើងក្នុងដំណាក់កាលបន្ទាប់នៃរបបនេះ ក៏ដូចជា ការព្យាយាមលុបបំបាត់វប្បធម៌ និងជាតិពន្ធរបស់ខ្មែរឥស្លាម និងចាម (រួមទាំងតាមរយៈការសម្លាប់ទ្រង់ទ្រាយធំ) នឹងបង្កឱ្យមានការប្រព្រឹត្តអំពើហិង្សាផ្លូវភេទកាន់តែខ្លាំងឡើង។

ទាក់ទងនឹងចំណុចនេះ ឧក្រិដ្ឋកម្មហិង្សាផ្លូវភេទលើជនជាតិភាគតិចគួរទទួលបានការយកចិត្តទុកដាក់ពិសេសក្នុងដំណើរការផ្តល់យុត្តិធម៌អន្តរកាលដែលត្រូវបានអនុវត្តនៅក្នុងបរិបទយុត្តិធម៌សម្រាប់ឧក្រិដ្ឋជន និងប្រជាជនស៊ីវិល។

---

104 មហាសន្និបាតក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (A/66/657*–S/2012/33*), របាយការណ៍របស់អគ្គលេខាធិការស្តីពីអំពើហិង្សាផ្លូវភេទក្នុងពេលសង្គ្រាម (១៣ ខែមករា ឆ្នាំ២០១២។ ជាការពកថាខណ្ឌ (បានឱ្យកុមារី ស្ត្រី និងការពារទៀត ឱ្យដទៃស្ថាប័នជាប្រតិករ និងរដ្ឋជំរុញបានសន្តិសុខឆ្លើយតប ក្រុមប្រឹក្សាជំទាស់ប្រសើរ និងកាន់តែ ការលើកលែងទោសចំពោះបទឧក្រិដ្ឋអំពើហិង្សា ផ្លូវភេទដែលបានប្រព្រឹត្តនៅពេលជិតផុតសង្គ្រាម។

# សេចក្តីសន្និដ្ឋាន



ជនជាតិភាគតិចទទួលរងអំពើហិង្សាផ្លូវភេទដែលនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ បន្តទទួលរងផលប៉ះពាល់នៃអំពើហិង្សានោះជាបន្តបន្ទាប់ ជាពិសេសផលប៉ះពាល់ផ្លូវចិត្ត។ ការទទួលរងអំពើហិង្សាផ្លូវភេទដោយផ្ទាល់ ការឃើញសកម្មភាពទាំងនេះប្រព្រឹត្តលើអ្នកដទៃ រួមទាំងការឃើញសាកសពដែលត្រូវបានកាត់ផ្តាច់ និងភាពភ័យខ្លាចត្រូវគេរំលោភ និងសម្លាប់ បានបណ្តាលឱ្យអ្នកផ្តល់បទសម្ភាសជាច្រើនក្នុងការសិក្សាស្រាវជ្រាវនេះ ទទួលរងការប៉ះទង្គិចផ្លូវចិត្តយូរអង្វែង។ ក្រុមសិក្សាស្រាវជ្រាវមានការមិនសប្បាយចិត្ត នៅពេលឃើញមានមនុស្សតិចតួចបានទទួលសេវា និងការគាំទ្រផ្លូវការ ជាពិសេស នៅពេលអ្នកដែលបានទទួលសេវានោះបានទទួលប្រយោជន៍ពីវា។ ការរងចាំដ៏យូរក្នុងការទទួលបានយុត្តិធម៌ពីឧក្រិដ្ឋកម្មដែលបានជួបប្រទះ បណ្តាលឱ្យមានឥទ្ធិពលអាក្រក់ដល់អ្នកនៅរស់រានមានជីវិត ដែលព្រួយបារម្ភថា មេដឹកនាំខ្មែរក្រហមដែលត្រូវបានកាត់ទោសនឹងស្លាប់មុនពេលកាត់ទោស។ ដំណើរការសម្រាប់ប្រជាជនស៊ីវិលដែលអនុញ្ញាតឱ្យមានការរៀបរាប់ និងទទួលស្គាល់រឿងរ៉ាវរបស់ជនរងគ្រោះ ផ្តល់នូវមធ្យោបាយដ៏មានតម្លៃផ្សេងទៀតក្នុងការផ្តល់យុត្តិធម៌អន្តរកាលនៅក្នុងបរិបទនេះ។ កិច្ចប្រជុំដើម្បីគោរពវិញ្ញាណក្ខន្ធរបស់អ្នកដែលបានបាត់បង់ជីវិត ការផ្តល់សេវាគាំទ្រដល់អ្នកនៅរស់រានមានជីវិត និងសំណងជាហិរញ្ញវត្ថុ និងសំណងផ្សេងៗក៏ជាមធ្យោបាយយូរអង្វែងមួយក្នុងការបន្ស្រាយភាពឈឺចាប់របស់ជនរងគ្រោះផងដែរ។

ការទទួលរងអំពើហិង្សាផ្លូវភេទរបស់ជនជាតិភាគតិចដែលនៅរស់រានមានជីវិត ទាមទារឱ្យមានការសិក្សាស្រាវជ្រាវប្រកបដោយការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីយល់ដឹងឱ្យពេញលេញអំពីការដែលរបបនេះប្រព្រឹត្តលើក្រុមជនជាតិភាគតិច និងផលវិបាកលើសហគមន៍ទាំងនោះ។ ភាពជោគជ័យនៃការសិក្សាស្រាវជ្រាវនេះក្នុងការស្វែងរកអ្នកនៅរស់រានមានជីវិត ដើម្បីចែករំលែកបទពិសោធន៍របស់ពួកគេបង្ហាញថា មានមនុស្សស្មគ្រចិត្តចែករំលែករឿងរ៉ាវរបស់ពួកគេ ដោយមានការការពារសុវត្ថិភាព និងមានការគាំទ្រ។

គេសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជា អ.វ.ត.ក អង្គការសង្គមស៊ីវិល អ្នកទាក់ទាញមតិគាំទ្រ និងអ្នកអនុវត្ត នឹងយកចិត្តទុកដាក់ពិចារណាលើភាពឈឺចាប់ក្នុងជីវិតរបស់ជនជនជាតិភាគតិចដែលជនល្មើសបានប្រព្រឹត្តអំពើហិង្សាផ្លូវភេទមកលើពួកគេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គេសង្ឃឹមទៀតថា សារៈសំខាន់នៃព័ត៌មានដែលបង្ហាញនៅក្នុងការសិក្សាស្រាវជ្រាវនេះ និងការសិក្សាស្រាវជ្រាវដទៃទៀតត្រូវបានទទួលស្គាល់ និងយកទៅប្រើប្រាស់។ អនុសាសន៍សម្រាប់អ្នកដើរតួនាទីផ្សេងៗគ្នាមានបង្ហាញក្នុងសេចក្តីសង្ខេប។ ការប្រឈមនឹងឧក្រិដ្ឋកម្មអំពើហិង្សាផ្លូវភេទកាលពីអតីតកាល ការឆ្លើយ

តបនឹងតម្រូវការរបស់អ្នកនៅរស់រានមានជីវិត និងការឱ្យជនល្មើសទទួលខុសត្រូវលើទង្វើរបស់ខ្លួន មានសារៈសំខាន់សម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសន្តិភាព ប្រកបដោយប្រសិទ្ធភាព និងយូរអង្វែងក្នុងប្រទេសកម្ពុជា។

# សទ្ទានុក្រម



| | |
|---|---|
| *អង្គការ* | ឈ្មោះទូទៅសម្រាប់អ្នកដឹកនាំនៃរបបខ្មែរក្រហម មានន័យថា "អង្គការ" |
| *ប្រជាជនមូលដ្ឋាន* | ប្រជាជនដែលធ្លាប់ធ្វើការជាកម្មករ ឬ កសិករ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលខ្មែរក្រហមឡើងគ្រប់គ្រងប្រទេស |
| *កម្មាភិបាល* | មន្ត្រី និងទាហានខ្មែរក្រហម |
| *បេក្ខជន* | ប្រជាជនដែលចូលរួមបំពេញការងារមួយចំនួនក្នុងថ្នាក់គ្រប់គ្រងសហករណ៍ ដើម្បីទទួលបានអាហារ និងការរស់នៅបានប្រសើរ |
| *ឈ្លប* | កងជីវពលមូលដ្ឋាន ដែលចាត់តាំងដោយមេដឹកនាំខ្មែរក្រហម ឱ្យការពារសន្តិសុខតាមឃុំ និងរាយការណ៍ជូនថ្នាក់ដឹកនាំ/ មេរបស់សហករណ៍ |
| *បទល្មើសខុសសីលធម៌* | ពាក្យប្រើប្រាស់ដោយខ្មែរក្រហមសម្រាប់ការរួមភេទជាមួយអ្នកដទៃមិនមែនជាប្ដីប្រពន្ធខ្លួន។ គោលនយោបាយផ្លូវការបានលើកឡើងថា បទល្មើសបែបនេះត្រូវតែដាក់ទណ្ឌកម្ម |
| *គណៈកម្មាភិបាល* | កម្មាភិបាលខ្មែរក្រហមក្នុងសហគមន៍មួយ |
| *កងចល័ត* | អង្គភាពយុវជនចល័តមួយ |
| *ខ្មាំង* | តាមន័យត្រង់ សត្រូវនៃរបបខ្មែរក្រហម |
| *កសាង* | ការិះគន់របស់ខ្មែរក្រហម |
| *មន្ទីរឈ្លប* | មជ្ឈមណ្ឌលកងជីវពលបុរស |
| *ប្រជាជនថ្មី* | ប្រជាជនរស់នៅក្រៅតំបន់គ្រប់គ្រងរបស់ខ្មែរក្រហមក្នុងអំឡុងពេលសង្គ្រាមជាមួយអ្នកដើរតាម លន់ នល់ និងអ្នកដែលថ្មីនឹងបដិវត្តន៍ បន្ទាប់មករាប់បញ្ចូលទាំងអ្នកមកពីទីក្រុង ដែលមានការអប់រំខ្ពស់ ឬ មានសញ្ជាតិខុសពីខ្មែរ |
| *ប្រជាជនចាស់* | ប្រជាជនរស់នៅក្នុងតំបន់ការគ្រប់គ្រងដោយខ្មែរក្រហមក្នុងអំឡុងសង្គ្រាមស៊ីវិលជាមួយអ្នកគាំទ្រ លន់ នល់ |

| | |
|---|---|
| *ប្រជាជនបម្រុង* | អ្នកដែលរស់នៅក្នុងតំបន់គ្រប់គ្រងដោយខ្មែរក្រហម ប៉ុន្តែសាច់ញាតិរស់នៅក្នុងតំបន់គ្រប់គ្រងដោយ លន់ នល់ ឬមកពីគ្រួសារថ្នាក់ខ្ពស់ ជានគរបាល ឬ ទាហាន |
| *ប្តេជ្ញា* | តាំងចិត្តរៀបការ |
| *អប់រំឡើងវិញ* | ទណ្ឌកម្មក្នុងការប្រឆាំង ឬ បំពានលើអង្គការអាចមានចាប់ពីការស្តីបន្ទោសរហូតដល់ការសម្លាប់ចោល |
| *ស្នើ* | ការសួរដោយសម្លេងបង្ខំ ដាក់សម្ពាធឱ្យធ្វើអ្វីមួយ |

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
CAMBODIAN DEFENDERS PROJECT

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ: giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

zfd Ziviler Friedensdienst
Wir scheuen keine Konflikte.